# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលតាម ប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. សុខ ស្រីពេជ្រ**

**ក. ជា លៀងហាក់**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ឆ្នាំចូលរៀន ២០១៧

ជំនាន់ទី ១៤ (អាហារូបករណ៍) ឆ្នាំសរសេរសារណា ២០២១

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal university of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១


| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
|---|---|
| និស្សិតឈ្មោះ **ក. សុខ ស្រីពេជ្រ** | **បណ្ឌិត អ៊ុន សកក្កដា** |
| **ក. ជា លៀងហាក់** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | | ឆ្នាំចូលរៀន | ២០១៧ |
| ជំនាន់ទី ១៤ (អាហារូបករណ៍) | | ឆ្នាំសរសេរសារណា | ២០២១ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **សុខ ស្រីពេជ្រ** និង**ជា លៀងហាក់** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ក្រុម P4C1 ឆ្នាំទី៤ ជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២១។

ជាបឋមនាងខ្ញុំមានកិត្តិយសសូមសេចក្តីអនុញ្ញាតដើម្បីបានសម្តែងនូវគារវកិច្ចដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ លោកឪពុក និងអ្នកម្តាយរបស់យើងខ្ញុំទាំងពីរនាក់ដែលជាអ្នកមានគុណដ៏ធំមហិមាដែលមិនអាចកាត់ថ្លៃបានក្នុងការផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ព្រមទាំងលះបង់នូវកម្លាំងកាយចិត្ត ទ្រព្យសម្បត្តិ ធនធានឱ្យកូនបានសិក្សារៀនសូត្រក្រេបយកចំណេះដឹងរហូតដល់ទទួលបានជោគជ័យដូចសព្វថ្ងៃ ដែលនេះជាគុណូបការៈដ៏អនេកប្បការ និងវិសេសវិសាលដ៏ខ្ពង់ខ្ពស់ថ្លៃថ្លាគ្មានអ្វីប្រៀបផ្ទឹមបាន។

សូមគោរពអរគុណដល់ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង គណៈគ្រប់គ្រងព្រមទាំងសាស្ត្រាចារ្យទាំងអស់** ដែលបានខិតខំប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការគ្រប់គ្រង និងដឹកនាំសាកលវិទ្យាល័យក្នុងគោលដៅបណ្តុះបណ្តាលមូលធនផ្នែកបញ្ញា ធនធានមនុស្សកម្ពុជាឱ្យមានចំណេះដឹង វិជ្ជាជីវៈ ក្រមសីលធម៌ខ្ពស់ និងប្រកបដោយគុណធម៌ក្នុងការរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិត ពិសេសជាទំពាំងស្នងឫស្សី និងជាសសរទ្រូងនៃប្រទេសជាតិឱ្យមានកាលានុវត្តភាពនៃការអភិវឌ្ឍប្រទេសជាតិយ៉ាងឆាប់រហ័ស។

សូមគោរពអរគុណដល់ **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សតក្ខដា** ដែលបានដឹកនាំ តម្រង់ទិសចង្អុលបង្ហាញ អប់រំបន្ថែម ព្រមទាំងជួយជ្រោមជ្រែងក្នុងការការផ្តល់យោបល់ល្អៗ និងការពន្យល់អំពីវិធិសាស្ត្រល្អៗ ការកែលម្អនូវរាល់ចំណុចខ្វះខាត ក៏ដូចជាចំណុចខុសឆ្គងមួយចំនួនដើម្បីឱ្យការរៀបរៀងសារណាមួយនេះចេញជារូបរាងដែលប្រកបដោយគុណភាព និងភាពជោគជ័យ រួមទាំងការចំណាយពេលដ៏មានតម្លៃតាំងពីដើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវ។

ជាចុងក្រោយ យើងខ្ញុំទាំងពីររូបមានកិត្តិយសសូមសេចក្តីអនុញ្ញាតគោរពជូនពរដល់ អ្នកមានគុណទាំងអស់សូមមេត្តាទទួលយកដោយក្តីអនុគ្រោះបំផុតនូវភក្តីភាពគោរពស្រឡាញ់ក្នុងភាពសុចរិតដែលជាគុណតម្លៃដ៏ឧត្តុង្គឧត្តមនៃសេចក្តីថ្លៃថ្នូរ ភាពចុំថ្កើង កិត្តិគុណ និងកតញ្ញូតាធម៌។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពជូនពរទៅដល់លោកអ្នកមានគុណទាំងអស់ និងមិត្តនិស្សិតទាំងអស់ទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច សុខភាពល្អមាំមួន និងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាមានការរីកលូតលាស់សេដ្ឋកិច្ចប្រកបដោយវឌ្ឍនភាព និងនិរន្តរភាពជាងពីរទសវត្សន៍មុន ដោយសារតែរាជរដ្ឋាភិបាលយើងមានឆន្ទៈដ៏មោះមុតក្នុងការលើកកម្ពស់គុណភាពសេវាសាធារណៈ ក្នុងគោលបំណងទទួលយកការផ្លាស់ប្តូរនៃបរិបទក្នុងការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈថ្មីតាមបែបបច្ចេកវិទ្យា ដើម្បីបំពេញតម្រូវការប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។ ក៏ប៉ុន្តែមុននឹងឈានការរីកចម្រើនក៏ជួបនូវការរាំងស្ទះនូវការផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ ដោយសារកំណើនប្រជាជនចេះតែកើនឡើង ហើយតម្រូវការ នៃការផ្តល់សេវាសាធារណៈទៅកាន់ប្រជាពលរដ្ឋក៏កាន់តែកើនឡើងជាលំដាប់ដែលធ្វើឱ្យមានការកកស្ទះ និងភាពយឺតយ៉ាវដោយសារការតម្រូវឱ្យមកដល់ទីកន្លែងផ្ទាល់ខ្លួនដើម្បីទទួលសេវាសាធារណៈនៅតាមស្ថាប័នចំណុះរបស់រាជរដ្ឋាភិបាល។ ដោយយោងតាមការមើលឃើញពីបញ្ហានេះទើបក្រុមនាងខ្ញុំជ្រើសរើសយកប្រធានបទដ៏ថ្មីស្រឡាង ដែលលើកយកមកបង្ហាញអំពីការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា មកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវនេះ។

នៅក្នុងសារណាក្រោមប្រធានបទ **ការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា** ដែលជាប្រធានបទថ្មីដែលពិពណ៌នាអំពីរបៀបក្នុងការផ្តល់សេវាសាធារណៈតាមបែបបច្ចេកវិទ្យាទំនើប ដែលហៅម្យ៉ាងទៀតបានថា **រដ្ឋាភិបាលឌីជីថល** ដែលបង្កឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងក្លាទាំងវិស័យសេដ្ឋកិច្ច និងសង្គម នាពេលបច្ចុប្បន្ន និងអនាគត។ ក្នុងខណៈដែលការផ្តល់សេវាសាធារណៈតាមបែបឌីជីថលនេះបាននាំមកនូវបញ្ហាប្រឈមមួយចំនួនដែលត្រូវការកែតម្រូវ និងអភិវឌ្ឍបន្ថែមទៀត ក្នុងពេលតែមួយនេះដែរ វាក៏បាននាំមកនូវលទ្ធផលល្អ និងថាមពលដល់មនុស្សគ្រប់រូបតាមរយៈការផ្តល់ឱ្យមានការទទួលសេវាសាធារណៈតាមការប្រើប្រាស់បណ្តាញឌីជីថលផ្សេងៗ។

សារណានេះ គឺជាស្នាដៃនៃការការពារការបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំ ក៏ជាស្នាដៃទីមួយក្នុងការខិតខំប្រឹងប្រែងធ្វើការស្រាវជ្រាវ និងចងក្រងទុកជាឯកសារនេះទុកផ្តល់ជាប្រយោជន៍ទៅកាន់ប្អូនៗ ក៏ដូចជានិស្សិតរដ្ឋបាលសាធារណៈជំនាន់ក្រោយដើម្បីធ្វើការស្វែងយល់ឱ្យកាន់តែមានប្រយោជន៍។ ដោយសារចំណេះដឹងនូវមានកម្រិត ដូច្នេះក្រុមយើងខ្ញុំសង្ឃឹមថាកំហុសខុសឆ្គងទៅលើអត្ថន័យខ្លឹមសារ ពាក្យពេចន៍ ឃ្លាឃ្លោង ទាំងអក្ខរាវិរុទ្ធ និងបច្ចេកទេសនៃការចងក្រង យើងខ្ញុំសូមមានការខន្តីអភ័យទោសចំពោះកំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយប្រការណាមួយពីសំណាក់លោកគ្រូសាស្ត្រាចារ្យ មិត្តនិស្សិត និងអ្នកអានទាំងអស់ ហើយយើងខ្ញុំទាំងពីរសូមទទួលយកនូវមតិរិះគុនក្នុងន័យស្ថាបនាដើម្បីធ្វើជាទុនក្នុងការកែលម្អ និងធ្វើដកជាបទពិសោធន៍ដើម្បីជំរុញឱ្យការស្រាវជ្រាវក្រោយទៀតកាន់តែល្អប្រសើរ និងប្រកបដោយគុណភាព។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការផ្ដល់សេវាសាធារណៈតាមបែបឌីជីថល**

**១.១. សញ្ញាណទូទៅនៃការផ្ដល់សេវាសាធារណៈតាមបែបឌីជីថល** ........................................ ៦

១.១.១. និយមន័យ ........................................ ៦

១.១.២. សារៈ ........................................ ១០

១.១.៣. រចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលរបស់ប្រទេសកម្ពុជា ........................................ ១២

១.១.៤. មុខងាររបស់រដ្ឋាភិបាលកម្ពុជាតាមបែបឌីជីថល ........................................ ១៣

**១.២. បំណែងចែកនៃការផ្ដល់សេវារបស់រដ្ឋាភិបាលឌីជីថល** ........................................ ១៤

១.២.១. ការផ្ដល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់ប្រជាពលរដ្ឋ (G2C) ........................................ ១៤

១.២.២.ការផ្ដល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់ធុរជន (G2B) ........................................ ១៥

១.២.៣. ការផ្ដល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់រដ្ឋាភិបាល (G2G) ........................................ ១៦

១.២.៤. ការផ្ដល់សេវាកម្មរបស់រដ្ឋាភិបាលឌីជីថលទៅកាន់បុគ្គលិក (G2E) ........................................ ១៦

**១.៣. ដំណាក់កាលនៃការអនុវត្តរបស់រដ្ឋាភិបាលឌីជីថលកម្ពុជា** ........................................ ១៨

១.៣.១. ក្របខណ្ឌគោលនយោបាយនៃរដ្ឋាភិបាលឌីជីថលកម្ពុជា ........................................ ២៣

១.៣.២. វិធានការគោលនយោបាយគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល ........................................ ២៣

១.៣.៣. គោលនយោបាយសេដ្ឋកិច្ចឌីជីថល ........................................ ៣៧

១.៣.៤.គោលនយោបាយសង្គមឌីជីថល ........................................ ៤០

**ជំពូកទី២**

**ស្ថានភាពរដ្ឋបាលសាធារណៈនៅកម្ពុជានាពេលបច្ចុប្បន្ន**

**២.១. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋាភិបាលឌីជីថលនាពេលបច្ចុប្បន្ន** ........................................ ៤២

២.១.១. របៀបរបបនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅតាមក្រសួង-ស្ថាប័ន ........................................ ៤៤

២.១.២. ការរីករាលដាលនូវជម្ងឺកូវីដ-១៩ នៅទូទាំងរាជធានី-ខេត្ត ........ ៦៣
២.១.៣. ការចាត់វិធានការទប់ស្កាត់នូវជម្ងឺកូវីដ-១៩ តាមរយៈប្រព័ន្ធបច្ចេកវិទ្យា ........ ៦៤
**២.២.លទ្ធផល និងការវិភាគលើការអនុវត្តការងារនៃរដ្ឋាភិបាលឌីជីថល** ........ ៦៨
២.២.១. សមិទ្ធផលនៃការអនុវត្តការងារ ........ ៧០
២.២.២. ការកែលម្អគុណភាពសេវាសាធារណៈ ........ ៧២
២.២.៣. ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ........ ៧៤
**២.៣ បញ្ហាប្រឈម និងទិសដៅការងារបន្ទាប់** ........ ៧៦
២.៣.១. បញ្ហាប្រឈម ........ ៧៧
២.៣.២. ទិសដៅការងារបន្ទាប់ ........ ៨៦
២.៣.៣. ដំណោះស្រាយ និងការប្រកួតប្រជែង ........ ៨៩
**សេចក្តីសន្និដ្ឋាន** ........ ៩៣
**អនុសាសន៍** ........ ៩៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាស្ថិតក្នុងការកសាង និងអភិវឌ្ឍន៍បន្ថែមអំពីការគ្រប់គ្រងរបស់រដ្ឋាភិបាលតាមកម្មវិធីឌីជីថល សម្រាប់ធ្វើការរៀបចំគ្រប់គ្រងដោយប្រព័ន្ធបច្ចេកវិទ្យាទំនើប ប្រើប្រាស់ដោយកុំព្យូទ័រហើយត្រូវការធនធានមនុស្ស ដែលមានជំនាញពិតប្រាកដ។ នៅក្នុងឆ្នាំ២០២១ ការអនុវត្តបន្ថែមទៅលើការបញ្ជាប្រព័ន្ធឌីជីថលមានភាព រហ័សជាងមុន ជាមួយនឹងការផ្តល់ព័ត៌មាន រួមសហការ ប្រតិបត្តិក្នុងការចូលជាជំនួយលើការផ្សព្វផ្សាយ និងការ បង្ហាញជាដើម។ ការចែករំលែកនៅក្នុងប្រទេសកម្ពុជាដោយប្រព័ន្ធបច្ចេកវិទ្យា ចាប់ផ្តើមមានការរីកចម្រើនគួរឱ្យ កត់សម្គាល់ និងស្របពេលវិបត្តិស្ថានការណ៍ជម្ងឺកូវីដ-១៩ (Covid-19) កំពុងផ្ទុះការកើតឡើងជាបន្តពី ឆ្នាំ២០១៩ រហូតមកដល់នាពេលបច្ចុប្បន្ន។ ការីកាលដាលនៃជម្ងឺនេះស្ថិតក្នុងស្ថានភាពដែលត្រូវការគ្រប់គ្រងតាមប្រព័ន្ធឌីជីថល ខ្ពស់សម្រាប់ការចែករំលែក ឬផ្តល់ព័ត៌មានទៅក្នុងសង្គមបានលឿនរហ័ស ដោយសារតែមានការលំបាកក្នុងការជួប ជុំផ្ទាល់នៅតាមទីកន្លែងណាមួយ។ ទាក់ទងនឹងអំឡុងពេលមានជម្ងឺរាតត្បាតកំពុងតែដើរអមជាមួយសង្គមធ្វើឱ្យ មានការកើតឡើងនូវវិធីសាស្ត្រផ្សេងៗលើការកែសម្រួលទម្រង់ ដើម្បីជួយដល់ភាពលំបាកនៅក្នុងសង្គមយើងគ្រប់ ផ្នែកដូចជាសេវាសាធារណៈដែលបានគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាផ្ទាល់ពីរដ្ឋាភិបាល។ សង្គមមានការផ្លាស់ប្តូរ និង កើនធនធានមនុស្សជាមួយដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិជាមួយការគ្រប់គ្រងប្រព័ន្ធឌីជីថល ប្រព័ន្ធគមនាគមន៍ និងប្រព័ន្ធប្រៃសណីយ៍។

ការផ្តល់សេវាសាធារណៈបានជួយដល់ប្រជាពលរដ្ឋបានច្រើន និងសម្របសម្រួលរបស់រដ្ឋាភិបាលក្នុង ការដោះស្រាយនូវបញ្ហានានាបានទាន់ស្ថានការណ៍ ហើយទម្រង់នូវការជួបប្តូរឯកសារទាំងអស់ត្រូវបានចាត់ប្តូរពី ឯកសារក្រៅ មកពិភាក្សានៅក្នុងបច្ចេកវិទ្យាវិញ។ ចំណុចនេះ បានជួយដល់ការរក្សាគម្លាតគ្នាពីទីប្រជុំជនដោយ ប្រយោល ចំណេញពេលវេលា និងថវិការលើការធ្វើដំណើរជាដើម។ តាមទម្លាប់នៃការអនុវត្តប្រព័ន្ធឌីជីថលកន្លង មកនៅក្នុងការចាប់ផ្តើមចូលការងាររបស់រាជរដ្ឋាភិបាលនៅក្នុងការប្រជុំនៃគណៈរដ្ឋមន្ត្រី ដែលតែងតែប្រើប្រាស់ជា កាលានុវត្តភាពសម្រាប់ការរំលេចជូនដល់បងប្អូនជនរួមជាតិ និងដៃគូអន្តរជាតិលើនីតិកាលថ្មី និងអំពីការប្តេជ្ញា ចិត្តយ៉ាងមោះមុតឥតងាករេ របស់រាជរដ្ឋាភិបាលទាំងមូលក្នុងការឈានទៅរកភាពជោគជ័យនូវបណ្តាលអាទិភាព ទាំងអស់នោះដើម្បីបម្រើនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិមាតុភូមិ ឆ្លើយតបទៅនឹងសំណូមពរ និងសេចក្តី ត្រូវការទាំងឡាយរបស់ប្រជាពលរដ្ឋកម្ពុជា ដែលរាជរដ្ឋាភិបាលបានទទួលការទុកចិត្តអំពីការបម្រើសេវាសាធារ ណៈក្នុងកិច្ចដំណើរការអនុវត្តបន្ត។ គោលដៅចម្បងបន្តគឺ យុទ្ធសាស្ត្រចតុកោណ នៃនីតិកាលទី៦ ពោលគឺការ ជំរុញលើកកម្ពស់ កំណើនសេដ្ឋកិច្ចការដោះស្រាយការងារសម្រាប់ការធានាសមធម៌ យុត្តិធម៌ សង្គម និងការលើក ស្ទួយប្រសិទ្ធភាពនៃវិស័យសាធារណៈតាមរយៈផែនការសកម្មភាពអភិបាលកិច្ច កំណែទម្រង់ស៊ីជម្រៅ និងប្រទាក់ ក្រឡាគ្នាគ្រប់ផ្នែកវិស័យយើងអាចកំណត់បាវចនានៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភានេះ ថាជា **រាជរដ្ឋាភិបាលដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព**។ យុទ្ធសាស្ត្រចតុកោណមាន៤ គឺដំណាក់កាល ទី១ សំដៅលើការលើកស្ទួយវិស័យកសិកម្ម ដំណាក់កាលទី២ គឺជាការបន្តស្តារ និងសាងហេដ្ឋារចនាសម្ព័ន្ធរូប វន្ត ដំណាក់កាលទី៣ ការអភិវឌ្ឍផ្នែកឯកជន និងការងារ និងដំណាក់កាលទី៤ គឺការកសាងសមត្ថភាព និងការ អភិវឌ្ឍធនធានមនុស្ស។

ស្របពេលនីតិវិធីគោលនយោបាយរដ្ឋាភិបាល ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុងវិស័យឌីជីថលនេះបន្តជំរុញលើកកម្ពស់ឱ្យស្របតាមស្តង់ដាអន្តរជាតិ មានតម្លៃសមរម្យ និងមានសេវាកម្មទំនើប គ្របដណ្តប់ទូទាំងប្រទេសតាមរយៈការអនុវត្តរបស់រាជរដ្ឋាភិបាលបើកទូលាយវិស័យប្រព័ន្ធបច្ចេកវិទ្យា សម្រាប់ការចូលរួមរបស់វិស័យឯកជនដោយគ្មានការរើសអើងដោយឈរលើមូលដ្ឋាននៃការប្តេជ្ញាចិត្ត និងកាតព្វកិច្ចទាំងឡាយរបស់កម្ពុជានៅក្នុងក្របខណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក។ ការរៀបចំក្នុងការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធឌីជីថលដោយក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ុណ្ណោះដែលចូលរួម ហើយនៅដំណាក់កាលបន្តបន្ទាប់នឹងមានស្ថាប័នរដ្ឋពាក់ព័ន្ធផ្សេងទៀតចូលរួមផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសដទៃទៀតដែលកំពុងស្ថិតក្នុងការអភិវឌ្ឍលើប្រព័ន្ធបច្ចេកវិទ្យាទំនើបបន្ថែម។ វិស័យនេះមានការកើតឡើងយ៉ាងគួរឱ្យកត់សម្គាល់ចំពោះប្រព័ន្ធឌីជីថល រដ្ឋបាលសាធារណៈដែលកំពុងបន្តការផ្តល់ព័ត៌មាន និងការអនុវត្តសម្រាប់ការដោះស្រាយបញ្ហាប្រឈមជាច្រើនអំឡុងពេលជម្ងឺរាតត្បាតកូវីដ-១៩ នៅតែរីករាលដាលខ្លាំង។ ការដឹកនាំរបស់រាជរដ្ឋាភិបាលលើវិស័យប្រព័ន្ធបច្ចេកវិទ្យា និងគមនាគមន៍មានការស្វះស្វែងរកនូវដំណោះស្រាយថ្មីៗសម្រាប់ធ្វើការទប់ស្កាត់ទៅលើសង្គម ហើយនឹងមើលថែប្រជាពលរដ្ឋដែលកំពុងរងទុក្ខជាបន្តបន្ទាប់ដោយសារការប៉ះពាល់យ៉ាងធ្ងន់ធ្ងរនេះ។ បច្ចុប្បន្នការរៀបចំផែនការផ្សេងៗលើការជួយផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ទៅកាន់ប្រជាពលរដ្ឋបានរហ័សក្នុងការសហការគ្នាដើម្បីថែរក្សាការពារ និងជួយឱ្យសង្គមមានការប្រុងប្រយ័ត្នខ្ពស់បន្ថែមពីការវាយលុកនៃស្ថានការណ៍ដែលកំពុងបន្តកើតឡើង។វិបត្តិពិភពលោកដែលបង្កឡើងដោយការឆ្លងរាលដាលនៃជម្ងឺកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាយ៉ាងខ្លាំងក្នុងឆ្នាំ២០២០ នេះស្របពេលដែលកម្ពុជាអាចប្រឈមនឹងការលុបចោលផ្នែកខ្លះនៅក្នុងបរិបទនេះ។ ការឆ្លងរាលដាលនេះបានបង្កឱ្យមានការធ្លាក់ចុះយ៉ាងខ្លាំងនូវស្ទើរគ្រប់ផ្នែកនៃក្បាលម៉ាស៊ីន ដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ចនៃត្រីមាសទី១ ឆ្នាំ២០២០ នេះរួមទាំងវិស័យទេសចរណ៍ និងសកម្មភាពសំណង់។ កំណើនត្រូវបានប៉ាន់ប្រមាណថានឹងមានការថយចុះយ៉ាងខ្លាំងមកនៅត្រឹម ២,៥ ភាគរយក្នុងឆ្នាំ២០២០ ក្នុងសេនារីយោខ្សែបន្ទាត់គោល។ ការផ្ទុះនៃជម្ងឺកូវីដ-១៩នេះ និងការងើបឡើងវិញយឺតៗនៃសកម្មភាពសេដ្ឋកិច្ចសាកលលោករួមទាំងចលាចលលើទីផ្សារហិរញ្ញវត្ថុអូសបន្លាយ ដែលធ្វើឱ្យមានហានិភ័យដល់ចក្ខុវិស័យកំណើនរបស់កម្ពុជា។ ស្ថានភាពអំឡុងពេលនៃឆ្នាំ២០២១ នៅតែបន្តអំពីវិបត្តិប្រឈមធ្លាក់ចុះនូវសេដ្ឋកិច្ចចំពោះបញ្ហាទាំងនេះដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសហការជាមួយក្រសួងដែលពាក់ព័ន្ធ ដើម្បីបន្តការចុះបញ្ជីធ្វើអាជីវកម្មតាមប្រព័ន្ធឌីជីថល និងដំណើរការឯកសារនានាតាមធម្មតាក្នុងការជួយសម្រួលដល់ម្ចាស់សហគ្រាស ឬអ្នកគ្រប់គ្រង។ អំពីការសិក្សាស្រាវជ្រាវខាងលើនេះបានបង្ហាញឱ្យឃើញនូវបញ្ហាចោទដូចខាងក្រោមដូចជា៖

- តើការផ្តល់សេវារដ្ឋបាលសាធារណៈតាមបែបឌីជីថលនៅកម្ពុជាមានលក្ខណៈយ៉ាងដូចម្តេច?
- តើការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈផ្តល់អត្ថប្រយោជន៍អ្វីខ្លះ?
- តើការអនុវត្តការងាររបស់រដ្ឋាភិបាលឌីជីថលជួបប្រទះទៅនឹងបញ្ហាប្រឈមអ្វីខ្លះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ក្នុងការជ្រើសរើសប្រធានដែលមានភាពថ្មីស្រឡាងនេះមកធ្វើការស្រាវជ្រាវក្រុមយើងខ្ញុំបានឆ្លងកាត់ការពិភាក្សាគិតគូរមុនមកហើយ និងមានគោលបំណងដូចតទៅនេះ៖

- បង្ហាញថាកម្ពុជាកំពុងស្ថិតក្នុងបដិវត្តន៍ឧស្សាហកម្ម៤.០ ដែលប្រទេសគឺស្ថិតក្នុងការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាក្នុងការស្រាវជ្រាវឱ្យមានការយល់ដឹងលម្អិត និងកាន់តែស៊ីជម្រៅអំពីការផ្ដល់សេវាសាធារណៈតាមបែបឌីជីថល ជាពិសេសធ្វើឱ្យយើងត្រៀមខ្លួនចូលរួមក្នុងការអនុវត្តតាមគោលនយោបាយរបស់រដ្ឋាភិបាលឌីជីថលដើម្បីឱ្យក្លាយខ្លួនជាពលរដ្ឋឌីជីថលធ្វើឱ្យប្រទេសជាតិទាំងមូលទទួលបានការរីកចម្រើននៃសេដ្ឋកិច្ច និងសង្គមឌីជីថលនៅថ្ងៃខាងមុខ
- ដើម្បីបង្កើនការយល់ដឹងនៃភាពទូលំទូលាយនូវល្បឿននៃបដិវត្តន៍ឌីជីថល និងផលប៉ះពាល់ជាច្រើនរបស់វា
- ការយល់ដឹងអំពីក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ បានដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើកតាមរយៈការរៀបចំមូលដ្ឋានគ្រឹះដែលជំរុញការទទួលយក និងការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គមទាំងរដ្ឋ ពលរដ្ឋ និងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ច និងការលើកកម្ពស់សុខុមាលភាពសង្គម
- ស្វែងយល់ពីស្ថានភាពក្នុងការគ្រប់គ្រង និងការចាត់វិធានការនាពេលបច្ចុប្បន្នរបស់រដ្ឋាភិបាលឌីជីថលផ្ដោតលើសមាសធាតុចំនួនប្រាំ ដែលចែកចេញជាគ្រឹះចំនួនពីររួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បដិវត្តកម្មឌីជីថលក្នុងការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល គោលនយោបាយបន្ទាប់ គឺការកសាងពលរដ្ឋឌីជីថលកសាងរដ្ឋាភិបាលឌីជីថល និងការជំរុញធុរកិច្ចឌីជីថល
- សមិទ្ធផលដែលសម្រេចបានពីការគ្រប់គ្រងទៅលើប្រព័ន្ធបច្ចេកវិទ្យាទំនើបនេះអាចទាញយកផលប្រយោជន៍ពីសេដ្ឋកិច្ចជាមួយនិងសង្គមឌីជីថលឱ្យបានជាអតិបរមាព្រមទាំងទទួលបានការកាត់បន្ថយពីផលប៉ះពាល់ឬផលអវិជ្ជមានឱ្យស្ថិតក្នុងកម្រិតអប្បបរមា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនេះមានទំហំ និងដែនកំណត់ក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវពីការគ្រប់គ្រងរដ្ឋបាល និងការផ្ដល់សេវាសាធារណៈរបស់រដ្ឋាភិបាលកម្ពុជាតាមបែបបច្ចេកវិទ្យា ដែលមានការធ្វើបដិវត្តន៍ជាច្រើនដំណាក់កាលដែលបានរំលេចឡើងអំពីកំណែទម្រង់រដ្ឋាភិបាលឌីជីថលតាំងពីសម័យបុព្វកាល រហូតមកដល់បច្ចុប្បន្នដោយបច្ចុប្បន្ននេះរាជរដ្ឋាភិបាលបាន និងកំពុងតែអនុវត្តន៍នូវគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាពីឆ្នាំ២០២១-២០៥០ ក្នុងចក្ខុវិស័យដើម្បីសម្រេចបាននូវវិសាលភាពនៃការអនុវត្តដែលឆាប់ស្រូបយកបច្ចេកវិទ្យា និងនវានុវត្តន៍ ព្រមទាំងការអភិវឌ្ឍប្រកបដោយចីរភាព។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ក្នុងកិច្ចការស្រាវជ្រាវនៃប្រធានបទនេះ គឺពិតជាបានផ្ដល់នូវសារៈសំខាន់ជាច្រើន មានដូចជា៖

**ចំពោះសង្គម ៖**

- បានបង្ហាញអំពីចក្ខុវិស័យក្នុងការអភិវឌ្ឍប្រទេសពីមួយដំណាក់កាលទៅមួយដំណាក់កាលនៃការធ្វើកំណែទម្រង់

- បង្ហាញពីវិសាលភាពក្នុងការផ្លាស់ប្តូរនៃការផ្តល់សេវាសាធារណៈ ហើយនឹងការពន្លឿនល្បឿននៃនវានុវត្តន៍ឌីជីថលជាពិសេសក្នុងបរិបទការអភិវឌ្ឍនេះ
- សាយភាយនូវចំណេះដឹងផ្នែកប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មាន និងគមនាគមន៍ទៅកាន់ប្រជាពលរដ្ឋឱ្យមានលក្ខណៈយល់ដឹង និងងាយស្រួលក្នុងការអនុវត្ត ព្រមទាំងឆាប់ចាប់យក និងរហ័សក្នុងការសម្របខ្លួនជាមួយការងារបែបទំនើបទាន់សម័យ
- សម្រួលនូវការទទួលបានសេវានៃការចុះបញ្ជីអាជីវកម្ម ឬការស្នើសុំសេវាសាធារណៈអ្វីមួយទៅកាន់រដ្ឋាភិបាលដោយធ្វើឡើងតាមរយៈប្រព័ន្ធឌីជីថល
- ទទួលបានទំនុកចិត្តពីប្រទេសនានាក្នុងការវិនិយោគ ឬការបណ្តាក់ទុនទៅលើការធ្វើអាជីវកម្មនៅកម្ពុជាកាន់តែច្រើនៗ
- បង្ហាញពីបច្ចេកវិទ្យាឌីជីថលអាចមានអន្តរកម្ម ជាមួយនឹងពិភពជីវសាស្ត្រផងដែរ។

**ចំពោះអង្គភាព ឬក្រុមហ៊ុនៈ**

- ទទួលបានការយល់ដឹងពីរបៀបក្នុងការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធអ៊ីនធឺណេត
- មានការយល់ដឹងបន្ថែមពីការប្រើប្រាស់សេវាសាធារណៈឱ្យចំទិសដៅ
- មានទំនុកចិត្តក្នុងការធ្វើអាជីវកម្មដោយកាត់បន្ថយភាពស្មុគស្មាញក្នុងការធ្វើអាជីវកម្ម ឬការចុះបញ្ជីអ្វីមួយ។

**ចំពោះក្រុមយើងខ្ញុំផ្ទាល់ៈ**

- បានពង្រឹងនូវចំណេះដឹង និងបទពិសោធន៍ជាច្រើនតាមរយៈការស្រាវជ្រាវ ការប្រមូលផ្តុំ និងការរៀបរៀងនូវកិច្ចការស្រាវជ្រាវ
- បានផ្តល់នូវពុទ្ធិតាមរយៈការស្វះស្វែងរកប្រភពព័ត៌មាន ឯកសារថ្មីៗជាច្រើន និងបានដកស្រង់នូវខ្លឹមសារល្អៗដែលទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា
- យល់ដឹងបន្ថែម និងកាន់តែច្បាស់ពីរបៀបរបបនៃការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការគ្រប់គ្រងរដ្ឋបាល និងការចាត់វិធានការទប់ស្កាត់ស្ថានភាពប្រទេសជាតិពីជម្ងឺដ៏កាចសាហាវ (កូវីដ-១៩)
- យល់ដឹងពីការប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមបែបថ្មី
- បណ្តុះឱ្យយើងមានភាពឆ្លាតវៃ ការតស៊ូ សាមគ្គីភាព និងការចែករំលែកគំនិតយោបល់គ្នាតាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់ការការពារសារណា។

**ចំពោះអ្នកអាន ឬអ្នកស្រាវជ្រាវជំនាន់ក្រោយៈ**

- មានការយល់ដឹងពីរបៀបរបបក្នុងការដឹកនាំតាមរយៈវិធីសាស្ត្រថ្មីដែលមានលក្ខណៈទំនើប និងជឿនលឿនរបស់រាជរដ្ឋាភិបាល
- យល់ដឹងបន្ថែមពីការចុះបញ្ជីធ្វើអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាដែលប្រកបដោយភាពងាយស្រួល ហើយចំណេញពេលវេលា ព្រមទាំងមានសុវត្ថិភាព
- ជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមប្រើប្រាស់ប្រព័ន្ធឌីជីថល
- សម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយអាចយកទៅសិក្សាស្រាវជ្រាវបន្តផងដែរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការស្រាវជ្រាវលើប្រធានបទស្តីពី **ការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា** នេះគឺយើងបានធ្វើការសិក្សាស្រាវជ្រាវបែបគុណភាព និងស៊ីជម្រៅទៅលើការផ្តល់សេវាសាធារណៈតាមបែបឌីជីថលរបស់រដ្ឋាភិបាល ការដាក់ចេញនូវគោលនយោបាយ ការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក និងការគ្រប់គ្រងស្ថានភាពជាក់ស្តែងដែលយើងពឹងផ្អែកទៅលើទិន្នន័យចម្បងដូចជា ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ឆ្នាំ២០១៩ និងច្បាប់ស្តីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្នាំ២០១៩ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ២០២១-២០៣៥ ព្រមទាំងទិន្នន័យបន្ទាប់បន្សំ ដែលរួមមានលិខិតបទដ្ឋានគតិយុត្តនានា ដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផងដែរ។ ចំពោះផ្នែកទ្រឹស្តីយើងបានដកស្រង់ចេញពីសេចក្តីសង្ខេបយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា និងទិន្នន័យមួយចំនួន គឺពួកយើងបានដកស្រង់ចេញពីឯកសារបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកសារព័ត៌មានទាំងជាតិ និងអន្តរជាតិដែលដកស្រង់តាមរយៈគេហទំព័រដែលមានប្រភពច្បាស់លាស់នៅលើប្រព័ន្ធអ៊ីនធឺណេត។ លើសពីនេះទៅទៀតក្រុមយើងខ្ញុំក៏មានការសិក្សាស្រាវជ្រាវពីការធ្វើបច្ចេកវិទ្យាឌីជីថលតាមរយៈ សៀវភៅបដិវត្តន៍ឧស្សាហកម្មលើកទី៤ របស់លោក Klaus Schwab ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យកិច្ចការស្រាវជ្រាវនេះមានសោភណ្ឌភាព របៀបរៀបរយ និងគុណភាពដែលផ្តល់ភាពងាយស្រួលទៅដល់អ្នកអាន ឬអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយបន្តបន្ទាប់ទើបក្រុមយើងខ្ញុំបានរៀបចំនូវការស្រាវជ្រាវដែលមានរចនាសម្ព័ន្ធនៃការស្រាវជ្រាវត្រឹមត្រូវតាមក្បួនខ្នាត និងមានលក្ខណៈពេញលេញដែលក្នុងនោះយើងខ្ញុំបានបែងចែកខ្លឹមសារចេញជាពីរជំពូកគឺ៖

**ជំពូកទី១ "សញ្ញាណទូទៅនៃការផ្តល់សេវារដ្ឋបាលសាធារណៈតាមបែបបច្ចេកវិទ្យា"៖** នៅក្នុងជំពូកនេះនាងខ្ញុំនឹងបែងចែកជាបីចំនុចបន្ថែមទៀតដោយចំនុចទី១ និយាយអំពី សញ្ញាណទូទៅនៃការផ្តល់នៅសេវារដ្ឋបាលសាធារណៈ រីឯចំនុចទី២ បង្ហាញអំពីបំណែងចែកនៃការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថល និងចំនុចទី៣ បរិយាយអំពីក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា។

**ជំពូកទី២ "ស្ថានភាពរដ្ឋបាលសាធារណៈនៅកម្ពុជានាពេលបច្ចុប្បន្ន"** ៖ នៅក្នុងជំពូកនេះនាងខ្ញុំនឹងបែងចែកជាបីចំនុចបន្ថែមទៀតដោយចំនុចទី១ និយាយអំពី ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលឌីជីថលកម្ពុជានាពេលបច្ចុប្បន្ន ចំនុចទី២ បានលើកពីលទ្ធផល និងការវិភាគលើការអនុវត្តការងារនៃរដ្ឋាភិបាលឌីជីថល និងចំណុចចុងក្រោយ បានបង្ហាញពីបញ្ហាប្រឈម និងទិសដៅការងារបន្ទាប់។

# ជំពូកទី១
# សញ្ញាណទូទៅនៃការផ្តល់
# សេវាសាធារណៈតាមបែបបច្ចេកវិទ្យា

# ជំពូកទី១
# សញ្ញាណទូទៅនៃការផ្តល់សេវាសាធារណៈតាមបែបឌីជីថល

## ១.១. សញ្ញាណទូទៅនៃការផ្តល់សេវាសាធារណៈតាមបែបឌីជីថល

សម័យបច្ចេកវិទ្យាទំនើបឌីជីថលនេះបានទំលាយនូវឧបសគ្គជាច្រើន ដែលកាលពីមុនធ្លាប់តែមានការប្រើប្រាស់ឯកសារដែលសរសេរដោយដៃ និងប្រើប្រាស់អាជ្ញាធរសាធារណៈដើម្បីការពារ។ ប៉ុន្តែបច្ចុប្បន្នវាបង្ហាញឱ្យឃើញនូវសមត្ថភាព ឬប្រសិទ្ធភាពក៏ស្ទួចស្ទើងរបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហា ដូចជាអភិបាលកិច្ច ឬរដ្ឋការផ្សេងៗតាមរយៈ ការប្រើប្រាស់អេឡិចត្រូនិក។ ការផ្តល់សេវាសាធារណៈតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានេះ គឺជាការផ្តល់នូវព័ត៌មាន និងការផ្តល់សេវាកម្មដ៏ប្រសើរដែលត្រូវនឹងតម្រូវការរបស់សង្គមជាតិយើងសព្វថ្ងៃ។ ប៉ុន្តែមុននឹងឈានជើងដល់ចំណុចល្អប្រសើរជាងមុននេះគឺ ប្រទេសកម្ពុជាបានឆ្លងកាត់នូវការធ្វើបដិវត្តន៍ក្នុងការផ្តល់សេវាសាធារណៈ។ ចំពោះសង្គម ការកែទម្រង់ឡើងវិញនូវប្រព័ន្ធប្រើប្រាស់ ប្រព័ន្ធផលិតកម្ម ប្រព័ន្ធគមនាគមន៍ និងប្រព័ន្ធប្រៃសនីយ៍។ល។ ការផ្លាស់ប្តូរពីការផ្តល់សេវាសាធារណៈតាមបែបប្រពៃណីនេះធ្វើឱ្យរបៀបរបបក្នុងការផ្តល់សេវាមានភាពរីកចម្រើនជាលំដាប់។ ដូចគ្នានេះដែររាជរដ្ឋាភិបាល និងស្ថាប័នទទួលបន្ទុកព្រមទាំងស្ថាប័នពាក់ព័ន្ធទាំងឡាយកំពុងចូលរួមក្នុងការកែប្រែប្រព័ន្ធគ្រប់គ្រងក៏ដូចជា ប្រព័ន្ធអប់រំ ប្រព័ន្ធថែទាំសុខភាព ប្រព័ន្ធគមនាគមន៍ និងប្រព័ន្ធផ្សេងៗជាច្រើនទៀត។ វិធីថ្មីនៃការប្រើប្រាស់បច្ចេកវិទ្យាដើម្បីផ្លាស់ប្តូរឥរិយាបថក្នុងការផ្តល់សេវាប្រព័ន្ធផលិតកម្ម និងការប្រើប្រាស់របស់យើង ក៏បានផ្តល់សក្តានុពលសម្រាប់ការគាំទ្រដល់ការបង្កើត និងល្បឿនវិសាលភាពនៃការផ្លាស់ប្តូរ។

### ១.១.១. និយមន័យ

**ក. រដ្ឋបាល**

រដ្ឋបាលមានអត្ថន័យទូលំទូលាយណាស់ ហើយយើងក៏អាចឱ្យអត្ថន័យជាច្រើនបែប ច្រើនយ៉ាងផងដែរ។ ខាងក្រោមនេះជាអត្ថន័យនៃពាក្យរដ្ឋបាលតាមលក្ខណៈខុសគ្នាដូចតទៅ៖

- **ន័យអក្សរសាស្ត្រ ៖** ពាក្យរដ្ឋបាល បានមកពីពាក្យ រដ្ឋ + អភិបាល ដោយរដ្ឋ មានន័យថា ដែន ឬប្រទេស ចំណែកឯអភិបាល សំដៅលើអ្នកគ្រប់គ្រង អ្នកបីបាច់ថែរក្សា អ្នកថែរក្សា។ ដូច្នេះ រដ្ឋបាល មានន័យថា អ្នករក្សាដែន ឬប្រទេស។[1]
- **ន័យអង្គការ ៖** រដ្ឋបាល គឺសំដៅលើរដ្ឋបាលសាធារណៈ មានន័យថាជារដ្ឋការ ឬរាជការ ពោលគឺក្រសួងសាធារណៈទាំងអស់ចំណុះរដ្ឋាភិបាល។ រដ្ឋការ ឬរាជការ ឬក្រសួងរាជការ ក៏សំដៅលើស្ថាប័នគ្រប់គ្រងអង្គការគ្រប់គ្រង ឬអំណាចគ្រប់គ្រង។ ដូច្នេះរដ្ឋការ គឺអង្គភាព មន្ទីរ ក្រសួង ស្ថាប័ន ដែលមានរចនាសម្ព័ន្ធ និងតួនាទីបំពេញគោលដៅប្រយោជន៍សាធារណៈ ទោះអង្គភាពនេះមានលកន្តិកៈប្រភេទណាក៏ដោយ។[2]

[1] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

[2] សៀវភៅ សិក្ខាប័ននីតិរដ្ឋបាល, រៀបរៀងដោយលោក អ ចំរើន, បោះពុម្ពឆ្នាំ២០១១, ទំព័រvii

- **ន័យទូលាយបែបបច្ចេកទេស ៖** ពាក្យរដ្ឋបាលត្រូវបានគេយល់គ្រប់គ្នាថាជាសកម្មភាព ឬជាការគ្រប់គ្រងរដ្ឋ ព្រោះជួនកាលគេប្រើជាសកម្មភាព ជួនកាលជាលក្ខណៈអង្គការ ហើយថែមទាំងប្រើបានទៅលើវិស័យឯកជន និងវិស័យសាធារណៈទៀតផង។
- **ន័យចង្អៀតបែបបច្ចេកទេស** ពាក្យរដ្ឋបាល សំដៅទៅលើរដ្ឋបាលសាធារណៈ។ យើងអាចប្រើពាក្យថា រដ្ឋការ ឬរាជការដែលមិននាំឱ្យមានការភ័ន្តច្រឡំជាមួយពាក្យ រដ្ឋបាល ក្នុងវិស័យឯកជននោះទេ។[3]

### ខ. និយមន័យនៃការគ្រប់គ្រងរដ្ឋបាលតាមបែបបច្ចេកវិទ្យា

ការគ្រប់គ្រងរដ្ឋបាលតាមបែបបច្ចេកវិទ្យា គឺផ្តោតទៅលើការផ្តល់សេវា និងការគ្រប់គ្រងរដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលអាចធ្វើការកំណត់អត្ថន័យពីរផ្សេងទៀត គឺរដ្ឋាភិបាលអេឡិចត្រូនិក និងរដ្ឋាភិបាលឌីជីថល។

- ***រដ្ឋាភិបាលអេឡិចត្រូនិក***

រដ្ឋាភិបាលអេឡិចត្រូនិក ពាក្យបច្ចេកទេសគឺ **E-government**[4] គឺសំដៅទៅលើរដ្ឋាភិបាលប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (**ICT**)[5] ជាពិសេសអ៊ីនធឺណេតជាឧបករណ៍ដើម្បីសម្រេចបានរដ្ឋាភិបាលកាន់តែប្រសើរ។ ពោលគឺរដ្ឋាភិបាលអេឡិចត្រូនិក គឺជាការប្រើប្រាស់ឧបករណ៍ទំនាក់ទំនងបច្ចេកវិទ្យាដូចជាកុំព្យូទ័រ និងអ៊ីនធឺណេតដើម្បីផ្តល់សេវាកម្មសាធារណៈបម្រើដល់ប្រជាពលរដ្ឋ និងមនុស្សដទៃទៀតនៅក្នុងប្រទេស ឬតំបន់។ រដ្ឋាភិបាលអេឡិចត្រូនិកផ្តល់នូវឱកាសថ្មីៗសម្រាប់ប្រជាពលរដ្ឋឱ្យចូលទៅកាន់រដ្ឋាភិបាលដោយផ្ទាល់ និងងាយស្រួលជាងមុនថែមទាំងសម្រាប់ការផ្តល់សេវាកម្មរបស់រដ្ឋាភិបាលដោយផ្ទាល់ដល់ពលរដ្ឋ។ និយាយដល់ពាក្យថារដ្ឋាភិបាលអេឡិចត្រូនិក គឺផ្តោតទៅលើការគ្រប់គ្រងរដ្ឋបាលដែលទាក់ទងនឹងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ឬICT ដោយប្រើប្រាស់នូវប្រព័ន្ធអ៊ីនធឺណេត (Internet) និងគេហទំព័រផ្អែកលើប្រព័ន្ធបច្ចេកវិទ្យា (Web-based Technologies) ដែលពាំនាំនូវព័ត៌មាន និងសេវាកម្មឱ្យក្លាយទៅជាពិភពលោកតែមួយចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ទី៩០មក។ រដ្ឋាភិបាលជាច្រើននៅជុំវិញពិភពលោកកំពុងអនុវត្តន៍រដ្ឋាភិបាលឌីជីថលរួមជាមួយនឹងភាពជឿជាក់នៅក្នុងដំណើរការរបស់រដ្ឋ។[6] បន្ថែមពីនេះទៅទៀតសមត្ថភាពផ្នែក ICT ទាំងខាងបច្ចេកទេស និងខាងគ្រប់គ្រងនៅតាមក្រសួងនានាមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការងារពង្រីករដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព។ មានអ្នកជំនាញដែលពូកែខាង ICT គឺជាគន្លឹះមួយដែលធ្វើឱ្យការផ្តួចផ្តើមការងាររដ្ឋាភិបាលឌីជីថល និងទទួលបានជោគជ័យនៅក្នុងគ្រប់ការងាររបស់រដ្ឋាភិបាល។ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាដើរតួយ៉ាងសំខាន់ក្នុងការរក្សានូវល្បឿននៃការអភិវឌ្ឍតាមរយៈការបង្កើននូវការពឹងពាក់គ្នាទៅវិញទៅមកនៅក្នុងក្របខណ្ឌសេដ្ឋកិច្ចទូទាំងពិភពលោក។ យើងក៏បានជឿជាក់ថាហេដ្ឋារចនាសម្ព័ន្ធ ICT លំដាប់ពិភពលោក គឺជាបុរេលក្ខខណ្ឌសំខាន់មួយសម្រាប់អ្នកវិនិយោគបរទេស។ ដោយសារតែផ្នែក ICT គឺផ្តោតទៅលើការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋាភិបាលចំនួន២៩ នៅក្នុងទីក្រុងភ្នំពេញដែលរួមមានក្រសួងចំនួន២៥ ទីស្តីការគណៈរដ្ឋមន្ត្រី សាលាក្រុងភ្នំពេញ និងរដ្ឋលេខាធិការដ្ឋានចំនួន២ ដែលត្រូវការអនុវត្តការងារដោយការប្រើប្រាស់បច្ចេកវិទ្យាក្នុងការដឹកនាំ ការរៀបចំសេវាសាធារណៈឱ្យប្រកបដោយភាពប៉ិនប្រសប់ និងភាព

[3] សៀវភៅ នីតិរដ្ឋបាលទូទៅ, អនុបណ្ឌិត ហៀង សាង, បោះពុម្ពលើកទី៣ ឆ្នាំ២០០១

[4] E-government = Electronic-government

[5] ICT= Information and Communication Technologies

[6] OECD, **the E-government Imperative**, Paris: OECD Publications, 2003.

ងាយស្រួល។ ដូច្នេះហើយកម្ពុជាបានកំណត់ស្តង់ដានៃសេវាសាធារណៈតាមបច្ចេកវិទ្យាឌីជីថលដោយរក្សាភាពជាម្ចាស់នៃក្រសួងស្ថាប័នដែលផ្អែកលើមូលដ្ឋាននៃការអភិវឌ្ឍវិស័យ ICT រដ្ឋាភិបាល និងសេវាសាធារណៈឌីជីថលបាន និងកំពុងលេចរូបរាងឡើងជាបណ្តើរៗ។[7]

- **រដ្ឋាភិបាលឌីជីថល**

រដ្ឋាភិបាលឌីជីថល (Digital Government) សំដៅលើការប្រើប្រាស់**បច្ចេកវិទ្យាឌីជីថល**[8] រួមបញ្ចូលជាមួយយុទ្ធសាស្ត្រធ្វើទំនើបកម្មរបស់រដ្ឋាភិបាលដើម្បីបង្កើតតម្លៃសាធារណៈ។ តួអង្គសំខាន់ៗរបស់ប្រព័ន្ធអេកូឡូស៊ីនៃរដ្ឋាភិបាលឌីជីថលរួមមានរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អាជីវកម្ម សហគមន៍ ប្រជាពលរដ្ឋ និងបុគ្គលដែលគាំទ្រដល់ការបង្កើត ការទទួលទិន្នផល សេវាកម្ម និងមាតិកាតាមរយៈអន្តរកម្មជាមួយរដ្ឋាភិបាល។[9]

រដ្ឋាភិបាលឌីជីថល គឺជាតួអង្គដែលត្រូវការជាចាំបាច់ក្នុងការរៀបចំសេដ្ឋកិច្ច និងសង្គមឌីជីថលលើសពីនេះទៅទៀតរាជរដ្ឋាភិបាលត្រូវឈានមុខគេក្នុងការប្រើប្រាស់ឌីជីថលដើម្បីបង្កើតឱ្យមានតម្រូវការផ្ទាល់ និងម្យ៉ាងទៀតដើម្បីឱ្យធុរជន និងប្រជាពលរដ្ឋចាប់យកវិស័យឌីជីថល។ ដោយសារតែវិស័យសាធារណៈមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវសេវាសាធារណៈជូនប្រជាពលរដ្ឋ ការធ្វើឌីជីថលូបនីយកម្មនៃសេវាសាធារណៈ និងការធ្វើបរិវត្តកម្មប្រព័ន្ធសេវាសាធារណៈ ដែលត្រូវឈរលើមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលប្រកបដោយភាពជឿនលឿន និងទាន់សម័យ។ សម្រាប់កម្ពុជារាជរដ្ឋាភិបាលបានអនុវត្តន៍នូវកម្មវិធី និងគំនិតផ្តួចផ្តើមមួយចំនួនក្នុងការធ្វើបរិវត្តកម្មឌីជីថលនូវប្រព័ន្ធរដ្ឋបាលសាធារណៈ និងសេវាសាធារណៈជាបន្តបន្ទាប់។ ទោះជាយ៉ាងនេះក្តីការធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធសាធារណៈគឺស្ថិតក្នុងល្បឿនមួយដែលយឺតធៀបនឹងកម្រិតមធ្យមនៅក្នុងអនុតំបន់ តំបន់ និងសកល។ ក្នុងបរិការណ៍នេះរាជរដ្ឋាភិបាលមានភាពចាំបាច់ដែលត្រូវពន្លឿនការអនុវត្តគំនិតផ្តួចផ្តើម និងកិច្ចការកែទម្រង់ពាក់ព័ន្ធដើម្បីសម្របខ្លួនទៅជារដ្ឋាភិបាលឌីជីថល។ ដូចនេះដើម្បីជំរុញរបៀបវារៈនៃការកែទម្រង់របស់រាជរដ្ឋាភិបាលដោយប្រើប្រាស់បច្ចេកវិទ្យា និងបង្កើតបរិយាកាសប្រកបដោយបរិយាបន្នកម្ម[10] មួយក្នុងការអភិវឌ្ឍ ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលដែលអាចគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវបេសកកម្មលើបរិវត្តកម្មឌីជីថល និងការពង្រីកបន្ថែមដើម្បីគាំទ្រដល់ធុរកិច្ច និងប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលផ្តោតការកសាងរដ្ឋាភិបាលឌីជីថលលើទិដ្ឋភាព៣ ដែលរួមមានរដ្ឋាភិបាលសេវាសាធារណៈឌីជីថលតាមរយៈការបន្តផ្តល់ភាពជាម្ចាស់ និងការទទួលខុសត្រូវនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័នសំខាន់ៗ និងការកសាងស្តង់ដាបច្ចេកទេសរួមសម្រាប់ការអនុវត្តនៅតាមក្រសួង-ស្ថាប័ន និងជាគន្លឹះជំរុញការអនុវត្តវិស័យឌីជីថល ព្រមទាំងអភិបាលកិច្ចផ្អែកលើទិន្នន័យ។[11]

---

[7] គេហទំព័រ https://www.jica.go.jp/project/cambodia ដកស្រង់ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២១

[8] បច្ចេកវិទ្យាឌីជីថល សំដៅដល់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) រួមមាន អ៊ីនធើណេត បច្ចេកវិទ្យា និងឧបករណ៍ចល័ត ក៏ដូចជាបច្ចេកវិទ្យាវិភាគទិន្នន័យដែលត្រូវបានប្រើដើម្បីធ្វើឱ្យប្រសើរឡើងនូវជំនាន់ ការប្រមូល ការផ្លាស់ប្តូរ ការរួមបញ្ចូលគ្នា ការវិភាគ ការលទ្ធភាពស្វែងរក និងការបង្ហាញនៃមាតិកាឌីជីថល រួមទាំងធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍសេវាកម្ម និងសូហ្វវែរកម្មវិធីផ្សេងៗទៀត។

[9] គេហទំព័រ https://secudemy.com/egov-digital/ ដកស្រង់ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២១

[10] "បរិយាបន្នកម្ម" មានន័យថា វិធានការ ឬគោលនយោបាយដែលរាប់បញ្ចូល ឬផ្តល់លទ្ធភាពដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចពីដំណើរការនៃការអនុវត្ត គម្រោងកម្មវិធី ឬគោលនយោបាយ។ ឧទាហរណ៍៖ ការបង្កលក្ខណៈឲ្យជនពិការមានការងារធ្វើជាបរិយាបន្នកម្មនៃដំណើរការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

[11] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច_និងសង្គមឌីជីថលកម្ពុជា_ឆ្នាំ២០២១_២០៣៥, ទំព័រទី១៧

រដ្ឋាភិបាលឌីជីថល នេះមានអន្តរកម្មឌីជីថលរវាង៖

- ✓ ពលរដ្ឋ និង រដ្ឋាភិបាលរបស់ពួកគេ (C2G)
- ✓ រដ្ឋាភិបាល និង ទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត (G2G)
- ✓ រដ្ឋាភិបាលនិងពលរដ្ឋ (G2C)
- ✓ រដ្ឋាភិបាល និងនិយោជិក (G2E)
- ✓ រដ្ឋាភិបាល និងធុរកិច្ច / មិត្តភក្តិ (G2B)។

គំរូនៃការចែកចាយតាមប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋាភិបាលអាចត្រូវបានបែងចែកជាប្រភេទដូចខាងក្រោមអន្តរកម្មនេះរួមមាន ៖

- ✓ ពលរដ្ឋប្រាស្រ័យទាក់ទងជាមួយគ្រប់កម្រិតនៃរដ្ឋាភិបាល (ទីក្រុង រដ្ឋ ខេត្ត ជាតិ និងអន្តរជាតិ)
- ✓ ជួយសម្រួលដល់ការចូលរួមរបស់ពលរដ្ឋក្នុងអភិបាលកិច្ចដោយប្រើប្រាស់ព័ត៌មាននិងការទំនាក់ទំនងបច្ចេកវិទ្យា (ICT) ដូចជាកុំព្យូទ័រនិងគេហទំព័រ និង
- ✓ ដំណើរការអាជីវកម្មឡើងវិញវិស្វកម្ម។

ក្រៅពីអត្ថន័យដែលបានកំណត់បង្ហាញខាងលើ ធនាគារពិភពលោក ( The World Bank ) បានកំណត់និយមន័យនៃរដ្ឋាភិបាលឌីជីថលថា "រដ្ឋាភិបាលឌីជីថល" សំដៅលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៃទីភ្នាក់ងាររបស់រដ្ឋាភិបាលដូចជា បណ្តាញតំបន់ធំទូលាយនៃប្រព័ន្ធអ៊ីនធឺណេត និងកុំព្យូទ័រចល័ត (Mobile Computer) ដែលមានសមត្ថភាពផ្លាស់ប្តូរទំនាក់ទំនងជាមួយពលរដ្ឋ អាជីវកម្ម និងធុរជនដទៃទៀតរបស់រដ្ឋាភិបាល។ បច្ចេកវិទ្យាទាំងនេះអាចផ្តល់ជូននូវភាពខុសគ្នាជាច្រើនដូចជា៖

- ✓ ការផ្តល់សេវាកម្មរបស់រដ្ឋាភិបាលឱ្យកាន់តែប្រសើរដល់ប្រជាពលរដ្ឋ
- ✓ ការធ្វើឱ្យប្រសើរឡើងនូវអន្តរកម្មជាមួយអាជីវកម្មនិងឧស្សាហកម្ម
- ✓ ការផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋតាមរយៈការទទួលបានព័ត៌មាន ឬការគ្រប់គ្រងរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព។
- ✓ អត្ថប្រយោជន៍ដែលទទួលបានអាចជាការកាត់បន្ថយអំពើពុករលួយ បង្កើននូវតម្លាភាព បង្កើនភាពងាយស្រួលដែលអាចឱ្យប្រជាជនមានអំណាចក្នុងការចូលទៅប្រើប្រាស់ព័ត៌មានកាន់តែឆាប់រហ័ស
- ✓ បង្កលក្ខណៈងាយស្រួលដល់រដ្ឋាភិបាលក្នុងការគ្រប់គ្រងរដ្ឋបាល
- ✓ ជួយឱ្យប្រទេសជាតិមានការកំណើនប្រាក់ចំណូលនៅតាមវិស័យតាមរយៈ ការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យា។[12]

ចំណែកឯក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានកំណត់និយមន័យរដ្ឋាភិបាលអេឡិចត្រូនិកថា ជាការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ដោយស្ថាប័នរដ្ឋាភិបាលដើម្បីធ្វើទំនាក់ទំនង ឬផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋ វិស័យឯកជន និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀត។[13]

[12] World Bank, "Definition of E-government" accessed 27 May 2008

[13] គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០ "ឆ្ពោះទៅសន្តិភាព និងកម្មញ្ញភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន" នៃឧបសម្ព័ន្ធទី១ វាក្យស័ព្ទទំព័រទី១

### **១.១.២. សាវតា**

បន្ទាប់មករបកគំហើញខាងបុរេប្រវត្តិនៃរបៀបប្រើប្រាស់ភ្លើង ដែលបានបង្កើនប្រភពនៃចំណីអាហារដែលរកបានការច្នៃប្រឌិតកង់បានជួយមនុស្សក្នុងការធ្វើដំណើរ និងគ្រប់គ្រងបរិស្ថានរបស់ខ្លួន។ កិច្ចអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីៗរួមមានយន្តបោះពុម្ព ទូរស័ព្ទ និងអន្តរជាលបានបន្ធូរបន្ថយរបាំងរូបខាងទំនាក់ទំនង និងអនុញ្ញាតឱ្យមនុស្សធ្វើអន្តរកម្មដោយសេរីទូទាំងពិភពលោក។ យ៉ាងណាក៏ដោយ បច្ចេកទេសមិនមែនទាំងអស់ទៅដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងសន្តិភាពនោះទេការអភិវឌ្ឍសព្វាវុធបានបង្កើនជានិច្ចនូវថាមពលបំផ្លិចបំផ្លាញបានចម្រើនជឿនលឿនតាមរយៈប្រវត្តិសាស្រ្តពីដំបងព្រនង់ទៅដល់អាវុធនុយក្លេអ៊ែរ។ ហើយបច្ចេកវិទ្យាបានជះឥទ្ធិពលដល់សង្គម និងអ្វីៗដែលនៅជុំវិញវាដោយមធ្យោបាយជាច្រើនក្នុងសង្គមផងដែរ។ ក្នុងចំណោមប្រទេសទាំងអស់លើសកលលោកប្រទេសកម្ពុជាក៏ជាប្រទេសមួយ ដែលស្ថិតនៅក្នុងការវិវដ្តពីសម័យកាលមួយទៅសម័យកាលមួយចាប់តាំងពីពេលបុរាណកាលមកយើងឃើញថាឆ្លងកាត់ពីជំនាន់មួយទៅជំនាន់មួយទៀត គឺតែងតែមានការកែប្រែទៅរកការរីកចម្រើនតាមរយៈការធ្វើកំណែទម្រង់នៃការគ្រប់គ្រងប្រទេស ឬរដ្ឋ។

ការរីកចម្រើនបច្ចេកវិទ្យាទំនើបយ៉ាងឆាប់រហ័សនៅក្នុងសម័យកាលនេះ ដែលត្រូវបានអនុញ្ញាតឱ្យមានការសំយោគបញ្ចូលគ្នា នូវមាតិការព័ត៌មាន ការប្រើប្រាស់ ការអភិវឌ្ឍបច្ចេកវិទ្យាកុំព្យូទ័រ ការផ្សព្វផ្សាយ ការទំនាក់ទំនង និងការចែកចាយ។ មិនតែប៉ុណ្ណោះឥទ្ធិពលនៃសមត្ថភាពធនធានមនុស្សបានជំរុញឱ្យមានការបង្កើតនូវគុណប្រយោជន៍ដ៏ពេញនិយមនាពេលបច្ចុប្បន្ននេះ គឺបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន។ ការរួមបញ្ចូលគ្នានៃបច្ចេកវិទ្យាបាននាំមកនូវការផ្លាស់ប្តូរ និងការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងវិស័យមួយចំនួនដូចជា ការគ្រប់គ្រងចំណេះដឹងរួមមានទាំងការបង្កើតការចម្រាញ់ ការរក្សាទុក ការចែករំលែក ការផ្សព្វផ្សាយចំណេះដឹង ការធ្វើសហប្រតិបត្តិការ និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងកម្រិតអប់រំ។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាបង្កើតនូវគោលនយោបាយបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានដែលនឹងតម្រូវឱ្យរាជរដ្ឋាភិបាលផ្តួចផ្តើមគំនិត និងគាំទ្រដើម្បីសម្រេចឱ្យបានជោគជ័យក្នុងចក្ខុវិស័យឆ្នាំ២០១៥។[14] ដែលហេតុនេះហើយទើបមានព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្រ្ត និងបច្ចេកវិទ្យាដែលហត្ថលេខា និងព្រះរាជលញ្ចករដោយប្រមុខរដ្ឋស្តីទីសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ចុះនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិវិទ្យាសាស្រ្តនិងបច្ចេកវិទ្យា ដែលសរសេរជាអក្សរកាត់ថា **ក.ជ.វ.ប** ដើម្បីជំរុញកិច្ចអភិវឌ្ឍវិទ្យាសាស្រ្ត និងបច្ចេកវិទ្យានៅកម្ពុជាឱ្យមានការរីកចម្រើនដូចបណ្តាប្រទេសជឿនលឿនក្នុងតំបន់ និងក្នុងសកលលោក។[15] ជាក់ស្តែងប្រទេសកម្ពុជាសម្រេចបាននូវការរីកចម្រើនទាំងផ្នែកសេដ្ឋកិច្ច និងសង្គមដ៏គួរឱ្យចាប់អារម្មណ៍នាប៉ុន្មានទស្សវត្សចុងក្រោយនេះ ប៉ុន្តែទាក់ទងទៅនឹង ការអភិវឌ្ឍទៅលើចំណេះដឹងជាមូលដ្ឋានកម្ពុជាមិនសូវមានការវិវឌ្ឍខ្លាំងទេបើប្រៀបធៀបទៅនឹងប្រទេសជិតខាង។ ទោះបីជាយ៉ាងណាក៏ដោយការផ្លាស់ប្តូរកំពុងកើតមានឡើងទាំងក្នុងកម្រិតរដ្ឋាភិបាលចំពោះការដាក់ចេញនូវឯកសារផែនការសំខាន់ស្តីពីវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា ព្រមទាំងកម្រិតសហគមន៍។

[14] គោលនយោបាយជាតិស្តី បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ឆ្នាំ ២០០៩ “ សំណើរគោលនយោបាយសំរាប់រាជរដ្ឋាភិបាលកម្ពុជា ”
[15] មាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា

**ឧទាហរណ៍៖** ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណេតនៅក្នុងប្រទេសកម្ពុជាបានកើនឡើងពី ៣២០,២៩០នាក់ ក្នុងឆ្នាំ២០១០ រហូតដល់ ៦,២៦៤,៩០២នាក់ ក្នុងខែមិថុនា ឆ្នាំ២០១៥។[16] ការជ្រៀបចូលចំពោះការប្រើប្រាស់អ៊ិនធឺណេត មានកម្រិត ២៥% ដែលមានកម្រិតនៅទាបនៅឡើយបើធៀបនឹងអត្រាជ្រៀបចូលនូវការប្រើប្រាស់អ៊ីនធឺណេតទូទាំងពិភពលោកដែលមាន៤២%។[17] ក៏ប៉ុន្តែកម្ពុជានៅតែបន្តអនុវត្តន៍នៅផែនការយុទ្ធសាស្ត្រនានា ដែលដាក់ចេញដោយក្របខណ្ឌអាស៊ាន និងពិភពលោកអំពីវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រលើសមាហរណកម្មតំបន់ និងការតភ្ជាប់។ ការអភិវឌ្ឍវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានសម្រាប់កម្ពុជា គឺជាឧបករណ៍នយោបាយប្រកបដោយប្រសិទ្ធភាពសម្រាប់ការបង្កើតនូវក្របខណ្ឌមួយដែលចូលរួមអភិវឌ្ឍគ្រប់ទិដ្ឋភាពនៃសង្គមនិងសេដ្ឋកិច្ចនាពេលអនាគត។ ការប្រើប្រាស់ប្រព័ន្ធឌីជីថលនាពេលបច្ចុប្បន្ន គឺជាចំណែកមួយដ៏សំខាន់ដល់ការផ្លាស់ប្តូរក្របខណ្ឌសង្គម និងសេដ្ឋកិច្ចរបស់កម្ពុជាតាមរយៈ ការបរិយាកាសវិនិយោគប្រកបដោយភាពទាក់ទាញ ការបង្កើតការងារ ការបង្កើនប្រាក់ចំណូល និងការលើកកម្ពស់ផលិតភាពតាមរយៈការទទួលបាននូវបច្ចេកវិទ្យាថ្មីៗ រួមទាំងការបង្កើតការងារក្នុងវិស័យគាំទ្រឧស្សាហកម្មដទៃទៀតដូចជា ខ្សែចង្វាក់តម្លៃចាប់តាំងពីការផលិត និងការផ្គត់ផ្គង់វត្ថុធាតុដើម សេវាដឹកជញ្ជូន ព្រមទាំងមានឡូជីស្ទីក វិស័យហិរញ្ញវត្ថុ និងបណ្តុះបណ្តាលជំនាញជាដើម។

**ចក្ខុវិស័យ** ដោយមានប្រវត្តិជាប្រទេសអច្ឆរិយ និងមានទីតាំងភូមិសាស្ត្រពិសេស ព្រះរាជាណាចក្រកម្ពុជា និងក្លាយជាដៃគូរប្រគួតប្រជែងពិតប្រាកដ និងជាសង្គមមានគ្រឹះចំណេះដឹង និងព័ត៌មានក្នុងពិភពលោក និងប្រកាន់នូវដំណោះស្រាយផ្អែកលើបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ប្រកបដោយចរីភាព។

**បេសកម្ម** ធ្វើសមាហរណកម្មនូវសកម្មភាពបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាននៅក្នុងវិស័យសាធារណៈ ព្រមទាំងឯកជន និងធានាជូននូវការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងលើកស្ទួយសង្គម ព្រមទាំងការសម្រេចនូវកិច្ចព្រមព្រៀងបទដ្ឋានសហគមន៍រួមមាន ការលើកកម្ពស់សម្បជញ្ញៈប្រឆាំងទៅនឹងកំណើនស៊ីគុណ្ឌភាពពិភពលោក ផ្តល់បទដ្ឋានច្បាប់ និងបទបញ្ញត្តិសម្រាប់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងឯកជនក្នុងការកសាងនូវសមត្ថភាពពាណិជ្ជកម្មអេឡិចត្រូនិក ដោយជំរុញឱ្យមានកំណើនបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានតំបន់។

**គោលបំណង** ដោយយោងទៅតាមចក្ខុវិស័យក្នុងការសំលឹងមើលការរៀបចំប្រទេសឱ្យទទួលបានការរីកចម្រើន និងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងគុណភាពទើបរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលបំណងដើម្បីសម្រេចការងារក្នុងការជំរុញការអភិវឌ្ឍប្រទេសឱ្យមានភាពកាន់តែឆាប់រហ័ស និងទទួលបានផលិតផលល្អប្រសើរតាមរយៈគោលបំណងដូចតទៅ៖

- បង្កើត និងផ្តល់នូវបទដ្ឋាន និងគោលនយោបាយជាតិ ដែលនឹងអនុញ្ញាតឱ្យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន រួមចំណែកក្នុងការធ្វើឱ្យសម្រេចបាននូវគោលបំណងអភិវឌ្ឍន៍ជាតិ
- ផ្តល់សេវាសកល និងលទ្ធភាពអាចប្រើប្រាស់បាននូវព័ត៌មាន រួមទាំងបរិក្ខារទំនាក់ទំនងនៅក្នុងប្រទេសដែលនឹងនាំឆ្ពោះទៅរកការប្រកួតប្រជែងទិន្នផល និងផលិតផលលើឆាកអន្តរជាតិ

[16] យោងតាមរបាយការណ៍ស្តីពី វិស័យឌីជីថល សង្គម និងទូរស័ព្ទចល័ត របស់អេភីអេស៊ី ឆ្នាំ ២០១៥

[17] បញ្ញត្តិករទូរគមនាគមន៍កម្ពុជា. "ការជាវអ៊ីនធឺណេត."

- ប្រែក្លាយព្រះរាជាណាចក្រកម្ពុជាឱ្យទៅជា សង្គមមួយដែលពោរពេញទៅដោយចំណេះដឹងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានសមស្រប
- ផែនការមេរបស់កម្ពុជាក្នុងវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន គឺបានផ្តោតទៅលើធនធានមនុស្ស ការបណ្តុះបណ្តាល និងការលើកកម្ពស់អក្ខរកម្មឌីជីថល (រាប់បញ្ចូលទាំងអ្នករស់នៅតាមជនបទ) លទ្ធភាពក្នុងការប្រើប្រាស់កុំព្យូទ័ររបស់មន្ត្រីរដ្ឋាភិបាលដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធខាងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ និងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណេត។ល។ គោលដៅជាក់លាក់នៃផែនការនេះ គឺធ្វើយ៉ាងណាឱ្យប្រជាជនកម្ពុជា អាចប្រើប្រាស់អ៊ីនធឺណេតបាន ៧០% នៅឆ្នាំ ២០២០
- ជំរុញឱ្យមានការអភិវឌ្ឍក្របខណ្ឌគតិយុត្ត និងធុរកិច្ចដើម្បីអនុវត្តន៍ពាណិជ្ជកម្ម និងវិស័យដទៃទៀតតាមប្រព័ន្ធអេឡិចត្រូនិក និងប្រកបដោយសុវត្ថិភាព។

### ១.១.៣. រចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលរបស់ប្រទេសកម្ពុជា

រចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលរបស់ប្រទេសកម្ពុជាបានផ្តល់នូវគម្រោងជាមូលដ្ឋានមួយសម្រាប់ការបង្កើតផែនការពង្រីកសេវាកម្មរដ្ឋាភិបាលឌីជីថលនេះ។ មុននឹងរៀបចំផែនការអ្វីមួយច្បាស់ណាស់ គឺត្រូវតែស្វែងយល់ឱ្យច្បាស់លាស់អំពីទិដ្ឋភាពទូទៅនៃរចនាសម្ព័ន្ធពីព្រោះវានឹងនាំមកនូវអត្ថប្រយោជន៍ជាច្រើនដល់ការរៀបចំផែនការ ឬការអនុវត្តផែនការ។ វាបង្ហាញនូវភាពចាំបាច់សម្រាប់ការផ្តល់នូវសេវាកម្មសាធារណៈ ជាមូលដ្ឋានលើប្រព័ន្ធអ៊ីនធឺណេតលើកលែងតែសេវាកម្មមួយចំនួនដែលមិនទាន់មាននៅក្នុងប្រទេសកម្ពុជា។ ដូចដែលរូបបានបង្ហាញនៅក្នុងឧបសម្ព័ន្ធខាងក្រោមនៅផ្នែកខាងឆ្វេង នៃរចនាសម្ព័ន្ធនេះវាបានកំណត់នូវបណ្តាញផ្តល់សេវាកម្មផ្សេងៗដូចជាគេហទំព័រ និងទូរស័ព្ទជាដើម។ បូកបញ្ចូលការកំណត់នូវផ្នែកមាតិកាគេហទំព័រដូចជា បញ្ជីសេវាកម្មផ្នែក Application[18] បណ្តាញNetwork និងបរិស្ថានជុំវិញ។ នៅក្នុងផ្នែក Application សេវាកម្មអេឡិចត្រូនិក (E-service)[19] ដែលមានស្រាប់មានពណ៌ត្នោត Database[20] ដែលមានស្រាប់មានពណ៌ប្រផេះ និងDatabase ដែលត្រូវការបន្ថែមសម្រាប់សេវាកម្ម រដ្ឋាភិបាលឌីជីថលមានពណ៌ស។ រចនាសម្ព័ន្ធនេះបានជំរុញឱ្យស្នូលសេវាកម្មរដ្ឋាភិបាលឌីជីថលរួមមួយក្លាយទៅជាច្រកចូលសម្រាប់សហគមន៍ជំនួញ និងប្រជាពលរដ្ឋផ្សេងៗ។ លក្ខណៈពិសេសមួយចំនួនរបស់រចនាសម្ព័ន្ធនេះរួមមាន ការផ្តល់បណ្តាញនានាសម្រាប់ប្រើប្រាស់ដោយអតិថិជនច្រើនគ្នា ការប្រើប្រាស់នូវ Interface របស់ Application រួមការផ្តល់នូវសេវាកម្ម និងព័ត៌មានលើ Portal រួមដែលផ្តោតទៅលើតម្រូវការរបស់ពលរដ្ឋស្របទៅតាមគោលបំណងរបស់សេវាកម្ម និងអនុវត្តន៍នូវកិច្ចសហប្រតិបត្តិការមួយដែលផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធដែលរួមបញ្ចូលគ្នាមួយដល់ប្រព័ន្ធ និងទីភ្នាក់ងារដែលមានស្រាប់នានា។ រចនាសម្ព័ន្ធនេះអនុវត្តន៍នូវគោលការណ៍ផ្តល់ការគាំទ្រជានិរន្តរ៍ដល់ប្រជាពលរដ្ឋ និងផ្តល់នូវសេវាកម្មច្រកចេញចូលតែមួយសម្រាប់ការធ្វើពាណិជ្ជកម្ម ព្រមទាំងតម្រូវការសេវាកម្មសាធារណៈផ្សេងៗទៀត ដែលស្របទៅការអនុវត្តជាសកលល្អបំផុតរបស់រដ្ឋាភិបាលប្រទេសជាច្រើនដូចជា ប្រទេសសិង្ហបុរី ប្រទេសម៉ាឡេស៊ី និងប្រទេស

[18] Application ៖ គឺជាកម្មវិធីកុំព្យូទ័រមួយដែលត្រូវបានរចនាឡើងដើម្បីបំពេញភារកិច្ចជាក់លាក់ណាមួយផ្សេងទៀត ដែលមានការទាក់ទងនឹងប្រតិបត្តិការរបស់កុំព្យូទ័រផ្ទាល់

[19] E-Service (Electronic service) ៖ ការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក សំដៅដល់ការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញ ឬសេវាលើកលែងគ្រឹះស្ថានធានារ៉ាប់រង។

[20] Database៖ សំណុំទិន្នន័យដែលមានរចនាសម្ព័ន្ធមាននៅក្នុងកុំព្យូទ័រជាពិសេសមួយដែលអាចចូលដំណើរការបានតាមវិធីផ្សេងៗគ្នា។

អូស្ត្រាលីជាដើម។ និយាយពីការពិពណ៌នាអំពីផ្នែកនីមួយៗ និងប្រព្រឹត្តទៅក្នុងទំព័របន្តបន្ទាប់តាមដំណាក់កាលនៃការអនុវត្តនីមួយៗ។ ក្នុងខណៈដែលរចនាសម្ព័ន្ធនេះបានដើរតួនាទី ជាផែនទីបង្ហាញផ្លូវដែលអាចកំណត់ទិសដៅបានត្រឹមត្រូវបំផុត សម្រាប់កម្មវិធីរដ្ឋាភិបាលឌីជីថលទូទៅនៅក្នុងប្រទេសកម្ពុជានេះវាក៏ ជាមគ្គុទ្ទេសដែលមានភាពបត់បែនតាម កាលៈទេសៈផងដែរ។ រចនាសម្ព័ន្ធនេះបានរៀបចំឡើង និងធ្វើការរួមបញ្ចូលគ្នានូវសេវាកម្មទៅតាមស្ថាប័នដែលពាក់ព័ន្ធយ៉ាងត្រឹមត្រូវ។ ក៏ប៉ុន្តែវានៅមានកត្តាផ្សេងៗទៀត ដែលស្ថិតនៅក្រៅក្របខណ្ឌនៃប្រតិបត្តិការរបស់ផតថលបច្ចុប្បន្នដែលនឹងអាចបំពេញនូវសេចក្តីត្រូវការ ឬគោលបំណងរបស់ទីភ្នាក់ងារជាក់លាក់ណាមួយ។ ជាក់ស្តែងសេវាកម្មអេឡិចត្រូនិក (E-Service) ដែលមានបច្ចុប្បន្នដូចជាទិដ្ឋាការអេឡិចត្រូនិក (E-Visa) ត្រូវបានគិតថានឹងត្រូវបានប្រើដើម្បីគ្រាន់តែចូលទៅកាន់ Link to portal ប៉ុណ្ណោះ។ ក៏ប៉ុន្តែផ្ទាំងគេហទំព័រដែលកំពុងដំណើរការនេះ អាចប្រើប្រាស់បានជាបន្តទៀតបន្ទាប់ពី Link នោះ។ ដូច្នេះ ជម្រើស ឬមុខងារ (option) ទាំងនេះត្រូវការនូវការពិនិត្យពិច័យម្តងមួយៗ ក្នុងពេលប្រតិបត្តិការការងារជាក់ស្តែង។[21]

### ១.១.៤. មុខងាររបស់រដ្ឋាភិបាលកម្ពុជាតាមបែបឌីជីថល

រដ្ឋាភិបាលឌីជីថលវាមើលទៅហាក់បីដូចជារលក ដែលរក្សានូវការរុញច្រានទៅមុខជានិច្ចនៅក្នុងផ្នែកសាធារណៈជុំវិញពិភពលោក។ រដ្ឋាភិបាលជាច្រើនបានចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ជាពិសេសប្រព័ន្ធអ៊ីនធឺណេត គេហទំព័រផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាផ្តល់នូវសេវាកាន់តែល្អ ព្រមទាំងជាសេនាធិការចំណុះឱ្យរដ្ឋាភិបាល សម្រាប់ប្រជាពលរដ្ឋ អាជីវកម្ម និងបុគ្គលិក។ លើសពីនេះទៅទៀតមុខងាររបស់រដ្ឋាភិបាលត្រូវបានពិពណ៌នាដូចខាងក្រោម៖

- ប្រជាពលរដ្ឋអាចចូលទៅប្រើប្រាស់ព័ត៌មានរបស់រដ្ឋាភិបាល ដែលផ្តល់មកនូវការចូលទៅប្រើប្រាស់ព័ត៌មានទាំងអស់របស់រដ្ឋាភិបាល គឺជាការផ្តួចផ្តើមដ៏សំខាន់របស់រដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក ប្រភេទនៃការផ្តួចផ្តើមនេះផ្តល់ឱ្យនូវការដាក់ដំណើរការជាប្រព័ន្ធ។

  **ឧទាហរណ៍៖** ផតថល (Portal) គេហទំព័រពឹងផ្អែកទៅលើចំនួនអតិថិជនដែលបានចូលមើល។
- សម្របសម្រួលភាពអនុលោមជាទូទៅ រដ្ឋាភិបាលអេឡិចត្រូនិក ក៏បានណែនាំប្រព័ន្ធអេឡិចត្រូនិកភ្ជាប់ទៅកាន់សេវាប្រើប្រាស់ដែលជួយសម្រួលភាពអនុលោមជាមួយនឹងបណ្តុំនៃច្បាប់ ឬបទប្បញ្ញត្តិផ្សេងៗ។
- ប្រជាពលរដ្ឋទទួលបានអត្ថប្រយោជន៍ផ្ទាល់ខ្លួនការដាក់ពាក្យស្នើសុំអនឡាញ និងព័ត៌មានដទៃទៀតបានផ្តល់ផលប្រយោជន៍ទៅដល់ពួកគេ។
- លទ្ធកម្មរួមមានការដេញថ្លៃ ការទិញយក និងការបង់ថ្លៃ ក្រុមហ៊ុនឯកជនអាចទទួលបានអត្ថប្រយោជន៍តាមរយៈទម្រង់ពាណិជ្ជកម្មអេឡិចត្រូនិក (E-commerce)[22] ដែលទម្រង់លទ្ធកម្មនេះអនុញ្ញាតឱ្យស្ថាប័នរបស់រដ្ឋាភិបាលទទួលបានឱកាសនេះជាមួយផ្នែកឯកជន។ ការប្រតិបត្តិការអេឡិចត្រូនិកបានបំពេញសេចក្តីត្រូវការនៃរដ្ឋាភិបាលខ្លួនឯង និងទៅកាន់ដៃគូឯកជនដទៃទៀត។

---

[21] Toolkit សម្រាប់រៀបចំផែនការបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) សម្រាប់ភ្នាក់ងាររដ្ឋាភិបាលរដ្ឋាភិបាល របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (NiDA) ឆ្នាំ២០០៨

[22] E-commerce (Electronic commerce) ៖ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញ ឬសេវាដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងរដ្ឋប្បវេណី ព្រមទាំងសកម្មភាព និងប្រតិបត្តិការនានារបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក

- ពីរដ្ឋាភិបាលធម្មតាទៅជាសមាហរណកម្មព័ត៌មាន និងសៅវាតែមួយរបស់រដ្ឋាភិបាលការចែកចាយព័ត៌មានអេឡិចត្រូនិក និងសមាហរណកម្មស្ថិតក្រោមលក្ខខណ្ឌនៃកម្មវិធីបញ្ជូនសេវាជាកញ្ចប់ឆ្លងកាត់ស្ថាប័នរដ្ឋាភិបាល និងសេនាធិការគ្រប់ផ្នែកទាំងអស់នៃរដ្ឋាភិបាល។
- ការចូលរួមរបស់ប្រជាពលរដ្ឋដោយប្រជាពលរដ្ឋអាចចូលរួមនៅក្នុងដំណើរការនៃ ការបង្កើតសេចក្តីសម្រេចតាមរយៈការប្រជុំពិភាក្សាតាមអនឡាញ ជាមួយនិងការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក (E-Voting)[23]។ ទាំងនេះអាចបម្រើសេវាកម្មជាចំនួនច្រើនបាន ដែលរដ្ឋាភិបាលជាច្រើនកំពុងតែពិចារណាក្នុងការធ្វើវាឱ្យប្រសើរជាងនេះ។

## ១.២. បំណែងចែកនៃការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថល

ការផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាលឌីជីថលកម្ពុជាមានបំណែងចែក ឬអន្តរកម្មរវាង៖ រដ្ឋាភិបាលឌីជីថលទៅកាន់ប្រជាពលរដ្ឋ (G2C), រដ្ឋាភិបាលឌីជីថលទៅកាន់ធុរជន (G2B), រដ្ឋាភិបាលឌីជីថលទៅកាន់រដ្ឋាភិបាល (G2G), រដ្ឋាភិបាលឌីជីថលទៅកាន់បុគ្គលិក (G2E)។ ការធ្វើបំណែងចែកនេះសម្រាប់ផ្តល់នូវភាពសម្របសម្រួលក្នុងកិច្ចការងារសង្គម និងសេដ្ឋកិច្ចជាតិដើម្បីឱ្យគ្រប់វិស័យទាំងអស់ទទួលបានការរីកចម្រើន និងតម្លាភាពក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត។

### ១.២.១. ការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់ប្រជាពលរដ្ឋ (G2C)

ប្រភេទនៃសេវានេះរក្សានូវក្រសែភ្នែកនៃសកម្មភាពរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋសម្រាប់ការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកនៅក្នុងសមត្ថភាពនៃចំណេះដឹងខាងប្រព័ន្ធអេឡិចត្រូនិក។ ប្រជាពលរដ្ឋអាចទទួលបានអត្ថប្រយោជន៍ពីព័ត៌មានរបស់រដ្ឋាភិបាល។ អត្ថប្រយោជន៍ចម្បងនៃសេវាកម្មរបស់រដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ (G2C) គឺជាទម្រង់បំពេញបែបបទធម្មតា និងពាក្យស្នើសុំអនឡាញ។ សេវាកម្ម២៤ម៉ោង ក្នុង៧ថ្ងៃ (២៤/៧) នៅតែដំណើរការជានិច្ចនៅលើប្រព័ន្ធអ៊ីនធឺណេត។ ប្រជាពលរដ្ឋអាចចូលទៅប្រើប្រាស់ព័ត៌មានរបស់រដ្ឋាភិបាលភ្លាមៗដោយពុំចាំបាច់ទៅកាន់ទីតាំងផ្ទាល់ទេ។ អត្ថប្រយោជន៍ផ្សេងៗទៀតគឺបានបម្រើសេវាកម្មនោះទៅកាន់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ចំណេះដឹងខាងព័ត៌មានវិទ្យានីតិវិធីសុវត្ថិភាព (Security procedure) និងការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិកជាដើម។ ម៉្យាងវិញទៀតសេវាកម្មនេះត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ សម្រាប់រូបវន្តបុគ្គលទូទៅ។ សេវាកម្មទាំងនេះរួមមាន ការបន្តសុពលភាពនៃប័ណ្ណបើកបរ ការបង់ពន្ធ ការជាកពិន័យ ការបង់ប្រាក់ជូនរដ្ឋ វិក័យបត្រដែលចេញដោយអង្គភាពរបស់រដ្ឋ ឬស្ថាប័ន និងការបង់ថ្លៃសេវាប្រភេទផ្សេងៗ។ ការកត់សម្គាល់ នៃសេវារបស់រដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋអនុញ្ញាតឱ្យពួកគេចូលទៅប្រើប្រាស់សេវាអេឡិចត្រូនិកគ្រប់ប្រភេទ គ្រប់ពេលវេលាទាំងអស់ដោយផ្ទាល់ និងងាយស្រួលតាមរយៈឧបករណ៍ផ្សេងៗដូចជា កុំព្យូទ័រ ទូរទស្សន៍ឆ្លាតវៃ ទូរស័ព្ទដៃ ឬឧបករណ៍ភ្ជាប់ទៅកាន់អ៊ីនធឺណេត។ វាក៏ជួយឱ្យរដ្ឋាភិបាលអាចនិយាយ ស្តាប់ គាំទ្រ និងធ្វើ

[23] E-Voting (Electronic Voting) ៖ការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក សំដៅទៅដល់ការបោះឆ្នោតតាមអេឡិចត្រូនិកគឺជាដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោត កត់ត្រាសន្លឹកនឹងដាក់តាមតារាអេឡិចត្រូនិក។

ទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋដោយផ្ទាល់ព្រមទាំងលើកទឹកចិត្តឱ្យពួកគេចូលរួមនៅក្នុងការប្រើប្រាស់តាមរយៈសារអេឡិចត្រូនិក (E-mail)[24] ឬក៏ជាការប្រជុំពិភាក្សាតាមអនឡាញ។

ជាក់ស្តែងសម្រាប់បច្ចុប្បន្ន ប្រជាពលរដ្ឋប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកមានកំណើនកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃ ដោយពួកគេប្រើប្រាស់ សម្រាប់ធ្វើជំនួញ និងការបង្រៀន (រៀនអនឡាញ Online class) ការទំនាក់ទំនង ការផ្តល់សេវាកម្មសាធារណៈទូទៅរបស់រដ្ឋាភិបាល ការទទួលសេវាកម្ម ការទូទាត់ប្រាក់។ល។ សកម្មភាពទាំងអស់នេះ គឺសុទ្ធសឹងតែឆ្លងកាត់ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិករហូតឈានដល់ដំណាក់កាលអាចនឹងគាំងស្ទះដំណើរការទាំងអស់នៅគ្រប់វិស័យប្រសិនបើមិនមានការប្រើប្រាស់ ឬការសម្រាលការងារពីប្រព័ន្ធបច្ចេកវិទ្យា។ វាអាចនាំឱ្យប្រទេសទាំងមូលមិនមានការអភិវឌ្ឍប្រសិនបើប្រទេសនោះមិនមានការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានោះ។ ពីព្រោះសម័យសតវត្សទី២១នេះ គឺជាសម័យនៃបច្ចេកវិទ្យា ឬសម័យអ៊ីនធឺណេតដោយគេប្រើប្រាស់វាដើម្បីរៀបចំការដឹកនាំប្រទេសឱ្យស្ថិតក្នុងភាពងាយស្រួល និងសុវត្ថិភាពព្រមទាំងមានភាពច្នៃប្រឌិត ជឿនលឿនក្នុងការផ្តល់ព័ត៌មាន ក៏ដូចជាការផ្តល់សេវាសាធារណៈទៅកាន់ប្រជាពលរដ្ឋ។

**១.២.២.ការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់ធុរជន** ( G2B )

ប្រភេទនៃសេវានេះផ្តោតសំខាន់ទៅលើសមត្ថភាពនៃការកាត់បន្ថយថ្លៃចំណាយ ការប្រមូលព័ត៌មាន និងបង្កើនការគ្រប់គ្រងកាន់តែប្រសើរឡើង។ នៅក្នុងសេវាកម្មនេះរដ្ឋាភិបាលអាចទទួលបានជាវត្ថុ ការបង់ថ្លៃវិក័យបត្រ និងបានឃើញពីសកម្មភាពអាជីវកម្មផ្សេងៗទៀត នៅក្នុងន័យបានទទួលផលប្រយោជន៍ពីអាជីវកម្មនោះ។ ការរក្សាបាននូវទិន្នន័យដើម្បីពិនិត្យបច្ច័យ និងជួយឱ្យការបង្កើតសេចក្តីសម្រេចអាចត្រូវធ្វើឡើងបាន ព្រមទាំងជួយគាំទ្ររដ្ឋាភិបាលតាមរយៈសេវាកម្មរដ្ឋាភិបាលទៅកាន់ធុរជន។ អត្ថប្រយោជន៍មួយចំនួនទៀតសម្រាប់ប្រភេទនៃសេវាកម្មនេះមានដូចជា បទប្បញ្ញត្តិតាមប្រព័ន្ធអនឡាញដែលបានបង្ហាញស្រាប់សម្រាប់ស្ថាប័នឯកជន និងសម្របសម្រួលដល់ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់សហគ្រាស ក្រុមហ៊ុន ឬអាជីវកម្ម។ កាលពីមុនវាពិតជាមានភាពលំបាក សម្រាប់ធុរជនទាំងនោះក្នុងការស្វែងរកព័ត៌មាននានាសម្រាប់ដំណើរការបើកអាជីវកម្មរបស់ខ្លួន ប៉ុន្តែនាបច្ចុប្បន្ននេះព័ត៌មានទាំងនោះអាចស្វែងរកបាននៅតាមគេហទំព័រតែមួយដែលមានភាពជឿជាក់សុវត្ថិភាពអត្រានៃការងារ បរិស្ថាន និងច្បាប់ស្តីពីសារពើពន្ធ។ នៅក្នុងនោះចំពោះសេវារបស់រដ្ឋាភិបាលទៅកាន់ធុរជនគឺជាសេវាដែលប្រើប្រាស់ដោយធុរជន ភ្នាក់ងារឯកជន និងការសហប្រតិបត្តិការសម្រាប់គោលបំណងពាណិជ្ជកម្មណាមួយ។

**ឧទាហរណ៍៖** ការទទួលបាននូវការបើកអាជីវកម្ម ការទទួលបាននូវការគាំទ្រពីរដ្ឋាភិបាល និងរក្សាបាននូវព័ត៌មានកម្លាំងពលកម្មនៃអាជីវកម្មរបស់ខ្លួន។ ចំពោះសេវាកម្មនេះរួមមានដំណើរការនៃការធ្វើលទ្ធកម្មប្រតិបត្តិការតាមប្រព័ន្ធបច្ចេកវិទ្យាជាមួយនឹងក្រុមហ៊ុន និងភ្នាក់ងារឯកជននានា។ វាក៏បានបង្កើតនូវទីផ្សារអេឡិចត្រូនិកផងដែរសម្រាប់រដ្ឋាភិបាលក្នុងការទាក់ទាញវិនិយោគិនជាតិ និងអន្តរជាតិ ព្រមទាំងកាត់បន្ថយការរាំងស្ទះមួយចំនួនដោយជំនួសមកវិញនូវដំណើរការកាន់តែងាយស្រួល ដើម្បីជួយឱ្យការស្ថាបនាគេហទំព័រណាមួយដំណើរការលឿន និងមានតម្លៃសមរម្យ។

[24] E-mail (Electronic mail) ៖ អ៊ីមែល ឬសារអេឡិចត្រូនិក សំដៅដល់សារព័ត៌មានដែលត្រូវបានបង្កើតឡើង បញ្ជូន ឬទទួលបានពីប្រព័ន្ធអេឡិចត្រូនិក រួមទាំងឯកសារភ្ជាប់ក្នុងអត្ថបទ រូបភាព សំឡេង វីដេអូ និងកំណត់ត្រាអេឡិចត្រូនិកណាមួយផ្សេងទៀតដែលអាចបញ្ជូនជាមួយសារបាន។

និយាយរួមការផ្តល់សេវារបស់រដ្ឋាភិបាលទៅកាន់ធុរជន គឺជាអន្តរកម្មក្រៅប្រព័ន្ធអ៊ីនធឺណេតរវាងរដ្ឋាភិបាលមូលដ្ឋាន និងកណ្តាលវិស័យជំនួញពាណិជ្ជកម្មក្នុងគោលបំណងផ្តល់ព័ត៌មានអាជីវកម្ម និងដំបូន្មានស្តីពីការអនុវត្តអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ បើមានការផ្តល់សេវារដ្ឋាភិបាលអេឡិចត្រូនិកនេះទៅកាន់ធុរជននោះវានឹងនាំមកនូវភាពងាយស្រួលក្នុងការបង្កើតអាជីវកម្មដោយស្របច្បាប់តាមរយៈការផ្តល់ព័ត៌មាន និងនីតិវិធីរបស់រដ្ឋាភិបាលនៅតាមគេហទំព័រនៃប្រព័ន្ធបច្ចេកវិទ្យា។ មិនតែប៉ុណ្ណោះនៅពេលដែលម្ចាស់ក្រុមហ៊ុន ឬម្ចាស់អាជីវកម្ម ព្រមទាំងវិនិយោគិនមិនខាតពេលវេលាច្រើនក្នុងការស្វែងយល់អំពីព័ត៌មានសម្រាប់ពាណិជ្ជកម្មរបស់ខ្លួនដូចកាលពីមុនឡើយ។ គោលបំណងរបស់ការផ្តល់សេវារបស់រដ្ឋាភិបាលទៅកាន់ធុរជន គឺដើម្បីកាត់បន្ថយការលំបាកសម្រាប់អាជីវកម្មផ្តល់ព័ត៌មានជាបន្ទាន់ និងបើកទំនាក់ទំនងតាមឌីជីថលតាមរយៈអាជីវកម្មអេឡិចត្រូនិក។ លើសពីនេះទៀតរដ្ឋាភិបាលគួរតែប្រើទិន្នន័យឡើងវិញនៅក្នុងរបាយការណ៍ឱ្យបានត្រឹមត្រូវ និងទាញយកប្រយោជន៍ពីពិធីសារប្រតិបត្តិការអេឡិចត្រូនិកពាណិជ្ជកម្ម។ សេវាកម្មរបស់រដ្ឋាភិបាលផ្តោតលើ សេវាមនុស្ស សេវាកម្មសហគមន៍ សេវាកម្មតុលាការ សេវាកម្មដឹកជញ្ជូន ធនធានដីធ្លី សេវាកម្មអាជីវកម្ម សេវាកម្មហិរញ្ញវត្ថុ និងផ្សេងៗទៀត (សមាសធាតុនីមួយៗដែលបានរាយខាងលើសម្រាប់ចង្កោមនីមួយៗនៃសេវាកម្មដែលពាក់ព័ន្ធដល់សហគ្រាស)។

### ១.២.៣. ការផ្តល់សេវារបស់រដ្ឋាភិបាលឌីជីថលទៅកាន់រដ្ឋាភិបាល (G2G)

ចំពោះសេវានេះវិញរួមមានការពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការ និងមុខងារអាជីវកម្មដោយខ្លួនឯង ឬជាមួយនឹងរដ្ឋាភិបាល។ ដើម្បីឱ្យសេវានេះទទួលបាននូវការប្រើប្រាស់ដ៏ទូលំទូលាយលុះត្រាតែ ជាប្រភេទសេវាជាកញ្ចប់ដែលមានសមាគម និងដៃគូសហប្រតិបត្តិការធ្វើការរួមគ្នាយ៉ាងស្អិតរមួត ជាមួយនឹងអគ្គនាយកដ្ឋានស្ថាប័ននានាដែលចំណុះឱ្យរដ្ឋាភិបាល។ វាអនុញ្ញាតឱ្យរដ្ឋាភិបាលកាត់បន្ថយនូវអត្រាគ្មានការងារធ្វើបទល្មើសអសុវត្ថិភាពតាមផ្ទះ (Homeless Security)។ សម្រាប់សកម្មភាពរដ្ឋាភិបាលបានណែនាំឱ្យមានការសហការគ្នាជាអន្តរក្រសួង បង្កើនការឆ្លើយតបឱ្យបានទាន់ពេលវេលា និងតភ្ជាប់ការប្រកាសរបស់អន្តរក្រសួង។ លើសពីនេះទៅទៀតសេវានេះផ្តល់ឱ្យនូវកិច្ចសហប្រតិបត្តិការទាំងអស់ទាំងក្នុង និងក្រៅស្ថាប័ន និងពង្រឹងសេវាទាំងក្នុង និងក្រៅរដ្ឋាភិបាល។ វាក៏មានការផ្លាស់ប្តូរព័ត៌មានជាមួយរដ្ឋាភិបាល។ ជាមួយគ្នានេះដែរ សេវាប្រភេទនេះក៏បានបង្កើតនូវទំនាក់ទំនងយ៉ាងល្អជាមួយនឹងអន្តការជាតិ ក្នុងស្រុក តំបន់ និងអង្គការអន្តរជាតិ។ ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការតាមប្រព័ន្ធអនឡាញ ដើរតួនាទីយ៉ាងសំខាន់រវាងស្ថាប័នរបស់រដ្ឋាភិបាល និងអគ្គនាយកដ្ឋាននានាដើម្បីចែករំលែកទិន្នន័យ ធនធាន ជំនាញ និងសមត្ថភាពលើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិរបស់រដ្ឋាភិបាល។

### ១.២.៤. ការផ្តល់សេវាកម្មរបស់រដ្ឋាភិបាលឌីជីថលទៅកាន់បុគ្គលិក (G2E)

យោងតាមប្រភេទនៃសេវានេះមានទំនាក់ទំនងរវាងរដ្ឋាភិបាល និងបុគ្គលិក។ ការផ្តល់សេវារដ្ឋាភិបាលទៅកាន់បុគ្គលិកលើកទឹកចិត្តឱ្យបុគ្គលិកចូលរួមដើម្បីបង្កើនប្រសិទ្ធភាព និងផ្តល់ឱ្យរបៀបនៃការសិក្សាពីចម្ងាយ (E-Learning)[25] ប្រមូលផ្តុំបុគ្គលិកទាំងអស់ លើកកម្ពស់សក្តិសិទ្ធិភាពក្នុងការធ្វើការងាររបស់ពួកគេ។ សេវានេះ

---

[25] E-learning (Electronic learning) ៖ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក សំដៅទៅលើការរៀបតាមបរយៈអេឡិចត្រូនិកដែលហៅម៉្យាងទៀតងាការសិក្សារៀនសូត្រ តាមអ៊ីនធឺណេត ឬជាការសិក្សាតាមអេឡិចត្រូនិក គឺជាការទទួលបានចំណេះដឹងតាមរយៈបច្ចេកវិទ្យាអេឡិចត្រូនិក និងប្រព័ន្ធផ្សព្វផ្សាយ

ត្រូវបានពិពណ៌នាដោយផ្តល់ឱ្យបុគ្គលិកអាចចូលទៅប្រើប្រាស់គោលនយោបាយដែលទាក់ទងទៅនឹង ការទូទាត់ប្រាក់សំណង និងអត្ថប្រយោជន៍ផ្សេងទៀតជាដើម។ ជាចុងក្រោយ សេវានេះបានជួយសម្រាបសម្រួលការគ្រប់គ្រង និងការទំនាក់ទំនងជាមួយបុគ្គលិករបស់រដ្ឋាភិបាលដើម្បីបង្កើតប្រព័ន្ធរកការងារតាមអេឡិចត្រូនិក (E-careers)[26] និងប្រព័ន្ធការិយាល័យអេឡិចត្រូនិក (E-office)[27]។[28]

| បំណែងចែកនៃសេវារបស់រដ្ឋាភិបាលទៅកាន់ | ព័ត៌មាន | ទំនាក់ទំនង | ប្រតិបត្តិការ |
|---|---|---|---|
| **ប្រជាពលរដ្ឋ** | ព័ត៌មានអំពីពន្ធ ប័ណ្ណបើកបរ តម្លៃនៃសេវាកម្ម ការផាកពិន័យ និងវិក័យបត្រប្រភេទផ្សេងៗ | និយាយ ស្តាប់ គាំទ្រ និងទំនាក់ទំនងជាមួយ រដ្ឋាភិបាល។ លើកទឹកចិត្តប្រជាពលរដ្ឋចូលរួមតាមរយៈសារអេឡិចត្រូនិក (Email) | ការប្រជុំពិភាក្សា ការបោះឆ្នោត និងការបញ្ជូនសេវា |
| **ធុរជន** | ព័ត៌មានអំពីការបើកអាជីវកម្ម សុវត្ថិភាពបរិយាកាសអំពីការងារ បរិស្ថាន និងច្បាប់ស្តីពីសារពើពន្ធ | ទំនាក់ទំនងជាមួយ រដ្ឋាភិបាល ចូលរួមដំណើរការនៃការបង្កើតសេចក្តីសម្រេច | ការធ្វើលទ្ធកម្ម ការធ្វើប្រតិបត្តិការ ការធ្វើទីផ្សារ ការបញ្ជូនសេវា |
| **រដ្ឋាភិបាលខ្លួនឯង** | ផ្លាស់ប្តូរព័ត៌មានពឹងផ្អែកទៅលើទិន្នន័យ ធនធាន និងគោលនយោបាយ | ទំនាក់ទំនងអនឡាញជាមួយនឹងអង្គការថ្នាក់ជាតិក្នុងស្រុក តំបន់ និងអន្តរជាតិ | ជំនួយការអន្តររដ្ឋាភិបាលចែករំលែកទិន្នន័យ និងព័ត៌មាន |
| **បុគ្គលិក** | ព័ត៌មានអំពីគោលនយោបាយទូទាត់ប្រាក់សំណងអត្ថប្រយោជន៍ការគ្រប់គ្រងការងារ និងការអភិវឌ្ឍជំនាញបុគ្គលិក | ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលចូលរួមដំណើរការបង្កើតសេចក្តីសម្រេច ទាក់ទងនឹងការងារ | ចែករំលែកទិន្នន័យ ព័ត៌មាន ការងារ ការសិក្សាពីចម្ងាយ (E-learning) ប្រព័ន្ធការិយាល័យតាមអេឡិចត្រូនិក (E-office)[29] |

[26] E-career (Electronic Career) ៖ការប្រកបរបរតាមអ៊ីនធឺណាត គឺជាអង្គការបណ្តុះបណ្តាលដែលមានការទទួលស្គាល់សម្រាប់បុគ្គល មហាវិទ្យាល័យ អាជីវកម្ម និងស្ថាប័នរដ្ឋាភិបាល។

[27] E-office (Electronic Office)៖ ត្រូវបានគេស្គាល់ផងដែរថា ការិយាល័យណាមួយដែលប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រដើម្បីដំណើរការ។

[28] Digital "Government-to-Business" service in Cambodia: Overview and Challenges by Maria Yang and Darapich Sovann publishes in January 28 2020

[29] តារាងទី១ ចរិកលក្ខណៈនៃបំណែងចែកការផ្តល់សេវារដ្ឋាភិបាលអេឡិចត្រូនិករកឃើញដោយ Fang (2002)

## ១.៣. ដំណាក់កាលនៃការអនុវត្តរបស់រដ្ឋាភិបាលឌីជីថលកម្ពុជា

ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ កម្ពុជាបានឆ្លងកាត់របបប្រល័យពូជសាសន៍ដែលបានសម្លាប់ប្រជាជនកម្ពុជាអស់ជាង៣លាននាក់ ដែលក្នុងនោះគឺសុទ្ធសឹងតែជាបញ្ញវន្តខ្មែរ មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ អ្នកជំនាញ អ្នកមានស្នាដៃ និងអ្នកដែលមានទេពកោសល្យ ដែលសុទ្ធតែជាធនធានស្នូលនៃការអភិវឌ្ឍប្រទេស ហើយបានបំផ្លិចបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធប្រទេស និងបន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រា និងអ្នកបាត់បង់កាយសម្បទា ដែលកង្វះខាតនូវស្បៀងអាហារ ព្រមទាំងកម្លាំងផលិតកម្ម។ តែដោយសារតែជ័យជំនះ ថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជាតិទាំងមូលដូចត្រូវបានស្រោចស្រង់ឡើងវិញទាំងមូលឱ្យរួចផុតពីរបបដ៏កាចសាហាវនេះហើយ ប្រជាជនគ្រប់រូបក៏ទទួលបានសិទ្ធិសេរីភាពក្នុងការរស់នៅឡើងវិញសារជាថ្មីដែរ។

ក្នុងឆ្នាំ១៩៩៣ បន្ទាប់ពីកម្ពុជាត្រូវបានរៀបចំនូវការបោះឆ្នោតជាសកលនៅក្នុងខែឧសភា ឆ្នាំ១៩៩៣ មក គឺប្រទេសកម្ពុជាក៏បានកែទម្រង់ប្រព័ន្ធនយោបាយ និងរៀបចំដឹកនាំប្រព័ន្ធរដ្ឋបាលនៅទូទាំងប្រទេស ថែមទាំងដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រថ្មីសម្រាប់ស្តារ និងអភិវឌ្ឍន៍ប្រទេសតាមប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ពោលគឺពីសេដ្ឋកិច្ចបែបផែនការទៅជា សេដ្ឋកិច្ចបែបទីផ្សារសេរី និងឈានចូលដល់ដំណាក់កាលថ្មីនៃការរក្សាសន្តិភាព និងការបង្រួបបង្រួមជាតិ ព្រមទាំងបានទទួលយករដ្ឋធម្មនុញ្ញថ្មីតាមរបបប្រជាធិបតេយ្យសេរីពហុបក្ស។ តែទោះបីជាមានការកត់សម្គាល់នៃការផ្លាស់ប្តូរដ៏អស្ចារ្យនេះក៏ដោយ ប្រទេសកម្ពុជាក៏នៅតែជួបប្រទះនូវឧបសគ្គនៃការគ្រប់គ្រងរដ្ឋបាលឱ្យមានប្រសិទ្ធភាព ដែលរួមមានអំពើពុករលួយ ខ្វះខាតការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងកង្វះខាតផ្នែកតម្លាភាព ព្រមទាំងគណនេយ្យភាពនៅក្នុងដំណើរការបង្កើតសេចក្តីសម្រេចជាសាធារណៈ និងការនាំមកនូវសេវាកម្មសាធារណៈជន។ បន្ទាប់ពីថ្ងៃទី៣០ មេសា ១៩៩៩ ដែលជាថ្ងៃដែលប្រទេសកម្ពុជាបានចូលជាសមាជិកនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) រួមមក កម្ពុជាក៏នៅតែបន្តជួបប្រទះនូវការបាត់បង់ចំណូលពីគម្រោងការនៃ ការអនុវត្តពន្ធអនុគ្រោះចំណូលទូទៅមានប្រសិទ្ធិភាព (CEPT)[30] ដែលតម្រូវឱ្យកម្ពុជាកាត់បន្ថយពន្ធនាំចូលត្រឹមតែ 0,៥% នៅឆ្នាំ២០១០។ ការកាត់បន្ថយពន្ធគយនាំចូលពិតជាបានប៉ះពាល់ដល់ថវិកាជាតិ ដោយសារតែថវិកាចំនួន ១៦.៣១% នៃថវិកាជាតិគឺពឹងផ្អែកទាំងស្រុងទៅលើពន្ធនាំចូលបញ្ហាទាំងអស់នេះហើយ ដែលនាំឱ្យមានការចោទសួរជាសំណួរជាច្រើនទៅកាន់រាជរដ្ឋាភិបាលដើម្បីឱ្យមានការផ្លាស់ប្តូរនៃការអនុវត្តការងារទម្រង់ថ្មី។ សំណើរដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយផ្សេងទៀត គឺជាការចាប់ផ្តើមនៃការប្រើប្រាស់បច្ចេកវិទ្យាមកអនុវត្តន៍ក្នុងការប្រព័ន្ធរដ្ឋបាលកម្ពុជា គឺរដ្ឋាភិបាលឌីជីថល ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃកម្មវត្ថុដែលមានទម្រង់ផ្សេងៗ ហើយមានប្រយោជន៍ដូចជាកាត់បន្ថយអំពើពុករលួយ លើកកម្ពស់តម្លាភាព ភាពងាយស្រួលក្នុងការអនុវត្តការងាររដ្ឋបាល ការកើនឡើងនៃប្រាក់ចំណូល និងកាត់បន្ថយការប្រើប្រាស់ថវិកា។ បន្ទាប់មកមានការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ហៅកាត់ថា NiDA[31] នៅក្នុងខែសីហា ឆ្នាំ២000 គឺកម្ពុជាបានចាប់ផ្តើមអនុវត្តន៍ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា។ ដោយបានដឹងអំពីសក្តានុពលនៃបណ្តាញ (network) ថ្មីរបស់

[30] CEPT = Common Effective Preferential Treatment

[31] NiDA = National Information Communications Technology Development Authority គឺជាអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។

រដ្ឋាភិបាល គឺជាហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាថ្នាក់ជាតិ (NII)[32] នេះ NiDA បានចាប់ផ្ដើមសិក្សាអំពីផែនការពង្រីកសេវាកម្មរដ្ឋាភិបាលឌីជីថល ដើម្បីទាញយកប្រយោជន៍ពីវាក្នុងកំរិតអតិប្បរមាតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ម្យ៉ាងវិញទៀតក្នុងគោលបំណង ដើម្បីកំណត់នូវតម្រូវការ Application របស់រដ្ឋាភិបាលឌីជីថល ដែលនឹងរួមចំណែកក្នុងការបង្កើតនូវសមត្ថភាពបំពេញការងារក្នុងស្ថាប័ន ការធ្វើឱ្យប្រសើរនូវសេវាកម្មសាធារណៈ ការប្រមូលទិន្នន័យសម្រាប់ការរៀបចំគោលនយោបាយនានា និងជាចុងក្រោយរួមចំណែកក្នុងការបង្កើតនូវផែនទីបង្ហាញផ្លូវដែលអាចកំណត់ទិសដៅបានត្រឹមត្រូវមួយសម្រាប់ការពង្រីកសេវាកម្មរដ្ឋាភិបាលឌីជីថល និងប្រកបដោយប្រសិទ្ធភាព។

នៅឆ្នាំ ២០០១ ដើម្បីសម្រេចបាននូវទិសដៅជាគោលការណ៍ខាងលើ **NiDA** បានអនុវត្តន៍នូវគម្រោងប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា**GAIS**[33] ដែលរួមមានការនាំចូលកុំព្យូទ័រប្រហែល១០០០គ្រឿងសម្រាប់ការិយាល័យរដ្ឋាភិបាល។ នៅឆ្នាំ២០០២ អាជ្ញាធរបានអនុវត្តន៍នូវគម្រោង **GAIS** ដែលជាកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលកម្ពុជានិងអ្នកជំនាញ និងជំនួយការជនជាតិកូរ៉េខាងត្បូង។ បន្ទាប់មក **NiDA** បានចាប់ផ្ដើមដំណើរការប្រព័ន្ធ **GAIS** និង ប្រព័ន្ធរដ្ឋបាលព័ត៌មានថ្នាក់ខេត្ត **PAIS**[34] ដែលជាគម្រោងបន្ថែមថ្មីមួយទៀតរបស់គម្រោង **GAIS** ដែលបានអនុវត្តន៍មុន ហើយក៏ជាគម្រោងដែលស្ថិតក្នុងដំណាក់កាលអភិវឌ្ឍនៃការពង្រីកសេវាបន្តទៀតដែលរួមបញ្ចូលទាំង **NII** និងបណ្ដាញ (Broadband network) នៃសេវាកម្មរបស់ស្ថាប័នរដ្ឋាភិបាលនានា ដើម្បីឱ្យប្រាកដថាផែនការនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបបច្ចេកវិទ្យានេះត្រូវបានអនុវត្តន៍ដោយស្របទៅតាមកិច្ចអភិវឌ្ឍន៍នៃហេដ្ឋារចនាសម្ព័ន្ធបណ្ដាញនៅក្នុងរដ្ឋាភិបាលទាំងមូល។ សេវាកម្មសាធារណៈតាមរយៈអ៊ីនធឺណេត ដែលដំណើរការក្រោមប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា អាចជួយឱ្យប្រជាជនកម្ពុជាទទួលបានភាពងាយស្រួលក្នុងការស្នើសុំការធ្វើលិខិតស្នាមរដ្ឋបាលតាមប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យា។

ដោយប្រព័ន្ធរដ្ឋបាលព័ត៌មានវិទ្យានេះមាន Application សម្រាប់រដ្ឋាភិបាលឌីជីថល ទំនាក់ទំនងទៅនឹងការអនុវត្តទៅលើទម្រង់បួនប្រភេទសំខាន់ៗដូចជា៖

- **ប្រព័ន្ធសច្ចានុម័តអេឡិចត្រូនិក EAS**[35] ៖ មានគោលបំណងអនុញ្ញាតឱ្យក្រសួងទាំងអស់ផ្លាស់ប្ដូរឯកសារគ្នាទាំងក្នុង និងក្រៅស្ថាប័ន ដោយរួមបញ្ចូលមុខងារការសរសេរដោយដៃ អនុញ្ញាតឱ្យមានការប្រើប្រាស់ប្រព័ន្ធមានភាពងាយស្រួល។ ទម្រង់នេះបានកាត់បន្ថយការពន្យាពេលមិនចាំបាច់មួយចំនួន និងលទ្ធផលកាន់តែប្រសើរឡើងក្នុងសេវាសាធារណៈ។
- **ប្រព័ន្ធចុះបញ្ជីយានយន្ត៖** សម្រាប់យានយន្ត និងទោចក្រយានយន្ត និងអនុវត្តន៍ទៅលើ ការចុះបញ្ជីយានយន្ត ការផ្ដល់អាជ្ញាបណ្ណ ការស្នើសុំបណ្ណបើកបរ និងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ការផ្លាស់ប្ដូររចនាសម្ព័ន្ធ ការផ្លាស់ប្ដូរម្ចាស់កម្មសិទ្ធិ ការត្រួតពិនិត្យ ការធ្វើប័ណ្ណសម្គាល់ (លេខអត្តសញ្ញាណកម្ម) ការធ្វើផ្លាកលេខ ការបង់ពន្ធប្រចាំត្រា វិញ្ញាបនបត្រយានយន្ត ស្ថិតិ និងការគ្រប់គ្រងកម្មសិទ្ធិយានយន្ត ឬទោចក្រយានយន្ត ។

[32] NII = គឺជាហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាថ្នាក់ជាតិ

[33] GAIS = Government Administration Information System

[34] PAIS = Provincial Administration Information System

[35] EAS = Electronic Approval System

- **ប្រព័ន្ធចុះបញ្ជីស្នាក់នៅ៖** សម្រាប់អនុវត្តន៍ទៅលើការគ្រប់គ្រងទិន្នន័យ នៃការចុះសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណៈភាព ការផ្លាស់ប្តូរទីលំនៅ ការគ្រប់គ្រងសៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារក៏ដូចជាព័ត៌មានសម្រាប់ការផ្តល់ឱ្យអត្តសញ្ញាណកម្ម ការចុះឈ្មោះបោះឆ្នោត ព្រមទាំងការស្នាក់នៅរបស់ជនបរទេស។
- **ប្រព័ន្ធចុះបញ្ជីអចលនទ្រព្យ៖** សម្រាប់គ្រប់គ្រងទៅលើអចលនទ្រព្យ ដូចជាការចុះបញ្ជី ឬការលុបចេញពីបញ្ជី ការបំបែក ការរួមបញ្ចូលទ្រព្យ ការគ្រប់គ្រងកម្មសិទ្ធិអចលនទ្រព្យ ការផ្លាស់ប្តូរកម្មសិទ្ធិ ដីរួម ពន្ធអចលនទ្រព្យ វិញ្ញាបនបត្រអចលនទ្រព្យ ព្រមទាំងស្ថិតិជាដើម។

ក្នុងចន្លោះឆ្នាំ ២០០២ ដល់ ២០១៣ ដែលមានអាជ្ញាធរទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា NiDA ជាភ្នាក់ងារអនុវត្តន៍។ ក្នុងគោលដៅជំរុញការបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យកាន់តែមានល្បឿនលឿនប្រកបដោយគុណភាពដោយក្រសួង-ស្ថាប័នពាក់ព័ន្ធនានាបានចូលរួមបង្កើតសេវាសាធារណៈឌីជីថលជាបន្តបន្ទាប់ ជាមួយនឹងភាពជាម្ចាស់លើប្រព័ន្ធរបស់ខ្លួន ដែលក្នុងនោះរួមមានដូចជា ការបង្កើតប្រព័ន្ធ E-visa សម្រាប់ការស្នើសុំទិដ្ឋាការតាមប្រព័ន្ធអនឡាញ ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA)[36] របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ប្រព័ន្ធចុះបញ្ជីពន្ធដារ ប្រព័ន្ធចុះបញ្ជីអាជីវកម្ម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)[37] ប្រព័ន្ធចុះបញ្ជីដីធ្លី (LMAP)[38] ប្រព័ន្ធចុះបញ្ជីក្នុងក្របខណ្ឌសន្តិសុខសង្គម (បេឡាជាតិសន្តិសុខសង្គម បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ ស៊ីវិល និងបេឡាជាតិអតីតយុទ្ធជន) ប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រព័ន្ធរបស់ក្រសួងមហាផ្ទៃ (ប្រព័ន្ធគ្រប់គ្រងទិន្នន័យអត្តសញ្ញាណកម្ម ប្រព័ន្ធរៀបចំលិខិតឆ្លងដែន និងប្រព័ន្ធគ្រប់គ្រងសេវានៅច្រកចេញ-ចូលតែមួយ) និងប្រព័ន្ធស្នើសុំអាជ្ញាបណ្ណវិស័យទេសចរណ៍របស់ក្រសួងទេសចរណ៍ជាដើម។ ភាពជាម្ចាស់នៃប្រព័ន្ធទាំងនេះរបស់ក្រសួង-ស្ថាប័នដែលបានជួយដល់ការលើកស្ទួយការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលឱ្យបានលឿន ព្រមទាំង ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

អាជ្ញាធរដែលអនុវត្តន៍ និងដឹកនាំប្រព័ន្ធ **GAIS** និង**PAIS** មានភារៈកិច្ចសម្របសម្រួល និងក្រសួង-ស្ថាប័នពាក់ព័ន្ធមានភារៈកិច្ចសហការរៀបចំផែនការសកម្មភាពលម្អិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលមានប្រភពធនធានពេលវេលា (សម្រាប់រយៈពេលខ្លី មធ្យម និងវែង) ដែលឈរលើមូលដ្ឋាននៃការរៀបចំ និងការអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗគ្នា។

ចំពោះ Application គឺសុទ្ធតែមានប្រភេទបញ្ជីទៅតាមបណ្តាក្រសួង ស្ថាប័ននីមួយៗខុសៗគ្នាសម្រាប់ប្រើប្រាស់លើប្រព័ន្ធបច្ចេកទេសដូចតទៅ៖

- បញ្ជី Application ដែលមានស្រាប់ត្រូវបានណែនាំសម្រាប់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យាថ្នាក់ជាតិ

[36] ASYCUDA = Automated System for Customs Data Cambodia

[37] FMIS = Financial Management Information System

[38] LMAP = Land Management and Administration Project

| ក្រសួង | នាយកដ្ឋាន/ទីភ្នាក់ងារ | ប្រព័ន្ធព័ត៌មាន |
|---|---|---|
| ទីស្ដីការគណៈរដ្ឋមន្ត្រី | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងបុគ្គលិក (HRMIS) |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អគ្គនាយកដ្ឋានពន្ធដារ | ប្រព័ន្ធពន្ធតាមរបបពិត (real-regime) |
| | អគ្គនាយកដ្ឋានគយ | ប្រព័ន្ធស្វ័យប្រវត្តសម្រាប់គ្រប់គ្រងទិន្នន័យគយ (ASYCUDA) |
| | អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) |
| ក្រសួងអប់រំយុវជន និងកីឡា | អគ្គនាយកដ្ឋានផែនការ | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការអប់រំ (EMIS) |
| | អគ្គនាយកដ្ឋានផែនការ | ប្រព័ន្ធគ្រប់គ្រងស្ថិតិ និងសូចនាករអប់រំសាធារណៈ(HRMIS) |
| | អគ្គនាយកដ្ឋានហិរញ្ញវត្ថុ | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ និងកម្មវិធី |
| | មិនមាន | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ (NFEMIS) |
| ក្រសួងសុខាភិបាល | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) | CamEwarn Database |
| | អគ្គនាយកដ្ឋានផែនការ | ប្រព័ន្ធព័ត៌មានវិទ្យាផ្នែកសុខាភិបាល (HIS) |
| ក្រសួងមហាផ្ទៃ | មិនមាន | លិខិតឆ្លងដែនអេឡិចត្រូនិក (e-Passport) |
| ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | មូលនិធិជាតិសម្រាប់សន្តិសុខសង្គម | ប្រព័ន្ធព័ត៌មានវិទ្យាផ្នែកការងារនៃមូលនិធិជាតិសម្រាប់សន្តិសុខសង្គម |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | មិនមាន | Database ផ្ទុកបញ្ជីដីធ្លី (LMAP) |
| ក្រសួងផែនការ | វិទ្យាស្ថានស្ថិតិជាតិ | ការផ្សព្វផ្សាយស្ថិតិ និងសេវាកម្មព័ត៌មានភូមិសាស្ត្រ(GIS) |
| ក្រសួងទេសចរណ៍ | អគ្គនាយកដ្ឋានព័ត៌មានវិទ្យា | ផ្ទុកស្ថិតិផ្នែកទេសចរណ៍ក្នុងបណ្ដុំទិន្នន័យដែលរក្សាទុកក្នុងប្រព័ន្ធកុំព្យូទ័រ[39] |

- ❖ បញ្ជី Application ថ្មីៗដែលត្រូវការសម្រាប់បម្រើសេវា E-Government ទាក់ទងនឹង៖
  - ➢ ការផ្ដល់ប្រាប់ឧបត្ថម្ភសម្រាប់ទ្រទ្រង់សន្តិសុខសង្គម (មូលនិធិជាតិសម្រាប់សន្តិសុខសង្គម ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ព្រមទាំងក្រសួងសុខាភិបាល)

[39] Project for Capacity Building on ICT Management for NiDA ទំព័រទី x

- ➢ ពាក្យបណ្ដឹងសម្រាប់បញ្ជូនទៅកាន់ស្ថានីយ៍ប៉ូលីស ( ក្រសួងមហាផ្ទៃ )
- ➢ សេវាកម្មនានាទាក់ទាងនឹងសុខភាព (ក្រសួងសុខាភិបាល ឬមន្ទីរពេទ្យ)
- ➢ លិខិតអនុញ្ញាត្តនានាទាក់ទងនឹងបរិស្ថាន (ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ)។

❖ បញ្ជី Application ថ្មីៗដែលស្នើរឡើងដោយក្រសួងនានាៈ

| ក្រសួង | រដ្ឋការស៊ីវិល/តម្រូវការផ្នែក Application | ផ្នែក/នាយកដ្ឋាន |
|---|---|---|
| ក្រសួងព័ត៌មាន | ការផ្ដល់អាជ្ញាប័ណ្ណដល់ប្រព័ន្ធផ្សព្វផ្សាយ | មជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មាន |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | Application សម្រាប់ផ្ដល់សិទ្ធិអ្នកនិពន្ធ | នាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ការចេញឱ្យប្រើប្រាស់ប័ណ្ណអនុញ្ញាតផ្ដល់ការងារ លិខិតអនុញ្ញាតការងារសម្រាប់ជនបរទេស | មិនមាន |
| | ការប្រកាសបង្កើតក្រុមហ៊ុនថ្មី | មិនមាន |
| ក្រសួងអប់រំយុវជន និងកីឡា | ប្រព័ន្ធគ្រប់គ្រងកម្មសិក្សាតាមរយៈប្រព័ន្ធអនឡាញ (Online) | សាស្ត្រាចារ្យតាមសាលានានា |
| | Application សម្រាប់សិក្សាពីចម្ងាយ និងជាសាធារណៈ (Open and Distance Learning Application) | សិស្ស/សាស្ត្រាចារ្យតាមសាលានានា |
| | ប្រព័ន្ធតាមដាន ESP | មិនមាន |
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ការចុះបញ្ជីប្រកាសនីយប័ត្រ | មិនមាន |
| ក្រសួងទេសចរណ៍ | ការគ្រប់គ្រងព័ត៌មានផ្នែកទេសចរណ៍ | ការិយាល័យផ្ដល់ព័ត៌មាន និងស្ថិតិ |
| ក្រសួងផែនការ | ឃ្លាំងផ្ទុកទិន្នន័យស្ថិតិ | ផ្ទៃក្នុង |
| | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអំពីឃុំ/សង្កាត់ | ផ្ទៃក្នុង |
| ក្រសួងបរិស្ថាន | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងបរិស្ថាន ការតាមដាន និងការវាយតម្លៃ | ការិល័យគ្រប់គ្រងទិន្នន័យបរិស្ថាន |
| ក្រសួងកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ការគ្រប់គ្រងឯកសារ និងទិដ្ឋាការ | ស្ថានកុងស៊ុលនៅតាមប្រទេសនានា |
| ក្រសួងការពារជាតិ | ការគ្រប់គ្រងឯកសារផ្លូវការ | ផ្ទៃក្នុង |
| ក្រសួងយុត្តិធម៌ | ការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងច្បាប់ | សាធារណៈ[40] |

[40] Project for Capacity Building on ICT Management for NiDA ទំព័រ xi

### ១.៣.១. ក្របខណ្ឌគោលនយោបាយនៃរដ្ឋាភិបាលឌីជីថលកម្ពុជា

ជាយូរមកហើយ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានសម្លឹងឃើញការផ្ដល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលថាជាចក្ខុវិស័យស្នូលមួយក្នុងចំណោមចក្ខុវិស័យស្នូលដទៃទៀត នៃចតុកោណទី២ មុំទី៣ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងនីតិកាលទី៦ នៃរដ្ឋសភាដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញដែលបានតម្រង់ទិសការអភិវឌ្ឍប្រទេសតាមរយៈការពន្លឿនការផ្ដល់សេវាសាធារណៈ និងពង្រឹងភាពប្រកួតប្រជែង។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ការបន្តធ្វើកំណែទម្រង់រដ្ឋបាលនៅក្នុងវិស័យសេវាសាធារណៈ គឺត្រូវការចាំបាច់ខណៈដែលវិមជ្ឈការ និងវិសហមជ្ឈការ ដែលអាចនាំសេវាសាធារណៈខិតទៅជិតនឹងប្រជាជន និងកាត់បន្ថយចំណាយធ្វើដំនួញ រដ្ឋាភិបាលឌីជីថល អាចជួយបង្កើនល្បឿនដំណើរការឯកសារ និងធានាពីតម្លាភាពនៃកិច្ចការដំណើការឯកសារ។ យុទ្ធសាស្ត្រនេះបានចង្អុលបង្ហាញយ៉ាងច្បាស់អំពីភាពចាំបាច់ក្នុងការត្រៀមខ្លួនដើម្បីចាប់យកការគ្រប់គ្រងរដ្ឋបាលឌីជីថល និងសេដ្ឋកិច្ចឌីជីថលដើម្បីឆ្លើយតបទៅនឹង**បដិវត្តន៍ឧស្សាហកម្ម៤.0 (Industry4.0)** ដែលសំដៅទៅលើការទាញយកផលប្រយោជន៍ពីភាពរីកចម្រើននៃបច្ចេកវិទ្យា។ សមត្ថផលដែលផ្ដល់ដោយបច្ចេកវិទ្យាឌីជីថលមិនបានកំណត់ត្រឹមតែវិស័យណាមួយ ឬធុរកិច្ចដែលពឹងផ្អែកទៅលើបច្ចេកវិទ្យាប៉ុណ្ណោះទេប៉ុន្តែថែមទាំងផ្ដល់នូវតម្លៃ និងប្រយោជន៍បន្ថែមទៅលើគ្រប់វិស័យទាំងសេដ្ឋកិច្ច និងសង្គម។ ក្នុងបរិបទនេះឌីជីថលូបនីយកម្មបានក្លាយជានិន្នាការដ៏មានឥទ្ធិពលដែលជា កម្លាំងចលករជំរុញកំណើនសេដ្ឋកិច្ចតំបន់ និងសង្គមជាតិទាំងមូល និងជាមគ្គុទេសក៏ក្នុងការអភិវឌ្ឍគ្រប់វិស័យ។[41]

ក្របខណ្ឌគោលនយោបាយនៃសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាបានកំណត់នូវចក្ខុវិស័យដែលកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គមផ្អែកលើប្រក្រតីភាពតាមគន្លងថ្មី។ ចក្ខុវិស័យនេះត្រូវសម្រេចបានក្នុងរយៈពេល១៥ឆ្នាំ ចាប់ផ្ដើមពី ឆ្នាំ២០២១ ដល់ ឆ្នាំ២០៣៥ ហើយអនុលោមតាមគោលការណ៍ចំនួនបី គឺការកសាងមូលដ្ឋានគ្រឹះឌីជីថល ការចាប់យកឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល ដែលក្នុងនោះរាល់វិធានការគោលនយោបាយត្រូវអនុវត្តន៍ដំណាលគ្នាប៉ុន្តែផ្ដល់អាទិភាពទៅលើវិធានការដែលឆ្លើយតបទៅនឹងគោលការណ៍នីមួយៗ។ មានន័យថា បរិវត្តកម្មឌីជីថលគឺជាគោលដៅចុងក្រោយដែលសំដៅសម្រេចបាននូវការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល ដែលពឹងផ្អែកទៅលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលយ៉ាងទូលំទូលាយក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ច និងគ្រប់សកម្មភាពសេដ្ឋកិច្ចដែលផ្សារភ្ជាប់មានអន្តរទំនាក់ទំនងជាមួយគ្នា និងបំពេញបន្ថែមគ្នា។[42]

### ១.៣.២. វិធានការគោលនយោបាយគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល

បន្ថែមពីលើគ្រឹះ និងសរសរស្តម្ភនៃការកសាងមូលដ្ឋាននៃសេដ្ឋកិច្ច និងសង្គមឌីជីថល ការដាក់ចេញនូវក្របខណ្ឌអាទិភាពនៃបរិវត្តកម្មឌីជីថលសម្រាប់ការសាងសេដ្ឋកិច្ច និងសង្គមឌីជីថល តាមចក្ខុវិស័យ និងគោលបំណងខាងលើ ក្របខណ្ឌគោលនយោបាយនេះកំណត់យកវិធានការគោលនយោបាយ ដែលជាគោលដៅអាទិភាពចម្បង៥ ដែលរួមមាន៖

[41] គេហទំព័រ https://www.kas.de/en/web/kambodscha/single-title/-/content/e-government-what-can-cambodia-learn-from-e-estonia ដកស្រង់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

[42] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១_២០៣៥ ទំព័រ២២

**១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលមូលដ្ឋាន៖** គឺផ្តោតទៅលើការពង្រីកបណ្តាញអ៊ីនធឺណេតល្បឿនលឿន ការរៀបចំប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល និងការរៀបចំប្រព័ន្ធឡូជីស្ទិក និងការដឹកជញ្ជូនគោលដៅចុងក្រោយ សម្រាប់ទ្រទ្រង់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ ក្នុងគោលដៅកសាងវិស័យឌីជីថលឱ្យក្លាយទៅជាចន្ទល់សេដ្ឋកិច្ចសម្រាប់កម្ពុជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលមូលដ្ឋាន គឺជាកិច្ចការចាំបាច់ដែលត្រូវគិតគូរ និងអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់គ្រប់ជ្រុងជ្រោយ។ ក្នុងបរិការណ៍នេះរាជរដ្ឋាភិបាលនឹងដើរតួនាទីសំខាន់ក្នុងការផ្តួចផ្តើមកម្មវិធី ឬគម្រោងវិនិយោគការតាមដាន និងការវាយតម្លៃអំពីប្រសិទ្ធភាពចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល។ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលចាំបាច់មិនកម្រិតត្រឹមបណ្តាញបញ្ជូនអ៊ីនធឺណេតល្បឿនលឿនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមបញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការទូទាត់សងប្រាក់ឌីជីថល និងប្រព័ន្ធឡូជីស្ទីក និងការដឹកជញ្ជូនគោលដៅចុងក្រោយផងដែរ។

**ក. វិធានការគោលនយោបាយផ្នែកការតភ្ជាប់ឌីជីថល**

ការអភិវឌ្ឍ និងការលើកកម្ពស់ការតភ្ជាប់ឌីជីថល គឺជាកត្តាដ៏សំខាន់ក្នុងការជំរុញការចាប់យកបច្ចេកវិទ្យាដែលក្នុងនោះរួមមាន ការកសាងហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណេតល្បឿនលឿន ការកសាងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យប្រកបដោយសមត្ថភាព សម្រាប់ត្រៀមខ្លួនឆ្លើយតបទៅនឹងការវិវឌ្ឍឥតឈប់ឈរនៃបច្ចេកវិទ្យា និងការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងទន់ ដែលគាំទ្រដល់ការរស់នៅបែបឆ្លាតរបស់ប្រជាពលរដ្ឋ។ ទិសដៅទាំងនេះអាចសម្រេចបានតាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការគន្លឹះដូចខាងក្រោម៖

- ជំរុញការអភិវឌ្ឍបណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណេតល្បឿនលឿនមានតម្លៃសមរម្យ និងមានគុណភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងដោយគ្របដណ្តប់ឱ្យបាន ៩៥% នៃចំនួនប្រជាពលរដ្ឋសរុប ក្នុងក្របខណ្ឌបណ្តាញឆ្អឹងខ្នងអ៊ីនធឺណេត (Internet Backbone) បណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រ ( Submarine Cables ) និងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណេតល្បឿនលឿនចល័ត និងអចល័ត ( Fixed and Mobile Broadband Communications )
- ធ្វើវិសោធនកម្ម ឬកែសម្រួលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការលើកកម្ពស់តួនាទីរបស់និយ័តករក្នុងការលើកស្ទួយការប្រកួតប្រជែង និងការផ្តល់ភាពបើកចំហរ
- កសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ[43]
- ជំរុញការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម ( Infrastructure sharing )
- អភិវឌ្ឍមូលដ្ឋានទិន្នន័យហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ (National Infrastructure Database) សម្រាប់ការគ្រប់គ្រង ការតាមដាន និងវាយតម្លៃ
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទិន្នន័យជាតិ និងបច្ចេកវិទ្យាក្លោដ ( National Data Center and Cloud Technology )
- រៀបចំគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធផ្នែកទិន្នន័យ

---

[43] វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ គឺសំដៅលើធនធានរបស់រដ្ឋដែលពុំត្រូវធ្វើជាកម្មវត្ថុនៃការលក់ទិញ ប៉ុន្តែអាចធ្វើជាកម្មវត្ថុនៃការជួល ឬការផ្តល់សិទ្ធិប្រើប្រាស់តាមរយៈការផ្តល់អាជ្ញាបណ្ណ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀត។

( Data and Cloud Computing Facility) ក្នុងគោលដៅលើកកម្ពស់ការបង្កើតមជ្ឈមណ្ឌលទិន្នន័យ ( Data Center ) នៅក្នុងស្រុកឱ្យបានច្រើន

- ជំរុញ និងលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការថ្នាលសុស្វវែរ ( Software ) និងសុស្វវែរចាំបាច់នានា ដែលមានអាជ្ញាបណ្ណ
- រៀបចំកម្មវិធី និងគម្រោងវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល
- បង្កើតក្របខណ្ឌតាមដាន និងវាយតម្លៃអំពីប្រសិទ្ធភាពចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល
- ជំរុញយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា ដើម្បីបំពេញគម្លាតនៃតម្រូវការវិនិយោគរបស់វិស័យឯកជន។

**ខ. វិធានការគោលនយោបាយផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល**

ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលត្រូវធានាបាននូវវិសាលភាពគ្របដណ្តប់ទាំងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ លក្ខណៈអន្តរប្រតិបត្តិការ (Interoperability) ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ដែលមានវិសាលភាពផ្តល់នូវប្រយោជន៍ និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុបែបជឿនលឿនតាមរបៀបឌីជីថល។ ក្នុងន័យនេះទិសដៅអាទិភាពនេះត្រូវសម្រេចបាន តាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការដាក់លាក់ដូចខាងក្រោម៖

- រៀបចំ និងដាក់ចេញនូវក្របខណ្ឌអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់ឌីជីថលដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- កសាងផែនការមេសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ ចូល ប្រព័ន្ធទូទាត់សងប្រាក់ថ្នាក់ជាតិ ( National Payment Gateway ) ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអន្តរប្រតិបត្តិការដែលមានវិសាលភាពទូលំទូលាយគ្របដណ្តប់លើការទូទាត់សងប្រាក់ឌីជីថល នៅក្នុងគ្រប់វិស័យ និងគ្រប់ទិដ្ឋភាព
- អភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលប្រកបដោយបរិយាបន្នកម្ម ដោយធានាបាននូវភាពដែលអាចរកបាន ( Availability ), ថ្លៃសមរម្យ ( Affordability ), ភាពងាយស្រួល ( Convenience ) និងគុណភាព ( Quality ) ក៏ដូចជាធានាបាននូវដំណើរការ និងប្រសិទ្ធភាពនៃអន្តរប្រតិបត្តិការនៃផលិតផល សេវាថ្នាល និងបណ្តាញទាក់ទងឌីជីថលនៅក្នុងវិស័យហិរញ្ញវត្ថុ
- បង្កើនការទូទាត់នៅក្នុងវិស័យសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់បម្រើឱ្យប្រតិបត្តិការទូទៅរបស់គ្រឹះស្ថានសាធារណៈ ក៏ដូចជាសម្រួលដល់ការផ្តល់សេវាសាធារណៈ
- រៀបចំបង្កើតក្របខណ្ឌច្បាប់ និងគោលការណ៍ណែនាំពាក់ព័ន្ធ ដើម្បីលើកកម្ពស់ទំនុកចិត្ត ភាពជឿជាក់ និងជំរុញការប្រើប្រាស់សេវាទូទាត់សងប្រាក់ឌីជីថលដែលមានសុវត្ថិភាព និងមានកិច្ចធានា
- រៀបចំ និងដាក់ចេញនូវក្របខណ្ឌជំរុញ លើកទឹកចិត្ត និងទាក់ទាញវិនិយោគ និងការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ជាពិសេសច្រកចេញ ចូលទូទាត់សង

ប្រាក់ឌីជីថល និងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលតាមរយៈបច្ចេកវិទ្យាហិរញ្ញវត្ថុដែលសំដៅលើការជំរុញ និងអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុឌីជីថល

- ធ្វើវិសោធនកម្ម ឬកែសម្រួលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួននៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយកាត់បន្ថយនូវភាពមិនច្បាស់លាស់ ភាពចន្លោះប្រហោង ភាពខ្វះខាតរបស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលអាចរារាំងស្ទះដល់នវានុវត្តន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងទីផ្សារ
- រៀបចំយុទ្ធសាស្ត្រជាផែនទីចង្អុលផ្លូវសម្រាប់ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ
- រៀបចំផែនការមេកសាងសមត្ថភាព និងជំនាញផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ
- បង្កើតយន្តការស្ថាប័នដែលអំណោយផលដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងទីផ្សារតាមរយៈ៖

  (១). ការបង្កើតឱ្យមានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ សម្រាប់និយ័តករនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

  (២). ការបង្កើតឱ្យមានយន្តការសម្របសម្រួល និងកិច្ចសហការផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុរវាងនិយ័តករនៅក្នុងវិស័យធនាគារ និងនិយ័តករនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

  (៣). ការបង្កើតឱ្យមានបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ( Regulatory Sandboxes ) បើមានភាពចាំបាច់នៅក្នុងទីផ្សារ។
- លើកកម្ពស់ចំណេះដឹងរបស់សាធារណជន និងសហគ្រិនប្រកបដោយបរិយាបន្នកម្មអំពីការប្រើប្រាស់ឧបករណ៍ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកជំនួសឱ្យសាច់ប្រាក់ ដែលសំដៅផ្លាស់ប្តូរឥរិយាបថទំនុកចិត្ត និងភាពជឿជាក់ លើមធ្យោបាយទូទាត់សងប្រាក់ឌីជីថល
- ពង្រីកវិសាលភាពនៃការទូទាត់ និងការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានលក្ខណៈសាមញ្ញ និងងាយស្រួល ដើម្បីត្រៀមលក្ខណៈក្នុងការរួមចំណែកធ្វើសមាហរណកម្មសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់។

**គ. វិធានការគោលនយោបាយផ្នែកឡូហ្ស៊ីស្ទិក និងការដឹកជញ្ជូនគោលដៅចុងក្រោយ**

ដើម្បីធ្វើការកែលម្អ ពង្រឹងប្រព័ន្ធឡូហ្ស៊ីស្ទិក និងការដឹកជញ្ជូនគោលដៅចុងក្រោយ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងវិសាលភាពធំ គឺជាការងារអាទិភាពមួយសម្រាប់បំពេញគម្លាតនៃប្រព័ន្ធអេកូឡូស៊ីនៃបរិការណ៍សេដ្ឋកិច្ចថ្មី ដែលនឹងសម្រេចបានតាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការជាក់លាក់ដូចខាងក្រោម៖

- កសាងផែនការមេសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ ដែលរួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធ ICT ដោយផ្តោតលើគុណភាព ប្រសិទ្ធភាព ការតភ្ជាប់ខាងក្នុងចរិភាព និងបរិយាបន្នកម្ម
- បង្កើតមជ្ឈមណ្ឌលឡូហ្ស៊ីស្ទិកជាតិតាមរយៈការបង្កើតគំរូអាជីវកម្មដែលឆ្លងកាត់ប្រព័ន្ធតែមួយ និងឃ្លាំងស្តុកទំនិញនៅតាមតំបន់សំខាន់ៗបង្កើតមជ្ឈមណ្ឌលភស្តុភារកម្មប្រៃសណីយ៍ជាតិដែលឆ្លងកាត់ប្រព័ន្ធតែមួយ និងឃ្លាំងស្តុកបញ្ញើប្រៃសណីយ៍នៅតាមតំបន់សំខាន់ៗ
- បង្កើតមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានឡូហ្ស៊ីស្ទិកជាតិ ( National Logistics Information System Center ) ដើម្បីបង្កើនប្រសិទ្ធភាពសេវាឡូហ្ស៊ីស្ទិកក្នុងប្រទេស និងអាចតភ្ជាប់ទៅនឹងថ្នាលពាក់ព័ន្ធរបស់វិស័យឯកជន និងស្ថាប័នអន្តរជាតិនានានៅក្នុងតំបន់ និងសកល

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងចរាចរណ៍ដោយផ្អែកលើទិន្នន័យ និងប្រព័ន្ធគោចរសម្រាប់ការដឹកជញ្ជូន ( Transportation Navigation System ) ក្នុងន័យធានាបាននូវប្រសិទ្ធភាព ភាពទាន់ពេលវេលា និងសុវត្ថិភាពនៃប្រព័ន្ធដឹកជញ្ជូន
- កសាងយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងវិស័យឡូហ្សីស្ទិក ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យនេះនៅដំណាក់កាលបន្ទាប់
- បន្តជំរុញ និងលើកកម្ពស់ការអនុវត្តវិធានការកិច្ចសម្រួលពាណិជ្ជកម្ម ដែលមានចែងក្នុងយុទ្ធសាស្ត្រកំណែទម្រង់ និងទំនើបកម្មគយព្រមទាំងយុទ្ធសាស្ត្រផ្សេងៗដែលពាក់ព័ន្ធ។

ជាមួយគ្នានេះ ដោយហេតុថាការអភិវឌ្ឍវិស័យដឹកជញ្ជូនគោលដៅចុងក្រោយស្ថិតនៅដំណាក់កាលនៃការចាប់ផ្តើម ការអភិវឌ្ឍ ការពង្រឹងបន្ថែមនៃវិស័យនេះចាំបាច់ត្រូវផ្តោតលើការដាក់ចេញ និងការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- រៀបចំកសាងផែនការយុទ្ធសាស្ត្រជំរុញ អភិវឌ្ឍន៍វិស័យដឹកជញ្ជូន និងការចែកបញ្ជើគោលដៅ ចុងក្រោយ ក្នុងន័យបង្កើតប្រព័ន្ធអេកូឡូស៊ី និងយន្តការដាក់លាក់ នៅក្នុងវិស័យ នេះ ដោយឈរ លើគោលការណ៍ ប្រសិទ្ធភាព នវានុវត្តន៍ ចីរភាពបរិស្ថាន ភាពធន់នឹងវិបត្តិ និងអន្តរទំនាក់ទំនង
- កសាងស្តង់ដារនៃអាស័យដ្ឋានកែលម្អប្រព័ន្ធកូដប្រៃសណីយ៍ព្រមទាំងដាក់ឱ្យអនុវត្ត និងចែករំលែកក្នុងទម្រង់ឌីជីថលដល់គ្រប់ភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយតាមការកំណត់ក្នុងផែនការមេឡូហ្សីស្ទិកជាតិ
- កសាងផែនការយុទ្ធសាស្ត្រសម្រាប់កែទម្រង់ និងធ្វើទំនើបកម្មប្រព័ន្ធប្រៃសណីយ៍ ដើម្បីធានាបាននូវសេវាប្រៃសណីយ៍ ដែលមានតម្លៃសមរម្យ ទាន់ពេលវេលា និងវិសាលភាពធំទូលាយ
- ធ្វើវិសោធនកម្ម ឬកែសម្រួលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដឹកជញ្ជូន ការចែកបញ្ជើ និងភស្តុភារកម្មប្រៃសណីយ៍នៅក្នុងស្រុកក្នុងន័យធ្វើសេរីភាវូបនីយកម្មសេវានេះ។

**២. ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល** ៖ ផ្តោតលើការកសាងប្រព័ន្ធច្បាប់ និងបង្កើនការយល់ដឹងអំពីសន្តិសុខនៃប្រព័ន្ធឌីជីថល តាមរយៈការកសាងក្របខណ្ឌច្បាប់ និងសន្តិសុខសាយប័រ ដែលត្រូវបានគិតគូរដោយឈរលើគោលការណ៍ចំនួន២គឺ៖

**ក. វិធានការគោលនយោបាយផ្អែកក្របខណ្ឌច្បាប់**

ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់សេដ្ឋកិច្ច និងសង្គមឌីជីថលត្រូវមានវិសាលភាពគ្រប់ជ្រុងជ្រោយមានតួនាទីចូលរួមបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់កសាងប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ច និងសង្គមឌីជីថលបណ្តុះភាពជឿទុកចិត្តឱ្យមានការចូលរួមពីតួអង្គពាក់ព័ន្ធ។ យ៉ាងណាមិញការរឹតបន្តឹងនឹងត្រូវធ្វើឡើងក្នុងទម្រង់ស្រាល ដើម្បីលើកស្ទួយការចូលរួមក្នុងប្រព័ន្ធ និងជំរុញឱ្យសេដ្ឋកិច្ច និងសង្គមឌីជីថលចាប់ផ្តើមដំណើរការលូតលាស់ជាងមុនតាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការដាក់លាក់ដូចខាងក្រោម ៖

- កសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលនៅសេសសល់ជាអាទិ៍ ច្បាប់ស្តីពីការការពារទិន្នន័យ និងឯកជនភាព ( Data Protection and Privacy Law ) ច្បាប់ស្តីពីព័ត៌មានសាធារណៈ ( Public Information Law ) ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ច្បាប់ស្តីពីអាថ៌កំបាំងពាណិជ្ជកម្ម និងព័ត៌មានដែលមិនអាចបង្ហាញចេញក្រមសីលធម៌អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

- ធ្វើវិសោធនកម្ម ឬកែសម្រួល បន្តរៀបចំ អនុវត្តនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសន្តិសុខសាយប័រ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មី និងស្ថានភាពជាក់ស្ដែង
- រៀបចំផែនការកសាងសមត្ថភាពរបស់អ្នករៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តព្រមទាំងមន្ត្រីជំនាញឱ្យមានចំណេះដឹងឌីជីថល
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវប្បធម៌នៃការគោរពច្បាប់ជាធរមាន តួយ៉ាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងច្បាប់ស្ដីពីការការពារអ្នកប្រើប្រាស់។

**ខ. វិធានការគោលនយោបាយផ្នែកសន្តិសុខសាយប័រ**

ប្រសិទ្ធភាពនៃការគ្រប់គ្រងសន្តិសុខសាយប័រនឹងជួយដល់ការកាត់បន្ថយហានិភ័យជាអតិបរមាក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថល ផ្ដល់នូវការរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចឌីជីថល និងធានាបាននូវសង្គមឌីជីថលមួយដែលមានសុវត្ថិភាព និងសន្តិសុខខ្ពស់។ ការយល់ដឹងអំពីបញ្ហាដែលពាក់ព័ន្ធនឹងឌីជីថល ជាពិសេសបញ្ហាសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណេត គឺជាកត្តាក៏សំខាន់ដើម្បីជំរុញ បង្កើនការប្រើប្រាស់ប្រកបដោយសុវត្ថិភាពដែលសម្រេចបានតាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការជាក់លាក់ដូចតទៅ៖

- បន្តកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងរៀបចំគោលនយោបាយ ឬយុទ្ធសាស្ត្រស្ដីពីសន្តិសុខសាយប័រ
- រៀបចំវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងសន្តិសុខសាយប័រថ្នាក់ជាតិក្រោមគណៈកម្មាធិការថ្នាក់ជាតិ ដើម្បីពិនិត្យ និងតាមដានជាប្រចាំ នូវហានិភ័យដែលកើតមាននៅក្នុងប្រទេស តំបន់ និងសកល
- បង្កើតយន្តការស្ថាប័ននៅតាមក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តួយ៉ាងមជ្ឈមណ្ឌលសម្រាប់ការឆ្លើយតបទៅនឹងឧប្បត្តិហេតុសន្តិសុខកុំព្យូទ័រ និងអ៊ីនធឺណេត ( Center for Computer and Internet Incident Response ) ដើម្បីគ្រប់គ្រង និងជាបង្គោលក្នុងការផ្លាស់ប្ដូរព័ត៌មានពីបញ្ហា និងហានិភ័យផ្សេងៗ
- រៀបចំស្តង់ដាក្របខណ្ឌបច្ចេកទេស និងនីតិវិធីនៃការឆ្លើយតបដើម្បីជាមូលដ្ឋានសម្រាប់ការអនុវត្តក្នុងការរៀបចំអភិវឌ្ឍប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលមានភាពធន់នឹងការវាយប្រហារ
- រៀបចំយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាសន្តិសុខសាយប័រតាមកម្រិត
- លើកកម្ពស់ការអភិវឌ្ឍជំនាញសន្តិសុខសាយប័រ ជាអាទិ៍ ការផ្ដល់ការទទួលស្គាល់ផ្លូវការ ( Accreditation) សម្រាប់អ្នកជំនាញសន្តិសុខសាយប័រការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសផ្នែកសន្តិសុខសាយប័រដែលរៀបចំក្របខណ្ឌសហប្រតិបត្តិការក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី និងបង្កើតកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការអន្តរជាតិ ឬសមាគម និងវិស័យឯកជនដែលពាក់ព័ន្ធនឹងសន្តិសុខសាយប័រ ដើម្បីចែករំលែកព័ត៌មាន បទពិសោធ និងឧត្តមានុវត្តន៍[44]។

[44] ឧត្តមានុវត្តន៍ សំដៅលើសំណុំនៃគោលការណ៍ណែនាំ ក្រមសីលធម៌ និងគំនិតដែលធានាបាននូវប្រសិទ្ធភាព និងការប្រុងប្រយ័ត្នខ្ពស់បំផុតនៃការងារ ឬការអភិវឌ្ឍសេដ្ឋកិច្ច។ ដកស្រង់ចេញពីគេហទំព័រហ្វេសបុក Commission of Economic Technology

**៣. ការកសាងពលរដ្ឋឌីជីថល៖** ផ្តោតទៅលើការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថល ដែលត្រូវមានចំណេះដឹង ជំនាញ និងទេព្យកោសល្យ ជាផ្នែកនៃការអភិវឌ្ឍ និងប្រមូលផ្តុំធនធានមនុស្សមានទេពកោសល្យឌីជីថល និងការប្រែក្លាយទៅជាពលរដ្ឋឌីជីថលដើម្បីបង្កើតជាចលករនៃបរិវត្តកម្មឌីជីថល ទាំងវិស័យសាធារណៈ និងវិស័យឯកជននៅគ្រប់កម្រិត និងស្រទាប់។

ខាងក្រោមនេះជាវិធានការគោលនយោបាយរបស់ការកសាងពលរដ្ឋឌីជីថល៖

**ក.វិធានការគោលនយោបាយផ្នែកអ្នកដឹកនាំឌីជីថល**

ការអភិវឌ្ឍឱ្យមានធនធានមនុស្សកម្ពុជាក្លាយទៅជាអ្នកដឹកនាំឌីជីថល ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់លើការអភិវឌ្ឍប្រទេស។ រាជរដ្ឋាភិបាលកម្ពុជាជាតួអង្គសំខាន់ជាងគេឈានមុខក្នុងការត្រួសត្រាយផ្លូវក្នុងដំណើរឆ្ពោះទៅកាន់បរិវត្តកម្មឌីជីថលនាពេលអនាគត ដែលរាជរដ្ឋាភិបាលត្រូវការដាក់ចេញ និងអនុវត្តនូវវិធានការជាក់លាក់ ដូចជា៖

- រៀបចំក្របខណ្ឌរួមស្តីពីការលើកកម្ពស់អក្ខរកម្មឌីជីថល ក្នុងចំណោមអ្នកដឹកនាំ និងមន្ត្រីនៅតាមក្រសួង ស្ថាប័នរដ្ឋ ដែលរួមបញ្ចូលទាំងការបណ្តុះបណ្តាលជំនាញ និងការកសាងភាពជាអ្នកដឹកនាំឌីជីថល
- រៀបចំក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅតាមក្រសួង ស្ថាប័នព្រមទាំងដាក់ចេញនូវយន្តការរួមក្នុងការលើកទឹកចិត្តអ្នកដឹកនាំ និងមន្ត្រីដែលមានគុណវុឌ្ឍិសមត្ថភាព និងនវានុវត្តន៍ឌីជីថលខ្ពស់
- រៀបចំផែនការយុទ្ធសាស្ត្រក្នុងការផ្លាស់ប្តូរជាដំណាក់កាលលើនីតិវិធីរដ្ឋបាល និងរបៀបវារៈនៃការគ្រប់គ្រង និងការចាត់ចែងការងារនៅតាមក្រសួង ស្ថាប័នដោយជំនួស ឬបំពេញដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល
- រៀបចំផែនការរយៈពេលខ្លី ឬមធ្យមសម្រាប់ការជំរុញការចាប់យកក្នុងការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និងការចាត់ចែងការងារព្រមទាំងការជំរុញ និងលើកកម្ពស់ការបណ្តុះបណ្តាលជំនាញឌីជីថលក្នុងចំណោមអ្នកដឹកនាំ មន្ត្រីនៅតាមមូលដ្ឋាន និងសាធារណៈជន
- រៀបចំផែនការរយៈពេលខ្លី ឬមធ្យមសម្រាប់ការជំរុញចាប់យកនៃការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និងការចាត់ចែងការងារព្រមទាំងការលើកកម្ពស់ការបណ្តុះបណ្តាលជំនាញឌីជីថល ព្រមទាំងភាពជាអ្នកដឹកនាំនៅក្នុងវិស័យឯកជន
- បង្កើនការផ្ទេរធនធានកៀរគរគាំទ្រទាំងផ្នែលបច្ចេកទេស ជាមួយនិងថវិកាក៏ដូចជាកិច្ចប្រតិបត្តិការនានាអំពីសំណាក់ដៃគូអភិវឌ្ឍ និងវិស័យឯកជន សម្រាប់ការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅថ្នាក់ក្រោមជាតិ។

**ខ. វិធានការគោលនយោបាយផ្នែលបណ្តុះធនធានមនុស្សដែលមានទេពកោសល្យឌីជីថល**

បណ្តុំនៃធនធានមនុស្សដែលពោពេញទៅដោយទេពកោសល្យទៅលើផ្នែកឌីជីថល គឺជាចំណែកមួយនៃការពាំនាំប្រទេសទៅរកការអភិវឌ្ឍធនធានមនុស្សឌីជីថល។ គោលដៅនេះអាចសម្រេចទៅបាន លុះត្រាតែមានការដាក់ចេញ និងមានការអនុវត្តនូវវិធានការជាក់លាក់ ដូចខាងក្រោម៖

- បង្កើត និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងថ្នាក់ជាតិស្តីពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម ជំនាញឌីជីថល ដោយធ្វើការសិក្សាជាទៀងទាត់ដើម្បីកំណត់ឱ្យបានជាក់លាក់អំពីបរិមាណ និងប្រភេទ ជំនាញឌីជីថលដែលមានតម្រូវការនៅក្នុងទីផ្សារបច្ចុប្បន្ន និងពេលអនាគត
- កសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការជំរុញការសិក្សា ការបណ្តុះបណ្តាល ការកសាង ជំនាញឌីជីថលនៅថ្នាក់ឧត្តមសិក្សានៅគ្រប់កម្រិតបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំង ជំរុញការកែលម្អកម្មវិធីសិក្សា ដើម្បីបន្សីគ្នារវាងតម្រូវការជំនាញ និងការបណ្តុះបណ្តាល
- រៀបចំ និងអនុវត្តកម្មវិធី ឬគំនិតផ្តួចផ្តើមថ្នាក់ជាតិក្នុងការអភិវឌ្ឍ ការបណ្តុះធនធានមនុស្សដែលមាន ទេពកោសល្យឌីជីថល រួមមានជាអាទិ៍ ការបង្កើតមូលនិធិថ្នាក់ជាតិសម្រាប់ផ្តល់អាហារូបករណ៍លើផ្នែក បច្ចេកវិទ្យាឌីជីថល ទាំងក្នុងប្រទេស និងក្រៅប្រទេស ដោយកៀរគរការធ្វើសហហិរញ្ញប្បទានពីវិស័យ សាធារណៈ វិស័យឯកជន និងគ្រឹះស្ថានសិក្សា
- រៀបចំ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និងការបណ្តុះគំនិតថ្មីដោយផ្អែកលើ តម្រូវការជំនាញថ្មី (New Skills Requirement ) នៅក្នុងវិស័យសាធារណៈ
- កសាងយុទ្ធសាស្ត្រលើកទឹកចិត្ត និងទាក់ទាញអ្នកមានទេព្យកោសល្យឌីជីថលពីក្រៅប្រទេសគួបផ្សំនឹង ការសម្រួលនីតិវិធីរដ្ឋបាលពាក់ព័ន្ធនានានៅក្នុងវិស័យឯកជន
- កសាងយុទ្ធសាស្ត្រលើកទឹកចិត្ត និងទាក់ទាញអ្នកមានទេពកោសល្យឌីជីថលពីក្រៅប្រទេស គួបផ្សំនឹង ការសម្រួលនីតិវិធីរដ្ឋបាលពាក់ព័ន្ធនានា នៅក្នុងវិស័យសាធារណៈ
- រៀបចំយន្តការលើកទឹកចិត្ត គាំទ្រ និងផ្តល់ភាពងាយស្រួលដល់វិស័យឯកជន ក្នុងការផ្តល់វគ្គបណ្តុះ បណ្តាលដល់កម្មករនិយោជិត លើជំនាញឌីជីថល ឬការផ្លាស់ប្តូរជំនាញទៅចាប់យកជំនាញឌីជីថល
- ជំរុញសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍ ព្រមទាំងនវានុវត្តន៍ឌីជីថល នៅតាមបណ្តាសាកលវិទ្យាល័យ គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងវិទ្យាស្ថាន ព្រមទាំងមជ្ឈមណ្ឌលស្រាវជ្រាវនានា តាមរយៈការចងក្រងជាប្រព័ន្ធនូវបណ្តាស្ថាប័ន-គ្រឹះស្ថានស្រាវជ្រាវ
- កសាងក្របខណ្ឌភាពជាដៃគូជាមួយនឹងវិស័យឯកជនក្នុងការជំរុញ នូវការអភិវឌ្ឍការងារស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍ រួមមានជាអាទិ៍។ ការរៀបចំឱ្យមានបណ្តុំមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ ឌីជីថល ដើម្បីជំរុញការផ្លាស់ប្តូរទិន្នន័យ ព័ត៌មាន ចំណេះដឹង គួបផ្សំនឹងការរៀបចំមូលនិធិថវិកាគាំទ្រ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

### គ. វិធានការគោលនយោបាយផ្នែកពលរដ្ឋឌីជីថល

គោលបំណងនៃវិធានគោលនយោបាយនេះគឺធានាបាននូវសង្គមឌីជីថល ប្រកបដោយចីរភាព និងធ្វើ ដោយណាឱ្យប្រជាពលរដ្ឋមានចំណេះដឹង មានជំនាញឌីជីថលគ្រប់គ្រាន់ ព្រមទាំងចេះប្រើប្រាស់ប្រព័ន្ធឌីជីថល ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។ ការលើកកម្ពស់គុណភាពនៃ ការសិក្សាកម្រិតទូទៅជារួម និងការបន្តធ្វើសមាហណកម្មវិស័យបច្ចេកវិទ្យា ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតនៃ ប្រព័ន្ធអប់រំ និងប្រព័ន្ធបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈអាចសម្រេចទៅបានតាមរយៈការដាក់ចេញ និងការអនុវត្តន៍ នូវវិធានការជាក់លាក់ដូចខាងក្រោម៖

- កែលម្អប្រព័ន្ធកម្មវិធីសិក្សា ដោយដាក់បញ្ចូលការសិក្សាផ្នែកបច្ចេកវិទ្យាឌីជីថលជាមុខវិជ្ជាគោលមួយ នៅគ្រប់កម្រិតចាប់ពីថ្នាក់បឋមសិក្សាដល់មធ្យមសិក្សា និងការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈគ្រប់កម្រិត គួបផ្សំនឹងការគាំទ្រ ការឧបត្ថម្ភដល់ក្រុមមនុស្សដែលមានតម្រូវការជាក់លាក់ និងក្រុមមនុស្សដែលងាយរងគ្រោះ
- កសាងផែនការវិនិយោគលើការបំពាក់សម្ភារបច្ចេកវិទ្យាឌីជីថល ការកសាងបន្ទប់ពិសោធន៍ឌីជីថល និងការតភ្ជាប់បណ្តាញអគ្គិសនី និងអ៊ីធឺណេតនៅតាមសាលារៀនរដ្ឋ គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ការសិក្សា និងការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាឌីជីថល
- រៀបចំកម្មវិធីលើកកម្ពស់គុណវឌ្ឍិ[45] និងការអភិវឌ្ឍស្តង់ដាសមត្ថភាពឌីជីថលសម្រាប់គ្រូបង្រៀនគ្រប់កម្រិតថ្នាក់ សំដៅបង្កើនការអនុវត្តវិធីសាស្ត្របង្រៀន ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនៅតាមគ្រប់គ្រឹះស្ថានសិក្សា និងបណ្តុះបណ្តាល
- រៀបចំផែនការផ្តល់មគ្គុទេសក៍ជំនាញអាជីពឌីជីថលនៅគ្រប់កម្រិតអប់រំ និងកម្រិតបណ្តុះបណ្តាលព្រមទាំងបញ្ជ្រាបការយល់ដឹង ការបំពាក់បំប៉នចំណេះដឹង និងជំនាញឌីជីថលសម្រាប់ការអប់រំក្រៅប្រព័ន្ធដើម្បីជំរុញការចាប់យកឌីជីថល ប្រកបដោយបរិយាបន្នកម្ម
- រៀបចំយន្តការផ្សព្វផ្សាយរួមមានជាអាទិ៍ ការរៀបចំព្រឹត្តិការណ៍ជាតិ ឬយុទ្ធនាការជាតិ ដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការចាប់យកឌីជីថលដោយការសហការជាមួយនឹងដៃគូអភិវឌ្ឍន៍អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន។

**៤. ការកសាងរដ្ឋាភិបាលឌីជីថល** ៖ ផ្តោតទៅលើការជំរុញសេវាសាធារណៈឌីជីថល ឈរលើគោលការណ៍សេវាកាន់តែសាមញ្ញ កាន់តែឆាប់រហ័ស កាន់តែប្រសើរ កាន់តែចំណាយតិច និងការរៀបចំពង្រឹងអភិបាលកិច្ចផ្អែកលើទិន្នន័យដែលនឹងជួយជំរុញ និងលើកកម្ពស់តួនាទីរបស់វិស័យសាធារណៈក្នុងការត្រួសត្រាយផ្លូវ ការបំពេញគម្លាតការវិនិយោគ និងការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងបរិការណ៍ឌីជីថល។ គោលការណ៍ផ្តួចផ្តើម និងពង្រីកដើម្បីប្រសិទ្ធភាពនេះផ្តោតលើការធ្វើទំនើបកម្មមុខងារស្នូលរបស់បណ្តាស្ថាប័នរបស់រាជរដ្ឋាភិបាល និងការផ្តល់សេវាសាធារណៈ ការកសាងថ្នាលបច្ចេកវិទ្យាមូលដ្ឋានជាគន្លឹះជំរុញការអនុវត្តឌីជីថល ( Digital Key Enablers ) និងអភិបាលកិច្ចផ្អែកលើទិន្នន័យ ( Data-Driven Governance ) ដែលដើរស្របទៅនឹងបង្គោលចររបស់ក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល។

### ក. វិធានការគោលនយោបាយផ្នែករដ្ឋាភិបាល និងសេវាសាធារណៈឌីជីថល

ការបង្កើតនូវសេវាសាធារណៈឌីជីថល ត្រូវបានគិតគូរដល់តម្រូវការរបស់អ្នកប្រើប្រាស់ និងការប្រាស្រ័យទាក់ទងក្នុងអង្គភាព ឬស្ថាប័នរដ្ឋាភិបាល។ ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវបន្តធ្វើទំនើកម្មសេវាឌីជីថលដែលមានស្រាប់ រួចបង្កើតសេវាសាធារណៈអាទិភាពជាឌីជីថល និងដាក់ដំណើរការនៃការផ្តល់សេវាសាធារណៈឌីជីថលជូនទៅប្រជាពលរដ្ឋ តាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការជាក់លាក់ ដូចតទៅ៖

[45] គុណវឌ្ឍិ (--វុឌ-ឍិ) = សេចក្តីចម្រើនដោយគុណ, ដំណើរចម្រើនដោយសេចក្តីល្អ, ដោយសេចក្តីរុងរឿង, ដោយសេចក្តីបរិសុទ្ធិ។

➢ រៀបចំ និងកែលម្អប្រព័ន្ធទិន្នន័យមូលដ្ឋាន ( Base Registry ) សម្រាប់ការចុះបញ្ជីគួបផ្សំនឹងការជំរុញឱ្យមានវប្បធម៌នៃការចែករំលែកទិន្នន័យគោលទាំងនេះ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

➢ រៀបចំឯកសារស្តង់ដាគំរូសម្រាប់កំណត់លក្ខខណ្ឌបច្ចេកទេស ពិធីសារ យន្តការអន្តរប្រតិបត្តិការ យន្តការសន្តិសុខសាយប័រ និងរូបរាងនៃការរចនាលើគេហទំព័រសេវាសាធារណៈឌីជីថលដើម្បីធ្វើសុខដុមនីយកម្មគ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលធានាបាននូវលក្ខខណ្ឌតម្រូវ នៃប្រព័ន្ធបច្ចេកវិទ្យាវិស័យឯកជន ដែលចង់ធ្វើអន្តរប្រតិបត្តិការជាមួយនឹងប្រព័ន្ធរបស់វិស័យសាធារណៈ

➢ រៀបចំកាតាឡុកនៃទិន្នន័យ ដែលត្រូវចែករំលែកពេលធ្វើអន្តរប្រតិបត្តិការ ( Catalogue for Service Interoperability ) ផ្តល់ភាពងាយស្រួលដល់ស្ថាប័នដទៃទៀតទាញយកទិន្នន័យក្នុងប្រព័ន្ធរបស់ខ្លួន និងចៀសវាងការផ្លាស់ប្តូរដោយមិនមានការជូនដំណឹង ពេលធ្វើអន្តរប្រតិបត្តិការ

➢ កំណត់សេវាអាទិភាពសម្រាប់អភិវឌ្ឍ និងសាកល្បងឌីជីថលូបនីយកម្ម ដោយផ្អែកលើតម្រូវការរបស់អ្នកទទួលសេវា

➢ ត្រួតពិនិត្យឡើងវិញនូវអនុលោមភាព និងបង្កើននូវស្វ័យប្រវត្តិកម្មនៃការផ្តល់សេវាសាធារណៈតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឈានមុខដើម្បីកាត់បន្ថយភាពស្មុគស្មាញនៃការប្រើប្រាស់សេវាសាធារណៈឌីជីថល

➢ ពង្រីកវិសាលភាព និងគុណភាពនៃសេវាសាធារណៈចាំបាច់តាមប្រព័ន្ធអេឡិចត្រូនិក ដែលអាចប្រើប្រាស់បានជាប្រចាំក្នុងរយៈពេល ២៤ម៉ោង និង៣៦៥ថ្ងៃ ដែលមានការកាត់បន្ថយការជួបមន្ត្រីដែលផ្តល់សេវាជាអតិបរមា

➢ បង្កើត និងធ្វើបច្ចុប្បន្នភាពនូវគេហទំព័រ ប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងបណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួង ស្ថាប័ន ឱ្យមានភាពសាមញ្ញដោយមានប្រមូលផ្តុំនូវព័ត៌មាន និងទិន្នន័យសំខាន់ៗដែលអាចជឿជាក់បាន និងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ

➢ រៀបចំវិធានការរួមស្តីពីសន្តិសុខសាយប័រ សុវត្ថិភាពទិន្នន័យដើម្បីពង្រឹងយន្តការការពារ ទប់ស្កាត់ និងឆ្លើយតបទៅនឹងការគំរាមកំហែងសន្តិសុខសាយប័រ

➢ ជំរុញការអនុវត្តវិធានការសន្តិសុខសាយប័រ សុវត្ថិភាពទិន្នន័យដើម្បីពង្រឹងសន្តិសុខសាយប័រ និងបង្កើនភាពជឿជាក់របស់អ្នកប្រើប្រាស់សេវាសាធារណៈ

➢ ពង្រឹងប្រសិទ្ធភាព និងគុណភាពសេវា ( Time Efficiency and Quality of Service ) ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជនលើការប្រើប្រាស់សេវាសាធារណៈឌីជីថល

➢ រៀបចំយន្តការផ្តល់សេវាសាធារណៈឌីជីថលប្រកបដោយគណនេយ្យភាព និងតម្លាភាព ព្រមទាំងយន្តការត្រួតពិនិត្យ វាយតម្លៃការផ្តល់សេវាសាធារណៈឌីជីថល ដោយប្រើប្រាស់ទិន្នន័យរួមទាំងបច្ចេកវិទ្យាឌីជីថល។

**ខ. វិធានការគោលនយោបាយផ្នែកគន្លឹះជំរុញការអនុវត្តឌីជីថល**

ការកសាងរដ្ឋាភិបាលឌីជីថលផ្តើមចេញពីការកសាងនូវថ្នាលបច្ចេកវិទ្យា ជាមូលដ្ឋានសម្រាប់គាំទ្រការអនុវត្តឌីជីថលដោយមានការរៀបចំក្របខណ្ឌផែនការច្បាស់លាស់ រួមទាំងធនធានសមត្ថភាពតាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការដាក់លាក់ដូចខាងក្រោម៖

- បន្តអភិវឌ្ឍន៍ និងប្រតិបត្តិថ្នាលផ្លាស់ប្តូរទិន្នន័យទាំងក្នុងក្របខណ្ឌបច្ចេកទេស និងក្របខណ្ឌច្បាប់ ដោយតម្រូវឱ្យប្រព័ន្ធឌីជីថលរបស់ក្រសួង-ស្ថាប័នរដ្ឋធ្វើអន្តរប្រតិបត្តិការជាមួយគ្នាដើម្បីពង្រឹងសេវាសាធារណៈឌីជីថល ព្រមទាំងជំរុញឱ្យមានសហថាមពល និងការសហការបង្កើតថ្មីជាមួយនឹងប្រព័ន្ធរបស់វិស័យឯកជននៅលើថ្នាលនេះ
- ធ្វើចំណាត់ថ្នាក់លើភាពរសើប នៃទិន្នន័យ និង រៀបចំបណ្តាញឯកជននិម្មិត (Virtual Private Network-VPN) សម្រាប់បម្រើដល់ការផ្លាស់ប្តូរទិន្នន័យដែលមានកម្រិតរសើប កម្រិតមធ្យម និងកម្រិតខ្ពស់
- អភិវឌ្ឍមជ្ឈមណ្ឌលទិន្នន័យរួមជាហេដ្ឋារចនាសម្ព័ន្ធជាសេវា (Infrastructure as a Service) និងថ្នាលជាសេវា (Platform as a Service) សម្រាប់ប្រតិបត្តិការនៃប្រព័ន្ធ ICT របស់រាជរដ្ឋាភិបាល
- រៀបចំថ្នាលផ្លាស់ប្តូរទិន្នន័យជាកញ្ចប់ដែលមានទំហំធំ (Bulky Data) ដើម្បីផ្លាស់ប្តូរ ទិន្នន័យ ឬឯកសារដែលមានទំហំធំ និងមិនសូវផ្លាស់ប្តូរញឹកញាប់
- រៀបចំថ្នាលគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេតនៃវត្ថុសម្រាប់បម្រើនូវមុខងារមួយចំនួន រួមមានចរាចរណ៍កាមេរ៉ាសុវត្ថិភាពក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ
- រៀបចំពិធីសារ និងថ្នាលឌីជីថលសម្រាប់ទីក្រុងឆ្លាតក្នុងរយៈពេលមធ្យម និងវែង
- រៀបចំប្រព័ន្ធគ្រប់គ្រងវិញ្ញាបនបត្រហត្ថលេខាឌីជីថលមេ (Root Certificate Authority) និងវិញ្ញាបនបត្រហត្ថលេខាឌីជីថល (Certificate Authority) សម្រាប់ប្រើប្រាស់ក្នុងការរៀបចំអត្តសញ្ញាណឌីជីថល ការសម្គាល់អតិថិជនឌីជីថល និងហត្ថលេខាឌីជីថលដែលអាចត្រូវបានប្រើប្រាស់ទូលំទូលាយទាំងក្នុងប្រព័ន្ធសាធារណៈ និងប្រព័ន្ធឯកជន
- ជំរុញការប្រើប្រាស់អត្តសញ្ញាណឌីជីថលហត្ថលេខាឌីជីថលក្នុងការកំណត់នូវការផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថលឱ្យបានទូលំទូលាយចំពោះប្រជាពលរដ្ឋស្ថាប័នឯកជន និងស្ថាប័នសាធារណៈ
- ផ្តល់ការបណ្តុះបណ្តាល និងប្រឹក្សាដល់មន្ត្រីបច្ចេកទេសICTតាមក្រសួង-ស្ថាប័នក្នុងការប្រើប្រាស់ថ្នាលឌីជីថលរួម
- លើកកម្ពស់វប្បធម៌នៃការផ្លាស់ប្តូរព័ត៌មាន ទិន្នន័យ និងធានាសមាហរណកម្មទិន្នន័យរវាងក្រសួង-ស្ថាប័ន
- ធានាបាននូវឯកជនភាព និងសុវត្ថិភាពនៃការចែករំលែក និងការប្រើប្រាស់ទិន្នន័យ
- ធានាសមាហរណកម្មទិន្នន័យអ្នកប្រើប្រាស់ និង សហគ្រាសទាំងឡាយនៅក្នុងវិស័យឯកជន
- ពង្រីកវិសាលភាពនៃការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) វិទ្យាសាស្ត្រទិន្នន័យ ទិន្នន័យធំ និងបច្ចេកវិទ្យាឈានមុខផ្សេងៗទៀតសម្រាប់បម្រើដល់ការចែករំលែកទិន្នន័យ និងការបង្កើតសេវាឌីជីថលដែលស្រួលប្រើប្រាស់
- រៀបចំ និងដាក់ឱ្យអនុវត្តន៍ច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថល ការធ្វើសមាហរណកម្មនៃការទំនាក់ទំនង និងការតភ្ជាប់បណ្តាញរវាងទីភ្នាក់ងាររបស់រាជរដ្ឋាភិបាល សំដៅទៅលើការសម្រួលការផ្តល់សេវាសាធារណៈក្រោមប្រព័ន្ធគ្រប់គ្រងរួមដោយមិនចាំបាច់តម្រូវឯកសារផ្លូវការ។

### គ. វិធានការគោលនយោបាយផ្នែកអភិបាលកិច្ចផ្អែកលើទិន្នន័យ

ការកសាងប្រព័ន្ធអភិបាលកិច្ចដោយផ្អែកលើទិន្នន័យដែលជួយបង្កើនប្រសិទ្ធភាព និងតម្លាភាពក្នុងកិច្ចការសាធារណៈតាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការជាក់លាក់ដូចខាងក្រោម៖

- ជំរុញការធ្វើឌីជីថលូបនីយកម្មក្នុងក្របខណ្ឌរដ្ឋ និងឯកជន ដើម្បីប្រមូលទិន្នន័យឱ្យបានច្រើនកម្រិត និងពីច្រើនប្រភព រួមមានជាអាទិ៍ ទិន្នន័យគោល ទិន្នន័យដែលកើតឡើងជាប្រចាំ (Transactional Data) ទិន្នន័យដែលផ្ទុកលើហេដ្ឋារចនាសម្ព័ន្ធប្លុកឆេន (Blockchain) សម្រាប់ជាមូលដ្ឋាននៃការវិភាគ
- បង្កើតយន្តការរួមក្នុងការកសាងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ និងលើកកម្ពស់សមត្ថភាពស្ថាប័ន
- គាំទ្រនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់ប្រមូលទិន្នន័យ បញ្ចូលការរៀបចំបច្ចេកវិទ្យាដោយប្រើប្រាស់ទិន្នន័យសម្រាប់ផ្តល់សញ្ញាព្រមានចំពោះហេតុការណ៍មិនរំពឹងទុកនានា រួមមានជាអាទិ៍ គ្រោះធម្មជាតិ ទឹកជំនន់ ការកាប់បំផ្លាញព្រៃឈើ កាប់ព្រៃឈើបម្លាស់ទីរបស់ជនអន្តោប្រវេសន៍
- ធានាបាននូវសមត្ថភាពក្នុងការប្រមូល និងការវិភាគទិន្នន័យតាមរយៈការរៀបចំបង្កើតម៉ាស៊ីនវិភាគរួម (Shared Analytics Engine)
- ពង្រឹងមុខងារ និងសមត្ថភាពនៃ ការប្រមូល និងការប្រើប្រាស់ទិន្នន័យដោយបង្កើត កន្លែងផ្ទុកទិន្នន័យសំខាន់នៅតាមស្ថាប័នពាក់ព័ន្ធរួមមានជាអាទិ៍ វិទ្យាស្ថានជាតិ ស្ថិតិ និងបណ្ណសារឌីជីថលជាតិ (National Digital Archive)
- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់ការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) នៅក្នុងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ ជាពិសេសការប្រើប្រាស់ ការវិភាគទិន្នន័យ និងយន្តការសម្រាប់ការបង្កើតសេវាឌីជីថលឱ្យមានស្វ័យប្រវត្តិកម្មខ្ពស់ និងងាយស្រួលប្រើប្រាស់
- ធានាបាននូវគុណភាពនៃទិន្នន័យ ព័ត៌មានតាមរយៈការធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងឡាយទាំងកម្រិតស្ថាប័ន និងអន្តរស្ថាប័នដោយផ្អែកលើយន្តការរួមនៃការកសាងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ
- ជំរុញការស្រាវជ្រាវលើការធ្វើឌីជីថលូបនីយកម្មភាសាខ្មែរ ដើម្បីផ្តល់លទ្ធភាពសម្គាល់ភាសាខ្មែរក្នុងការស្វែងរក ការវិភាគទិន្នន័យជាអក្សរខ្មែរ និងលាយអក្សរបរទេស
- ជំរុញ ផ្សព្វផ្សាយ និងចែករំលែកទិន្នន័យមួយចំនួនជាសាធារណៈ
- ចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយ និងក្របខណ្ឌច្បាប់ដែលគាំទ្រដល់ការប្រព្រឹត្តទៅនៃរដ្ឋាភិបាលឌីជីថល ជាពិសេសការលើកកម្ពស់អភិបាលកិច្ចផ្អែកលើទិន្នន័យ។

**៥. ការជំរុញធុរកិច្ចឌីជីថល** ៖ ផ្តោតទៅលើការលើកទឹកចិត្តសហគ្រាសជារួម និងសហគ្រាសធុនតូច និងមធ្យមជាពិសេសឱ្យចាប់យកឌីជីថលឱ្យបានទូលំទូលាយ ការបង្កើតប្រព័ន្ធអេកូឡូស៊ីសម្រាប់បណ្តុះធុរកិច្ចថ្មីៗ និងការចូលរួមក្នុងខ្សែច្រវាក់ឌីជីថលនៅក្នុងតំបន់ និងសកល សំដៅជំរុញធុរកិច្ចឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ក្នុងន័យទទួលបានអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល និងការជំរុញនវានុវត្តន៍។

### ក. វិធានការគោលនយោបាយផ្នែកបរិវត្តកម្មឌីជីថលសហគ្រាស

ការធ្វើបរិវត្តកម្មឌីជីថលសហគ្រាស គឺជាផ្នែកមួយដ៏សំខាន់នៃការធ្វើទំនើបកម្មរចនាសម្ព័ន្ធសហគ្រាស និងការលើកកម្ពស់ការត្រៀមខ្លួនរបស់សហគ្រាសនៅក្នុងស្រុកក្នុងការចាប់យក និងការធ្វើសមាហរណកម្មខ្សែ

ច្រវាក់ផលិតកម្មទៅក្នុងសេដ្ឋកិច្ចឌីជីថល នៅក្នុងប្រទេស តំបន់ និងសកល ។ ក្នុងន័យនេះក្របខណ្ឌការងារ និងធនធានគាំទ្រដល់សហគ្រាសនានាទាំងកម្រិតធំ មធ្យម និងតូចក្នុងការធ្វើបរិវត្តកម្មឌីជីថនឹងត្រូវបានរៀបចំ និងកសាង តាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការជាក់លាក់ដូចខាងក្រោមៈ

- រៀបចំយុទ្ធសាស្ត្រទំនើបកម្ម និង/ឬ ឧស្សាហកម្ម ៤.0 សម្រាប់សហគ្រាស នៅក្នុងគ្រប់វិស័យ គ្រប់ទំហំ និងធុរកិច្ចថ្មីដោយរួមបញ្ចូលការគាំទ្រនានា សំដៅកសាងសមត្ថភាពឌីជីថលនូវការធ្វើឌីជីថលូបនីយកម្មផលិតកម្មសំដៅបង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច
- បន្តជំរុញ និងលើកកម្ពស់ការអនុវត្តវិធានការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមដែលមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម និងយុទ្ធសាស្ត្រផ្សេងៗដែលពាក់ព័ន្ធគួបផ្សំនឹងធ្វើការសិក្សាយ៉ាងលម្អិតអំពីសមត្ថភាពក្នុងការស្រូបយកការត្រៀមខ្លួន (Digital and Industry 4.0 Readiness) ការរាំងស្ទះ (Bottlenecks) និងតម្រូវការ (Skill Needs) ក្នុងការចាប់យកបច្ចេកវិទ្យាថ្មី និងការធ្វើបរិវត្តកម្មឌីជីថលរបស់សហគ្រាសធុនតូច និង មធ្យម និងឧស្សាហកម្ម
- បង្កើតយន្តការផ្សព្វផ្សាយ ប្រឹក្សាយោបល់ និងលើកកម្ពស់ការយល់ដឹងអំពីសេដ្ឋកិច្ចឌីជីថលដែលមានសមត្ថកិច្ចផ្តល់សេវាដោយឥតគិតថ្លៃ ឬថ្លៃសមរម្យដល់សហគ្រាសដែលមានបំណងចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងប្រតិបត្តិការរបស់ខ្លួន
- ពង្រឹងក្របខណ្ឌ ឬបន្តសម្រួលយន្តការចុះបញ្ជី និងការផ្តល់អាជ្ញាបណ្ណតាមថ្នាលបច្ចេកវិទ្យាព័ត៌មានសម្រាប់សហគ្រាស និងធុរកិច្ចថ្មីគួបផ្សំនឹងយន្តការលើកទឹកចិត្តផ្នែកពន្ធ និងមិនមែនពន្ធដើម្បីបំពេញភាពស្របច្បាប់ និងទទួលបានកម្មវិធីគាំទ្រ និងសេវាសាធារណៈសំខាន់ៗពីរាជរដ្ឋាភិបាល
- បន្តជំរុញ និងលើកកម្ពស់ការអនុវត្តវិធានការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានចែងក្នុងយុទ្ធសាស្ត្រស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងយុទ្ធសាស្ត្រផ្សេងៗដែលពាក់ព័ន្ធ
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងថ្នាលឌីជីថលរួម ដើម្បីគាំទ្រដល់សហគ្រាសជាទូទៅដែលរួមមានៈ
  ១. ថ្នាលសម្រាប់សម្រួលប្រសិទ្ធភាពប្រតិបត្តិការធុរកិច្ចរួមមានជាអាទិ៍ ការគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុទំនាក់ទំនងជាមួយនឹងអតិថិជន
  ២. ថ្នាលដែលគាំទ្រដល់ការពង្រីកទីផ្សារលក់ក្នុងប្រទេស និងក្រៅប្រទេស។
- ជំរុញកិច្ចសហការរវាងវិស័យសាធារណៈ វិស័យឯកជននៅក្នុងវិស័យបច្ចេកវិទ្យា និងនវានុវត្តន៍សំដៅផ្តល់ដំណោះស្រាយ និងសេវាឌីជីថលស្តីពីប្រតិបត្តិការអាជីវកម្មជាអាទិ៍ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងគណនេយ្យ ការគ្រប់គ្រងការបញ្ជាទិញ ការគ្រប់គ្រង់សន្និធិការគ្រប់គ្រងអតិថិជនដល់សហគ្រាស
- ជំរុញការចាប់យក និងការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសំដៅដល់ការបង្កើនភាពងាយស្រួលសម្រាប់ប្រតិបត្តិការនានារបស់សហគ្រាស
- បន្តធ្វើឱ្យប្រសើរឡើងនូវបរិស្ថានគាំទ្រផ្នែកហិរញ្ញវត្ថុបច្ចេកទេស និងសមត្ថភាពដល់ការអភិវឌ្ឍសហគ្រាសតាមរយៈ៖
  ១. ការកំណត់វិស័យអាទិភាពសម្រាប់ការគាំទ្រដល់ការចាប់យកឌីជីថល

២. ការពង្រឹង និងការពង្រីកភាពជាដៃគូរវាងតួអង្គរដ្ឋាភិបាល មិនមែនរដ្ឋាភិបាល ក្នុងការស្រាវជ្រាវអំពីវិស័យអាទិភាព និងការផ្គត់ផ្គង់ផលិតផល ឬសេវា

៣. ការបង្កើតមជ្ឈមណ្ឌលគាំទ្រសហគ្រាសនៅគ្រប់ដំណាក់កាលនៃកំណើន

៤. ការបង្កើតកម្មវិធីអប់រំ និងបណ្តុះបណ្តាលស្របទៅតាមតម្រូវការរបស់និយោជិត និងនិយោជកសម្រាប់ធុរកិច្ចជាពិសេសនៅក្នុងវិស័យឌីជីថល

៥. ការសិក្សាស៊ីជម្រៅអំពីលទ្ធភាពក្នុងការចាប់យកឌីជីថលរបស់សហគ្រាស ។

**ខ. វិធានការគោលនយោបាយផ្នែកបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និងធុរកិច្ចថ្មី**

រាជរដ្ឋាភិបាលត្រូវបន្តលើកកម្ពស់នូវលក្ខខណ្ឌអំណោយផលសម្រាប់ប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ចឌីជីថល និងការចាប់យកខ្សែច្រវាក់ផលិតកម្ម និងតម្លៃពីប្រព័ន្ធថ្មីនេះតាមរយៈការពង្រឹងសហគ្រិនភាព បូករួមការជំរុញធុរកិច្ចថ្មីទាំងផ្នែកសមត្ថភាព និងធនធានហិរញ្ញវត្ថុ។ ការណ៍នេះអាចសម្រេចបានតាមរយៈការដាក់ចេញ និងការអនុវត្តនូវវិធានការជាក់លាក់ ដូចខាងក្រោម៖

- ពង្រឹងការអនុវត្ត និងកែសម្រួលយន្តការគាំទ្រកម្មវិធីផ្តួចផ្តើមរបស់ស្ថាប័ននានាក្នុងការអភិវឌ្ឍសហគ្រិនភាព និងនវានុវត្តន៍សម្រាប់សហគ្រាស ជាពិសេសសហគ្រាសធុនតូច មធ្យម និងធុរកិច្ចថ្មី
- ជំរុញការអនុវត្តបន្តការកែសម្រួល កសាងក្របខណ្ឌច្បាប់ដែលមានគោលការណ៍គាំទ្រការកសាងទំនុកចិត្ត និងភាពជឿជាក់ដល់វិនិយោគិន ព្រមទាំងជំរុញបង្កើតបណ្តាញវិនិយោគដ៏រឹងមាំ
- កសាងយុទ្ធសាស្ត្រជាតិស្តីពីការជំរុញការស្រាវជ្រាវអភិវឌ្ឍន៍ និងនវានុវត្តន៍ សំដៅផ្តល់ទិសដៅដល់ការលើកកម្ពស់គំនិតផ្តួចផ្តើមកម្មវិធី គម្រោងនានាសម្រាប់ការស្រាវជ្រាវមានការអភិវឌ្ឍ និងនវានុវត្តន៍
- ជំរុញការចុះបញ្ជីកម្មសិទ្ធិបញ្ញា និងពង្រឹងការការពារសិទ្ធិកម្មសិទ្ធិបញ្ញា (Intellectual Property Right) របស់សហគ្រាស និងធុរកិច្ចថ្មីចំពោះការច្នៃប្រឌិត
- បង្កើនបរិយាកាសអំណោយផលសម្រាប់ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍ តាមរយៈ៖

  ១. ការពង្រឹងការអនុវត្តគោលនយោបាយ ទាក់ទងនឹងវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍

  ២. ការជំរុញ និងការលើកកម្ពស់គុណភាពមជ្ឈមណ្ឌលស្រាវជ្រាវសាធារណៈក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ឌីជីថល

  ៣. ការបង្កើតមូលនិធិនវានុវត្តន៍ឌីជីថលដើម្បីលើកទឹកចិត្តវិស័យឯកជនក្នុងការវិនិយោគ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ឌីជីថលសម្រាប់ពាណិជ្ជកម្ម។
- លើកកម្ពស់វប្បធម៌សហគ្រិនភាព ផ្នត់គំនិតច្នៃប្រឌិត ការយល់ដឹងពីទីផ្សារឌីជីថល និងកាលានុវត្តភាពធុរកិច្ចឌីជីថលសម្រាប់សហគ្រាសធុនតូច និងមធ្យម ដោយសាកល្បងកសាងអភិវឌ្ឍតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម ផ្តោតលើវិស័យអាទិភាព
- បង្កើតយន្តការសហប្រតិបត្តិការ និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងដៃគូពាក់ព័ន្ធទាំងជាតិ និងអន្តរជាតិតាមរយៈការបង្កើតភ្នាក់ងារ ជាមួយនិងមូលនិធិអភិវឌ្ឍន៍ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យានិយ័តកម្ម (RegTech)

- បង្កើតក្របខណ្ឌជំរុញទាក់ទាញវិនិយោគ និងការចូលរួមរបស់វិស័យឯកជនក្នុងគម្រោងវិនិយោគដែលមានបច្ចេកវិទ្យាទំនើបៗ គួបផ្សំនឹងការបណ្តុះបណ្តាល ការប្រើប្រាស់ និងការផ្ទេរបច្ចេកវិទ្យា ព្រមទាំងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍
- បង្កើនសេវាគាំទ្រធុរកិច្ចថ្មីដែលរួមមាន៖

  ១. ការលើកទឹកចិត្តឱ្យមានការវិនិយោគលើអ្នកជំរុញ បើកផ្លូវប្រព័ន្ធអេកូឡូស៊ីសហគ្រាសឌីជីថល

  ២. ការបង្កើតមជ្ឈមណ្ឌលព័ត៌មានសម្រាប់ធុរកិច្ចថ្មី

  ៣. ការលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជនដែលផ្តត់ផ្គង់សេវាប្រឹក្សាយោបល់ និងសេវាដទៃទៀតសម្រាប់ធុរកិច្ចថ្មី

  ៤. ការរៀបចំយុទ្ធនាការរៀបចំទីផ្សារ (Marketing) សម្រាប់ធុរកិច្ចថ្មី

  ៥. ការកសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដើម្បីកាត់បន្ថយបន្ទុកអនុលោមភាព ព្រមទាំងការពារកម្មសិទ្ធិបញ្ញារបស់ធុរកិច្ចថ្មី

  ៦. ការលើកទឹកចិត្តសហអភិវឌ្ឍន៍សិទ្ធិកម្មសិទ្ធិបញ្ញា និងការផ្តផ្គងសិទ្ធិកម្មសិទ្ធិបញ្ញា

  ៧. ការរៀបចំក្របខណ្ឌបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការបង្កើតឱ្យមានបរិស្ថានសាកល្បងបច្ចេកវិទ្យា( Regulatory Sandboxes ) សម្រាប់ធុរកិច្ចឌីជីថលថ្មីៗ

  ៨. ការផ្តល់ការគាំទ្រហិរញ្ញវត្ថុ និងការណែនាំសម្រាប់ការអភិវឌ្ឍបណ្តាញសហគ្រិនភាព

  ៩. ការរៀបចំយុទ្ធសាស្ត្រលើកទឹកចិត្តធុរកិច្ចឌីជីថល ដែលអាចជួយទ្រទ្រង់ដល់សហគ្រាសដទៃទៀត និងអ្នកជំរុញបើកផ្លូវប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី។

គោលដៅទាំង៥នេះនឹងត្រូវអនុវត្តក្រោមយន្តការសម្របសម្រួលដើម្បីធានានូវកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីបុរេសកម្ម ការវិនិយោគ និងការចូលរួមពីអង្គពាក់ព័ន្ធរួមទាំងវិស័យសាធារណៈ វិស័យឯកជនដៃគូអភិវឌ្ឍន៍ និងប្រជាពលរដ្ឋទូទៅ។ ក្របខណ្ឌគោលនយោបាយនេះកំណត់ផងដែរនូវតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ដំណើរការការងារ ការសម្របសម្រួល និងទំនាក់ទំនងក្នុងការអនុវត្តវិធានការ និងផែនការសកម្មភាព។[46]

**១.៣.៣. គោលនយោបាយសេដ្ឋកិច្ចឌីជីថល**

បច្ចុប្បន្នកម្ពុជាកំពុងតែស្ថិតនៅក្នុងយុគសម័យបដិវត្តន៍បច្ចេកវិទ្យា ព័ត៌មាន និងទំនាក់ទំនងដែលហៅថា “ បដិវត្តន៍ឧស្សាហកម្ម ៤.០ ” ដែលជាវិសាលភាពដ៏ធំធេងក្នុងការអភិវឌ្ឍ និងការរស់នៅរបស់មនុស្សក្នុងគ្រប់ទិដ្ឋភាព។ ចំពោះក្នុងទិដ្ឋភាពសេដ្ឋកិច្ចការរីកចម្រើនបែបឌីជីថល បាន និងកំពុងតែបង្កើតគំរូធុរកិច្ចថ្មីៗផ្លាស់ប្តូរដំណើរការផលិតកម្ម ការប្រើប្រាស់និងការចែកចាយទំនិញ និងសេវា ព្រមទាំងផ្លាស់ប្តូរនូវរបៀបធ្វើការជាបណ្តើរៗ សំដៅពង្រីកមូលដ្ឋានផលិតផល និងសេវាឌីជីថល គួបផ្សំនឹងការធ្វើទំនើបកម្មផលិតកម្ម និងការបង្កើនផលិតភាពប្រសិទ្ធភាពសេដ្ឋកិច្ចដែលឆ្លើយតបទៅនឹងការអភិវឌ្ឍនៃបច្ចេកវិទ្យា ដែលយើងហៅថា **សេដ្ឋកិច្ចឌីជីថល**។

- ក្នុងន័យចង្អៀតសេដ្ឋកិច្ចឌីជីថល សំដៅលើទីផ្សារដែលពឹងផ្អែកលើបច្ចេកវិទ្យាឌីជីថលក្នុងការសម្រួលដល់ការដោះដូរទំនិញ និងការផ្តល់សេវាតាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬម្យ៉ាងទៀត

[46] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥ ទំព័រទី២៣

គឺជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផ្អែកលើអ៊ីនធឺណេតនៅក្នុងដំណើរការផលិតកម្មនៃការដោះដូរទំនិញ និងសេវា

➢ ក្នុងន័យទូលំទូលាយសេដ្ឋកិច្ចឌីជីថល សំដៅទៅដល់ប្រព័ន្ធទំនាក់ទំនងសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលពឹងផ្អែកលើការប្រើប្រាស់ប្រព័ន្ធ ICT និងឌីជីថល។[47]

សេដ្ឋកិច្ចឌីជីថលមានលក្ខណៈពិសេស៤ចំណុច ដែលអាចបែងចែកភាពខុសដោយឡែកពីសេដ្ឋកិច្ចបែបប្រពៃណីក្នុងនោះរួមមាន៖

១. ការមិនផ្តោតខ្លាំងលើទីតាំងភូមិសាស្ត្រ

២. តួនាទីសំខាន់របស់ថ្នាល (Platform)

៣. ឥទ្ធិពលនៃបណ្តាញ (Network Effect) និង

៤. ការប្រើប្រាស់ទិន្នន័យធំ (Big Data)។

ក្រៅពីលក្ខខណៈរួមខាងលើសេដ្ឋកិច្ចឌីជីថលត្រូវបានកត់សម្គាល់ថា មាន៤សមាសភាគសំខាន់ៗរួមមាន៖

- ✓ ផលិតផល និងសេវាដែលមានភាពឌីជីថលខ្ពស់ (Highly Digital Goods and Services)៖ មានដូចជាផលិតផល និងសេវាមួយផ្នែកធំដែលត្រូវបានផ្តត់ផ្គង់តាមមធ្យោបាយឌីជីថល រួមមាន សេវាព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក (The Washington Posts, Nikkei Asian Review, Bloomberg, The Diplomat Magazine), ការលក់សុស្វវែរ (Microsoft, Adobe, Zoom) និងការអប់រំតាមប្រព័ន្ធអ៊ីនធឺណេត (Coursera, Udemy, edX) ជាដើម
- ✓ ផលិតផល និង សេវាដែលរួមផ្សំឌីជីថល (Mixed Digital Goods and Services)៖ មានដូចជាការលក់រាយនូវផលិតផលរូបីដូចជា កាសែត, សៀវភៅ, ផ្កា, សម្លៀកបំពាក់, ឧបករណ៍អេឡិចត្រូនិក, ឡាន, បន្ទប់សណ្ឋាគារ, អាហារ និង ភេសជ្ជៈជាដើមតាមប្រព័ន្ធ អេឡិចត្រូនិកដោយគិត ទាំងសេវាកម្មនៃ ការលក់ និង ការផ្សព្វផ្សាយ (Amazon, Alibaba, Little Fashion, Khmer24, Booking.com, Food Panda, Grab)
- ✓ សេវាកម្មឬផលិតកម្មដែលពឹងផ្អែកលើបច្ចេកវិទ្យាព័ត៌មានខ្លាំង (IT-Intensive Services or Goods Production)៖ មានដូចជា សេវាដែលត្រូវបានផ្តត់ផ្គង់ដោយពឹងផ្អែកយ៉ាងខ្លាំងលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឧទាហរណ៍ សេវាគណនេយ្យ (Deloitte, KPMG, PwC) និងសេវារចនាវិស្វកម្មស្មុគស្មាញជាដើម ព្រមទាំងផលិតកម្មនៃផលិតផលរូបីដែលពឹងផ្អែកលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានខ្លាំងក្នុងដំណើរការផលិតកម្ម។ ឧទាហរណ៍៖ ផលិតកម្មដែលប្រើប្រាស់ម៉ាស៊ីនជំនាញ ឬកុំព្យូទ័រក្នុងការផលិត និងការគ្រប់គ្រងក្នុងរោងចក្រ (Apple, Samsung, Honda, General Motors, Airbus)
- ✓ ផ្នែកមួយចំនួនរបស់វិស័យបច្ចេកវិទ្យាព័ត៌មាន ដែលទ្រទ្រង់ផ្នែកទាំងបីខាងលើនៃលើសេដ្ឋកិច្ចឌីជីថល (the segments of the IT industry that support these three segments of digital economy) មានដូចជា ផលិតផល និងសេវានៅក្នុងវិស័យ ICT ដែលទ្រទ្រង់ដោយផ្ទាល់ដល់សមាសភាពទាំងបីខាងលើនៃសេដ្ឋកិច្ចឌីជីថលរួមមាន បណ្តាញកុំព្យូទ័រ (AT&T, EZECOM, Digi, Opennet)

[47] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥ ទំព័រទី៩

ផលិតកម្ម កុំព្យូទ័រ (Dell, Apple, Samsung, Microsoft, Huawei) និងសហគ្រាសផ្តល់សេវាប្រឹក្សាយោបល់ផ្នែកបច្ចេកវិទ្យាព័ត៌មាន(IBM Global Services) ជាដើម។

ក្នុងនោះដែរដើម្បីសម្រេចនូវគោលនយោបាយនេះកម្ពុជាមានសក្តានុពលទៅលើវិស័យសេដ្ឋកិច្ចឌីជីថលនេះឱ្យប្រកបដោយប្រសិទ្ធភាព និងគុណភាពក្នុងការអភិវឌ្ឍផងដែរ។ ដែលសក្តានុពលសំខាន់ៗទាំងនោះរួមមាន៖

**ការតភ្ជាប់នឹងខ្សែច្រវាក់ផលិតកម្ម និងខ្សែច្រវាក់តម្លៃតំបន់ និងសកល៖** ដែលផ្តោតទៅលើផលិតកម្មនៅក្នុងស្រុកនឹងស្ថិតក្នុងវិសាលភាពទូលំទូលាយគ្មានព្រំដែននៃបច្ចេកវិទ្យាឌីជីថល និងសម្របបានតាមនិន្នាការសកលភាវូបនីយកម្មតាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃតំបន់ និងសកល។ ជាពិសេសការតភ្ជាប់សហគ្រាសធុនតូច និងមធ្យម ( SMEs ) ទៅក្នុងខ្សែច្រវាក់ផលិតកម្មតំបន់ និងសកលត្រូវបានរំពឹងថានឹងក្លាយជាមូលដ្ឋានដ៏រឹងមាំក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច។

**ការជំរុញសកម្មភាពពាណិជ្ជកម្ម និងធុរកិច្ច៖** សេដ្ឋកិច្ចឌីជីថលបានធ្វើឱ្យមានគូប្រកួតប្រជែងយ៉ាងធំទូលាយ ហេតុនេះហើយទើបជាកត្តា ដែលជំរុញឱ្យមានសកម្មភាពពាណិជ្ជកម្មកាន់តែមានភាពរីកដុះដាលពីមួយថ្ងៃទៅមួយថ្ងៃ។ ការផ្លាស់ប្តូរដ៏សំខាន់នៅលើផ្នែកតម្រូវការកំពុងតែធ្វើឱ្យអាជីវកម្មនៅកម្ពុជាមានការរីកលូតលាស់ឡើងផងដែរ រួមទាំងបង្កើនតម្លាភាព ការចូលរួមពាក់ព័ន្ធពីអតិថិជន និងគំរូនៃឥរិយាបថអតិថិជនថ្មី ហើយបង្កើតឡើងកាន់តែខ្លាំងឡើងៗលើដំណើរការនៃសកម្មភាពពាណិជ្ជកម្ម ធុរកិច្ចតាមបណ្តាញចល័ត និងទិន្នន័យតាមប្រព័ន្ធអ៊ីនធឺណេតដែលបង្កឱ្យក្រុមហ៊ុន សហគ្រាសធំ ឬតូចចូលរួមគិតគូរធ្វើយ៉ាងណាឱ្យអាជីវកម្មតាមប្រព័ន្ធឌីជីថលមានការរីកចម្រើនសម្របតាមវិធីដែលពួកគេបានរចនាឡើងក្នុងផ្នែកទីផ្សារ និងមានការផ្តល់នូវផលិតផលដែលមានស្រាប់ ផលិតផលថ្មី និងការផ្តល់សេវាទៅកាន់អតិថិជនប្រកបដោយភាពប៉ិនប្រសប់ផងដែរ។ ផ្តោតលើប្រសិទ្ធភាពនៃប្រតិបត្តិការនៃការទិញ-លក់ទំនិញ និងសេវា ជាពិសេសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈការទូទាត់កាន់តែងាយស្រួល រហ័សគួបផ្សំនឹងការដឹកជញ្ជូនលឿន និងមានតម្លៃសមរម្យនឹងត្រូវបានលើកកម្ពស់។ បន្ថែមលើនេះការគ្រប់គ្រងអាជីវកម្ម និងផលិតកម្មនឹងកាន់តែមានប្រសិទ្ធភាពដោយសារការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលបូកផ្សំនឹងកម្លាំងពលកម្មប្រកបដោយជំនាញ។ ជាមួយគ្នានេះការរៀបចំពិព័រណ៍តាមប្រព័ន្ធអេឡិចត្រូនិកការរៀបចំថ្នាលសម្រាប់ដាក់លក់ ផ្សព្វផ្សាយផលិតផលដើម្បីជំរុញការនាំចេញ និងការផ្សារភ្ជាប់ទីផ្សារឱ្យបានដល់អតិថិជនចុងក្រោយក៏អាចប្រព្រឹត្តទៅបានតាមបច្ចេកវិទ្យាឌីជីថល។

**ការបង្កើតការងារ ជំនាញ និងការវិនិយោគ៖** សព្វថ្ងៃនេះសេដ្ឋកិច្ច គឺអាស្រ័យទៅតាមតម្រូវការ ពោលគឺសេដ្ឋកិច្ចកំពុងតែផ្លាស់ប្តូរមូលដ្ឋានទំនាក់ទំនងរបស់យើងជាមួយ និងការងារ ព្រមទាំងរបៀបនៃការរៀបចំសង្គមបែបថ្មីផងដែរ។ ជាទូទៅនិយោជទាំងឡាយគឺសុទ្ធតែប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការគ្រប់គ្រង និងដំណើរការក្រុមហ៊ុនរបស់ពួកគេឱ្យមានភាពទំនើប និងងាយស្រួលក្នុងការគ្រប់គ្រងទិន្នន័យការងារ។ ដោយសារកត្តា ការប្រើប្រាស់ឌីជីថលក្នុងការបំពេញការងារនេះហើយ ទើបមានការបង្កើតឱ្យមានតម្រូវការបុគ្គលិក និងកម្រិតជំនាញត្រូវបានរំពឹងថានឹងកើនឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារតាមរយៈយន្តការរដ្ឋ និងឯកជន។ ជាមួយគ្នានេះការលើកកម្ពស់សហគ្រិនភាព និងនវានុវត្តន៍នឹងរួមចំណែកក្នុងការបង្កើតធុរកិច្ចថ្មី និងការទាក់ទាញការវិនិយោគនៅក្នុងស្រុក និងក្រៅស្រុកនៅក្នុងវិស័យ ICT។ មិនតែប៉ុណ្ណោះសម្រាប់មនុស្សដែលធ្វើការតាមបែបឌីជីថល

នេះគឺទទួលបាននូវគុណសម្បត្តិចម្បង ដែលបានរស់នៅក្នុងសេរីភាពដោយការធ្វើការពីចម្ងាយតាមរយៈអ៊ីនធឺណេត ដោយមិនចាំបាច់ក្នុងការទៅធ្វើការដល់ទីកន្លែង ម្យ៉ាងទៀតវាអាចជាបរិបទថ្មីបើធៀបនឹងការប្រកបមុខរបរ ឬការបំពេញការងារតាមបែបប្រពៃណី គឺមានភាពខុសគ្នាជាច្រើនរវាងបច្ចុប្បន្នកាល និងអតីតកាល។ លើសពីនេះទៅទៀត ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មលើកទីបួន គឺជាកត្តាលីករក្នុងការបង្កើននូវកម្លាំងពលកម្ម ជំនាញ និងសមត្ថភាពជាច្រើននៅក្នុងវិជ្ជាជីវៈ ឬវិស័យនៃជំនាញឯកទេសទៅតាមការផ្លាស់ប្តូរនៃបច្ចេកវិទ្យានានាដែលមនុស្សជំនាន់ថ្មីត្រូវរៀនសូត្រ។ ម្យ៉ាងទៀតអ្នកធ្វើការងារក្នុងប្រទេសកំពុងអភិវឌ្ឍន៍ក៏ជាប្រភពធនធានមនុស្សមួយនៅកម្រិតជំនាញជាច្រើនដែលអាចបំពេញតម្រូវការទីផ្សារការងារដែលខុសពីប្រទេសអភិវឌ្ឍន៍។ ការផ្លាស់ប្តូរទេពកោសល្យ គឺជាអ្នកនាំឱ្យមានគំនិតច្នៃប្រឌិត នាំនុវត្តន៍ឧស្សាហកម្ម និងប្រសិទ្ធភាពការងារ ហើយការទប់ស្កាត់ពលករចំណាកស្រុកឱ្យចូលទៅក្នុងទីផ្សារក្នុងស្រុកវិញ។

**ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ៖** ចំពោះវិស័យសាធារណៈ ការផ្តល់សេវាសាធារណៈត្រូវបានប្រព្រឹត្តទៅយ៉ាងរលូន មានភាពងាយស្រួល ព្រមទាំងមានប្រសិទ្ធភាព និងតម្លាភាពកាន់តែខ្ពស់តាមរយៈការទទួលយកផ្នត់គំនិតឌីជីថល និងការលើកកម្ពស់សមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ និន្នាការនេះក៏បានបង្កើនឱកាសសម្រាប់ការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធនៅក្នុងវិស័យប្រពៃណី រួមទាំងវិស័យសេដ្ឋកិច្ច សង្គម និងសន្តិសុខ។[48]

### ១.៣.៤. គោលនយោបាយសង្គមឌីជីថល

ទន្ទឹមនឹងការគាំទ្រដល់ការអភិវឌ្ឍ និងការជំរុញកំណើនសេដ្ឋកិច្ច វឌ្ឍនភាពសង្គមកម្ពុជាអាចសម្រេចបានតាមរយៈការរៀបចំនូវសង្គមឌីជីថលមួយ ដែលមានការចូលរួមពីកោសិកាសង្គមទាំងអស់ ពោលគឺបុគ្គលគ្រប់រូបអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការប្រាស្រ័យទាក់ទងរវាងបុគ្គល ក្រុមគ្រួសារ និងសហគមន៍ ការចូលរួមចំណែកបម្រើឱ្យសកម្មភាពសង្គម និងការទទួលបានសេវាសាធារណៈដោយគ្មានការរើសអើង។ ក្នុងនោះដែរដើម្បីសម្រេចបាននូវគោលនយោបាយនេះកម្ពុជាមានសក្តានុពលទៅលើវិស័យសង្គមឌីជីថលនេះឱ្យប្រកបដោយប្រសិទ្ធភាព និងគុណភាពក្នុងការអភិវឌ្ឍផងដែរ។

ក្នុងគោលនយោបាយខាងលើនេះក៏មានបង្កប់នូវសក្តានុពលសំខាន់ៗទាំងនោះរួមមាន៖

**ការទទួលបានសេវាសង្គមកាន់តែងាយស្រួល និងភាពទូលំទូលាយតាមរយៈថ្នាលបច្ចេកវិទ្យាឌីជីថល៖** កោសិកាសង្គមបាន និងកំពុងប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថលដើម្បីទទួលបានសេវាសាធារណៈទាញយកព័ត៌មាន និងទិន្នន័យ សិក្សារៀនសូត្រ និបង្រៀនសរសេរអត្ថបទចែករំលែកចំណេះដឹង ស្វែងរកការងារ និងដៃគូជីវិតបង្ហាញពីទេពកោសល្យផ្ទាល់ខ្លួន និងកសាងបណ្តាញសម្រាប់ទំនាក់ទំនងទាំងនៅក្នុងប្រទេស និងឆ្លងប្រទេស។

**ការពង្រឹងទំនាក់ទំនង និងការចែករំលែកក្នុងសង្គមកាន់តែស៊ីជម្រៅ៖** បុគ្គលម្នាក់ៗចាប់ផ្តើមមានទំនាក់ទំនង ការផ្សារភ្ជាប់គ្នាទៅវិញទៅមក និងអន្តរសកម្មកាន់តែស្និទ្ធស្នាលបើកចំហដោយពុំខ្វល់ខ្វាយពីភាពខុសគ្នានៃឋានៈសង្គម ភូមិសាស្ត្រ ភេទ សាសនា និងជាតិសាសន៍ឡើយ។ ក្នុងបរិការណ៍នេះ ឧបករណ៍ ឆ្លាត ជាពិសេសឧបករណ៍ចល័ត គួបផ្សំនឹងវិសាលភាពនៃការតភ្ជាប់បណ្តាញ និងសេវាទូរគមនាគមន៍ក្នុងតំបន់នីមួយៗ គឺជាកត្តាកំណត់ការភ្ជាប់បណ្តាញសង្គមឌីជីថល ជាពិសេសការកសាងសង្គមឌីជីថលផ្ទាល់ ដើម្បីទាញយក

[48] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥ ទំព័រទី៦

អត្ថប្រយោជន៍ពីសកលភាវូបនីយកម្មឌីជីថលទៅតាមធនធានដែលមាន។ សម្រាប់កម្ពុជាចំនួននៃការតភ្ជាប់នូវអ៊ីនធឺណេតតាមឧបករណ៍ចល័ត ជាពិសេសទូរស័ព្ទចល័តមានរហូតដល់ ១២៨% នៃចំនួនប្រជាជនសរុបដែលភាគច្រើនជាអ្នកប្រើប្រាស់ថ្នាល ឬប្រព័ន្ធសង្គម។ តួលេខនេះបានបង្ហាញពីការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជាកាន់តែសកម្ម និងទូលំទូលាយក្នុងសង្គមឌីជីថលដោយបានប្រែក្លាយជាសកម្មភាពនៃជីវភាពប្រចាំថ្ងៃ ។

**ការទទួលបានការកម្សាន្ត និងព័ត៌មានពីសង្គមតាមតម្រូវការ៖** សេវាឌីជីថលផ្សេងៗដូចជា និន្នាការនៃការភ្ជាប់ទូរទស្សន៍ឌីជីថល ការលេងហ្គេមវីដេអូ និងការបំពេញតម្រូវការមូលដ្ឋានដទៃទៀតតាមមធ្យោបាយឌីជីថលត្រូវបានសង្កេតឃើញថាបាន និងកំពុងចាប់ផ្តើមជ្រៀតចូលសង្គមបន្តិចម្តងៗ ជាពិសេសក្នុងបរិការណ៍នៃការរីករាលដាលនៃជម្ងឺកូវីដ-១៩។ ក្នុងពេលបច្ចុប្បន្នរវជនកម្ពុជាមានទំនោរខ្ពស់ទៅរកការប្រើប្រាស់ បច្ចេកវិទ្យា ទូរស័ព្ទចល័ត និងសេវាអ៊ីនធឺណេតដើម្បីសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃប៉ុន្តែផ្តោតលើគោលដៅបំពេញតម្រូវការកម្សាន្ត។[49]

[49] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ២០២១-២០៣៥ ទំព័រទី៧ និងទី៨

# ជំពូកទី២
# ស្ថានភាពរដ្ឋបាលសាធារណៈ
# នៅកម្ពុជានាពេលបច្ចុប្បន្ន

# ជំពូកទី២

# ស្ថានភាពរដ្ឋបាលសាធារណៈនៅកម្ពុជានាពេលបច្ចុប្បន្ន

## ២.១. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋាភិបាលឌីជីថលនាពេលបច្ចុប្បន្ន

រដ្ឋាភិបាលកម្ពុជា កំពុងអភិវឌ្ឍខ្លួនឱ្យក្លាយទៅជារដ្ឋាភិបាលឌីជីថលមួយ ដើម្បីធ្វើការគ្រប់គ្រងសង្គមតាមប្រព័ន្ធបច្ចេកវិទ្យាកុំព្យូទ័រទំនើបៗធ្វើឱ្យមានតម្រូវការធនធានមនុស្សដែលមានជំនាញច្បាស់លាស់ខណៈពេលដែលបច្ចុប្បន្នប្រទេសកម្ពុជាយើង សម្បូរទៅដោយសាលារៀនគ្រប់កម្រិត និងផ្តល់ភាពងាយស្រួលក្នុងការទទួលយកចំណេះដឹងដើម្បីទៅថ្ងៃមុខជាធនធានបន្តទៅលើវិស័យការងារជាច្រើនទៀត។[50] ផែនការមេស្តីពីបច្ចេកវិទ្យាជាតិកម្ពុជា ឆ្នាំ២០១៤-២០២០ ត្រូវបានគេផ្សព្វផ្សាយកាលពីខែតុលា ឆ្នាំ២០១៤ ដោយក្រសួងផែនការ និងមានការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េផងដែរ។ ការបង្កើតផ្នែកថ្មីឡើងនីមួយៗដូចជា ឧស្សាហកម្មចម្បងៗ គឺត្រូវយកចិត្តទុកដាក់ដ៏សំខាន់មួយ ជាពិសេសនៅក្នុងវិស័យកសិកម្ម និងរួមជាមួយវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។ ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងនេះក្តីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការចាប់យកវិស័យឌីជីថលនៅប្រឈមច្រើនរួមមានភាពកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានគាំទ្រដល់វិស័យឌីជីថល ភាពជឿទុកចិត្ត ចំណេះដឹង ជំនាញ និងភាពជាអ្នកដឹកនាំឌីជីថល។ មួយវិញទៀត ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចឌីជីថលនៅកម្ពុជាកំពុងស្ថិតនៅដំណាក់កាលចាប់ផ្តើម និងចូលរួមបានតិចតួចក្នុងខ្សែច្រវាក់តម្លៃតំបន់ និងសកលនៅឡើយ។ ទន្ទឹមនេះរដ្ឋាភិបាលឌីជីថលដែលមានតួនាទីស្នូល និងដឹកមុខក្នុងដំណើរការបរិវត្តកម្មឌីជីថលក៏ហាក់មិនទាន់រៀបចំខ្លួនឱ្យបានពេញលេញនិងស៊ីជម្រៅ។ ករណីនេះបង្ហាញអំពីភាពចាំបាច់ក្នុងការកំណត់ ការរៀបចំ និងការដាក់ចេញនូវអាទិភាពជាមូលដ្ឋានដែលមានភាពប្រទាក់ក្រឡា និងភាពឆ្លើយតបគ្នាទៅវិញទៅមក សំដៅលើការរៀបចំខ្លួនចាប់យកកាលានុវត្តភាពនៅក្នុងវិស័យឌីជីថលបានឆាប់រហ័ស។[51]

តាមស្ថានភាពនាបច្ចុប្បន្នរបស់យើងនៅអំឡុងពេលការកកើតឡើងនៃជម្ងឺរីករាលដាលអំពី កូវីដ-១៩ ធ្វើឱ្យប្រទេសកម្ពុជាមិនអាចចេញចូល ឬធ្វើការប្រាស្រ័យទាក់ទងផ្ទាល់ ឬជួបទល់មុខបានឡើយ។ មិនថាត្រឹមតែប្រទេសយើងប៉ុណ្ណោះទេប្រទេសជិតខាង និងប្រទេសឆ្ងាយទាំងឡាយបានជួបនៅឧបសគ្គដូចៗគ្នាក្នុងការរៀបចំផែនការសម្រាប់ការធ្វើដំណើរមិនថាតែការណាត់ជួប ការធ្វើដំណើរផ្លាស់ប្តូរពីកន្លែងមួយទៅទីកន្លែងមួយទៀតដោយងាយស្រួលដូចពីមុនការផ្ទុះនៃវីរុស។ ដើម្បីជាជំនួយដល់ការពិភាក្សាគម្រោងការនានាបន្តគេអាចជួបតាមរយៈប្រព័ន្ធអេឡិចត្រូនិកតាមប្រព័ន្ធបច្ចេកវិទ្យាដោយជួបតាមរយៈឧបករណ៍កម្មវិធីផ្សេងៗដូចជា Google Meet, Zoom, Hangouts, ដែលអាចប្រើប្រាស់ជាមួយការជួប ឬនិយាយពិភាក្សាតាមរយៈ Email, Telegram និងVideo Callជាដើម។ ប្រសិនយោងតាមផែនការមេគ្រប់គ្រងលើវិស័យបច្ចេកវិទ្យា គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សង្គមប្រទេសជាតិយើង។ កាលពីឆ្នាំ២០១៤ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុបានមានប្រសាសន៍ថាដំណើរការធ្វើនូវសេចក្តីព្រាងថវិការបស់ប្រទេសកម្ពុជា គឺមានលក្ខណៈស្មុគស្មាញខ្លាំងដោយសារការកង្វះនូវបច្ចេកវិទ្យាដែលធ្វើ

[50] គេហទំព័រ https://opendevelopmentcambodia.net/km/topics/science-and-technology/ ដកស្រង់ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០២១

[51] គេហទំព័រ https://www.ocm.gov.kh/wp- ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១

ឱ្យក្រសួងមិនមានការអនុញ្ញាតរបស់លោកមានដំណើរការបានរហ័សអំពីការចែករំលែកព័ត៌មានដល់សាធារណជន។[52] អាស្រ័យហេតុនេះទើបមានការផ្តោតសំខាន់ទៅលើធនធានមនុស្សក្នុងការជួយបណ្តុះបណ្តាល និងលើកកម្ពស់អក្ខរកម្មឌីជីថល( រួមទាំងការរាប់បញ្ចូលទៅតាមអ្នករស់នៅជនបទ )។ បន្ទាប់មកលទ្ធភាពក្នុងការប្រើប្រាស់កុំព្យូទ័ររបស់មន្ត្រីរាជរដ្ឋាភិបាលបានពង្រឹងបន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធខាងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណេត។ ចំណែកគោលដៅបន្តរបស់រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំផែនការត្រូវធ្វើយ៉ាងណាឱ្យប្រទេសកម្ពុជា អាចមានការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេតកើនបាន ៧០ភាគរយ នៅឆ្នាំ២០២០។

តាមរយៈប្រព័ន្ធសន្និសីទក្រសួងមហាផ្ទៃបើកកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីពិភាក្សា និងប្រមូលធាតុចូលលើសេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២១-២០៣០ដែលដឹកនាំដោយសហប្រធានពីររូប គឺរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងក្រុមការងារពាក់ព័ន្ធ ក្រសួងមហាផ្ទៃ ព្រមទាំងមន្ត្រីជំនាញមួយចំនួនទៀតផងដែរ។ ចំពោះកិច្ចប្រជុំសេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២១-២០៣០ ក្នុងគោលបំណងលើកកម្ពស់គុណភាពជីវិត និងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈកាន់តែប្រសើរដោយបានដាក់ចេញនូវវិធានការគោលនយោបាយអាទិភាពក្រោមក្របខណ្ឌយុទ្ធសាស្ត្រចំនួន៥ រួមមាន៖

ទី១. បទដ្ឋានគតិយុត្តរដ្ឋាភិបាលឌីជីថល

ទី២. ហេដ្ឋារចនាសម្ព័ន្ធឌីជីថល

ទី៣. សេវារដ្ឋាភិបាលឌីជីថល

ទី៤. ការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល និង

ទី៥. ភាពជាដៃគូររវាងរដ្ឋ និងឯកជន។

ជាមួយគ្នានេះដែរ ចក្ខុវិស័យនេះនឹងប្រែក្លាយព្រះរាជាណាចក្រកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ ឆ្នាំ២០៥០ រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភាពបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ដោយសង្កត់ធ្ងន់ទៅលើការធ្វើ "ពិពិធកម្មសេដ្ឋកិច្ច" ដែលជាយុទ្ធសាស្ត្រស្នូល។ ការធ្វើពិពិធកម្មសេដ្ឋកិច្ចទទួលបានជោគជ័យត្រូវដើរស្របទៅនឹងនិន្នាការពិភពលោក ដើម្បីទទួលបាន "ការចូលរួមវិនិយោគពីវិស័យឯកជន" ទាំងក្នុង និងក្រៅប្រទេស។

គួរបញ្ជាក់ថានាពេលបច្ចុប្បន្នការវិវត្តនៃរដ្ឋាភិបាលឌីជីថលកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយដោយហេតុថា ឌីជីថលលូបនីយកម្មតាមក្រសួង-ស្ថាប័នមិនមានការប្រមូលផ្តុំភាគច្រើនផ្តោតសំខាន់លើការអភិវឌ្ឍកម្មវិធីសម្រាប់សម្រួលដល់ការងារដោយគ្មានយុទ្ធសាស្ត្រសម្រាប់ការផ្លាស់ប្តូរទៅឌីជីថលរយៈពេលវែង ការគិតគូរជាសំខាន់ពីប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដែលអាចកើតចេញពីទិន្នន័យប្រមូលផ្តុំបាន។[53]

---

[52] គេហទំព័រ https://www.trc.gov.kh/summary-on-cambodian-ict-masterplan-2020/ ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១

[53] គេហទំព័រ https://www.interior.gov.kh/news/detail/2347 ដកស្រង់ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០២១

### ២.១.១. របៀបរបបនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅតាមក្រសួង-ស្ថាប័ន

ដំណើរការប្រព្រឹត្តនៃក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធនាបច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងតែអនុវត្ត និងបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងនីតិកាលទី៦នៃរដ្ឋសភាដោយឈរលើក្របខណ្ឌគោលនយោបាយ និងបានផ្តល់ការឆ្លើយតបដល់ការធ្វើបដិវត្តន៍ឧស្សាហកម្ម៤.០ដើម្បីទទួលបានការរីកចម្រើន និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងនោះដែរ មានការសហការពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និងបានអនុវត្តន៍ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ទើបនាំឱ្យមានការផ្តល់សេវាសាធារណៈតាមបែបឌីជីថលនេះឡើង ដូចជាការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលត្រូវបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានការចូលរួមសហការជាមួយនឹងក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មិនតែប៉ុណ្ណោះនៅមានការចូលរួមសហការដោយក្រសួងមួយចំនួនទៀតនៅថ្ងៃអនាគត។

ខាងក្រោមនេះគឺជារបៀបនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានៅតាមក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនីមួយៗដូចតទៅៈ

**ក. ក្រសួងពាណិជ្ជកម្ម**

- **ការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន**

ការចុះបញ្ជីអាជិវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលធ្វើតាមរយៈ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបអនឡាញទាំងស្រុង គឺជានីតិវិធីថ្មីក្នុងការបង្កើតអាជីវកម្មរបស់សហគ្រាតូច ធំ រូបវន្តបុគ្គល និងនិតិបុគ្គលដែលមានលក្ខណៈបង្រួបបង្រួមក្នុងការបង្កើតអត្តសញ្ញាណផ្ទាល់ខ្លួនសម្រាប់អាជីវកម្មជៀសវាងការបង្កើតអាជីវកម្មខុសច្បាប់ដែលត្រូវទទួលការផាកពិន័យរហូតឈានទៅដល់ការផ្អាកដំណើរការ ឬបិទទ្វារអាជីវកម្មដូច្នេះនឹងនេះការចុះបញ្ជីអាជីវកម្មស្របតាមនីតិវិធីរបស់រដ្ឋាភិបាលគឺទទួលបានការគាំពារតាមផ្លូវច្បាប់ មិនតែប៉ុណ្ណោះអ្នកដែលបានចុះបញ្ជីអាជីវកម្មគឺទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀតពីបេឡាសន្តិសុខសង្គម។ ចំពោះការចុះបញ្ជីអាជីវកម្មតាមថ្នាលឌីជីថលដែលជាបរិបទថ្មីនេះអាចធ្វើការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសក្នុងពេលតែមួយបាននៅលើថ្នាលបច្ចេកវិទ្យាព័ត៌មានតែមួយ ដោយឡែកក្នុងដំណាក់កាលដំបូងនេះការចុះបញ្ជី ឬសុំការអនុញ្ញាតពីក្រសួង-ស្ថាប័នដទៃក្រៅពីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលតម្រូវឱ្យអ្នកធ្វើតាមនីតិវិធីដដែលរបស់ក្រសួង-ស្ថាប័នសាមី។ តាមរយៈដំណើរការចុះបញ្ជីថ្មីនេះការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលវេលារង់ចាំយ៉ាងយូរ៨ថ្ងៃ នៃថ្ងៃធ្វើការលុបបំបាត់ការបំពេញឯកសារដដែលៗ ចំណាយថវិកាតិចជាងមុនច្រើនទូទាត់ថ្លៃសេវាទាំងអស់ក្នុងការចុះបញ្ជីអាជីវកម្មក្នុងពេលតែមួយតាមអនឡាញទទួលបានអាជ្ញាបណ្ណ និងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថលតាមរយៈប្រព័ន្ធខណៈពេលដែលតម្លៃសេវាថោកជាងមុន។

បច្ចុប្បន្នធុរជនត្រូវប្រើប្រាស់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ដើម្បីអាចបង្កើតគណនីនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។[54] ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការចុះបញ្ជីអាជីវកម្មយន្ត

[54] សេចក្តីជូនដំណឹងរបស់ធនាគារជាតិ លេខ ធ៧.០២០.៥៦៩ ស.ជ.ណ ចុះនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ស្តីពីយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ការថ្មីត្រូវធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមមួយ ដែលត្រូវបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ហើយវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ផ្សេងៗត្រូវចេញជាទម្រង់ឌីជីថល ដែលធុរជនអាចបោះពុម្ព (Print) ដោយ ខ្លួនឯង និងយកទៅប្រើប្រាស់ជាផ្លូវការបាន ដោយមិនបាច់តម្រូវឱ្យយកឯកសារដែលមានត្រាច្បាប់ដើមដូចមុនទៀតទេ។ វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ផ្សេងៗក្នុងទម្រង់ឌីជីថលអាចបញ្ជាក់ពីភាពត្រឹមត្រូវបានតាមរយៈលេខសម្គាល់សហគ្រាស ដែលអាចផ្ទៀងផ្ទាត់បានលើគេហទំព័រចុះបញ្ជីពាណិជ្ជកម្ម។

អាស្រ័យហេតុនេះគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវចាប់ផ្តើមទទួលយកឯកសារ ដែលបោះពុម្ព (Print) ចេញពីឯកសារទម្រង់ឌីជីថលស្របតាមយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។[55]

❖ **នីតិវិធីនៃការចុះបញ្ជីអាជីវកម្ម**

បុគ្គលស្នើសុំត្រូវបំពេញព័ត៌មាននិងបញ្ចូលឯកសារភ្ជាប់តាមលក្ខខណ្ឌតម្រូវទាំងអស់ក្នុងទម្រង់អេឡិចត្រូនិកដែលកំណត់ក្នុងគេហទំព័រចុះបញ្ជី https://www.registrationservices.gov.kh ។

បុគ្គលស្នើសុំអាចផ្ទេរសិទ្ធិឱ្យអ្នកតំណាងចុះបញ្ជីដើម្បីធ្វើការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះក្នុងនាមបុគ្គលស្នើសុំដោយមានភ្ជាប់មកជាមួយនូវឯកសារផ្ទេរសិទ្ធិ និងឯកសារពាក់ព័ន្ធស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។[56] ព័ត៌មាននិងឯកសារភ្ជាប់ស្នើសុំចុះបញ្ជីអាជីវកម្ម ដែលបានបំពេញដោយបុគ្គលស្នើសុំសម្រាប់តម្កល់តាមក្រសួង-ស្ថាប័នមានសមត្ថកិច្ច ជាទម្រង់អេឡិចត្រូនិកត្រូវបញ្ជូនដល់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចដូចមានចែងក្នុងជំពូកទី៣នៃអនុក្រឹត្យនេះតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange-CamDX) សម្រាប់ជាកម្មវត្ថុនៃការពិនិត្យ និងសម្រេចផ្តល់ការអនុញ្ញាតការចុះបញ្ជីអាជីវកម្ម។ ក្រសួង-ស្ថាប័នមានសមត្ថកិច្ចត្រូវពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាន និងឯកសារភ្ជាប់តាមសមត្ថកិច្ចពាក់ព័ន្ធរបស់ក្រសួង-ស្ថាប័ននីមួយៗក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះដោយអនុលោមតាមអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។[57]

ក្នុងករណីព័ត៌មាន និងឯកសារភ្ជាប់មិនត្រឹមត្រូវ ឬ និងមិនគ្រប់គ្រាន់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចត្រូវជូនដំណឹងដល់បុគ្គលស្នើសុំដើម្បីធ្វើការកែតម្រូវ ឬបំពេញបន្ថែម។ ក្រសួង-ស្ថាប័នមានសមត្ថកិច្ចត្រូវផ្តល់វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ ក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យ នេះ ដោយគិតចាប់ពីថ្ងៃដែលបុគ្គលស្នើសុំបានកែតម្រូវ ឬបំពេញបន្ថែម។

កម្រៃសេវាពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្មត្រូវកំណត់ ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ កម្រៃសេវានេះមិនត្រូវបានប្រគល់ជូនបុគ្គលស្នើសុំឡើយទោះបីជាមានការបដិសេធលើការស្នើសុំក៏ដោយ។[58]

---

[55] អនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃពុធ ០៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០

[56] មាត្រា៥ នៃអនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពីការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ចុះនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០

[57] មាត្រា៦ នៃអនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពីការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ចុះនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០

[58] មាត្រា៧ នៃអនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពីការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ចុះនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០

❖ **ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិក**

ពេលវេលា និងទីកន្លែងនៃការបញ្ជូនចេញ និងការទទួលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកៈ

១. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលៈ

ក. ព័ត៌មាននោះបានចាកចេញពីប្រព័ន្ធព័ត៌មាន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើ ឬរបស់ដែលផ្ញើជំនួសក្នុងនាមអ្នកផ្ញើ

ខ. ក្នុងករណីដែលព័ត៌មាននោះត្រូវបានបញ្ជូនតែមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើ ឬរបស់ភាគីដែលផ្ញើជំនួសព័ត៌មានចាត់ទុកថាបានបញ្ជូនចេញនៅពេលដែលព័ត៌មាននោះត្រូវបានទទួលក្នុងពេលណាមួយ។

២. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានសន្មតថា បានបញ្ជូនចេញពីទីតាំងជីវកម្មរបស់អ្នកផ្ញើ ទោះបីព័ត៌មាននោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ

៣. ពេលវេលានៃការទទួលព័ត៌មានគឺដែលព័ត៌មាននោះអាចទាញយកបានដោយអ្នកទទួលនៅក្នុងអាសយដ្ឋានអេឡិចត្រូនិក[59] ដែលអ្នកទទួលបានបញ្ជាក់ជាមុន។ ព័ត៌មានត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល

៤. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកមិនត្រូវបានផ្តល់ដោយអ្នកទទួល នោះពេលវេលាទទួលបានព័ត៌មាន គឺជាពេលវេលាដែលអ្នកទទួលបានដឹងពីការផ្ញើចេញ និងអាចទាញយកព័ត៌មាននោះតាមរយៈអាសយដ្ឋានអេឡិចត្រូនិកណាមួយ ហើយសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល

៥. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្តល់ដោយអ្នកទទួល ព័ត៌មានក្នុងទំនាក់ទំនង អេឡិចត្រូនិកត្រូវបានសន្មតថាបានទទួលនៅពេលព័ត៌មាននោះបានទៅដល់ អាសយដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល ហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។[60]

សំណើបង្កើតកិច្ចសន្យារាល់ការស្នើសុំចុះកិច្ចសន្យាតាមរយៈទំនាក់ទំនងអេឡិចត្រូនិកដែលមិនសំដៅតែដល់បុគ្គលណាមួយជាក់លាក់ផ្សេងទៀតត្រូវបានចាត់ទុកថា ជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។ ការស្នើសុំចុះកិច្ចសន្យានោះនឹងត្រូវចាត់ទុកថាជាសំណើបង្កើតកិច្ចសន្យា ប្រសិនបើការស្នើសុំនោះបានបង្ហាញឱ្យឃើញច្បាស់អំពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ចនៅពេល មានស្វីការពីភាគីម្ខាងទៀត។[61]

ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តសម្រាប់បង្កើតកិច្ចសន្យា គឺជាកិច្ចសន្យាដែលបង្កើតឡើងដោយអន្តរកម្មរវាងប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយឬជាមួយប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបានបដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យានោះឡើយ

[59] អាសយដ្ឋានអេឡិចត្រូនិក (Electronic Address) សំដៅដល់លេខ ឬអាសយដ្ឋានប្រើប្រាស់សម្រាប់ផ្ញើ ឬទទួលការជូនដំណឹងឯកសារ ព័ត៌មាន ឬទំនាក់ទំនងតាមមធ្យោបាយអេឡិចត្រូនិក។

[60] មាត្រា១៥ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[61] មាត្រា១៦ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

ដោយសម្អាងលើហេតុផលអវត្តមាន នៃរូបវន្តបុគ្គលក្នុងការពិនិត្យឬក្នុងការចូលធ្វើសកម្មភាពដោយផ្ទាល់ក្នុងប្រព័ន្ធស្វ័យប្រវត្តិ[62] ឬក្នុងការបង្កើតកិច្ចសន្យា។[63]

កំហុសឆ្គងនៃការបញ្ចូលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកនៅពេល ដែលបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យប្រវត្តរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តនេះមិនផ្តល់ឱកាសឱ្យបុគ្គលនោះធ្វើការនោះក៏ប្រើនូវព័ត៌មានដែលខុសបុគ្គលឬភាគី ដែលជំនួសមុខឱ្យបុគ្គលដែលបញ្ចូលព័ត៌មាននោះមានការកែតម្រូវ ឬដកចេញនូវព័ត៌មានដែលខុសនោះបានក្នុងករណី៖

១. បុគ្គលនោះបានជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើងឱ្យបានជាប់បំផុត ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក និង

២. បុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយដោយសារការបញ្ចូលព័ត៌មានខុសនេះមុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ហើយមិនបង្កការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត ឬតតិយជនណាមួយ។[64]

❖ **សកម្មភាព និងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក**

**ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ**

១. ក្រសួងឬស្ថាប័នរដ្ឋនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាព និងប្រតិបត្តិការដូចខាងក្រោម៖

ក. ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើតឬរក្សាទុកឯកសារ

ខ. ការចេញអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត

គ. ការកំណត់មធ្យោបាយនិងរបៀបក្នុងការទូទាត់ប្រាក់ ឬ

ឃ. សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

២. នៅពេលដែលក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់ សកម្មភាព ឬប្រតិបត្តិការណាមួយដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើ ក្រសួងឬស្ថាប័ន នោះអាចបញ្ជាក់៖

ក. របៀប និងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវទទួលចុះបញ្ជី ការបង្កើតរក្សាទុក ឬការបោះផ្សាយ

ខ. ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេល ដែលមានការតម្រូវឱ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ

គ. របៀប និងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក

ឃ. ដំណើរការគ្រប់គ្រង និងនីតិវិធីដែលសមស្របដើម្បីធានាសុក្រឹតភាព សុវត្ថិភាព និងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់

---

[62] ប្រព័ន្ធស្វ័យប្រវត្តិ (Automated System) សំដៅដល់កម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធ ឬបណ្តាញអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹង ឬឆ្លើយតបដោយស្វ័យប្រវត្តិដោយគ្មានអន្តរាគមន៍ពីរូបវន្តបុគ្គលណាមួយ។

[63] មាត្រា១៧ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[64] មាត្រា១៨ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

ង. លក្ខខណ្ឌកំណត់ផ្សេងៗទៀតដែលផ្តល់តម្លៃសមមូលរវាងឯកសារ ឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិក ជាមួយនឹងឯកសារ ឬការទូទាត់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។[65]

❖ **ការទូទាត់ ឬការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក**

**ប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកជាការផ្តល់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដល់សាធារណជនត្រូវស្នើសុំការអនុញ្ញាត ឬអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។

២. ធនាគារជាតិនៃកម្ពុជាជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិ ទាក់ទងនឹងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។[66]

**ការទទួលខុសត្រូវរបស់បុគ្គលផ្តល់សេវាទូទាត់**

១. បុគ្គលផ្តល់សេវាទូទាត់មិនត្រូវផ្តល់ជូនអតិថិជននូវឧបករណ៍ទូទាត់ ដែលអតិថិជន មិនបានស្នើសុំនោះទេ លើកលែងតែករណីដែលបណ្ណទូទាត់នោះជាបណ្ណទូទាត់ហួសរយៈពេល ប្រើប្រាស់ ឬដល់ពេលត្រូវផ្លាស់ប្តូរ

២.មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកបុគ្គលផ្តល់សេវាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជននិងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវលើករណីដូចខាងក្រោម៖

- ក. ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន
- ខ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំ បាត់បង់ ឬចោរកម្មនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក
- គ. ប្រតិបត្តិការកើតឡើង បន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨ខាងក្រោម
- ឃ. ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជនឬការប្រតិបត្តិខុសពីបញ្ជារបស់អតិថិជន
- ង. ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

៣. បុគ្គលផ្តល់សេវាទូទាត់អាចរួចផុតពីការទទួលខុសត្រូវបានតែក្នុងករណីប្រធានស័ក្តិ ឬជាកំហុសរបស់អតិថិជនផ្ទាល់ប៉ុណ្ណោះ

៤. ក្នុងករណីដែលបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវ បុគ្គលផ្តល់សេវាទូទាត់ត្រូវសងថ្លៃខូចខាតជូនអតិថិជនក្នុងរយៈពេលមិនឱ្យលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨ នៃច្បាប់នេះនូវកម្រៃប្រតិបត្តិការដែលបានខាតបង់សោហ៊ុយ និងការពិន័យក្នុងការបង់ការប្រាក់យឺតយ៉ាវកើតចេញពីប្រតិបត្តិការនេះ ដោយមិនទាន់គិតបញ្ចូលការសងថ្លៃខូចខាតដទៃទៀតដែលអាចកើតឡើងចំពោះអតិថិជន

[65] មាត្រា៣៤ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[66] មាត្រា៤៦ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

៥. បុគ្គលទាំងឡាយមិនត្រូវចេញផ្សាយបណ្ណទូទាត់ ឬកែប្រែបណ្ណទូទាត់ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើមដោយគ្មានការអនុញ្ញាតក្នុងគោលបំណងទុច្ចរិត ឆបោក ឬក្លែងបន្លំដែលនាំឱ្យមានព្យសនកម្មដល់បុគ្គលមួយផ្សេងទៀតឡើយ។[67]

**ការទទួលខុសត្រូវរបស់អតិថិជន**

១. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់អំពីប្រតិបត្តិការដែលកើតឡើង២៦ឆ្នាំ ក៏អនុញ្ញាតកំហុសឆ្គង ឬភាពមិនត្រឹមត្រូវផ្សេងទៀតនៅក្នុងគណនីរបស់ខ្លួន។

២. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ ឬគ្រឹះស្ថានដែលទទួលបានការអនុញ្ញាតពីបុគ្គលផ្តល់សេវាទូទាត់អំពីករណីបាត់បង់ឬអំពើចោរកម្មលើឧបករណ៍មធ្យោបាយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬការលួចយកទិន្នន័យសម្រាប់ប្រើប្រាស់ជាមួយឧបករណ៍ទូទាត់។ ការជូនដំណឹងនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយអេឡិចត្រូនិកណាមួយដែលទទួលយកដោយបុគ្គលផ្តល់សេវាទូទាត់ ហើយត្រូវជូនដំណឹងជាបន្ទាន់តាមលទ្ធភាព ដែលអាចធ្វើទៅបានឬមិនឱ្យលើស រយៈពេល២(ពីរ)ថ្ងៃ បន្ទាប់ពីបានដឹងថាមានករណីចោរកម្ម ឬបាត់បង់ឧបករណ៍ទូទាត់កើតឡើង។

៣. ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាការបាត់បង់ឬការខូចខាតក្នុងករណីខាងលើ ជាកំហុសរបស់អតិថិជន បុគ្គលផ្តល់សេវាទូទាត់មានសិទ្ធិទាមទារឱ្យអតិថិជនទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ ឬការខូចខាតនោះ។

៤. ក្នុងករណីមិនមានភស្តុតាងបញ្ជាក់អំពីកំហុសរបស់អតិថិជនទេ ដែលបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោដោយឥតលក្ខខណ្ឌ។[68]

- **ទិដ្ឋភាពរួមនៃការចុះបញ្ជីអាជីវកម្មតាមនីតិវិធីចាស់ និងថ្មី**

ការចុះបញ្ជីអាជីវកម្មមួយអាចពាក់ព័ន្ធជាមួយក្រសួង-ស្ថាប័នច្រើន ប៉ុន្តែជាទូទៅក្រសួង-ស្ថាប័នគោលដែលពាក់ព័ន្ធរួមមានក្រសួងពាណិជ្ជកម្ម, អគ្គនាយកដ្ឋានពន្ធដារ, និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដើម្បីដំណើរការអាជីវកម្មបានដោយស្របច្បាប់ អ្នកដែលជាម្ចាស់អាជីវកម្មរួចបន្តចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ និងធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដោយឡែកអាជីវកម្មមួយចំនួនត្រូវចុះបញ្ជី ឬសុំការអនុញ្ញាតពីក្រសួង-ស្ថាប័នដទៃបន្ថែមទៀតដែលអាចជាក្រសួងទេសចរណ៍ (សម្រាប់ភោជនីយដ្ឋាន) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (សម្រាប់ក្រុមហ៊ុនសំណង់) និងក្រសួងសុខាភិបាល (សម្រាប់ឱសថស្ថាន ឬមន្ទីរពេទ្យ) ជាដើម។

តាមគោលការណ៍ចាស់អ្នកត្រូវទៅចុះបញ្ជីអាជីវកម្មរបស់អ្នកនៅក្រសួង-ស្ថាប័នផ្សេងៗគ្នា និងតាមនីតិវិធីខុសៗគ្នា។ ការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលវេលារង់ចាំច្រើនដងទម្រាំក្រសួង-ស្ថាប័ននីមួយៗផ្តល់ការអនុញ្ញាត។ ចំណែកប្រព័ន្ធចុះបញ្ជីរបស់ក្រសួង-ស្ថាប័ននីមួយៗមានលក្ខណៈដាច់ដោយឡែកពីគ្នា និងមិនអាចផ្សារភ្ជាប់ផ្លាស់ប្តូរទិន្នន័យគ្នាបានដែលត្រូវឱ្យអ្នកបំពេញព័ត៌មានដដែលៗលើពាក្យស្នើសុំផ្សេងគ្នានៅក្រសួង-ស្ថាប័នផ្សេងគ្នា។

[67] មាត្រា៤៧ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

[68] មាត្រា៤៨ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

សម្រាប់ការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីនេះអ្នកអាចធ្វើការចុះបញ្ជីពាណិជ្ជកម្ម ឬចុះបញ្ជីពន្ធដារ និងការធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសក្នុងពេលតែមួយបាននៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតែមួយ (សូមមើលក្នុងឧបសម្ព័ន្ធ រូបភាពទី២ ដែលបង្ហាញពីនីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន)។ ដោយឡែកក្នុងដំណាក់កាលដំបូងនេះការចុះបញ្ជី ឬសុំការអនុញ្ញាតពីក្រសួង-ស្ថាប័នដទៃក្រៅពីក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតម្រូវឱ្យអ្នកធ្វើតាមនីតិវិធីដដែលរបស់ក្រសួង-ស្ថាប័នសាមី។ តាមរយៈដំណើរការចុះបញ្ជីថ្មីនេះការចុះបញ្ជីអាជីវកម្មមួយអាចចំណាយពេលយ៉ាងយូរ ៨ថ្ងៃនៃថ្ងៃធ្វើការ និងត្រូវបង់ថ្លៃសេវាតិចជាងមុន។ អ្នកក៏អាចទូទាត់សងប្រាក់សេវាទាំងអស់ក្នុងការចុះបញ្ជីអាជីវកម្មតាមអនឡាញដោយប្រើប្រាស់ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក (Electronic fund transfer) តាមកាតឥណទាន ឬកាតឥណពន្ធសម្រាប់អតិថិជនធនាគារមួយចំនួននៅកម្ពុជា។ ក្រោយការចុះបញ្ជីអាជីវកម្មជោគជ័យអ្នកនឹងទទួលបានអាជ្ញាបណ្ណ និងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថលតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

តារាង១ ការប្រៀបធៀបពីការចុះបញ្ជីអាជីវកម្មតាមនីតិវិធីចាស់ និងថ្មី

| **បញ្ហាប្រឈមដែលបានកើតឡើងពីមុន** | **អត្ថប្រយោជន៍ដែលទទួលបានពីប្រព័ន្ធបច្ចុប្បន្ន** |
|---|---|
| • ផ្តល់ព័ត៌មានដដែលៗរាល់ពេលចុះបញ្ជីនៅក្រសួង-ស្ថាប័ន្តនីមួយៗ<br>• ចុះឈ្មោះនៅក្រសួង-ស្ថាប័នច្រើនតាមនីតិវិធីខុសៗគ្នា<br>• រង់ចាំច្រើនដង ទម្រាំក្រសួង-ស្ថាប័ន្តនីមួយៗផ្តល់ការអនុញ្ញាត<br>• មានប្រព័ន្ធចុះបញ្ជីដាច់ដោយឡែក និងមិនអាចផ្សារភ្ជាប់គ្នាបាន<br>• ចំណាយថវិកាច្រើន។ | • ចំណាយពេលវេលារង់ចាំយ៉ាងយូរ៨ថ្ងៃ នៃធ្វើការ<br>• លុបបំបាត់ការផ្តល់ព័ត៌មានដដែលៗ<br>• ចំណាយថវិកាតិចជាងមុនច្រើន<br>• ទូទាត់សងប្រាក់សេវាទាំងអស់ក្នុងពេលតែមួយតាមអនឡាញ<br>• ទទួលបានអាជ្ញាបណ្ណ និងវិញ្ញាបនបត្រក្នុងទម្រង់ឌីជីថល។ |

តារាង២ សេចក្តីសង្ខេបទម្រង់សហគ្រាស[69]

| **ទម្រង់សហគ្រាស** | | | | | | | |
|---|---|---|---|---|---|---|---|
| **ក្រុមហ៊ុនមូលធន** | | **ក្រុមហ៊ុនបរទេស** | | | **សហគ្រាសឯកបុគ្គល** | **ក្រុមហ៊ុនសហកម្មសិទ្ធិ** | |
| ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត | ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត | សាខាក្រុមហ៊ុនបរទេស | ការិយាល័យតំណាងពាណិជ្ជកម្ម | បុត្រសម្ព័ន្ធ | | ក្រុមហ៊ុនសហកម្មសិទ្ធទូទៅ | ក្រុមហ៊ុនសហកម្មសិទ្ធមានកម្រិត |

[69] គេហទំព័រ https://www.registrationservices.gov.kh/wp-content/uploads/2020/06/User-Guide-Kh-1 ដកស្រង់ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០២១

## ខ. អគ្គនាយកដ្ឋានពន្ធដា

❖ **បេសកកម្ម**

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តន៍កម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តន៍ទោសទណ្ឌតាមការកំណត់ នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវា ការអប់រំអ្នកជាប់ពន្ធដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាពមានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់ និងបទញ្ញត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារដើម្បីបង្កើនការជឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធក្នុងការរៀបចំកម្មវិធី កិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាពចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

❖ **តួនាទី និងភារកិច្ច**

អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចតទៅៈ

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តន៍ការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុកដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់ គ្រងប្រចាំឆ្នាំនីមួយៗ។

**❖ សេវាកម្មអេឡិចត្រូនិកពន្ធដា**

អគ្គនាយកដ្ឋានពន្ធដាបានបែងចែកជាបីកម្មវិធីដើម្បីបម្រើដល់ការផ្តល់សេវាសាធារណៈតាមរយៈការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនោះគឺ៖

**កម្មវិធីលើគេហទំព័រ (Web App) មានដូចជា៖**

- ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tax on Income-ToI E-Filing[70])
- ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (e-Filing For Web Application)
- ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ (Tax Certificate Management System)
- ប្រព័ន្ធគ្រប់គ្រងពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិយានជំនិះតាមអនឡាញ (Online Tax on Vehicle Transfering System)
- បង់ប្រាក់ពន្ធតាមអនឡាញ (E-Payment)[71]
- ប្រព័ន្ធគ្រប់គ្រងការសិក្សាពន្ធដារ (Tax learning Management System)
- ស្នើរសុំជៀសវាងការយកពន្ធត្រួតគ្នា DTA (DTA System)[72]
- ការស្នើសុំការលើកទឹកចិត្ត (Tax Incentive)
- កម្មវិធី បញ្ជូនឯកសារអេឡិចត្រូនិក (e-Document Submission System)[73]
- ស្នើសុំបង្វិលសងអតប (E-Vat)[74]។

**កម្មវិធីទូរស័ព្ទ**

- កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT[75] Tax Prefilling App)
- កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)
- កម្មវិធីគណនាពន្ធមធ្យោបាយ (Cambodia Road Tax)
- កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track)
- កម្មវិធីប្រតិទិនពន្ធដារ (Cambodia Tax Calendar)
- កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat)
- កម្មវិធីព័ត៌មានស្តីពីពន្ធដារ (GDT News)
- កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (Cambodia Salary Tax)។

[70] ToI E-Filing = Tax on Income Electronic Filing
[71] E-Payment = Electronic Payment
[72] DTA System = Double Tax Agreement System
[73] e-Document Submission System = Electronic Document Submission System
[74] E-vat = Expanded Value Added Tax
[75] GDT = General Department of Taxation

**កម្មវិធីលើកុំព្យូទ័រ (Desktop App)**

កម្មវិធីគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម។[76]

❖ **របៀបនៃការបង់ពន្ធតាមអនឡាញ (E-Payment)**

ជាដំបូងចុចចូលទៅគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ហើយចុចលើសេវាអេឡិចត្រូនិកពន្ធដារ រួចចុចលើ icon បង់ប្រាក់ពន្ធតាមអនឡាញ (ប្រសិនបើលោកអ្នក មិនទាន់មានគណនីទេ អាចបង្កើតគណនីថ្មីមួយដើម្បីធ្វើការ Log in ដើម្បីចូលទៅកាន់កម្មវិធីនោះ ដោយគ្រាន់តែបំពេញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកចូលឱ្យត្រឹមត្រូវ និងគ្រប់គ្រាន់ជាការស្រេច)។ ក្នុងកម្មវិធីនេះបានផ្តល់នូវភាពងាយស្រួលដល់អ្នកប្រើប្រាស់ដោយអាចជ្រើសរើសប្រភេទនៃពន្ធដែលយើងចង់បង់ព្រមទាំងមានធនាគារជាច្រើនដែល ជាជម្រើសក្នុងការបង់ពន្ធរបស់អ្នកជាប់ពន្ធ។ នៅពេលដែលអ្នកបានបញ្ចូលលេខគណនីចូលរួចហើយនោះប្រព័ន្ធនឹងលោតបញ្ចូលលេខគណនីរបស់អ្នកក្នុងព័ត៌មានបង់ពន្ធ និងប្រកាសពន្ធដោយស្វ័យប្រវត្តិបើពិនិត្យឃើញថាត្រឹមត្រូវហើយនោះចុចត្រួតពិនិត្យប្រព័ន្ធនឹងបង្ហាញពាក្យស្នើសុំបង់ពន្ធ និងបង្ហាញធនាគារដែលអ្នកបានជ្រើសរើសរួចបញ្ចូលនូវលេខគណនី និងព័ត៌មានគណនីរបស់អ្នកហើយប្រព័ន្ធនឹងបង្ហាញពាក្យVerify ដើម្បីបញ្ជាក់ម្តងទៀតរួចប្រព័ន្ធនឹងបង្ហាញបង្កាន់ដៃអេឡិចត្រូនិកបញ្ជាក់ការបង់ប្រាក់ពន្ធជាការស្រេច។ លោកអ្នកអាចចូលមើលពីការណែនាំរបៀបនៃការបង់ពន្ធតាមអនឡាញដើម្បីធ្វើការស្វែងយល់បន្ថែម។

❖ **ការបើកប្រាក់បៀវត្សតាមរយៈធនាគារ**

បន្ត និងពង្រីកទៅលើការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតាមប្រព័ន្ធធនាគារតាមការសម្រេចរបស់រាជរដ្ឋាភិបាល។ ហេតុនេះក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តត្រូវរៀបចំឯកសារសម្រាប់ការអនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលាដើម្បីធានាប្រសិទ្ធភាពនៃការបើកផ្តល់បៀវត្សទៀងទាត់រៀងរាល់សប្តាហ៍ទី៤ នៃខែនីមួយៗ។ ចំពោះក្រសួង-ស្ថាប័នមួយចំនួន ដែលមិនទាន់អនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារបានពេញលេញត្រូវពិនិត្យលទ្ធភាពក្នុងការពង្រីកការអនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារនេះ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬទំនាក់ទំនងផ្ទាល់ជាមួយគណៈកម្មការចម្រុះទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ។

ក្រសួងមុខងារសាធារណៈ នឹងបោះពុម្ពឯកសារតារាងបៀវត្សប្រចាំខែនីមួយៗ របស់ក្រសួងស្ថាប័ន ព្រមជាមួយការផ្តល់ទិដ្ឋាការ ហើយផ្ញើឱ្យក្រសួង-ស្ថាប័នសាមី យ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែនីមួយៗ។ បន្ទាប់ពីទទួលបានឯកសារតារាងបៀវត្សប្រចាំខែ និងទិដ្ឋាការពីក្រសួងមុខងារសាធារណៈ ហើយក្រសួង-ស្ថាប័នសាមីត្រូវបោះផ្សាយអាណត្តិបើកប្រាក់បៀវត្ស និងចុះហត្ថលេខាក្នុងនាមអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិ តាមរយៈការធ្វើប្រតិភូកម្មសិទ្ធិតាមខ្សែបណ្តោយ ហើយដាក់ឆ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៅអមក្រសួង-ស្ថាប័នស្រាប់ចុះហត្ថលេខាក្នុងនាមអភិបាលហិរញ្ញវត្ថុរួចផ្ញើមកអគ្គនាយកដ្ឋានរតនាគារជាតិយ៉ាងយូរត្រឹមថ្ងៃទី១៨នៃខែនីមួយៗ ដើម្បីអគ្គនាយកដ្ឋានរតនាគារជាតិអាចរៀបចំការបើកផ្តល់ជូនក្រសួង-ស្ថាប័ននីមួយៗបន្តបន្ទាប់ក្នុងរយៈពេល៥ថ្ងៃនៃសប្តាហ៍ទី៤ ទៅតាមលំដាប់អាទិភាព និងទំហំទឹកប្រាក់ដែលអាចបើកផ្តល់បានក្នុងមួយថ្ងៃៗ។

[76] គេហទំព័រ www.tax.gov.kh ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១

ចំពោះចំនួនក្របខណ្ឌ និងប្រាក់បៀវត្សរបស់មន្ត្រីរាជការ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវតែពិនិត្យអនុវត្តទៅតាមតារាងបៀវត្សដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលចេញដោយក្រសួងមុខងារសាធារណៈ និងរាល់ក្របខ័ណ្ឌគតិយុត្តិដែលនៅមានជាធរមានពិសេស អនុក្រឹត្យ សារាចរណែនាំ និងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ការត្រួតពិនិត្យឡើងវិញនូវចំនួន និងការគ្រប់គ្រងមន្ត្រីរាជការ និងការកែសម្រួលប្រាក់បៀវត្សប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជាដើម។ ក្នុងករណីមានការ ផ្ទេរមន្ត្រីរាជការពីក្រសួង-ស្ថាប័នមួយទៅក្រសួង-ស្ថាប័នមួយទៀតនៅក្នុងឆ្នាំ សាមីខ្លួនត្រូវបន្តទទួល បៀវត្សនៅក្រសួង-ស្ថាប័នដើមរហូតដល់ដំណាច់ឆ្នាំ ហើយត្រូវធ្វើការផ្ទេរ និងគ្រោងបៀវត្សនៅក្រសួងស្ថាប័នដែលបានផ្ទេរចូលឱ្យទាន់ពេលនៅឆ្នាំបន្ទាប់។ ដើម្បីឱ្យការប្រើប្រាស់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់ កិច្ចសន្យា និងបុគ្គលិកអណ្តែតមានសង្គតិភាព និងឯកភាពគ្នានៅគ្រប់ក្រសួង-ស្ថាប័នត្រូវអនុវត្តឱ្យបាន មឹុងម៉ាត់តាមសារាចរលេខ ០០១ សហវ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការប្រើប្រាស់ និងការផ្តល់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត។ ក្រសួង-ស្ថាប័នសាមីត្រូវសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនបើការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតមុននឹងស្នើសុំទិដ្ឋាការពីក្រសួងមុខងារសាធារណៈ។[77]

- **ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ**

  (Tax on Income -ToI E-Filing)

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹង ដល់ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងលោក លោកស្រីជាប្រធានសមាគមនិងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងបរទេសទាំងអស់ឱ្យបានជ្រាបថាកន្លងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវសេចក្តីណែនាំលេខ០០៣ សហវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាម អនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ សម្រាប់ដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែ។ បន្ថែមលើការអនុវត្តតាមសេចក្តីណែនាំខាងលើ និងស្របតាមយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ និងគោលការណ៍កំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានអភិវឌ្ឍរួចរាល់នូវប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ដើម្បីសម្រួលដល់ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដើម្បីពង្រឹងសេវាផ្នែកចាត់ចែងលិខិតប្រកាសពន្ធជូនអ្នកជាប់ពន្ធឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ស័ក្តិសិទ្ធិភាព ធានាបាននូវតម្លាភាព ភាពងាយស្រួល឴ ឆាប់រហ័ស ចំណេញពេលវេលា និងភាពជឿទុកចិត្តក្នុងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ។

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ចាប់ពីខែមីនា ឆ្នាំ២០២១ នេះតទៅ ដោយត្រូវអនុវត្តតាមបែបបទ និងនីតិវិធីដូចខាងក្រោម៖

[77] គេហទំព័រ https://mef.gov.kh/download-counter?post=3310 ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១

## ១. សម្រាប់អ្នកជាប់ពន្ធបធ្យមនិងធំ

អ្នកជាប់ពន្ធមធ្យមនិងធំទាំងអស់ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយប្រើប្រាស់ប្រព័ន្ធ គ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tol E-Filing) ក្នុងរយៈពេល ៣ ខែក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ។

### ១.១. ការចូលប្រើប្រាស់ប្រព័ន្ធ Tol E-Filing

អ្នកប្រើប្រាស់ដែលមានគណនី និងធ្លាប់ប្រើប្រាស់ប្រព័ន្ធ E-Filing ដើម្បីបង់ពន្ធប្រចាំខែរួចហើយមិនតម្រូវឱ្យចុះឈ្មោះប្រើប្រាស់ឡើងវិញទេដោយគ្រាន់តែចូលប្រើប្រាស់គណនីដែលមានស្រាប់ដូចធ្លាប់ចូលប្រើប្រាស់ប្រព័ន្ធ E-Filing ប្រចាំខែនេះ។ ដោយឡែកចំពោះអ្នកប្រើប្រាស់ទាំងឡាយណាដែលពុំទាន់មានគណនីត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tol E-Filing) ដោយត្រូវចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន https://www.tax.gov.kh/ ដើម្បីចុះឈ្មោះបង្កើតគណនី (User Account) សម្រាប់ប្រើប្រាស់ប្រព័ន្ធដោយត្រូវវាយបញ្ចូលព័ត៌មានដូចខាងក្រោម៖

- ព័ត៌មានបុគ្គលរបស់អ្នកប្រើប្រាស់
- លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកប្រើប្រាស់
- លេខសម្គាល់ការចុះបញ្ជីព័ត៌មានបុគ្គល (TID) ប្រសិនបើមាន
- ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ រួមមានអ្នកជាប់ពន្ធ, អ្នកតំណាងក្រុមហ៊ុន, ឬភ្នាក់ងារសេវាកម្មពន្ធដារ (និងត្រូវបំពេញលេខអាជ្ញាប័ណ្ណ សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ) និង
- លេខទូរស័ព្ទ និងអ៊ីម៉ែលដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារ និងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទ ឬអ៊ីម៉ែលត្រូវបានផ្លាស់ប្តូរលោក-លោកស្រីត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

### ១.២. នីតិវិធីលម្អិតក្នុងការប្រើប្រាស់ប្រព័ន្ធ Tol E-Filing

បន្ទាប់ពីបានចុះឈ្មោះបង្កើតគណនី (User Account) សម្រាប់ប្រើប្រាស់ហើយ ឬមានគណនីដែលបានបង្កើតរួចស្រាប់អ្នកប្រើប្រាស់អាចចូលក្នុងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអន ឡាញ (Tol E-Filing) បានដោយត្រូវអនុវត្តតាមនីតិវិធីលម្អិត ដូចខាងក្រោម៖

- ចូលទៅគេហទំព័រដែលមានអាសយដ្ឋាន https://www.tax.gov.kh ដោយប្រើប្រាស់គណនីដែលបានបង្កើតរួច ដោយត្រូវជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tol E-Filing)
- បន្ទាប់មកបង្កើតពាក្យស្នើសុំប្រកាសពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដើម្បីបញ្ចូលព័ត៌មានសហគ្រាសដែលត្រូវប្រកាសដូចខាងក្រោម៖
    - លេខអត្តសញ្ញាណកម្មសារពើពន្ធ (VATIN)
    - លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration_Identification Card) នៅលើប័ណ្ណប្លាស្ទីកដែលអគ្គនាយកដ្ឋានពន្ធដារផ្តល់ជូនលោក-លោកស្រី

- លេខទូរស័ព្ទដែលបានផ្ដល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទត្រូវបានផ្លាស់ប្ដូរលោក-លោកស្រីត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដើម្បីផ្លាស់ប្ដូរលេខទូរស័ព្ទ)។ អគ្គនាយកដ្ឋានពន្ធដារនឹងមិនទទួលខុសត្រូវចំពោះការបញ្ចូលព័ត៌មានលេខទូរស័ព្ទខុសរបស់អ្នកប្រើប្រាស់ឡើយ ហើយករណីបញ្ចូលខុសអ្នកប្រើប្រាស់នឹងមិនអាចចូលប្រើប្រាស់ប្រព័ន្ធបានឡើយ។

➢ បញ្ចូលព័ត៌មាននៃប្រតិបត្តិការរបស់សហគ្រាសជាបន្តបន្ទាប់តាមរំហូរដែលមានក្នុងប្រព័ន្ធ តាមចំណុចលម្អិតនីមួយៗពីទំព័រទី១ ដល់ទំព័រទី១៦(ដូចមានក្នុងឧបសម្ព័ន្ធ TOI 01)

➢ ផ្ទៀងផ្ទាត់ទិន្នន័យ និងចុចប៊ូតុងបង្កើតពាក្យស្នើសុំប្រកាសពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ រួចចុចបញ្ជូន (Submit)

➢ ក្នុងការបង់ប្រាក់ពន្ធ អ្នកជាប់ពន្ធអាចមានជម្រើសដូចខាងក្រោម៖

- ក្នុងករណីអ្នកជាប់ពន្ធបង់ប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅធនាគារ អ្នកជាប់ពន្ធត្រូវបោះពុម្ពពាក្យស្នើសុំប្រកាសពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (ដូចមានក្នុងឧបសម្ព័ន្ធ TOI 01-A) ដើម្បីទៅបង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារជាដៃគូដែលបានចុះ អនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ
- ក្នុងករណីអ្នកជាប់ពន្ធបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) អ្នកជាប់ពន្ធអាចជ្រើសរើសគណនីធនាគារជាដៃគូ ដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់លោក-លោកស្រី (ដូចមានក្នុងឧបសម្ព័ន្ធ TOI 01-C) និងបង់ពន្ធ ហើយបោះពុម្ពបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ(ដូចមានក្នុងឧបសម្ព័ន្ធ TOI 01-B)។

➢ អ្នកជាប់ពន្ធពុំចាំបាច់យកលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ និងពាក្យស្នើសុំបង់ប្រាក់ពន្ធមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ ដោយគ្រាន់តែបោះពុម្ពលិខិតបញ្ជាក់ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំចំនួន ១៦ ទំព័រ និងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធដើម្បីទុកជាឯកសារ និងត្រូវរក្សាទុកឯកសារនានាដែលពាក់ព័ន្ធនឹងការដាក់លិខិតប្រកាសនេះ ដើម្បីបង្ហាញជូនរដ្ឋបាលសារពើពន្ធនៅពេលដែលត្រូវបានស្នើសុំត្រួតពិនិត្យ ឬធ្វើសវនកម្មពន្ធដារ។

### ២. សម្រាប់អ្នកជាប់ពន្ធតូច

អ្នកជាប់ពន្ធតូចអាចដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដោយប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) ក្នុងរយៈពេល៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ។ ក្នុងករណីអ្នកជាប់ពន្ធតូចមិនទាន់អាចបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលតាមកម្មវិធីនេះបានអាចបំពេញលិខិតប្រកាសពន្ធ ដោយដៃនិងដាក់លិខិតប្រកាសពន្ធនៅរដ្ឋបាលសារពើពន្ធបាន។

### ២.១ ការទាញយក និងចូលប្រើប្រាស់កម្មវិធី

អ្នកប្រើប្រាស់ដែលមានគណនី និងធ្លាប់ប្រើប្រាស់កម្មវិធីខាងលើដើម្បីបង់ពន្ធប្រចាំខែរួចហើយមិនតម្រូវឱ្យចុះឈ្មោះប្រើប្រាស់ឡើងវិញទេ ដោយគ្រាន់តែចូលប្រើប្រាស់គណនីដែលមានស្រាប់ដូចធ្លាប់ចូលប្រើប្រាស់កម្មវិធីនេះ។ ដោយឡែក ចំពោះអ្នកប្រើប្រាស់ទាំងឡាយណាដែលពុំទាន់មានគណនីត្រូវចុះឈ្មោះប្រើប្រាស់

ដោយចូលទៅទាញយក កម្មវិធីបានតាម App Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ iOS) ឬទាញយកពី Play Store (សម្រាប់អ្នក ប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ Android) ដោយស្វែងរកពាក្យ GDT Tax Prefiling App និងត្រូវវាយបញ្ចូលព័ត៌មាន មួយចំនួនដូចខាងក្រោម៖

- ព័ត៌មានបុគ្គលរបស់អ្នកប្រើប្រាស់
- លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកប្រើប្រាស់
- លេខសម្គាល់ការចុះបញ្ជីព័តិមានបុគ្គល (TID) ប្រសិនបើមាន
- ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ រួមមាន អ្នកជាប់ពន្ធ, អ្នកតំណាងក្រុមហ៊ុន, ឬភ្នាក់ងារសេវាកម្មពន្ធដារ (និងត្រូវបំពេញលេខអាជ្ញាប័ណ្ណ សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ) និង
- លេខទូរស័ព្ទ និងអ៊ីម៉ែលដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទនិងអ៊ីម៉ែលត្រូវបានផ្លាស់ប្តូរ លោក-លោកស្រីត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

### ២.២ នីតិវិធីលម្អិតក្នុងការប្រើប្រាស់កម្មវិធី

ក្នុងការប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefilling App) អ្នកប្រើប្រាស់ត្រូវ អនុវត្តតាមនីតិវិធីលម្អិតដូចតទៅ៖

- ចូលទៅកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច ដោយប្រើប្រាស់គណនីដែលបានបង្កើតរួច
- បន្ទាប់មក ចុចប៊ូតុង បន្ថែមសហគ្រាសថ្មី ដើម្បីបញ្ចូលព័ត៌មានសហគ្រាសដែលត្រូវប្រកាសដូចខាងក្រោម៖
  - លេខអត្តសញ្ញាណកម្មសារពើពន្ធ (BIN)
  - លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration Identification Card) នៅលើប័ណ្ណបាស្ទីកដែលអគ្គនាយកដ្ឋានពន្ធដារផ្តល់ជូនលោក លោកស្រី
  - លេខទូរស័ព្ទរបស់ម្ចាស់ភាគហ៊ុនដែលឈរឈ្មោះនៅលើប័ណ្ណពន្ធប៉ាតង់ និងបានផ្តល់នៅពេលចុះបញ្ជីពន្ធដារ និងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទ ត្រូវបានផ្លាស់ប្តូរ លោក-លោកស្រីត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។ អគ្គនាយកដ្ឋានពន្ធដារនឹងមិនទទួលខុសត្រូវចំពោះការបញ្ចូលព័ត៌មានលេខទូរស័ព្ទខុសរបស់អ្នកប្រើប្រាស់ឡើយ ហើយករណីបញ្ចូលខុស អ្នកប្រើប្រាស់នឹងមិនអាចចូលប្រើប្រាស់កម្មវិធីបានឡើយ។
- ជ្រើសរើសជម្រើសគ្រប់គ្រងការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ
- បញ្ចូលព័ត៌មាននៃប្រតិបត្តិការរបស់សហគ្រាសជាបន្តបន្ទាប់តាមរំហូរដែលមានក្នុងកម្មវិធី
- ផ្ទៀងផ្ទាត់ទិន្នន័យ និងចុចប៊ូតុងបង្កើតលេខកូដសម្រាប់បង់ពន្ធប្រចាំឆ្នាំ
- ក្នុងការបង់ប្រាក់ពន្ធ លោក លោកស្រីអាចបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) ដោយចុចប៊ូតុងបង់ប្រាក់រួចជ្រើសរើសធនាគារដើម្បីធ្វើប្រតិបត្តិការបង់ពន្ធ។ ពេលលោក-លោកស្រីបង់ពន្ធជោគជ័យ

កម្មវិធីនឹងផ្ញើបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធទៅសារអេឡិចត្រូនិកដែលលោក-លោកស្រីប្រើនៅពេលចុះឈ្មោះបង្កើតគណនី

- លោក-លោកស្រីក៏អាចបង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារជាដៃគូដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អ្នកជាប់ពន្ធដែលប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច(GDT Tax Prefilling App) ពុំចាំបាច់យកលិខិតប្រកាសមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ។

**៣. ការបំពេញលិខិតប្រកាសពន្ធដោយដៃ**

អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច ដែលមិនទាន់អាចប្រើប្រាស់ប្រព័ន្ធនេះបានអាចស្នើសុំមករដ្ឋបាលសារពើពន្ធ ដើម្បីបំពេញលិខិតប្រកាសពន្ធដោយដៃនិងដាក់លិខិតប្រកាសពន្ធនៅរដ្ឋបាលសារពើពន្ធជាបណ្ដោះអាសន្នបាន។ អ្នកជាប់ពន្ធដែលស្នើសុំបំពេញលិខិតប្រកាសពន្ធដោយដៃ អាចបញ្ជូនលិខិតប្រកាសពន្ធនិងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ ពន្ធមករដ្ឋបាលសារពើពន្ធ តាមរយៈប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ (E-Uploader) ដោយអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងសេចក្ដីណែនាំលេខ ៧៧០៥ អពដ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ (ដូចមានក្នុងឧបសម្ព័ន្ធ-សេចក្ដីណែនាំលេខ ៧៧០៥ អពដ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០)។

ដើម្បីឈ្វេងយល់បន្ថែមអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) និងកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) អ្នកប្រើប្រាស់ អាចពិនិត្យមើលលម្អិតក្នុងសៀវភៅណែនាំស្ដីពីការប្រើប្រាស់ របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមាននៅលើគេហទំព័រ https://www.tax.gov.kh/ ឬចូលទស្សនាវីដេអូណែនាំ (Video Tutorial) ឬអាចទូរស័ព្ទមក Call Center 1277 ឬចូល ជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រី ជាអភិបាលបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងលោក-លោកស្រីជាប្រធានសមាគមនិងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងបរទេសទាំងអស់នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំ ស្ដីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ដើម្បីធ្វើការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ និងទទួលបាននូវប្រសិទ្ធភាពខ្ពស់។[78]

**គ. ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈមាននូវគេហទំព័ររបស់ក្រសួងផ្ទាល់សម្រាប់ការផ្ដល់ព័ត៌មានក៏ដូចជា សេវាសាធារណៈទៅកាន់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងវិស័យការងារ និងការបណ្ដុះបណ្ដាល។ ដោយ

[78] សេចក្ដីណែនាំ លេខ៣១៤០ អពដ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្ដីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tax on Income-ToI E-Filing)

ក្នុងនោះដែរមានការបែងចែកចំពោះការផ្តល់សេវាពាក់ព័ន្ធវិស័យការងារ សេវាពាក់ព័ន្ធវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងសេវាពាក់ព័ន្ធជនបរទេស។[79]

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ក្នុងគោលបំណងដាក់ឱ្យដំណើរការការផ្តល់សេវាសាធារណៈពាក់ព័ន្ធនឹងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងស្របតាមសំណើររបស់វិស័យឯកជននៅក្នុងក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈនៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន។

ចំពោះសេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានដាក់ឱ្យប្រើតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ចំពោះសេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ថ្នាក់កណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នូវសេវាសាធារណៈ ដូចខាងក្រោម៖

- សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ https://lacms.mlvt.gov.kh
- សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ https://tvcms.mlvt.gov.kh
- សម្រាប់សេវាសាធារណៈពាក់ព័ន្ធជនបរទេស https://fwcms.mlvt.gov.kh

ដោយឡែកចំពោះសេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពច្រកចេញ-ចូលតែមួយរាជធានី-ខេត្តនឹងត្រូវឱ្យដាក់ដំណើរការ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ តទៅ។[80]

ក្រសួងក៏បានរៀបចំឡើងនូវប្រព័ន្ធមួយសម្រាប់ផ្តល់សេវាពាក់ព័ន្ធនឹងការងារជូនទៅកាន់នយោជក ឬម្ចាស់សហគ្រាសទាំងឡាយក្នុងការប្រើប្រាស់ប្រព័ន្ធទិន្នន័យរួមប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ព្យួរកិច្ចសន្យាការងារ និងប្រព័ន្ធ Upload បញ្ជីឈ្មោះបច្ចុប្បន្នភាពរបស់កម្មករនិយោជិត។ល។

សេវាសាធារណៈដែលផ្តល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានរៀបចំ ជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវារយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

នៅកន្លែងផ្តល់សេវាសាធារណៈត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដាសេវា ឬមានការយកកម្រៃលើសការកំណត់ ឬការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលមានកំណត់ជាដើម។ ចំពោះការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិកដែលផ្តល់ឱកាសឱ្យអតិថិជនអាចមានទំនាក់ទនង ឬប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬអង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

[79] គេហទំព័រ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១

[80] ប្រការ២ នៃប្រកាសលេខ៤៣០/២០ ក.ប/ប្រ.ក.ខ/ល ស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

ក្នុងករណីមានបណ្តឹងតវ៉ា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវពិនិត្យលទ្ធភាពដោះស្រាយឱ្យបានឆាប់ ឬដោះស្រាយក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបណ្តឹងតវ៉ាសាមីជន។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការ ដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំង ដែលបានកំណត់ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនេះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online System) សម្រាប់ការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។ រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រលើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្តត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំដាច់ដោយឡែកពីគ្នា ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសាធារណៈនីមួយៗ យោងតាមភារកិច្ចប្រមូលចំណូលរៀងៗខ្លួន ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ និងសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

នៅពេលអនុវត្តន៍ចំណូលរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរការងារ និងបណ្តុះបណ្តាលវីជ្ជាជីវៈរាជធានី ខេត្តត្រូវទទួលខុសត្រូវប្រាក់កាសលើចំណូលប្រមូលបានបង់ប្រាក់ចំណូល និងធ្វើសលាកបត្របង់ប្រាក់ចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជីកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី នៃមាតិកាចំណូលថវិកា។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់សម្រាប់របាយការណ៍ប្រចាំឆ្នាំ។ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្តត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ ប្រចាំឆ្នាំផ្ញើជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

### ឃ. ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចដឹកនាំគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់លើវិស័យរដ្ឋបាលដឹកនាំគ្រប់គ្រងនគរបាលជាតិការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការពារសុវត្ថិភាពជូនប្រជាពលរដ្ឋកម្ពុជា។

ក្រសួងមហាផ្ទៃបានចេញសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្រសួងមហាផ្ទៃដោយមានរដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ ជាប្រធាន និងមានសមាភាពជាអនុប្រធានចំនួន ០២រូប ព្រមទាំងសមាជិក១២ រូប។ សម្រាប់ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននេះផងដែរ មានលេខាធិការដ្ឋានមួយជាជំនួយការដែលដឹកនាំដោយនាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ។

- **គួរបញ្ជាក់ថាក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់ក្រសួងមហាផ្ទៃមានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

ទី១-ធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ លើកការងាររដ្ឋាភិបាលឌីជីថលក្របខណ្ឌក្រសួងមហាផ្ទៃ និង គ្រប់គ្រងគម្រោងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៅតាមបណ្ដាអគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួង

ទី២-សហការជាមួយដៃគូពាក់ព័ន្ធ ទីប្រឹក្សា និងអ្នកជំនាញតាមការចាំបាច់ ដើម្បីរៀបចំកសាងផែនការ មេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងការបណ្ដុះបណ្ដាលលើកកម្ពស់សមត្ថភាពធនធានមនុស្ស

ទី៣-គ្រប់គ្រងការធ្វើសមាហរណកម្មតភ្ជាប់រវាង ប្រព័ន្ធបច្ចេកវិទ្យាគមនាគន៍ និងព័ត៌មានរបស់ក្រសួង មហាផ្ទៃ ជាមួយប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃបណ្ដាក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល កម្ពុជា

ទី៤-គ្រប់គ្រងការធ្វើបច្ចុប្បន្នភាពវាយតម្លៃគុណភាពប្រព័ន្ធ និងសម្ភារៈបច្ចេកទេស បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឱ្យសមស្របតាមស្ថានភាពរីកចម្រើននៃបច្ចេកវិទ្យាពិភពលោកបម្រើដល់ការងារជំនាញ និងការងារផ្ដល់ សេវាសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព

ទី៥-រៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដើម្បីធានាដល់ការងារអនុវត្ត ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ការងាររដ្ឋាភិបាលឌីជីថល ពលរដ្ឋឌីជីថល និងធុរកិច្ចឌីជីថលក្របខណ្ឌ ក្រសួងមហាផ្ទៃ

ទី៦-រៀបចំរបាយការណ៍អំពីលទ្ធផលការងារតាមដំណាក់កាលនីមួយៗ ជូនរដ្ឋមន្ត្រីដើម្បីជូនជ្រាប ឬស្នើ សុំមតិដឹកនាំតាមការចាំបាច់។[81]

- **ការអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ**

នាពេលបច្ចុប្បន្ននេះ ក្រសួងមហាផ្ទៃក៏បានចេញនូវសេចក្ដីណែនាំពីការអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការ នូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ (E-Crime2020) ក្នុងគោលបំណងធានាបាននិរន្តរភាព និងសន្តិសុខ ទិន្នន័យបទល្មើសព្រហ្មទណ្ឌស្ថិតនៅក្នុងនិយាម បណ្ណសារដ្ឋានស្របតាមបច្ចេកវិទ្យាព័ត៌មានវិទ្យា អគ្គស្នង ការដ្ឋាននគរបាលជាតិបានឯកភាពជាគោលការណ៍ អនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យ បទល្មើសព្រហ្មទណ្ឌ (E-Crime2020) ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១ នេះតទៅ។ ដើម្បីទាញយក ទិន្នន័យបទល្មើសព្រហ្មទណ្ឌចេញពី Database យកទៅប្រើប្រាស់ផ្លូវការក្នុងការវិភាគ វាយតម្លៃអំពីស្ថានភាព បទល្មើសតាមភូមិសាស្ត្រ តាមកាលកំណត់ ព្រមជាមួយនឹងការគ្រប់គ្រងសាវតារជាតិ ជនសង្ស័យ ជនរងគ្រោះ ប្រវត្តិនៃការអនុវត្តទោសរបស់ជនល្មើស ក៏ដូចជាការអនុវត្តដីកាបង្គាប់ប្រកបដោយ ប្រសិទ្ធភាព ជាពិសេសការ ទាញយកទិន្នន័យទាំងនោះបានគ្រប់កាលៈទេសៈ អគ្គស្នងការដ្ឋាននគរបាលជាតិសូមធ្វើការណែនាំដល់នាយកដ្ឋាន អង្គភាពជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដូចខាងក្រោម៖

១. ត្រូវបានកំណត់ជាគោលការណ៍សម្រាប់រយៈពេល នៃការបញ្ចូលទិន្នន័យបទល្មើសទៅក្នុងប្រព័ន្ធ អំឡុងពេល ៤៨ម៉ោង បន្ទាប់ពីបទល្មើសបានកើតឡើង និងកំណត់ឱ្យកត់ត្រាទិន្នន័យដីកាបង្គាប់ ចាប់ពីឆ្នាំ ២០០០ រហូតមកដល់បច្ចុប្បន្ន ព្រមទាំងត្រូវធ្វើបច្ចុប្បន្នភាពទិន្នន័យជាប្រចាំ។

[81] គេហទំព័រ ក្រសួងមហាផ្ទៃ https://interior.gov.kh/news/detail/2364 ដកស្រង់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១

២. ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវធានានិរន្តរភាពធនធានមន្ត្រី និងការបំពាក់ឧបករណ៍ សម្ភារៈបច្ចេកទេស រួមទាំងការផ្គត់ផ្គង់អ៊ីនធឺណេតសម្រាប់ផែនសេនាធិការ ឬក្រុមមន្ត្រីមានសមត្ថកិច្ចបញ្ចូលទិន្នន័យបទល្មើសរក្សាទុកក្នុងទិន្នដ្ឋាន។

៣. នាយកដ្ឋានសរុប-ផែនការ និងនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ត្រូវពង្រឹងកិច្ចសហការក្នុងការតាមដានត្រួតពិនិត្យទិន្នន័យបទល្មើសព្រហ្មទណ្ឌដែលមន្ត្រីជំនាញ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្តបានកត់ត្រាបញ្ចូលរក្សាទុកក្នុងទិន្នដ្ឋាន និងណែនាំឱ្យបញ្ចូលទិន្នន័យបានត្រឹមត្រូវតាមគោលការណ៍កំណត់។

៤. ផែនព្រហ្មទណ្ឌ និងផែនសេនាធិការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវសហការក្នុងការផ្តល់ឯកសារ ព័ត៌មាន រូបថត ពាក់ព័ន្ធករណីបទល្មើសតាមទម្រង់ឯកភាពគ្នា ដើម្បីធ្វើជាមូលដ្ឋានក្នុងការបញ្ចូលទិន្នន័យរក្សាទុកក្នុងទិន្នដ្ឋានឱ្យបានទាន់ពេលវេលា។ ក្នុងករណីដែលស្នងការដ្ឋាននគរបាលរាជធានី-ខេត្តពុំមានរូបថត ជនសង្ស័យ ឬជនរងគ្រោះសូមស្នើកិច្ចសហការពីនាយកដ្ឋាននគរបាលព្រហ្មទណ្ឌដើម្បីដោះស្រាយផ្តល់ជូន។

៥. បន្ទាប់ពីទិន្នន័យបទល្មើសដែលត្រូវបានកត់ត្រារក្សាទុកក្នុងទិន្នដ្ឋានរួចហើយ ក្នុងអំឡុងពេល៤៨ម៉ោង មន្ត្រីជំនាញកត់ត្រាអាចកែតម្រូវទិន្នន័យបានគ្រប់ចំណុចនៅក្នុងប្រព័ន្ធ ប៉ុន្តែបន្ទាប់ពី៤៨ម៉ោង ប្រព័ន្ធពុំអនុញ្ញាតឱ្យមន្ត្រីជំនាញកត់ត្រានៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត កែតម្រូវកំណត់ត្រាបទល្មើសបានឡើយ។ លើកលែងតែស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើសំណើជាផ្លូវការមកប្រធាននាយកដ្ឋានសរុបផែនការពិនិត្យសម្រេច និងអនុញ្ញាតឱ្យក្រុមការងារបច្ចេកទេសកែតម្រូវជូន។

៦. ក្នុងករណីដំណើរការប្រតិបត្តិការប្រព័ន្ធមានភាពរអាក់រអួល សូមមន្ត្រីជំនាញកត់ត្រាទំនាក់ទំនង មកមន្ត្រីជំនាញបច្ចេកទេសព័ត៌មានវិទ្យានៃអគ្គស្នងការដ្ឋាននគរបាលជាតិរៀងរាល់ម៉ោងធ្វើការ តាមរយៈលេខទូរស័ព្ទដែលបានផ្តល់ជូនក្នុងប្រព័ន្ធ ឬ ក្នុងគ្រុប Telegram ។

៧. ដើម្បីពង្រឹងការសម្ងាត់ផ្ទៃក្នុង និងចៀសវាងទិន្នន័យបទល្មើសបែកធ្លាយចេញទៅក្រៅអង្គភាព ផែនសេនាធិការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត គឺត្រូវធ្វើបច្ចុប្បន្នភាពមន្ត្រីមានសមត្ថកិច្ចប្រើប្រាស់ប្រព័ន្ធក្នុងករណីមានការផ្លាស់ប្តូរ ផ្ទេរចេញ ឬមានបទបញ្ជាពីថ្នាក់ដឹកនាំអង្គភាព សូមជូនដំណឹងបន្ទាន់មកប្រធាន នាយកដ្ឋានសរុប-ផែនការ ដើម្បីពិនិត្យលុបគណនីនោះចេញពីប្រព័ន្ធ។

៨. ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវប្រកាសផ្សព្វផ្សាយអំពីការប្រើប្រាស់ផ្លូវការនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ (E-Crime2020) និងណែនាំលើកកម្ពស់ស្មារតីទទួលខុសត្រូវ ក្នុងការអនុវត្តភារកិច្ចរបស់ក្រុមការងារបញ្ចូលទិន្នន័យឱ្យខិតខំប្រមូលទិន្នន័យបទល្មើសដែលបានកើតឡើងក្នុងដែនសមត្ថកិច្ចរាជធានី-ខេត្តនីមួយៗ យកមកបញ្ចូលរក្សាទុកក្នុងទិន្នដ្ឋានតាមគោលការណ៍កំណត់។

ទទួលបានសេចក្តីណែនាំនេះស្នើប្រធាននាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ចាត់តាំងអនុវត្តប្រកបដោយប្រសិទ្ធភាព ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។[82]

[82] សេចក្តីណែនាំ នៃក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ លេខ០១១ សណន ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់ផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ (E-Crime 2020)

### ង.ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សំដៅទៅលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺចង់សំដៅលើច្រកទ្វារអេឡិចត្រូនិកផ្តល់ព័ត៌មានសេវាសាធារណៈ និងជានវានុវត្តមួយថ្មីទៀតដែលក្រសួងមុខងារសាធារណៈក្រោមការដឹកនាំសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួង-ស្ថាប័ន បានផ្តួចផ្តើមបង្កើតឡើងក្នុងគោលបំណងសម្រួលដល់ប្រជាជនក្នុងការទទួលបានព័ត៌មាន និងការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា ព្រមទាំងលើកកម្ពស់តម្លាភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវា។ ច្រកទ្វារអេឡិចត្រូនិកនេះ គឺជាគេហទំព័រផ្តល់ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងជាច្រកទ្វារដែលប្រជាជនអាចចូលទៅយកសេវាសាធារណៈរបស់ក្រសួង-ស្ថាប័ន តាមប្រព័ន្ធអេឡិចត្រូនិកដោយវាបានប្រមូលផ្តុំនូវព័ត៌មានអំពីសេវាសាធារណៈនិងបណ្តាញ (Link) ចូលទៅកាន់គេហទំព័រនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង-ស្ថាប័ន។ ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ ដែលអ្នកប្រើប្រាស់អាចរកបានតាមច្រកទ្វារអេឡិចត្រូនិករួមមាន៖

១. ឈ្មោះសេវា
២. គោលបំណងនៃសេវា
៣. រយៈពេលនៃការផ្តល់សេវា
៤. តម្លៃសេវា
៥. សុពលភាពនៃសេវា
៦. ឯកសារតម្រូវដើម្បីទទួលបានសេវា
៧. នីតិវិធីនៃការផ្តល់សេវា
៨. អាសយដ្ឋាន លេខទូរស័ព្ទ និងគេហទំព័រសម្រាប់ទំនាក់ទំនងរបស់អង្គភាពផ្តល់សេវា។

អ្នកប្រើប្រាស់សេវាអាចចូលទៅយកសេវារបស់ក្រសួង-ស្ថាប័ន ដោយចុចលើបណ្តាញចូលទៅកាន់គេហទំព័ររបស់អង្គភាពផ្តល់សេវា ដែលត្រូវបានបង្ហាញនៅតាមសេវានីមួយៗ។ ច្រកទ្វារអេឡិចត្រូនិកផ្តល់ព័ត៌មានសេវាសាធារណៈ ដែលបានត្រូវដាក់ឱ្យអនុវត្តនៅដំណាក់កាល ទី១នេះ បានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពីអង្គការតម្លាភាពកម្ពុជាដើម្បីប្រមូលទិន្នន័យ និងរៀបចំដាក់បញ្ចូលផ្សព្វផ្សាយក្នុងគេហទំព័រ www.seva.gov.kh ឬ www.service.gov.kh នូវសេវារបស់ក្រសួង ស្ថាប័នចំនួន៦ គឺក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា និងការិយាល័យក្រុង ស្រុក ខណ្ឌ។ ច្រកទ្វារអេឡិចត្រូនិកផ្តល់ព័ត៌មានសេវាសាធារណៈ គឺជាជំហានថ្មីមួយទៀត បន្ទាប់ពីក្រសួងមុខងារសាធារណៈបានដាក់ឱ្យដំណើរការកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈតាមរយៈ ទូរស័ព្ទស្មាតហ្វូន និងការបោះពុម្ពផ្សាយនូវកម្រងព័ត៌មានស្តីពីការផ្តល់សេវាសាធារណៈ។

### ២.១.២. ការរីករាលដាលនូវជម្ងឺកូវីដ-១៩ នៅទូទាំងរាជធានី-ខេត្ត

ជម្ងឺរាតត្បាតកូវីដ១៩ បានផ្តល់នូវសម្ពាធយ៉ាងខ្លាំងដល់រដ្ឋាភិបាល ដែលវាតម្រូវឱ្យរដ្ឋាភិបាលអនុវត្តន៍បទបញ្ជា និងគោលនយោបាយថ្មីៗដើម្បីទប់ស្កាត់ការរីករាលដាលនៃជម្ងឺនេះ។ នៅប្រទេសកម្ពុជាបញ្ហាសេដ្ឋកិច្ចនិងសង្គម ដែលបង្កឡើងដោយជម្ងឺរាតត្បាតនេះភាគច្រើនកើតចេញពីការធ្លាក់ចុះនៃសកម្មភាពពាណិជ្ជកម្មនៅ

ថ្នាក់ជាតិ និងអន្តរជាតិជាពិសេសការធ្លាក់ចុះយ៉ាងខ្លាំងលើវិស័យទេសចរណ៍ជាអន្តរជាតិ។ តួរយ៉ាងរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវបទប្បញ្ញត្តិបន្ទាន់ជាច្រើន ដើម្បីទប់ស្កាត់ការរីករាលដាលនៃជម្ងឺនេះក៏ដូចជាដើម្បីទប់ទល់ផលប៉ះពាល់អវិជ្ជមានរបស់វាទៅលើសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេស។ ជាក់ស្តែងចំនួនករណីផ្ទុក និងអត្រានៃការកើតមានជម្ងឺកូវីដ១៩នៅប្រទេសកម្ពុជាមានកម្រិតទាប បើប្រៀបធៀបទៅនឹងប្រទេសជាច្រើននៅលើពិភពលោកនេះបើយោងទៅតាមអង្គការសុខភាពពិភពលោកខណៈករណីឆ្លងភាគច្រើន (៨៤%)ជាករណីនាំចូល។[83] ដំបូងឡើយអ្នកធ្វើដំណើរមកពីប្រទេសដែលមានអត្រាឆ្លងខ្ពស់មានដូចជា សហរដ្ឋអាមេរិក អាឡឺម៉ង់ បារាំង អេស្ប៉ាញ និងអ៊ីរ៉ង់ត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរចូលមកប្រទេសកម្ពុជាដើម្បីកាត់បន្ថយករណីឆ្លងនាំចូលខណៈប្រទេសដទៃទៀតត្រូវបានដាក់ចូលជាបន្តបន្ទាប់ក្នុងបញ្ជីដែលហាមឃាត់ក្នុងការធ្វើដំណើរចូលមកប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀតការឆ្លងកាត់ព្រំដែនក៏ត្រូវបានផ្អាកផងដែរ ដូចដែលប្រទេសកម្ពុជាបានបិទព្រំដែនរបស់ខ្លួនជាបណ្តោះអាសន្នជាមួយប្រទេសវៀតណាម។

អ្នកទេសចរ ដែលវិលត្រឡប់មកប្រទេសកម្ពុជាពីប្រទេសផ្សេងៗវិញក៏ត្រូវឆ្លងកាត់ការធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃផងដែរ ដែលនេះជាវិធានការណ៍បង្ការទុកជាមុនប្រឆាំងនឹងការឆ្លង។ ទោះជាយ៉ាងណាចាប់តាំងពីខែឧសភារដ្ឋាភិបាលកម្ពុជាបានបន្ធូរបន្ថយការរឹតត្បិតការធ្វើដំណើរអន្តរជាតិ ដោយបានអនុញ្ញាតឱ្យអ្នកដំណើរបរទេសមកពីប្រទេសមួយចំនួនដូចជាអ៊ីតាលី អេស្ប៉ាញ និងបារាំង។[84] ជនជាតិបរទេសដែលមកពីប្រទេសផ្សេងៗទៀតត្រូវបានតម្រូវឱ្យមានការធ្វើតេស្តអវិជ្ជមានក្នុងរយៈពេល ៧២ ម៉ោងចុងក្រោយ ហើយពួកគេក៏ត្រូវមានទឹកប្រាក់សម្រាប់ការធានារ៉ាប់រងសុខភាពចំនួន ៥ ម៉ឺនដុល្លារដើម្បីចំណាយលើការព្យាបាលក្នុងករណីមានឆ្លងនូវជម្ងឺកូវីដ១៩។ ច្បាប់ក្នុងការដាក់ប្រទេសក្នុងស្ថានភាពអាសន្ន ត្រូវបានអនុម័តដែលជាវិធានការណ៍មួយដែលអាចនឹងត្រូវបានអនុវត្តន៍ប្រសិនបើចាំបាច់ក្នុងការទប់ស្កាត់ការរីករាលដាលនៃកូវីដ១៩ និងដើម្បីធានានូវសុវត្ថិភាពរបស់ប្រជាជនកម្ពុជា។ ច្បាប់នេះបានផ្តល់ឱ្យរដ្ឋាភិបាលនូវអំណាចបន្ថែមទៀត ដូចជាការឃ្លាំមើលទៅលើផ្នែកទំនាក់ទំនងទូរគមនាគមន៍ដើម្បីគ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ននៅពេលមានជម្ងឺរាតត្បាត។ ការអនុម័តច្បាប់ស្តីពីការដាក់ប្រទេសក្នុងស្ថានភាពអាសន្នបានបង្កការទាក់ទាញចំណាប់អារម្មណ៍យ៉ាងខ្លាំងដោយសារតែផលជាប់ពាក់ព័ន្ធរបស់វាទៅលើសិទ្ធិមនុស្ស និងសេរីភាពរបស់ប្រជាជនខណៈពេលដែលប្រទេសកម្ពុជាបានកំពុងប្រឈមមុខនឹងការរិះគន់រួចទៅហើយជុំវិញការមិនបានគោរពតាមគោលការណ៍សិទ្ធិមនុស្ស។ ភាពមានកម្រិតទៅលើតម្លាភាព និងការពិគ្រោះយោបល់សុទ្ធសឹងតែជាដែនកំណត់នៃការអនុវត្តន៍ការដាក់ប្រទេសក្នុងស្ថានភាពអាសន្ននៅក្នុងប្រទេសកម្ពុជា។[85]

### ២.១.៣. ការចាត់វិធានការទប់ស្កាត់នូវជម្ងឺកូវីដ-១៩ តាមរយៈប្រព័ន្ធបច្ចេកវិទ្យា

រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានភ្លាមៗអំពីការទប់ស្កាត់នូវការបង្កឡើងពីជម្ងឺកូវីដ-១៩ ដែលកំពុងរីករាលដាលខ្លាំងរហូតមកដល់បច្ចុប្បន្ន។ ការចាត់វិធានការនេះ គឺសំដៅលើការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាលើការ

[83] គេហទំព័រ https://www.who.int/docs/default-source/wpro—documents/countries/cambodia/covid-19/covid-19-joint-who-moh-sitrep-05.pdf?sfvrsn=845 ដកស្រង់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១

[84] គេហទំព័រ https://focusweb.org/cambodia-covid-19-situationer/.ដកស្រង់ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២១

[85] គេហទំព័រ https://www.asiapacific.ca/publication/cambodias-state-emergency-law-and-fight-against-covid-19 ដកស្រង់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១

ផ្សព្វផ្សាយ, ការប្រកាសតាមបណ្ដាញប្រព័ន្ធអ៊ីនធឺណេត អំពីការទប់ស្កាត់ក្នុងការកើនឡើងនៃជម្ងឺ។ គ្រប់កន្លែងធ្វើការក្រសួង-ស្ថាប័នរដ្ឋ, ក្រុមហ៊ុនឯកជន, សាកលវិទ្យាល័យ, សាលារៀនរដ្ឋ, សាលារៀនឯកជន, កន្លែងទីប្រជុំជន (មានមនុស្សច្រើនធ្វើឱ្យមានហានិភ័យខ្ពស់), កន្លែងបោះដុំអីវ៉ាន់ធំៗ, ផ្សារទំនើប (កន្លែងមានម៉ាស៊ីនត្រជាក់ច្រើនក៏អាចងាយនឹងឆ្លងរហ័ស), និងបណ្ដាលហាងនានា (ភោជនីយដ្ឋានជាដើម)។ ការជួយពីប្រជាពលរដ្ឋក្នុងការទប់ស្កាត់បន្ថែម ជៀសវាងការជួបជុំផ្ទាល់ជាមួយមនុស្សច្រើននៅទីកន្លែងណាមួយ ត្រូវមកទាក់ទងគ្នាតាមបណ្ដាញប្រព័ន្ធអេឡិចត្រូនិក ដូចជាការប្រើប្រាស់ទូរស័ព្ទ (ចុច Call ឬVideo Call សម្រាប់ទំនាក់ទនង) ប្រព័ន្ធអ៊ីនធឺណេតប្រើប្រាស់ដោយកុំព្យូទ័រអាចប្រើបានជាមួយបណ្ដាល Email, Message, Facebook, Telegram, Line, និងApps ជាច្រើនទៀតផងដែរ។ ការដឹងជញ្ជូន ឬមានការបញ្ជាទិញអីវ៉ាន់ពីអតិថិជន យើងអាចមកផ្លាស់ប្ដូរឱ្យក្រុមហ៊ុនដឹកជញ្ជូនមកទទួល និងយកទៅឱ្យអ្នកទិញផ្ទាល់បានតាមរយៈបណ្ដាញទាក់ទងអ៊ីនធឺណេត ឬប្រើ App ដែលយើងបានចុះឈ្មោះសម្រាប់ការដាក់កុម៉្មង់ ឬឱ្យដឹកជញ្ជូនដោយមិនចាំបាច់ចេញពីកន្លែងស្នាក់នូវ។

❖ **ក្រសួង-ស្ថាប័នរដ្ឋ និងក្រុមហ៊ុនឯកជន**

ការប្រកាសឱ្យបុគ្គលិកទាំងធ្វើការបម្រើរដ្ឋ និងបម្រើវិស័យឯកជនចាប់ផ្ដើមអនុវត្តន៍វិធានការទប់ស្កាត់លើបរិបទជម្ងឺកូវីដ-១៩ បន្តការផ្ទុះឡើង។ ការប្រកាសឱ្យមានការកាត់បន្ថយចំនួនបុគ្គលិក នៅក្នុងកន្លែងធ្វើការស្ថិតក្នុងការិយាល័យឱ្យមានចំនួនតិចជាងមុន (កាត់បន្ថយពាក់កណ្ដាល ឬច្រើនជាងនឹង) មូលហេតុចង់ឱ្យមានការរក្សាគម្លាតពីគ្នា និងអាចថែរក្សាសុខភាពបានខ្ពស់។ កន្លែងធ្វើការក្រុមហ៊ុនឯកជនត្រូវមានការប្រុងប្រយ័ត្នប្រសិនជាអាចឱ្យបុគ្គលិកធ្វើការពីផ្ទះដោយអនឡាញបានត្រូវមានការអនុញ្ញាត និងប្រសិនបើក្រុមហ៊ុនមិនអាចខ្វះអ្នកប្រចាំការបាននៅកន្លែងធ្វើការត្រូវមានការផ្លាស់វេនរវាងបុគ្គលិកដូចជាខាងរដ្ឋបាលជាដើម។

❖ **ក្រសួងសុខាភិបាល**

ក្រសួងសុខាភិបាលបានប្រកាសដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យា QR Code "ទប់ស្កាត់កូវីដ-១៩ Stop Covid-19"។ សេចក្ដីប្រកាសនេះផ្ដែកលើការឆ្លងរីករាលដាលនៃជម្ងឺនេះត្រូវមានយុទ្ធសាស្ត្រក្នុងការទប់ស្កាត់បន្ថែម គណនៈកម្មាធិការអន្តរក្រសួងប្រយុទ្ធនឹងជម្ងឺកូវីដ-១៩ បានជម្រាបឱ្យបានដឹងថា ការបង្កើនប្រសិទ្ធភាពការបង្ការ និងទប់ស្កាត់ជៀសវាងហានិភ័យនៃការរីករាលដាលពីស្ថានភាពជម្ងឺ Covid-19 ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានដាក់ឱ្យប្រើប្រាស់ QR Code នៅពេលចេញចូលទៅតាមទីកន្លែងណាមួយដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន កន្លែងកម្សាន្ត អាគារស្នាក់នៅរួម ខុនដូ ក្រុមហ៊ុន រោងចក្រ សហគ្រាស ដែលជាទីតាំងមានមនុស្សចេញចូលច្រើនដើម្បីផ្ដល់ភាពងាយស្រួលក្នុងការតាមដានការ Scan ព័ត៌មានតាមប្រព័ន្ធបច្ចេកវិទ្យា QR Code បានលឿន ហើយងាយគ្រប់គ្រងបានពីទីតាំងដែលប្រជាពលរដ្ឋបានទៅ។

ក្នុងករណីនេះ ប្រសិនជាមានករណីផ្ទុះកូវីដ-១៩ កើតឡើងនៅកន្លែងណាមួយផ្ដល់ភាពងាយស្រួលអំពីទិន្នន័យព័ត៌មានដែលបានរក្សាក្នុងប្រព័ន្ធបច្ចេកវិទ្យា។

➢ **ការចុះឈ្មោះចាក់វ៉ាក់សាំងតាមរយៈប្រព័ន្ធអនឡាញ**

ដើម្បីចុះឈ្មោះតាមប្រព័ន្ធអនឡាញ តម្រូវឱ្យលោកអ្នកស្កេន QR CODE ឬចូលទៅកាន់ Website របស់ក្រសួងសុខាភិបាលតាមរយៈ (LINK): https://cambodia-vaccine.gov.kh/login ដើម្បីទាញយក និង

ដំឡើងកម្មវិធីចាក់វ៉ាក់សាំង (Khmer Vacc APP)។ បន្ទាប់មកចូលទៅកាន់កម្មវិធីចាក់វ៉ាក់សាំងខ្មែរ រួចចុចលើពាក្យចុះឈ្មោះថ្មី និងបញ្ចូលឈ្មោះទៅតាមការណែនាំឱ្យបានត្រឹមត្រូវអំពី[៨៦]៖

- គោត្តនាម និងនាម
- ឈ្មោះជាអក្សរឡាតាំង
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- លេខអត្តសញ្ញាណប័ណ្ណ
- លេខទូរស័ព្ទ

➢ **អាស័យដ្ឋានបច្ចុប្បន្ន**

- រាជធានី-ខេត្ត
- ស្រុក-ខណ្ឌ
- ឃុំ-សង្កាត់

➢ **បញ្ចូលឈ្មោះ និងលេខសម្ងាត់ដែលបានចុះរួច** (រួចចុចពាក្យ "បញ្ជូន")

- ឈ្មោះ
- ពាក្យសម្ងាត់ថ្មី
- ពាក្យសម្ងាត់ថ្មីម្តងទៀតជាការស្រេច។

នៅពេលដែលអ្នកធ្វើការចុះឈ្មោះតាមប្រព័ន្ធអនឡាញរួចរាល់នោះខាងក្រសួងនឹងធ្វើការទាក់ទងរៀបចំផ្ញើសារចូលប្រអប់សារតាមរយៈប្រព័ន្ធព័ត៌មានដែលអ្នកបានបំពេញ។ ការចុះឈ្មោះនេះផ្តល់ភាពងាយស្រួលទៅកាន់ប្រជាពលរដ្ឋទទួលដឹងនៅទីតាំងដែលត្រូវទៅចាក់វ៉ាក់សាំងលើកទី១ នៅតាមបណ្តាលមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែកតាមខេត្ត មន្ទីរបង្អែកស្រុក ឬចូលទៅកាន់ប្រអប់សារដែលក្រសួងបានផ្ញើសារមកទៅកាន់អាគារចាក់វ៉ាក់សាំងកូវីដ-១៩ (COVID-19 VACCINE STATION) ដែលមានអាយុចាប់ពី១៨ ឆ្នាំឡើងទៅ ដើម្បីទទួលបានការចាក់វ៉ាក់សាំងការពារជម្ងឺកូវីដ-១៩។ មុននឹងទទួលបានការចាក់វ៉ាក់សាំង គ្រូពេទ្យនឹងធ្វើការណែនាំអំពីប្រភេទវ៉ាក់សាំងដែលត្រូវចាក់ជូន។ ការចាក់វ៉ាក់សាំងលើកទី២ អាចទៅតាមទីតាំងកន្លែងដដែល ឬធ្វើការចាក់លើកទី២ក្បែរផ្ទះរបស់ប្រជាពលរដ្ឋក៏បាន អាស្រ័យទៅតាមកន្លែងនោះមានប្រកាសចាក់វ៉ាក់សាំងលើកទី២ដែរ។ នៅពេលការចាក់វ៉ាក់សាំងទាំងពីរលើករួច អ្នកនឹងទទួលបានកាតវ៉ាក់សាំងភ្លាមៗពីកន្លែងចាក់សម្រាប់កាតមានរូបរាងពណ៌ខៀវ។ ប៉ុន្តែសម្រាប់កន្លែងចាក់វ៉ាក់សាំងណាដែលធ្វើការថតរូបជាមួយគ្នាក្នុងការចាក់វ៉ាក់សាំងដែរត្រូវធ្វើការរងចាំនៅរយៈពេលក្រោយនៃការទទួលបានកាត ដោយសារគេត្រូវបោះពុម្ពរូបថតដែលបានថតភ្ជាប់ជាមួយកាត ប៉ុន្តែកាតទាំងពីរនេះមានកន្លែងសម្រាប់ស្កេនកូដ (Scan Code) បានដូចគ្នា។ ហើយអ្នកដែលមិនទាន់ទទួលបានកាតការចាក់លើកទីពីររួច គេនឹងឱ្យក្រដាសប្រកាន់ដៃសម្រាប់សម្គាល់ថាលោកអ្នកពិតជាបានចាក់ទាំងពីរលើករួចពិតមែន។ ចំពោះការចាក់វ៉ាក់សាំងបង្ការជម្ងឺកូវីដ-១៩នេះ គឺធ្វើឡើងដោយការស្ម័គ្រចិត្ត និងឥតគិតថ្លៃ។[87]

[86] គេហទំព័រ https://cambodia-vaccine.gov.kh/login ដកស្រង់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១

[87] គេហទំព័រ https://youtu.be/Cv5YSq989tc ដកស្រង់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១

ចំពោះភោជនីយដ្ឋាន និងទីប្រជុំជននៅតាមទីកន្លែងបរិភោគនីមួយៗ ត្រូវមានការស្កេន QR CODE ដើម្បីងាយស្រួលគ្រប់គ្រងចំនួនអ្នកដែលធ្វើការចេញចូលរួមទាំងបុគ្គលិកដែលកំពុងធ្វើការ អតិថិជន និងអ្នកដឹកជញ្ជូនទៅដល់គេហដ្ឋានជាដើម។ ការធ្វើបែបនេះមានលក្ខណៈល្អប្រសើរខ្លាំងក្នុងការជួយធ្វើការទប់ស្កាត់នៃជម្ងឺកូវីដ-១៩។ ហើយត្រូវធ្វើតាមការណែនាំរបស់ក្រសួងសុខាភិបាលអំពីការរក្សាគម្លាត កំណត់ចំនួនមនុស្សមិនឱ្យច្រើនលើសហួសពេក និងប្រកាន់គោលជំហរឱ្យបានខ្ជាប់ខ្ជួនមិនឱ្យខុសគោលការណ៍ក្នុងសេចក្តីជូនដំណឹង។

ក្រសួងបានធ្វើការប្រកាស អំពីកន្លែងដែលមានមនុស្សច្រើនត្រូវធ្វើការកាត់បន្ថយ និងរក្សាគម្លាតពីគ្នា។ នៅទីកន្លែងផ្សារសេរីដូចជារឿងពិបាកក្នុងការគ្រប់គ្រងបន្តិចដោយសារមូលហេតុមួយចំនួនលើមុខរបរដែលប្រជាជនខំប្រឹងប្រែងរកស៊ីទាំងភ័យខ្លាចផងដែរ។ ការប្រឈមនឹងការឆ្លងវីរុសលឿនដោយសារមនុស្សច្រើន និងមិនអាចសម្គាល់រោគសញ្ញាវិនិច្ឆ័យបានខ្ជាប់ខ្ជួនល្អ។

- **ក្រសួងអប់រំ យុវជន និងកីឡា**

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការសម្រាប់ការសិក្សាពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាដើម្បីដោះស្រាយបញ្ហាក្នុងការសិក្សាស្របពេលនៃការផ្ទុះឡើងជម្ងឺកូវីដ១៩ និងដើម្បីបង្កើនសមត្ថភាពសម្រាប់ការអប់រំនៅពេលអនាគត។ ជាលើកដំបូងបង្អស់ដែលកម្មវិធីសិក្សានៅទូទាំងកម្ពុជាត្រូវបានផ្លាស់ប្តូរពីការសិក្សានៅតាមសាលារៀនផ្ទាល់មកជាការសិក្សាតាមប្រព័ន្ធអនឡាញ(Online) ទាំងស្រុងដោយក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតកម្មវិធីសិក្សាពីចម្ងាយសម្រាប់ចាប់ពីថ្នាក់មត្តេយ្យសិក្សាដល់មធ្យមសិក្សាដើម្បីបង្ការការរីករាលដាលនៃជម្ងឺកូវីដ១៩។ លើសពីនេះទៅទៀតក្រសួងក៏បានរៀបចំរួចជាស្រេចនូវទស្សនវិស័យសំខាន់ៗដើម្បីពង្រឹងប្រព័ន្ធអប់រំតាមបែបឌីជីថល (Digital) នៅព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើងសម្រាប់ពេលខាងមុខ។ អគ្គលេខាធិការ និងជាអ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជាក់ប្រាប់ Focus ថាដើម្បីចូលរួមទប់ស្កាត់ការរាតត្បាតនៃជម្ងឺកូវីដ១៩ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតឱ្យមានការសិក្សាពីចម្ងាយ និងប្រព័ន្ធអេឡិចត្រូនិកដោយការផ្សាយតាមរយៈប៉ុស្តិ៍ទូរទស្សន៍ គេហទំព័រ ទំព័រហ្វេសប៊ុកជាដើម ដើម្បីជួយសម្រួលក្នុងការសិក្សា និងការបង្រៀននៅទូទាំងប្រទេស។ ជាទូទៅ ក្រសួងអប់រំ យុវជន និងកីឡា សង្កេតឃើញថាមាតាបិតា សិស្សានុសិស្ស និងគ្រប់ភាគីពាក់ព័ន្ធបានស្វាគមន៍ គាំទ្រសេវាសិក្សាពីចម្ងាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសជាមួយនឹងការផ្សាយតាមរយៈប្រព័ន្ធបច្ចេកវិទ្យាអ៊ីនធឺណេត (Zoom, Loom, Microsoft Team, Google Classroom, Email, និងTelegram ជាដើម) តាមរយៈទូរទស្សន៍ដែលអាចបន្តឱ្យមានការរៀន និងបង្រៀននៅទីក្រុង និងជនបទទូទាំង ២៥ រាជធានី-ខេត្ត ក្នុងឱកាសចូលរួមទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ១៩។

ការសិក្សារបស់និស្សិត និងសិស្សត្រូវធ្វើការផ្អាកការសិក្សាជាបណ្តោះអាសន្ន និងប្តូរមករៀនតាមប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗ ដើម្បីជួយបង្ការការឆ្លងរីករាលដាលបន្ថែម។ ជាពិសេស "និស្សិតនៅកម្ពុជានៅមានកង្វះការយល់ដឹងអំពីការរៀនសូត្រឯករាជ្យដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការរៀនសូត្រពីចម្ងាយ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់និតរបស់ប្រជាជនកម្ពុជាមិនទាន់ត្រៀមខ្លួនដើម្បីសម្របខ្លួនពេញលេញទៅនឹងការរៀនសូត្រពីចម្ងាយ និងការសិក្សាតាមអេឡិចត្រូនិកនៅឡើយទេ"។ អ្នកជំនាញផ្នែកអប់រំរូបនេះបានលើកឡើងពីវិធានការមួយចំនួនដែលលោកយល់ថាវាសំខាន់សម្រាប់ការរៀបចំការសិក្សាតាមប្រព័ន្ធអនឡាញនៅកម្ពុជាឱ្យមានប្រសិទ្ធភាព។

លោកស្នើឱ្យមានគម្រោងផ្សព្វផ្សាយគោលនយោបាយប្រសើរជាងមុនដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគាំទ្រ និង យុទ្ធសាស្ត្រប្រតិកម្មក្នុងការចូលរួមដោះស្រាយបញ្ហា និងការអនុវត្ត។ បន្ថែមពីលើនេះ លោកថាការកែលំអនៅតាមសាលារដ្ឋដោយត្រូវបង្កើនចំនួនសម្ភារ និងគប្បីមានគម្រោងអភិវឌ្ឍន៍សមត្ថភាពដល់បុគ្គលិកបន្ថែមទៀត។ ការសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជាស្តីពីអក្ខរកម្មឌីជីថលកាលពីខែតុលា ឆ្នាំ២០១៩ បានបង្ហាញថាដើម្បីអភិវឌ្ឍខ្លួនឱ្យក្លាយទៅជាសង្គមឌីជីថលមួយ ដែលពេញលេញកម្ពុជាត្រូវការយុទ្ធសាស្ត្ររយៈពេលវែងក្នុងការពង្រឹងវិស័យសំខាន់ៗដូចជាវិស័យអប់រំ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងក្របខណ្ឌច្បាប់ក្នុងការគ្រប់គ្រង ពីព្រោះកម្ពុជាមានបញ្ហាប្រឈមជាច្រើនដូចជាធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធឌីជីថល អភិបាលកិច្ច និងការច្នៃប្រឌិតឌីជីថល។ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំសម្រាប់ឆ្នាំ២០១៩-២០២៣ ដែលក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញក៏មានដាក់បញ្ចូលអំពីការអប់រំតាមបែបឌីជីថល ដើម្បីឆ្លើយតបនឹងគោលនយោបាយ និងទិសដៅនៃសេដ្ឋកិច្ចឌីជីថលកម្ពុជា។[88]

- **ក្រសួងពាណិជ្ជកម្ម**

ការដាក់ឱ្យប្រើប្រាស់ទីផ្សារអនឡាញក្រសួងពាណិជ្ជកម្មសម្រាប់លក់គ្រឿងឧបភោគ បរិភោគចាំបាច់ក្នុងអំឡុងពេល បិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល។ ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា យោងតាមសេចក្តីណែនាំ លេខ០១ សណន ស្តីពីវិធានការលម្អិតដើម្បីរឹតបន្តឹងការអនុវត្តសេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានី ភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល ក្រសួង បានដាក់ឱ្យប្រើប្រាស់ទីផ្សារអនឡាញក្រសួងពាណិជ្ជកម្មសម្រាប់លក់គ្រឿងឧបភោគបរិភោគចាំបាច់ជូនប្រជាពលរដ្ឋរស់នៅក្នុងតំបន់ក្រហម ចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ នេះតទៅ ។

ដើម្បីធ្វើការបញ្ជាទិញ សូមចូលទៅកាន់គេហទំព័រ https://shop.moc.gov.kh/ ឬតាម QR Code (ដូចបានបង្ហាញក្នុងឧបសម្ព័ន្ធខាងក្រោម)។[89]

## ២.២.លទ្ធផល និងការវិភាគលើការអនុវត្តការងារនៃរដ្ឋាភិបាលឌីជីថល

ការបញ្ជ្រាបការយល់ដឹង និងជំនាញឌីជីថលទៅដល់ អ្នកដឹកនាំនៅតាមសហគមន៍មូលដ្ឋាន ក៏មានភាពប្រសើរឡើងជាលំដាប់។ នៅក្នុងវិស័យឯកជន ការចាប់យកឌីជីថលនៅក្នុងធុរកិច្ច និងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ យ៉ាងណាមិញ ការផ្លាស់ប្តូរទៅរកភាពជាអ្នកដឹកនាំឌីជីថល ដែលឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាចាំបាច់ត្រូវការនូវកិច្ចខិតខំរយៈពេលវែងក្នុងការអភិវឌ្ឍអ្នកដឹកនាំឌីជីថល និងការកសាងភាពជាអ្នកដឹកនាំឌីជីថល។ ការទាក់ទាញធនធានមនុស្សមានទេពកោសល្យឌីជីថល។ ធនធានប្រភេទនេះ គឺជាតួអង្គដ៏សំខាន់នៅក្នុងការដែលបរិការណ៍នៃបរិវត្តកម្មឌីជីថល ដែលចូលរួមធានាបាននូវការបង្កើតថ្មី និងនវានុវត្តន៍ រាប់ទាំងការបង្កើតធុរកិច្ចថ្មីៗ ការដោះស្រាយបញ្ហាបានឆាប់រហ័សក្នុងប្រព័ន្ធICT និងការការពារសុវត្ថិភាពនៃប្រព័ន្ធទាំងមូល។ តាមការប៉ាន់ស្មានបច្ចុប្បន្នកម្ពុជា

[88] គេហទំព័រ https://www.moeys.gov.kh/index.php/kh/dgaf/3735.html#.YQy-2o5KjlU ដកស្រង់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១

[89] សេចក្តីប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់ទីផ្សារអនឡាញក្រសួងពាណិជ្ជកម្មសម្រាប់លក់គ្រឿងឧបភោគ បរិភោគចាំបាច់ ក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល

មានធនធានមនុស្សដែលជាអ្នកមានទេពកោសល្យឌីជីថល ប្រមាណ ៥០,០០០ នាក់។ ជាមួយគ្នានេះ អត្រានិស្សិតចុះឈ្មោះចូលរៀនលើជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ក្នុងកម្រិតឧត្តមសិក្សាមានប្រមាណត្រឹម ២៧,១% តែប៉ុណ្ណោះ ខណៈ ដែលប្រមាណ ០,០៣% ផ្សេងទៀត បានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ។ ម្យ៉ាងវិញទៀតជំនាញផ្នែកបច្ចេកវិទ្យាទាំងនោះមិនទាន់មានលក្ខណៈប្រមូលផ្ដុំ និងមិនស៊ីជម្រៅតាមឯកទេសនៅឡើយ។ ការណ៍នេះបង្ហាញឱ្យឃើញថា ធនធានមនុស្សដែលមានជំនាញឌីជីថលនៅកម្ពុជានៅមិនទាន់អាចឆ្លើយតបទៅនឹង តម្រូវការជំនាញជាក់ស្ដែងនៅក្នុងទីផ្សារ ជាពិសេសជំនាញដែលជាមូលដ្ឋានក្នុងការអភិវឌ្ឍ និងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល ។ គួរកត់សម្គាល់ថារាជរដ្ឋាភិបាលបាន និងកំពុងដាក់ចេញនូវកិច្ចខិតខំប្រឹងប្រែងមួយចំនួនដើម្បីសម្រួចជំនាញទាំងនោះតាមរយៈការអប់រំបណ្ដុះបណ្ដាល និងការអនុវត្តជាដើម។ ជាក់ស្ដែងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះមានការបង្កើតនូវគំនិតផ្ដួចផ្ដើមថ្មីៗដូចជា ការបង្កើតឡើងនូវមូលនិធិអភិវឌ្ឍន៍ជំនាញ មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី និងមជ្ឈមណ្ឌល ICT ជាដើម។ បន្ថែមពីលើនេះវិស័យឯកជនក៏បាន និងកំពុងចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍ធនធានមនុស្សឌីជីថលផងដែរ។ ជាក់ស្ដែងនាពេលកន្លងមកក្រុមហ៊ុនទូរគមនាគមន៍នានាបានសហការជាមួយនឹងរាជរដ្ឋាភិបាលក្នុងការបង្កើតមូលនិធិកសាងសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យទូរគមនាគមន៍ និងICT។ មូលនិធិនេះបានរួមចំណែកយ៉ាងច្រើនក្នុងការកសាងសមត្ថភាព និងជំនាញឌីជីថលសម្រាប់យុវជនតាមរយៈកម្មវិធីផ្ដល់អាហារូបករណ៍សិក្សាផ្នែកបច្ចេកវិទ្យាព័ត៌មានការបំពាក់បរិក្ខារ បច្ចេកវិទ្យានៅតាមសាលារៀន និងព្រឹត្តិការណ៍ផ្សព្វផ្សាយ និងប្រកួតប្រជែងលើផ្នែកបច្ចេកវិទ្យាជាដើម។ ទោះជាយ៉ាងនេះ ការកសាងធនធានមនុស្សជាកិច្ចការរយៈពេលវែង ដែលត្រូវការទាំងការបណ្ដុះបណ្ដាល និងការអនុវត្តឱ្យបានជិតដល់។

ឆ្លងកាត់ការអនុវត្តកម្មវិធីកំណែទម្រង់ ទំនើបកម្ម ការពង្រឹងអនុលោមភាព និងការអនុវត្តច្បាប់ជាបន្តបន្ទាប់ ទាំងកម្មវិធីសម្រាប់រយៈពេលខ្លី និងរយៈពេលមធ្យមនាពេលកន្លងមក អគរ សម្រេចបានលទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- បានរៀបចំ និងដាក់ឱ្យអនុវត្តន៍ជាបន្តបន្ទាប់នូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីលើកកម្ពស់អនុលោម និងការអនុវត្តច្បាប់
- បានចុះធ្វើសវនកម្មក្រោមពេលបញ្ចេញទំនិញទៅតាមសហគ្រាស និងបានជំរុញវិស័យឯកជនឱ្យងាកទៅរកអនុលោមភាព និងការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត
- បានលើកកម្ពស់ការយល់ដឹងជាសាធារណៈតាមរយៈការផ្សព្វផ្សាយនូវបទប្បញ្ញត្តិ នីតិវិធី និងព័ត៌មានពាក់ព័ន្ធ
- បានពង្រឹងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិដើម្បីចែករំលែកព័ត៌មាន និងជួយគ្នាទៅវិញទៅមកលើការអនុលោមភាព និងការអនុវត្តច្បាប់តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា
- បានកសាងធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ និងសមត្ថភាពជំនាញបច្ចេកទេស ព្រមទាំងបានបំពាក់មធ្យោបាយបំពេញការងារ ស្របតាមការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យា និងសកលភាវូនីយកម្មបានបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ បន្លំពន្ធ និងបទល្មើសឆ្លងដែនផ្សេងៗជាច្រើនករណី។

ឌីជីថលក្នុងការងារសាធារណៈរបស់ស្ថាប័នរដ្ឋ និងមន្ត្រីរាជការ ប៉ុន្តែនៅប្រឈមនឹងបញ្ហាមួយចំនួនដូចជាកម្រិតនៃការយល់ដឹងខុសគ្នា និងការព្រួយបារម្ភចំពោះកត្តាសន្តិសុខព័ត៌មាន និង សុវត្ថិភាពទិន្នន័យ។

ក្នុងន័យនេះការគិតគូរសម្រាប់ទិសដៅអនាគត ការអភិវឌ្ឍរដ្ឋាភិបាល និងសេវាសាធារណៈឌីជីថល និងផ្តោតទៅលើ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងស្រុង រួមទាំងនីតិវិធីនៃការអនុវត្តការងារ ផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក និងការផ្តល់ព័ត៌មាននានា, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា, ការលើកកម្ពស់ការយល់ដឹង និងជំនាញឌីជីថលដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ រួមទាំងនៅថ្នាក់មូលដ្ឋាន។

ការអនុវត្តឌីជីថល ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់មុខងារស្នូលរបស់ស្ថាប័នរដ្ឋ និងសេវាសាធារណៈពុំគ្រប់គ្រាន់សម្រាប់ប្រែក្លាយជារដ្ឋាភិបាលឌីជីថលពេញលេញឡើយ ព្រោះប្រព័ន្ធទាំងនេះត្រូវការថ្នាលបច្ចេកវិទ្យាមូលដ្ឋាន និងបទប្បញ្ញត្តិមួយចំនួនសម្រាប់គាំទ្រដែលខ្វះខាតនៅឡើយ។ ថ្នាលបច្ចេកវិទ្យាមូលដ្ឋានទាំងនោះមានដូចជា បច្ចេកវិទ្យាភ្ជោះលើមជ្ឈមណ្ឌលទិន្នន័យរួមរបស់រាជរដ្ឋាភិបាល ថ្នាលផ្លាស់ប្តូរទិន្នន័យសម្រាប់អន្តរប្រតិបត្តិការ និងសន្ទានកម្ម អត្តសញ្ញាណឌីជីថល និងប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន។[90]

### ២.២.១. សមិទ្ធផលនៃការអនុវត្តការងារ

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និងប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលនៅក្នុងវិស័យហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ។ នៅក្នុងវិស័យធនាគារការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកបាន និងកំពុងបន្តកើនឡើងតាមរយៈកំណើននៃចំនួនគណនីប្រាក់បញ្ញើ (៨,៩ លានគណនី) គណនីអេឡិចត្រូនិក (៦,៩១ លានគណនី) និងបណ្ណទូទាត់ (៦,៨ លានបណ្ណ) គួបផ្សំនឹងការបន្តធ្វើទំនើបកម្ម ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ចម្រុងៗដូចជាប្រព័ន្ធ Online Banking និងប្រព័ន្ធបាគងជាដើម។ ប៉ុន្តែអវត្តមាននៃការទូទាត់រួមសម្រាប់ពហុភាគីដែលអាចតភ្ជាប់បានគ្រប់ធនាគារ និងអ្នកចេញវិក្កយបត្រនៅតែជាកត្តារាំងស្ទះដ៏ធំមួយដល់ការពង្រីកសេវាតាមប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋ និងវិស័យឯកជន។ ទន្ទឹមនេះនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារការចាប់យកបច្ចេកវិទ្យាហិរញ្ញវត្ថុនៅមានកម្រិតតិចតួច។ ជារួមការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់ឌីជីថលនៅមានកម្រិតដោយហេតុថាការចូលរួមរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមួយចំនួននៅក្នុងដំណើរការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់សងប្រាក់ និងដំណើរការបរិវត្តកម្មឌីជីថលនៅមិនទាន់មានលក្ខណៈពេញលេញ និងរហូតនៅឡើយដោយសារស្ថានភាព និងធនធានរបស់គ្រឹះស្ថានផ្ទាល់។ ការណ៍នេះបានរារាំងដល់វិសាលភាពនៃការប្រើប្រាស់ និងលទ្ធភាពទទួលបានសេវាទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកគួបផ្សំនឹងប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់ឌីជីថល និងការយល់ដឹងរបស់សាធារណជនពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុឌីជីថលនៅមានកម្រិត។ ការបង្កើតឡើងត្រូវមានការពង្រឹងយុទ្ធសាស្ត្រអំពីគោលនយោបាយពាក់ព័ន្ធជាមួយប្រព័ន្ធបច្ចេកវិទ្យាដែលអាចជួយទ្រទ្រង់នូវការអភិវឌ្ឍផ្តល់សេវាជូនព័ត៌មានទៅកាន់ប្រជាពលរដ្ឋបានលឿន និងភាពទុកចិត្តនូវការផ្សព្វផ្សាយអំពីគោលបំណងនៃការចែកចាយមតិ ឬការផ្តល់ជូនតាមបណ្តាញអ៊ីនធឺណេត។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដឹកជញ្ជូនគ្រប់មធ្យោបាយ និងការរៀបចំនូវប្រព័ន្ធឡូហ្ស៊ីស្ទិក ដ៏រស់រវើកនៅមានកម្រិតនៅឡើយ។ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលរួមមាន ដូចជាផ្លូវថ្នល់ ផ្លូវដែក ផ្លូវអាកាស ផ្លូវទឹក និង ICTរបស់កម្ពុជានៅមិនទាន់មានភាពអំណោយផលដល់វិស័យឡូហ្ស៊ីស្ទិក។ ម្យ៉ាងទៀតការដឹកជញ្ជូនគោលដៅចុងក្រោយនៅមានលក្ខណៈបែកខ្ញែក និងមាន

[90] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥ ទំព័រទី១៣៥

លក្ខណៈប្រពៃណីនៅឡើយដែលធ្វើឱ្យថ្លៃដឹកជញ្ជូនមានកម្រិតខ្ពស់ និងមិនមានប្រសិទ្ធភាពសម្រាប់ធុរកិច្ចជាពិសេសសហគ្រាសខ្នាតតូច។ បន្ថែមលើនេះកង្វះមូលដ្ឋានទិន្នន័យនៃប្រព័ន្ធអាសយដ្ឋានជាក់លាក់ គឺជាកត្តាដ៏សំខាន់ដែលរាំងស្ទះដល់ការអភិវឌ្ឍវិស័យនេះឱ្យកាន់តែមានការរីកចម្រើន និងទំនើបខណៈដែលប្រតិបត្តិការនៃសេវាប្រៃសណីយ៍នៅក្នុងស្រុកនៅមានកម្រិតតិចតួចដោយសារភាពបែកប្លែកខ្លាំងនៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងវិស័យដឹកជញ្ជូន។ ជារួមវិស័យឡូជីស្ទិក និងដឹកជញ្ជូនគោលដៅចុងក្រោយនេះនៅពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងកំណើនតម្រូវការបច្ចុប្បន្ន និងនាពេលខាងមុខនៅឡើយដោយសារប្រតិបត្តិការដឹកជញ្ជូននៅមិនទាន់បានប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យបានពេញលេញជាពិសេសការដឹកជញ្ជូននៅក្នុងស្រុក ។

ការសម្រេចស្តីពីនាយកដ្ឋានព័ត៌មានវិទ្យាស្តីពីការរៀបចំ និងការប្រព្រឹតទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិកាដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានកែសម្រួល ហើយនឹងបំពេញបន្ថែម។ សមិទ្ធផលបានមកពីគម្រោងនានាក្នុងការដឹកនាំអនុវត្តន៍ប្រព័ន្ធបច្ចេកវិទ្យា រួមទាំងគម្រោងផ្តល់សេវាភ្ជាប់អ៊ីនធឺណេតទាំងបណ្តាញក្នុង និងក្រៅសម្រាប់ភាពងាយស្រួលក្នុងការចាប់យកនៃព័ត៌មានពិសេសៗ រួមទាំងសេវាផ្សេងៗ។ ការពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធបច្ចេកវិទ្យារួមមានប្រព័ន្ធទំនាក់ទំនងជាសម្លេងសាររូបភាពអេឡិចត្រូនិកនិងប្រព័ន្ធគ្រប់គ្រងឯកសារជាដើម។ នៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការដ្ឋានទាំងអស់នៃគម្រោងប្រព័ន្ធបច្ចេកវិទ្យាទំនើបៗត្រូវរៀបចំដោយនាយកដ្ឋាន។ ការផ្តល់យោបល់ និងអំពីរបៀបសិក្សារៀបចំចងក្រងឡើងនូវឯកសារតម្រូវបច្ចេកទេសសម្រាប់ផ្តល់ការពង្រឹងវិសាលភាពនៃការអនុវត្តប្រព័ន្ធទាំងនេះ។[91] ចំពោះការបំពេញការងារបច្ចេកវិទ្យានេះ គឺបានបំពេញដោយមុខងារជាសេនាធិបការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋាន លើការងារបច្ចេកវិទ្យា ដោយធ្វើការបំពេញភារកិច្ចដូចជា ការគ្រប់គ្រង និងអនុវត្តន៍នូវគម្រោងនានា។ អំពីការគ្រប់គ្រងនេះ តម្រូវឱ្យមានការសហការ ផ្តល់យោបល់ និងជួយសម្របសម្រួលខាងផ្នែកបច្ចេកទេសជូនទៅថ្នាក់ដឹកនាំក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានានៃក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ទៅលើការងារដែលពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ និងការផ្គត់ផ្គង់អនុវត្តន៍គោលនយោបាយសេដ្ឋកិច្ចឌីជីថលជាដើម។ គ្រប់ដំណាក់កាលនៃធនធានត្រូវធានាផលសម្រេច និងគោលដៅដែលបានដាក់ត្រូវប្រសិទ្ធថាធ្វើឱ្យបាន ហើយនឹងការកែទម្រង់នូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាលកម្ពុជា។

របៀបរៀបចំ ការបង្កើតឡើងត្រូវមានការពង្រឹងយុទ្ធសាស្ត្រអំពីគោលនយោបាយ ដែលពាក់ព័ន្ធជាមួយប្រព័ន្ធបច្ចេកវិទ្យា ដែលអាចជួយទ្រទ្រង់នូវការអភិវឌ្ឍ ផ្តល់សេវាជូនព័ត៌មានទៅកាន់ប្រជាពលរដ្ឋបានលឿន និងទុកចិត្តនូវការផ្សព្វផ្សាយអំពីគោលបំណងនៃការចែកចាយមតិ ឬការផ្តល់ជូនតាមបណ្តាញអ៊ីនធឺណេត។

**ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ៖**

១. ក្រសួង-ស្ថាប័នរដ្ឋនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាព និងប្រតិបត្តិការដូចខាងក្រោម៖

- ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើត ឬរក្សាទុកឯកសារ
- ការចេញអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត

[91] គេហទំព័រ https://fmis.mef.gov.kh/contents/uploads/2020/11/20200803_675_announcement_about_to_add_ITD_office_of_MEF_From_cabinet ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

- ការកំណត់មធ្យោបាយ និងរបៀបក្នុងការទូទាត់ប្រាក់
- សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ

២. នៅពេលដែល ក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាព ឬប្រតិបត្តិការណាមួយ។[92]

### ២.២.២. ការកែលម្អគុណភាពសេវាសាធារណៈ

បណ្តាក្រសួង និងស្ថាប័នរដ្ឋមួយចំនួនបាន និងកំពុងដំណើរការរដ្ឋបាល ICT និងគម្រោងឌីជីថលក្នុងនោះរួមមានការចុះបញ្ជីឌីជីថលសម្រាប់កម្មសិទ្ធិដីធ្លី ការចុះបញ្ជីយានយន្ត និងពន្ធដារជាដើម។ ជាមួយគ្នានេះ ការគ្រប់គ្រងចំណូលរបស់អង្គភាពប្រមូលចំណូលរដ្ឋក៏កំពុងតភ្ជាប់នឹងឌីជីថលជាជំហានៗ ជាពិសេស ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធប្រកាសពន្ធអនឡាញ (E-Filing) និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម និងឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញ (Online VAT Refund and Online VAT Credit) និងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window) និងថ្មីៗនេះ ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា (Online Business Registration) ជាដើម។ យោងតាមការស្ទង់មតិរបស់អង្គការសហប្រជាជាតិស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០២០, រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានវឌ្ឍនភាពល្អលើកិច្ចខិតខំប្រឹងប្រែងក្នុងការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក (Online Service Index) ដោយទទួលបានពិន្ទុ 0,៤៥ លើអនុសន្ទស្សន៍ការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិកនៃពិន្ទុមាត្រដ្ឋាន ១,00 ដែលខ្ពស់ខ្លាំងជាងប្រទេសមីយ៉ាន់ម៉ា និងឡាវ។

ការកើនឡើងនៃការធ្វើបរិវត្តកម្មឌីជីថលក្នុងរដ្ឋាភិបាលឌីជីថលជាសញ្ញាមួយល្អ ប៉ុន្តែក៏មានចំណុចអវិជ្ជមានមួយចំនួនដែលត្រូវគិតគូរ ដើម្បីអាចឈានទៅរករដ្ឋាភិបាលឌីជីថលពេញលេញមួយ។ បើទោះបីជាមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក៏ដោយក៏ស្ថាប័នរដ្ឋភាគច្រើននៅតម្រូវឱ្យផ្តល់ឯកសារ ឬព័ត៌មានដដែលៗ ដោយសារពុំមានការចែករំលែករវាងស្ថាប័នពាក់ព័ន្ធមួយចំនួនស្របពេលដែលការដាក់ឯកសារនៅតម្រូវក្នុងទម្រង់ជាក្រដាសស្នាម និងការទទួលយកតាមប្រព័ន្ធអេឡិចត្រូនិកនៅមានតិចតួចនៅឡើយ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលពុំទាន់មានស្តង់ដាបច្ចេកទេសតម្រូវ (Specification) រួមមួយសម្រាប់ជាលក្ខណៈកំណត់ក្នុងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលធានាបាននូវសង្គតិភាពនៃរូបរាងការរចនាផ្ទាំងកម្មវិធីអ្នកប្រើប្រាស់ (User Interface) យន្តការអន្តរប្រតិបត្តិការព្រមទាំងស្តង់ដាសន្តិសុខព័ត៌មាន និងសុវត្ថិភាពទិន្នន័យ។ ក្រៅពីការធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធរបស់ស្ថាប័នសាធារណៈដែលត្រូវគិតគូររាជរដ្ឋាភិបាលក៏ត្រូវផ្តល់លទ្ធភាពនៃការធ្វើសន្ទានកម្ម (Interface) ប្រព័ន្ធរបស់វិស័យសាធារណៈ ជាមួយនឹងវិស័យឯកជនដើម្បីឱ្យមានសហថាមពល (Synergy) និងការសហការបង្កើតថ្មី (Co-creation) ឬការសហការនវានុវត្តន៍ (Co-innovation) ក្នុងធុរកិច្ចរបស់ខ្លួន ដែលរួមចំណែកសម្រេចបានការស្រូបយក និងបរិវត្តកម្មឌីជីថល។

- ទំនាក់ទំនងសាធារណៈរវាងក្រសួង-ស្ថាប័ន និងប្រជាពលរដ្ឋត្រូវបានពង្រឹងតាមរយៈប្រព័ន្ធឌីជីថល ដែលរួមមាន ដូចជា ការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញសង្គម ដូចជា Facebook និង Youtube និងការចែករំលែកព័ត៌មាន និងឯកសារតាម Telegram និងWhatsApp របស់ក្រសួង-ស្ថាប័នជាដើម។

[92] មាត្រា៣២ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩

ការប្រើប្រាស់ប្រព័ន្ធទាំងនេះមិនត្រឹមតែជាការផ្លាស់ប្តូរ និងការផ្សព្វផ្សាយ គឺថែមទាំងជាការគ្រប់គ្រងព័ត៌មានដែលចៀសវាងបាននូវព័ត៌មានមិនពិតព័ត៌មានញុះញង់ និងព័ត៌មានមិនបានធ្វើបច្ចុប្បន្នភាព។

- ថ្មីៗនេះ ដោយសារផលវិបាកនៃជម្ងឺកូវីដ-១៩ កិច្ចប្រជុំ និងកិច្ចសន្ទនានានារវាងស្ថាប័នរដ្ឋ និងរដ្ឋ និងរវាងវិស័យទំនាក់ទំនងសាធារណៈរវាងក្រសួង-ស្ថាប័ន និងប្រជាពលរដ្ឋត្រូវបានពង្រឹងតាមរយៈប្រព័ន្ធឌីជីថលដែលរួមមាន ដូចជាការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញសង្គម ដូចជា Facebook និង Youtube និងការចែករំលែកព័ត៌មាន ឯកសារតាម Telegram និង WhatsApp របស់ក្រសួង-ស្ថាប័នជាដើម។ ការប្រើប្រាស់ប្រព័ន្ធទាំងនេះមិនត្រឹមតែជាការផ្លាស់ប្តូរ និងការផ្សព្វផ្សាយ គឺថែមទាំងជាការគ្រប់គ្រងព័ត៌មានដែលចៀសវាងបាននូវព័ត៌មានមិនពិត ព័ត៌មានញុះញង់ និងព័ត៌មានមិនបានធ្វើបច្ចុប្បន្នភាព។ ថ្មីៗនេះដោយសារផលវិបាកនៃជម្ងឺកូវីដ-១៩ កិច្ចប្រជុំ និងកិច្ចសន្ទនានានារវាងស្ថាប័នរដ្ឋ និងរដ្ឋ និងរវាងវិស័យសាធារណៈ និងវិស័យឯកជនត្រូវបានធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិកដូចជាតាមរយៈកម្មវិធី Zoom, Microsoft Teams និងGoogle Meet ជាដើម។ ទាំងនេះជាសញ្ញាណដំបូងនៃការទទួលយកផ្នត់គំនិតឌីជីថលក្នុងការងារសាធារណៈរបស់ស្ថាប័នរដ្ឋ និងមន្ត្រីរាជការប៉ុន្តែនៅប្រឈមនឹងបញ្ហាមួយចំនួនដូចជា កម្រិតនៃការយល់ដឹងខុសគ្នា ការព្រួយបារម្ភចំពោះកត្តាសន្តិសុខព័ត៌មាន និងសុវត្ថិភាពទិន្នន័យ។

ក្នុងន័យនេះការគិតគូរសម្រាប់ទិសដៅអនាគត ការអភិវឌ្ឍរដ្ឋាភិបាល និងសេវាសាធារណៈឌីជីថលនឹងផ្តោតលើ៖

១. ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងស្រុងរួមទាំងនីតិវិធីនៃការអនុវត្តការងារ ការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក និងការផ្តល់ព័ត៌មាននានា

២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា

៣. ការលើកកម្ពស់ការយល់ដឹង និងជំនាញឌីជីថលដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ រួមទាំងនៅថ្នាក់មូលដ្ឋាន ។

ការបង្កើតឡើងនាបច្ចុបនប្បន្នចំពោះការអភិវឌ្ឍផ្នែកខាងបច្ចេកវិទ្យានូវកម្មវិធីថ្មីៗ សម្រាប់ជួយលើកកម្ពស់ដល់ក្នុងវិស័យនេះជាបន្តបន្ទាប់។ ការប្រាស្រ័យទំនាក់ទំនងបន្ថែមបានធ្វើឱ្យដំណើរការក្នុងប្រព័ន្ធបច្ចេកវិទ្យារលូនទៅមុខល្អជាងពីមុន ជួយសម្រួលដល់ការបម្រើកិច្ចការ និងការប្រព្រឹត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។ មានការចូលរួមចំណែកក្នុងការសាងសងនៃសមត្ថភាពអ្នកដែលចេះចាត់ចែង និងប្រើប្រាស់ការគ្រប់គ្រងពិតប្រាកដទៅលើបណ្តាញជូនមន្ត្រីនៃក្រសួងសម្រាប់ការចុះផ្សាយនូវព័ត៌មានថ្មីៗបានរហ័សមិនមានភាពរអាក់រអួល។

មិនតែប៉ុណ្ណោះមានការចូលរួមប្រតិបត្តិបំពេញការងារ ឬគម្រោងការផ្សេងៗទៀតតាមការកំណត់ណាមួយរបស់អគ្គលេខាធិការដ្ឋាន ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើវិស័យបច្ចេកវិទ្យាអំពីព័ត៌មាន និងគមនាគមន៍។

ត្រូវបានកែសម្រួលតម្លៃសេវាសាធារណៈលើប្រភេទសេវាចំនួនបីនៃកម្រងសេវាសាធារណៈ ដែលជាឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១២១៧ សហវ. ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម៖

| លេខរៀង ចំនួនសេវា | បរិយាយ | តម្លៃសេវាចាស់ | តម្លៃសេវាកែសម្រួលថ្មី |
|---|---|---|---|
| | I. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម | | |
| | នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម | | |
| | ក. ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | | |
| ១ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ១ ៦៨០ ០០០ រៀល | ១ ០១០ ០០០ រៀល |
| ២ | ២ សហគ្រាសឯកបុគ្គល ឬពាណិជ្ជករ ដែលត្រូវចុះបញ្ជី | ៣០០ ០០០ រៀល | ១៨០ ០០០ រៀល |
| ១៤ | ឆ. ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស | ៤០ ០០០ រៀល | ២៥ ០០០ រៀល |

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។[93]

### ២.២.៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្សឱ្យមានភាពជាអ្នកដឹកនាំឌីជីថល គឺជានិន្នាការថ្មីមួយដែលទាមទារឱ្យអ្នកដឹកនាំបង្កើនការទទួលយក និងការសម្របខ្លួនទៅនឹងការវិវឌ្ឍនៃប្រព័ន្ធបច្ចេកវិទ្យាដើម្បីកសាងនូវរបៀបគ្រប់គ្រងថ្មីផ្អែកលើមូលដ្ឋាននៃបច្ចេកវិទ្យាឌីជីថលសម្រាប់ការធ្វើអភិបាលកិច្ចការប្រាស្រ័យទាក់ទងការសម្រេចចិត្ត ឬការដោះស្រាយបញ្ហានានា។ នាពេលបច្ចុប្បន្ននេះការទទួលយកឌីជីថលក្នុងចំណោមអ្នកដឹកនាំទាំងផ្នែកវិស័យសាធារណៈ និងវិស័យឯកជនមានវឌ្ឍនភាពជាវិជ្ជមាន។ រាជរដ្ឋាភិបាលបានបង្ហាញពីភាពជាអ្នកដឹកនាំឌីជីថលរបស់ខ្លួនតាមរយៈការគិតគូរដាក់ចេញជាបន្តបន្ទាប់នូវយន្តការចាំបាច់នានាសំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលដែលរួមមានជាអាទិ៍ ការធ្វើសមាហរណកម្មវិស័យ បច្ចេកវិទ្យាទៅក្នុងប្រព័ន្ធអប់រំ ការដាក់ចេញនូវផែនការមេ និងគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន។ ទន្ទឹមនេះ ការយល់ដឹង និងជំនាញឌីជីថលទៅដល់អ្នកដឹកនាំនៅតាមសហគមន៍មូលដ្ឋានក៏មានភាពប្រសើរឡើងជាលំដាប់។ នៅក្នុងវិស័យឯកជនការចាប់យកឌីជីថលនៅក្នុងធុរកិច្ច និងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលក៏មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ផងដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ យ៉ាងណាមិញការផ្លាស់ប្តូរទៅរកភាពជាអ្នកដឹកនាំឌីជីថល ដែលឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាចាំបាច់ត្រូវការនូវកិច្ចខិតខំរយៈពេលវែងក្នុងការអភិវឌ្ឍអ្នកដឹកនាំឌីជីថល និងការកសាងភាពជាអ្នកដឹកនាំឌីជីថល។

ការទាក់ទាញធនធានមនុស្សមានទេពកោសល្យឌីជីថល។ ធនធានប្រភេទនេះ គឺជាតួអង្គ ដ៏សំខាន់នៅក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថល ដែលចូលរួមធានាបាននូវការបង្កើតថ្មី និងនវានុវត្តន៍រាប់ទាំងការបង្កើតធុរកិច្ចថ្មីៗ, ការដោះស្រាយបញ្ហាបានឆាប់រហ័សក្នុងប្រព័ន្ធ ICT និងការការពារសុវត្ថិភាពនៃប្រព័ន្ធទាំងមូល។ តាមការ

[93] ប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

ប៉ាន់ស្មាន បច្ចុប្បន្នកម្ពុជាមានធនធានមនុស្សដែលជាអ្នកមានទេពកោសល្យឌីជីថល ប្រមាណ៥០ ០០០នាក់។ ជាមួយគ្នានេះអត្រានិស្សិតចុះឈ្មោះចូលរៀនលើជំនាញវិទ្យាសាស្ត្រ, បច្ចេកវិទ្យា, វិស្វកម្ម និង គណិតវិទ្យា (STEM) ក្នុងកម្រិតឧត្តមសិក្សា មានប្រមាណត្រឹម ២៧,១% តែប៉ុណ្ណោះខណៈដែលប្រមាណ ០,០៣% ផ្សេងទៀត បានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ម្យ៉ាងវិញទៀត ជំនាញផ្នែកបច្ចេកវិទ្យាទាំងនោះមិនទាន់មានលក្ខណៈប្រមូលផ្តុំ និងមិនស៊ីជម្រៅតាមឯកទេសនៅឡើយ។ ការណ៍នេះបង្ហាញឱ្យឃើញថា ធនធានមនុស្សដែលមានជំនាញឌីជីថលនៅកម្ពុជា នៅមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការជំនាញជាក់ស្តែងនៅក្នុងទីផ្សារ ជាពិសេសជំនាញដែលជាមូលដ្ឋានក្នុងការអភិវឌ្ឍ និងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល។ គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលបាន និងកំពុងដាក់ចេញនូវកិច្ចខិតខំប្រឹងប្រែងមួយចំនួនដើម្បីសម្រួចជំនាញទាំងនោះ តាមរយៈការអប់រំបណ្តុះបណ្តាល និងការអនុវត្តជាដើម។ ជាក់ស្តែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការបង្កើតនូវគំនិតផ្តួចផ្តើមថ្មីៗដូចជា ការបង្កើតឡើងនូវមូលនិធិអភិវឌ្ឍន៍ជំនាញ, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និង មជ្ឈមណ្ឌល ICT ជាដើម។ បន្ថែមពីលើនេះវិស័យឯកជនក៏បាន និងកំពុងចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍ធនធានមនុស្សឌីជីថលផងដែរ។ ជាក់ស្តែងនាពេលកន្លងមកក្រុមហ៊ុនទូរគមនាគមន៍នានា ដែលបានសហការជាមួយនឹងរាជរដ្ឋាភិបាលក្នុងការបង្កើតមូលនិធិកសាងសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យទូរគមនាគមន៍ និង ICT។ មូលនិធិនេះបានរួមចំណែកយ៉ាងច្រើនក្នុងការកសាងសមត្ថភាព និងជំនាញឌីជីថលសម្រាប់យុវជនតាមរយៈកម្មវិធីផ្តល់អាហារូបករណ៍សិក្សាផ្នែកបច្ចេកវិទ្យាព័ត៌មាន, ការបំពាក់បរិក្ខារបច្ចេកវិទ្យានៅតាមសាលារៀន, ព្រឹត្តិការណ៍ផ្សព្វផ្សាយ និងប្រកួតប្រជែងលើផ្នែកបច្ចេកវិទ្យាជាដើម។ ទោះជាយ៉ាងនេះការកសាងធនធានមនុស្សជាកិច្ចការរយៈពេលវែងដែលត្រូវការទាំងការបណ្តុះបណ្តាល និងការអនុវត្តឱ្យបានជិតដល់។[94]

ក្នុងចំណុចនេះដែរ រាជរដ្ឋាភិបាលបានរៀបចំនូវការិយាល័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ មានភារកិច្ចទៅលើការគ្រប់គ្រងជួសជុល និងថែទាំបណ្តាញតភ្ជាប់ និងឧបករណ៍ សម្ភារៈបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយគម្រោងប្រព័ន្ធដឹកនាំអនុវត្តន៍ដោយនាយកដ្ឋាន។[95] នៅបណ្តាលក្រសួង-ស្ថានប័នរដ្ឋមួយចំនួនបាន និងកំពុងដំណើរការរដ្ឋបាល ICT គម្រោងឌីជីថលក្នុងនោះរួមមានការចុះបញ្ជីឌីជីថលសម្រាប់កម្មសិទ្ធិដីធ្លី ការចុះបញ្ជីយានយន្ត និងពន្ធដារជាដើម។ ការគ្រប់គ្រងចំណូលរដ្ឋក៏កំពុងតភ្ជាប់នឹងឌីជីថលជាជំហានៗជាពិសេសការដាក់ឱ្យប្រើ និងអនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអនុវត្តន៍ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។ ការអភិវឌ្ឍធនធានមនុស្សឱ្យមានភាពជាអ្នកដឹកនាំឌីជីថល គឺជានិន្នាការថ្មីមួយដែលទាមទារឱ្យអ្នកដឹកនាំបង្កើនការទទួលយក និងការសម្របខ្លួនទៅនឹងការវិវឌ្ឍនៃប្រព័ន្ធបច្ចេកវិទ្យាដើម្បីកសាងនូវរបៀបគ្រប់គ្រងថ្មីផ្អែកលើមូលដ្ឋាននៃបច្ចេកវិទ្យាឌីជីថលសម្រាប់ការធ្វើអភិបាលកិច្ចការប្រាស្រ័យទាក់ទង ការសម្រេចចិត្ត ឬការដោះស្រាយបញ្ហានានា។

នាពេលបច្ចុប្បន្ននេះ ការទទួលយកឌីជីថលក្នុងចំណោមអ្នកដឹកនាំទាំងផ្នែកវិស័យសាធារណៈ និងវិស័យឯកជនមានវឌ្ឍនភាពជាវិជ្ជមាន។ រាជរដ្ឋាភិបាលបាន បង្ហាញពីភាពជាអ្នកដឹកនាំឌីជីថលរបស់ខ្លួន តាមរយៈការ

[94] ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ទំព័រទី១៥

[95] ដកស្រង់ចេញពីសៀវភៅ "The Law on Consumer Protection and The Law on E-commerce" ទំព័រទី១៣

គិតគូរដាក់ចេញជាបន្តបន្ទាប់នូវយន្តការចាំបាច់នានា សំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល ដែលរួមមានជាអាទិ៍ការធ្វើសមាហរណកម្មវិស័យ បច្ចេកវិទ្យាទៅក្នុងប្រព័ន្ធអប់រំ ការដាក់ចេញនូវផែនការមេ និង គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍។

លើសពីនេះទៅទៀតរាជរដ្ឋាភិបាលបាន និងកំពុងបណ្តុះបណ្តាលវិស័យអប់រំទាក់ទងទៅនឹងបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានដល់សិស្សានុសិស្សគ្រប់ជំនាន់។ ក្រៅពីនេះក៏មានការផ្តល់អទិភាពដល់សិស្ស និង និស្សិតទាំងពីរភេទក្នុងការចាប់យកជំនាញបច្ចេកវិទ្យា IT ដើម្បីសិក្សារៀនសូត្រនៅថ្នាក់បរិញ្ញាបត្រ ដោយទទួល បានការលើកទឹកចិត្តក្នុងការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវរបស់ពួកគេ។ ក្នុងនោះដែរ រដ្ឋាភិបាលក៏បានបង្កើត នូវសាលាបណ្តុះបណ្តាលវិស័យបច្ចេកវិទ្យា ដែលមានការរៀបចំនូវឧបករណ៍ប្រើប្រាស់ទំនើប និងគ្រប់គ្រាន់ដែល អាចបំពេញនូវតម្រូវការរបស់សិស្ស និងនិស្សិតទាំងអស់ ជាពិសេសដើម្បីផ្តល់នូវភាពងាយស្រួលក្នុងការសិក្សា ស្រាវជ្រាវ។

ដើម្បីពន្លឿនការចាប់យក និងការទាញយកអត្ថប្រយោជន៍ពីការវិវឌ្ឍនៃបច្ចេកវិទ្យាឌីជីថល សំដៅជំរុញ និងអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល រាជរដ្ឋាភិបាលកំណត់យកគោលការណ៍ធំៗចំនួន ៣ ដែលរួមមាន ការកសាង មូលដ្ឋានគ្រឹះឌីជីថល ការចាប់យកឌីជីថល និងការធ្វើបដិវត្តកម្មឌីជីថល។ ក្នុងក្របខណ្ឌពេលវេលាដែលបាន កំណត់ បណ្តាវិធានការគោលនយោបាយនឹងត្រូវអនុវត្តក្នុងពេលដំណាលគ្នា ប៉ុន្តែគោលការណ៍ទាំង ៣ នេះនឹង ផ្តល់ជាគន្លងអាទិភាព ដែលមានភាពប្រទាក់ក្រឡាគ្នាសម្រាប់ការអនុវត្ត និងការសម្រេចនូវវិធានការគោល នយោបាយទៅតាមក្របខណ្ឌពេលវេលាអនុវត្តសមស្របទៅនឹងលទ្ធភាព និងសមត្ថភាពរបស់កម្ពុជានៅក្នុងវិស័យ ឌីជីថល ជាពិសេសផ្នែកធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន។

## ២.៣. បញ្ហាប្រឈម និងទិសដៅការងារបន្ទាប់

ការផ្លាស់ប្តូររបស់ប្រទេសនីមួយៗតែងតែមានជាបន្តបន្ទាប់ ក៏ដូចទៅនឹងការប្រឈមនូវបញ្ហានានាដែល កំពុងកើតឡើងក្នុងល្បឿនមួយដែលធ្វើឱ្យមានការស្មុគស្មាញ។ អំពីបញ្ហាដែលបានកើតឡើងផ្សំជាមួយនឹងភាព ភ័យខ្លាច និងឱកាសផ្សេងៗដែលអាចជាទីគួរឱ្យចាប់អារម្មណ៍ធ្វើឱ្យចិត្តគំនិតមិននឹងន។ សកម្មភាពក្នុងការ ផ្លាស់ប្តូរនៅចំណុចប្រព័ន្ធបច្ចេកវិទ្យាទំនើបត្រូវបានទាមតារបន្ថែមឡើង ដោយចង់ឱ្យមានការលូតលាស់អំពីវិស័យ ឌីជីថល ស្របពេលបច្ចុប្បន្នមានការផ្ទុះឡើងនូវជម្ងឺកូវីដ១៩ កើនជាលំដាប់ផង។ ដូច្នេះសង្គមនេះតម្រូវឱ្យមានការ គ្រប់គ្រងរដ្ឋបាលឌីជីថលលើសពីពេលមុនៗដោយសារតែកម្មវិធីនេះអាចជួយផ្តល់ព័ត៌មានបានរហ័ស និងអាស្រ័យ លើពេលវេលាដែលមិនតម្រូវឱ្យមានការជួបជុំគ្នាច្រើន ៣កុំ ៣ការពារ។ តាមការចង្អុលបង្ហាញក្នុងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ និងទាញយកសក្តានុពលនៃបរិវត្តកម្មឌីជីថល "ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥" ត្រូវបានគិតគូរ និងរៀបចំឡើងដោយផ្តែកទៅលើតម្រូវការជាក់ស្តែង សក្តានុពល ធនធាន និងសមត្ថភាពទាំងនៅក្នុងវិស័យសាធារណៈ និងទាំងនៅក្នុងវិស័យឯកជនសម្រាប់ការ តម្រង់ទិសការអភិវឌ្ឍ និងដំណើរការនៃបរិវត្តកម្មឌីជីថលនៅកម្ពុជា។ បរិវត្តកម្មឌីជីថលនឹងនាំមកនូវបច្ច័យ វិជ្ជមានដ៏សន្ធឹកសន្ធាប់ដល់សេដ្ឋកិច្ចសង្គមកម្ពុជាពោលគឺជាចន្ទល់កំណើនថ្មី ដែលមានភាពអត់ធន់ខ្ពស់ទៅនឹង ការផ្លាស់ប្តូរជារចនាសម្ព័ន្ធនាពេលអនាគតផង ហើយក៏ជាចលករក្នុងការជំរុញក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ច

ដែលមានស្រាប់ផងខណៈដែលពេលបច្ចុប្បន្នក្បាលម៉ាស៊ីនកំណើនទាំងនោះចាប់ផ្តើមមានសម្ទុះថមថយ និងរងនូវផលប៉ះពាល់ខ្លាំងបណ្តាលមកពីវិបត្តិនៃជម្ងឺកូវីដ-១៩។

**២.៣.១. បញ្ហាប្រឈម**

ការផ្ទុះឡើងដំបូងនៃជម្ងឺកូវីដ១៩ ត្រូវបានគេរាយការណ៍ថាបានកើតឡើងនៅក្នុងប្រទេសចិននៅចុងឆ្នាំ២០១៩ ហើយនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ អង្គការសុខភាពពិភពលោក (WHO)[96] បានប្រកាសថាវាជាការព្រួយបារម្ភជាអន្តរជាតិនូវភាពអាសន្នទៅលើផ្នែកសុខភាពសាធារណៈ(PHEIC)[97]។ ជម្ងឺរាតត្បាតកូវីដ១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ចពិភពលោក ហើយការកើនឡើងនៃវិបត្តិនេះកំពុងប៉ះពាល់ដល់ប្រទេសកំពុងអភិវឌ្ឍន៍ មិនត្រឹមតែទៅលើភាពអាសន្នផ្នែកសុខភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លាញដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដល់ប្រទេសទាំងនោះយ៉ាងធ្ងន់ធ្ងរផងដែរ។[98] ដូចគ្នានេះដែរ បណ្តាប្រទេសសមាជិកអាស៊ានទាំងអស់កំពុងរងនូវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមពីជម្ងឺកូវីដ១៩។[99] ខណៈការផ្ទុះឡើងនៃជម្ងឺនេះជាសកលបាននាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់បង្កជាការរាំងស្ទះទៅដល់តម្រូវការ ព្រមទាំងលំហូរនៃការធ្វើដំណើរពាណិជ្ជកម្ម និងការវិនិយោគដែលជាហេតុបាននាំមកនូវការរំខានទៅលើគ្រប់វិស័យនៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសអាស៊ានក្នុងនោះរួមទាំងប្រទេសកម្ពុជាផងដែរ។

ផលប៉ះពាល់នៃបរិវត្តកម្មឌីជីថលកើតឡើងដោយសារការបង្កើតទម្លាប់ថ្មីដែលនាំទៅការបំផ្លាញទម្លាប់ចាស់ (Creative Destruction) តាមរយៈវត្តមាននៃបច្ចេកវិទ្យាឌីជីថលទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមបង្កឱ្យមានផលប៉ះពាល់មួយចំនួន ដូចខាងក្រោម៖

- ការផ្លាស់ប្តូររចនាសម្ព័ន្ធកម្លាំងពលកម្ម និងការងារ
- ការងារបែបប្រពៃណីមួយចំនួនអាចប្រឈមខ្ពស់នឹងការបាត់បង់ខណៈសេដ្ឋកិច្ចឌីជីថលនឹងបង្កើតប្រភេទការងារថ្មីដែលទាមទារឱ្យមានចំណេះដឹង និងជំនាញខ្ពស់ជាងមុនជាពិសេសជំនាញឌីជីថល
- ជាមួយគ្នានេះចរន្តឌីជីថលអាចនាំមកនូវការផ្លាស់ប្តូររបៀបធ្វើការងារ ការជំនួសការងារដោយម៉ាស៊ីនស្វ័យប្រវត្តិ និងគ្រឿងយន្ត។

ការបង្វែរអាទិភាពនៃចំណាយវិនិយោគសាធារណៈនៅក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល រាជរដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការដឹកនាំ និងការជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលឆ្លើយតបទៅនឹងតម្រូវការ ដែលនេះទាមទារឱ្យមានការកៀរគរធនធានសម្រាប់ការវិនិយោគ។ ជាលទ្ធផលការណ៍នេះនឹងក្លាយជាបន្ទុកសម្រាប់ការប្រមូលចំណូល ដើម្បីបំពេញតម្រូវការនៃការវិនិយោគ ព្រមទាំងនឹងក្លាយជាសម្ពាធលើការចែករំលែកធនធាន ដែលមានកំណត់សម្រាប់ការអភិវឌ្ឍវិស័យនេះដែលតម្រូវឱ្យមានការថ្លឹងថ្លែងលើអាទិភាពវិនិយោគសាធារណៈទាំងមូល។

[96] អង្គការសុខភាពពិភពលោក (World Health Organization)

[97] Public Health Emergency of International Concern

[98] កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) «វិបត្តិកូវីដ-១៩ ដែលបានគំរាមកំហែងដល់សេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍»

[99] អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) «ការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ នៅក្នុងរដ្ឋសមាជិកអាស៊ាន»

| ការប៉ាន់ស្មាន និងព្យាករមកលើសេដ្ឋកិច្ចកម្ពុជា គិតជា(%) | | | | |
|---|---|---|---|---|
| ស្ថាប័ន | មុនពេល កូវីដ-១៩ | | ក្រោយពេល កូវីដ-១៩ | |
| | ២០២០ ប៉ាន់ស្មាន | ២០២១ ព្យាករណ៍ | ២០២០ ព្យាករណ៍ | ២០២១ ព្យាករណ៍ |
| រាជរដ្ឋាភិបាលកម្ពុជា (RGC) | ៦.៥ | ៧.០ | - ១.៩ | ៣.៥ |
| ធនាគារអភិវឌ្ឍអាស៊ី (ADB) | ៦.៨ | *N/A* | - ៤.០ | ៥.៩ |
| ធនាគារពិភពលោក (WB) | ៦.៩ | ៦.៨ | - ២.០ | ៤.៣ |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ៦.៧ | ៦.៧ | - ២.៨ | ៦.៨ |

- រាជរដ្ឋាភិបាលកម្ពុជា (RCG): (២០២០ប៉ាន់ ៦.៥, ២០២១ព្យា.៧.០, ២០២០ព្យា-១.៩, ២០២១ព្យា. ៣.៥)[100]
- ធនាគារអភិវឌ្ឍអាស៊ី (ADB)*:* (២០២០ប៉ាន់ ៦.៨)[101], (២០២១ព្យា.*N/A*, ២០២០ព្យា-៤.០, ២០២១ ព្យា. ៥.៩)
- ធនាគារពិភពលោក (WB)*:* (២០២០ប៉ាន់ ៦.៩, ២០២១ព្យា.៦.៨)[102], (២០២០ព្យា-២.០, ២០២១ ព្យា. ៤.៣)[103]
- មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF): (២០២០ប៉ាន់ ៦.៧, ២០២១ព្យា.៦.៧, ២០២០ព្យា-២.៨, ២០២១ ព្យា. ៦.៨)

កម្រិត និងទំហំនៃបដិវត្តន៍បច្ចេកវិទ្យាដែលបាន និងកំពុងកើតឡើងបានចង្អុលបង្ហាញនូវការប្រែប្រួលលើវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ក្នុងបរិមាណមួយជាបាតុភូតដែលគេសឹងតែគិតមិនដល់។ ទោះជាយ៉ាងណាក៏ដោយការអធិប្បាយ និងវិភាគនូវផលប៉ះពាល់ដ៏សក្តានុពលនៃបដិវត្តន៍ឧស្សាហកម្មលើកទី៤ លើសេដ្ឋកិច្ចពាណិជ្ជកម្ម រដ្ឋាភិបាលក្នុងបណ្តាប្រទេសនានា សង្គម និងបុគ្គលម្នាក់ៗ។ ក្នុងវិស័យនេះទាំងអស់ផលប៉ះពាល់ក្នុងចំណោមផលប៉ះពាល់ដែលធំជាងគេបំផុតទំនងជាកើតចេញអំពីកម្លាំងដ៏ធំមួយការផ្តល់អំណាច គឺជារបៀប

---

[100] គេហទំព័រ https://data.opendevelopmentcambodia.net/dataset/national-strategic-development-plan-nsdp- ដកស្រង់ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២១

[101] គេហទំព័រ https://www.adb.org/sites/default/files/publication/492711/ado2019 ដកស្រង់ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២១

[102] គេហទំព័រ https://documents1.worldbank.org/curated/en/843251556908260855/pdf/Cambodia-Economic-Update-Recent-Economic- Developments-and-Outlook.ដកស្រង់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

[103] គេហទំព័រ https://openknowledge.worldbank.org/bitstream/handle/10986/34497/9781464816413 ដកស្រង់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០២១

ដែលរដ្ឋាភិបាលទំនាក់ទំនងជាមួយប្រជាមួយប្រជាពលរដ្ឋរបៀប ដែលសហគ្រាសទំនាក់ទំនងជាមួយបុគ្គលិកម្ចាស់ភាគហ៊ុន និងអតិថិជនជារបៀបដែលប្រទេសមហាអំណាច ទំនាក់ទំនងជាមួយប្រទេសតូចតាច។

### ក. សេដ្ឋកិច្ច

ផលប៉ះពាល់យ៉ាងធំសម្បើមលើសេដ្ឋកិច្ចពិភពលោកយ៉ាងធំធេង ហើយពហុមុខរហូតដល់មានការលំបាកក្នុងការវែកញែកផលប៉ះពាល់បន្ទាប់ទៀត។ តាមពិតទៅគ្រប់អថេរធំៗទាំងអស់ ដែលគេអាចគិតដល់ដូចជាផលិតផលក្នុងស្រុកសរុបវិនិយោគទុនការប្រើប្រាស់ការងារពាណិជ្ជកម្មអតិផរណា[104]ជាដើម។ លើសពីនេះទៅទៀតត្រូវទទួលរងដូចជាផលិតផលក្នុងស្រុក វិនិយោគទុន ការប្រើប្រាស់ការងារពាណិជ្ជកម្មអិតផរណាជាដើមនឹងត្រូវទទួលរងឥទ្ធិពល។ ការផ្តោតសំខាន់មានពីរចំណុច គឺកំណើន ឬការីកចម្រើន (ភាគច្រើនតាមរយៈរូបភាព នៃកត្តាកំណត់យូរអង្វែង គឺផលិតផល) និងការងារ។ ការប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច គឺជាបញ្ហាមួយដែលធ្វើឱ្យសេដ្ឋកិច្ចលើបច្ចេកវិទ្យាយល់ថាការចូលរួមរបស់បដិវត្តន៍ឌីជីថលដែលមានកន្លងមក និងផលប៉ះពាល់របស់វាស្ទើរតែលែងមានទៅហើយ។ ចំពោះបច្ចេកវិទ្យាអះអាងថា បច្ចេកវិទ្យា និងនវានុវត្តន៍ស្ថិតនៅលើចំណុចបត់បែន និងបង្កើតឱ្យមាននូវការស្ទុះឡើងផលិតភាព និងកំណើនសេដ្ឋិច្ចខ្ពស់ជាងមុន។ ការពិនិត្យលើផលប៉ះពាល់ប្រកបដោយសក្តានុពលនៃបដិវត្តន៍ឧស្សាហកម្មលើកទី៤ លើកំណើនដោយយោងទៅលើនិន្នាការសេដ្ឋកិច្ចថ្មីៗ និងកត្តាផ្សេងៗទៀតដែលរួមចំណែកដល់កំណើនពិតជាមានសារៈសំខាន់ណាស់។ ប៉ុន្មានឆ្នាំមុននៃការកើតមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានចាប់ផ្តើមនៅឆ្នាំ២០០៨ សេដ្ឋកិច្ចសាកលលោកមានកំណើនប្រហែលប្រាំភាគរយ (៥%) ក្នុងមួយឆ្នាំ។ ប្រសិនបើអត្រានេះចេះតែបន្ត ដូច្នេះផលិតផលក្នុងស្រុកសរុប និងកើនឡើងទ្វេគុណរៀងរាល់ដប់បួន(១៤) ឆ្នាំ ឬដប់ប្រាំ (១៥) ឆ្នាំម្តង ហើយប្រជាជនរាប់ពាន់លាននាក់នឹងចាកចេញផុតពិភាពក្រីក្រ។ ភ្លាមៗបន្ទាប់ពីមហាវិបត្តិសេដ្ឋកិច្ច ក្តីរំពឹងថាសេដ្ឋកិច្ចសាកលលោក និងត្រឡប់ទៅរកលំនាំនៃកំណើនខ្ពស់ដូចពីមុនបានជ្រួតជ្រាបយ៉ាងទូលំទូលាយ។ ប៉ុន្តែការរំពឹងទុកមិនបានកើតឡើងសេដ្ឋកិច្ចសាកលលោក ហាក់ដូចជានូវជាប់គាំងនៅត្រឹមអត្រាកំណើនមួយទាបជាងកម្រិតមធ្យមនៃកំណើនក្រោយសង្គ្រាម គឺប្រហែលជា ៣,៥% ក្នុងមួយឆ្នាំ។

### ខ. ផលិតភាព

ជាងមួយទសវត្សកន្លងទៅផលិតភាពជុំវិញពិភពលោកទោះបីវាស់ស្ទង់តាមរយៈផលិតភាពការងារពលកម្ម ឬតាមរយៈផលិតភាពកត្តាសរុបក៏ដោយ ក៏នៅមានភាពយឺតយ៉ាវទោះបីជាកំណើនគាំទ្រដោយការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងការវិនិយោគលើនវានុវត្តន៍ក៏ដោយ។ ទម្រង់ផ្លាស់ប្តូរដែលថ្មីៗបំផុតនៃភាពផ្ទុយគ្នារបស់ផលិតភាពពោលគឺបរាជ័យដែលគេសន្មតនៃនវានុវត្តន៍បច្ចេកវិទ្យាដើម្បីបង្កើតផលិតភាពកម្រិតខ្ពស់គឺប្រស្នាសេដ្ឋកិច្ចមួយដ៏ធំក្នុងចំណោមប្រស្នាធំៗនាពេលបច្ចុប្បន្ន ដែលកើតមានមុនការចាប់ផ្តើមមានមហាវិបត្តិសេដ្ឋកិច្ច ហើយដែលគ្មានការពន្យល់ឱ្យបានពេញចិត្តនៅឡើយទេ។ ចំពោះសហរដ្ឋអាមេរិក ដែលផលិតភាពការងារកើនជាមធ្យម ២,៨% រវាងឆ្នាំ១៩៤៧ និងឆ្នាំ១៩៨៣ និង ២,៦% រវាងឆ្នាំ២០០០ និងឆ្នាំ២០០៧ ប្រៀបនឹង ១,៣% រវាងឆ្នាំ២០០៧ និង២០១៤។ ភាគច្រើននៃការធ្លាក់ចុះ គឺដោយសារតែផលិតភាពកត្តាសរុប (TFP) ទាបជាងមុនដែលជាម្ចាស់ទូទៅបំផុតពាក់ព័ន្ធជាមួយនឹងការរួមចំណែកចំពោះប្រសិទ្ធផលកើតចេញពីបច្ចេកវិទ្យា និងនវានុវត្តន៍។ ការិយាល័យស្ថិតិការងារអាមេរិក ដែលបានបង្ហាញថាកំណើនផលិតភាពកត្តាសរុបរវាងឆ្នាំ២០០៧ និង២០១៤។

[104] អតិផរណា គឺជាការកើនឡើងនៃកំរិតថ្លៃរួម ហើយវាកើតឡើងនៅពេលដែលថ្លៃជាច្រើនកើនឡើងព្រមៗគ្នា ។

មានតែ 0,៥% ប៉ុណ្ណោះដែលជាការធ្លាក់ចុះយ៉ាងខ្លាំង បើប្រៀបធៀបទៅកំណើនប្រចាំឆ្នាំ១,៤% រវាងឆ្នាំ១៩៩៥ និងឆ្នាំ២០០៧។ ការធ្លាក់ចុះនូវផលិតភាព ដែលបានវាស់ស្ទង់នេះមានលក្ខណៈគួរឱ្យព្រួយបារម្ភដោយសារថាវាកើតឡើងនៅពេលដែលក្រុមហ៊ុនអាមេរិកធំៗបំផុត ចំនួន៥0 បានប្រមូលសាច់ប្រាក់ជាងមួយសែនកោដិដុល្លារ ទោះជាអត្រាការប្រាក់ពិតនៅខឹងប្រហែលជាសូន្យភាគរយអស់រយៈពេលជិតប្រាំឆ្នាំក៏ដោយ។ 20ផលិតភាព គឺជាកត្តាកំណត់ដ៏សំខាន់បំផុតមួយនៃកំណើនរយៈពេលយូរអង្វែង និងអវត្តមាននៃកំណើនស្តង់ដាជីវភាពរស់នៅ ប្រសិនបើអាចរក្សាបានក្នុងអំឡុងបដិវត្តន៍ឧស្សាហកម្មលើកទី៤។ មានន័យថាយើងនឹងទទួលបានស្ថានភាពទាប មួយនៃស្ថានភាពទាំងពីរនេះ។ ទោះជាយ៉ាងនេះក៏ដោយ តើយើងអាចរួមបញ្ចូលនូវទិន្នន័យ ដែលបង្ហាញពីការធ្លាក់ចុះនូវផលិតភាពជាមួយនឹងការរំពឹងទុកនូវផលិតភាពខ្ពស់ដែលទំនងជាមានទំនាក់ទំនងជាមួយនឹងកំណើន ការគាំទ្រនៃបច្ចេកវិទ្យា និងនវានុវត្តន៍យ៉ាងដូចម្តេច? សូចនាករបឋមជាផ្តោតលើការប្រឈមនៃការវាស់ស្ទង់លើធាតុចូល គឺចែកធាតុចេញនូវផលិតភាព។

ទំនិញ និងសេវាកម្មប្រកបដោយភាពច្នៃប្រឌិត ដែលបង្កើតនៅក្នុងបដិវត្តន៍ឧស្សាហកម្មលើកទី៤.0 គឺមានលក្ខណៈបំពេញមុខងារ និងគុណភាពខ្ពស់ជាងមុនហើយដែលនឹងត្រូវចែកចាយក្នុងទីផ្សារ ដែលមានភាពខុសគ្នាជាមូលដ្ឋានពីទីផ្សារដែលត្រាវបានគេប្រើប្រាស់ដើម្បីវាស់ស្ទង់តាមលក្ខណៈប្រពៃណី។ ទំនិញ និងសេវាកម្មថ្មីៗជាច្រើនមានលក្ខណៈ "គ្មានដៃគូប្រជែង" មានការចំណាយផ្សេងៗស្មើសូន្យ ឬបង្កើតទីផ្សារឱ្យមានការប្រកួតប្រជែងខ្ពស់តាមរយៈមធ្យោបាយឌីជីថល ដែលទាំងអស់នេះនាំឱ្យតម្លៃទាបជាងមុន។ ក្នុងលក្ខខណ្ឌបែបនេះស្ថិតិប្រពៃណីរបស់យើងនឹងមិនអាចគ្របដណ្តប់កំណើនតម្លៃពិតដោយសារតែតម្លៃលើសនៃអ្នកប្រើមិនបានឆ្លុះបញ្ចាំងក្នុងការលក់ជាទូទៅ ឬចំណេញខ្ពស់ទេ។ សេដ្ឋកិច្ចវិទូដ៏សំខាន់របស់ក្រុមហ៊ុនហ្គោហ្គល (Google) បានចង្អុលបង្ហាញនូវឧទាហរណ៍ផ្សេងៗដូចជាកំណើនប្រសិទ្ធភាពនៃការហៅតាក់ស៊ីតាមទូរស័ព្ទដៃ ឬការជួលរថយន្តតាមរយៈអំណាចសេដ្ឋកិច្ចតាមតម្រូវការ។ មានសេវាស្រដៀងគ្នាជាច្រើនទៀត ដែលត្រូវបានប្រើប្រាស់ ទំនងជាបានបង្កើនប្រសិទ្ធិផល និងផលិតភាព។ ដោយយោងតាមសារសេវាទាំងនេះប្រើប្រាស់ឥតគិតថ្លៃ ដូច្នេះវាបានផ្តល់នូវតម្លៃដែលមិនបានរាប់បញ្ចូលទាំងនៅក្នុងផ្ទះ និងទាំងនៅកន្លែងធ្វើការ។ ការណ៍នេះបង្កើតឱ្យមានភាពមិនស្របគ្នារវាងតម្លៃដែលគិតថ្លៃតាមរយៈការផ្តល់សេវាកម្មប្រៀបធៀបនឹងកំណើន ដែលបានវាស់ស្ទង់ដោយស្ថិតិជាតិ។ មានកាលើកឡើងផងដែរថាយើងពិតជាបាននិងកំពុងផលិត និងការប្រើប្រាស់មានប្រសិទ្ធិផលជាងសូចនាកររបស់យើងបានលើកឡើងទៅទៀត។ នៅពេលផលិតភាពដែលបានមកពីបដិវត្តន៍ឧស្សាហកម្មលើកទី៣កំពុងចុះថមថយ ទៅពិភពលោកមិនទាន់បានជួបប្រទះនូវការផ្ទុះឡើងនូវផលិតភាព និងបង្កើតឡើងដោយរលកនៃបច្ចេកវិទ្យាថ្មី ដែលបង្កើតនៅក្នុងបេះដូងនៃបដិវត្តន៍ឧស្សាហកម្មលើកទី៤នៅឡើយ។ តាមពិតទៅក្នុងនាមជាអ្នកសុទិដ្ឋិនិយម តាមកាលម្នាក់ យើងទើបតែចាប់ផ្តើមមានអារម្មណ៍អំពីផលប៉ះពាលបដិវត្តន៍ឧស្សាហកម្មលើកទី៤ ចំពោះពិភពលោកប៉ុណ្ណោះ។ ប្រភពសំខាន់ៗបីគឺ៖

ទី១. បដិវត្តន៍ឧស្សាហកម្មលើកទី៤ ផ្តល់នូវឱកាសសមាហរណកម្មលើតម្រូវការដែលមិនទាន់អាចបំពេញបាននៃប្រជាជនពីរពាន់លាននាក់នៅក្នុងសេដ្ឋកិច្ចសាកលលោក ដែលនាំឱ្យមានតម្រូវការបន្ថែមចំពោះផលិតផល សេវានាពេលបច្ចុប្បន្នតាមរយៈការពង្រឹងអំណាច ការភ្ជាប់ទំនាក់ទំនងបុគ្គលម្នាក់ៗ និងសហគមន៍នានាពាសពេញសាកលលោកទៅអ្នកដទៃទៀត

ទី២. បដិវត្តន៍ឧស្សាហកម្មលើកទី៤ នឹងជួយបង្កើនសមត្ថភាពដោះស្រាយបញ្ហាខាងក្រៅផ្សេងៗដែលមានលក្ខណៈអវិជ្ជមាន ហើយក្នុងដំណើរការមួយ វាជួយជម្រុញកំណើនសេដ្ឋកិច្ចប្រកបដោយសក្តានុពល។ ឧទាហរណ៍៖ ការបញ្ចេញឧស្ម័នកាបូន ដែលជាបញ្ហាអវិជ្ជមានខាងក្រៅយ៉ាងសំខាន់មួយ។ រហូតមកដល់បច្ចុប្បន្ននេះ ការវិនិយោគលើបរិស្ថានបៃតងមានភាពទាក់ទាញដោយសារតែរដ្ឋាភិបាលបានឧបត្ថម្ភថវិកាទ្រទ្រង់ជាខ្លាំងប៉ុណ្ណោះ។ ករណីនេះមានកាន់តែតិចទៅៗ ហើយការរីកចម្រើនយ៉ាងឆាប់រហ័សខាងបច្ចេកវិទ្យាលើវិស័យថាមពលកើតឡើងវិញប្រសិទ្ធិផលនៃការប្រើប្រេងឥន្ធនៈ និងការរក្សាទុកថាមពលមិនត្រឹមតែធ្វើឱ្យការវិនិយោគក្នុងវិស័យទាំងនេះទទួលបានផលចំណេញកើនឡើងជាបន្តបន្ទាប់ និងជម្រុញកំណើនផលិតផលសរុបក្នុងស្រុកបន្ថែមទៀតប៉ុណ្ណោះទេ ថែមទាំងចូលរួមចំណែកកាត់បន្ថយបម្រែបម្រួលអាកាសធាតុដែលជាបញ្ហាប្រឈមមួយក្នុងចំណោម បញ្ហាប្រឈមសកលលោកធំៗក្នុងសម័យកាលើយើងនេះ។

ទី៣. ការប្រកបដោយសក្តានុពលនៃបច្ចេកវិទ្យាលើកំណើនសេដ្ឋកិច្ចនោះក៏ដោយសារៈសំខាន់ចំពោះការបង្ហាញឱ្យឃើញពីផលប៉ះពាល់ ជាអវិជ្ជមានរបស់វានៅលើទីផ្សារការងារយ៉ាងតិចណាស់ក៏ក្នុងរយៈពេលខ្លីដែរ។ ការភ័យខ្លាចអំពីផលប៉ះពាល់នៃបច្ចេកវិទ្យានៅលើនិយោជន៍នោះ ក្រោយមកបានឱ្យមានការកាត់បន្ថយក្នុងការប្រើប្រាស់កម្លាំងពលកម្មខ្លះ និងបែរមករកលើការប្រើប្រាស់ប្រព័ន្ធបច្ចេកបវិទ្យាជំនួយវិញ។ មូលហេតុដែលនាំឱ្យបដិវត្តន៍ បច្ចេកវិទ្យាថ្មីនេះ និងការបង្កឱ្យមានចលាចលច្រើនជាងបដិវត្តន៍ឧស្សាហកម្មពីពេលមុនៗល្បឿន (អ្វីគ្រប់យ៉ាងដែលកំពុងកើតឡើងក្នុងល្បឿនលឿនជាងពេលពីមុន) វិសាលភាព និងជម្រៅ (ផ្លាស់ប្តូររ៉ាឌីកាលជាច្រើនត្រូវបានកើតមានឡើងក្នុងពេលដំណាលគ្នា) និងការផ្លាស់ប្តូរប្រព័ន្ធទាំងស្រុង។ ផលប៉ះពាល់នៃការប្រកួតប្រជែងពីរ ដែលបច្ចេកវិទ្យាអនុវត្តន៍លើវិស័យការងារ ឬនិយោជន៍៖

- ផលវិនាសកម្មនៃការផ្ទុះឡើងនៃបច្ចេកវិទ្យា និងស្វ័យប្រវត្តិកម្មមកជំនួសមូលធនសម្រាប់កម្លាំងពលកម្មដែលធ្វើឱ្យកម្មករបាត់បង់ការងារ ឬដើម្បីរៀបចំជំនាញរបស់ពួកគេឡើងវិញនៅគ្រប់ទីកន្លែង
- ផលវិនាសកម្មដោយការផ្ទុះឡើងនៃបច្ចេកវិទ្យាកើតឡើងជាមួយ និងផលមូលធនកម្មដែលតម្រូវការទំនិញថ្មីៗ និងសេវាកម្មនានាមានការកើនឡើង ហើយឈានទៅរកការបង្កើតនូវអាជីពថ្មី ឬមុខរបរថ្មីៗជំនួញ ឬពាណិជ្ជកម្មថ្មី និងឧស្សាហកម្មថ្មីៗ។

ពេលវេលា និងវិសាលភាពទៅរកផលមូលធនកម្មដែលជំនួសឱ្យផលវិនាសកម្មនៃការលូតលាស់ និងថាតើការជំនួសនេះវានឹងលឿនប៉ុណ្ណា? មានផ្នែកផ្ទុយគ្នាពីរនៅពេលដែលនិយាយអំពីផលប៉ះពាល់នៃបច្ចេកវិទ្យាកំពុងរីកចម្រើនទៅលើទីផ្សារការងារសម្រាប់អ្នកដែលជឿថាពួកគេ និងមានសេចក្តីសប្បាយចិត្តនៅទីបញ្ចប់ គឺថាអ្នកដែលត្រូវរងគ្រោះដោយបច្ចេកវិទ្យាជំនួសការងាររបស់ពួកគេនឹងអាចរកកាងារថ្មីមកជំនួសវិញបាន រីឯបច្ចេកវិទ្យានឹងធ្វើឱ្យមានសករាជថ្មីនៃភាពរុងរឿងមួយ។

សំណួរសួរថា តើអ្វីដែលយើងគួរតែធ្វើ ដើម្បីជំរុញ ឱ្យមានលទ្ធផលជាវិជ្ជមានកាន់តែច្រើន និងជួយដល់ពួកគេអាចតាមទាន់ នៅក្នុងការផ្លាស់ប្តូរនេះ? វាតែងតែមានករណីដែលនវានុវត្តន៍បច្ចេកវិទ្យានេះនឹងបំផ្លាញការងារមួយចំនួន ដែលជំនួសដោយអ្វីផ្សេងទៀតទៅតាមសកម្មភាពផ្សេងគ្នា និងអាចធ្វើទៅបាននៅក្នុងកន្លែងមួយផ្សេងទៀតជានិច្ច។ នៅសហរដ្ឋអាមេរិកមានមនុស្សធ្វើការនៅលើដី នោះមាន ៩០% នៃកម្លាំងពលកម្មសរុបនៅដើមនៃសតវត្សទី១៩ ប៉ុន្តែនាពេលបច្ចុប្បន្ននេះមានតែចំនួនតិចជាង ២% ដែលធ្វើការងារក្នុងផ្នែកនេះ។ ការ

កាត់បន្ថយ ឬកម្លាំងពលកម្មកាន់តែតូចទៅៗយ៉ាងខ្លាំងនេះបានកើតឡើងយ៉ាងរលូនដោយសឹងតែគ្មានការរំខានជាសង្គម ឬក៏ជាជម្ងឺ នៃភាពគ្មានការងារធ្វើទេ។ ស្ថាបនិករបស់ក្រុមហ៊ុនអេផល (Apple) បានអនុញ្ញាតឱ្យអ្នកអភិវឌ្ឍន៍ខាងក្រៅបង្កើតកម្មវិធីសម្រាប់ទូរស័ព្ទអាយហ្វូន (iPhone)។ នៅពាក់កណ្តាលឆ្នាំ២០១៥ អេបសេដ្ឋកិច្ចសកលលោកត្រូវបានរំពឹងថានឹងបង្កើតប្រាក់ចំណូលបានជាង១០០ពាន់លានដុល្លារ គឺរកចំណូលបានកើនលើសពីឧស្សាហកម្មភាពយន្តដែលមានជាងមួយសតវត្សរ៍មុននេះ។ ផលិតភាព និងការបង្កើនទ្រព្យសម្បត្តិនិងនាំឆ្ពោះទៅរកតម្រូវការសម្រាប់សេវាកម្ម ទំនិញ និងប្រភេទនៃការងារថ្មីដែលពួកគេពេញចិត្ត។ ឧបសគ្គរារាំងឱ្យដំណើរការថយនឹងកើតមានធម្មតា និងការធ្លាក់ចុះដុនដាបម្តងម្កាល ហើយតែងតែនឹងមានការងារសម្រាប់អ្នករាល់គ្នាវិញមិនខាន។ តើអ្វីដែលជាភ័ស្តុតាងសម្រាប់គាំទ្រការងារទាំងនេះ? ហើយតើអ្វីដែលនឹង ប្រាប់យើងឱ្យដឹងអំពីអ្វីដែលនឹងកើតឡើងនៅពេលខាងមុខ? សញ្ញាដំបូងចង្អុលទៅរករលកនៃនវានុវត្តន៍ថ្មី ដែលមកជំនួសកម្លាំងពលកម្មរបស់មនុស្សយ៉ាងច្រើន និងនៅទូទាំងឧស្សាហកម្មចម្រុះហើយទំនងជានឹងមានការងារគ្រប់ប្រភេទនឹងកើតឡើងក្នុងទសវត្សរ៍ខាងមុខ។ ការជំនួសកំលាំងពលកម្មមានការងារជាច្រើនប្រភេទជាពិសេសការងារ ដែលតម្រូវឱ្យមនុស្សបញ្ជាគ្រឿងម៉ាស៊ីនចំដែលៗ និងតាមវដ្តវិលជុំទៅវិញទៅមកដែលច្បាស់លាស់ គឺពេលនេះត្រូវបានគេជំនួសដោយម៉ាស៊ីនស្វ័យប្រវត្តិហើយ។ ការងារផ្សេងៗទៀតជាច្រើនក៏នឹងមានការវិវត្តដូចគ្នាអញ្ចឹងដែរ ដោយសារបច្ចេកវិទ្យានៃម៉ាស៊ីនកុំព្យូទ័រដែលកំពុងតែបន្តការរីកចម្រើនគ្មានដែនកំណត់។ ការស្រាវជ្រាវនេះសន្និដ្ឋានថាការងារសរុបប្រហែលជា៤៧ ភាគរយនៅក្នុងសហរដ្ឋអាមេរិកស្ថិតក្នុងស្ថានភាពហានិភ័យប្រហែលជាមួយទសវត្សរ៍ ឬពីរទសវត្សរ៍ក្រោយការងារជាច្រើននឹងត្រូវបានបាត់បង់ហើយលឿនជាងការផ្លាស់ប្តូរទីផ្សារការងារដែលយើងធ្លាប់បានឃើញពីមុនមកនៅក្នុងបដិវត្តន៍ឱស្សាហកម្ម។ បន្ថែមពីនេះទៀតចលនាវិវត្តិនៃការងារទាំងនោះ គឺឈានទៅដល់ការធ្វើសមាហរណកម្មក្នុងទីផ្សារការងារ។ ការងារជាច្រើនរីកដុសដាលនៅក្នុងប្រភេទជំនាញ ដែលរកចំណូលបានខ្ពស់ មានភាពច្នៃប្រឌិត និងការងារចំណូលទាបដែលធ្វើតាមប្រព័ន្ធ និងទំលាប់ប៉ុន្តែការវិវត្តនៃបច្ចេកវិទ្យានិងបំផ្លាញការងារចំណូលមធ្យម និងការងារដែរ។

ឧទាហរណ៍៖ ការបំពេញការងារទាំងអស់នេះ គឺមានន័យថាការងារដែល ដំណើការដោយម៉ាស៊ីនគឺល្អប្រសើរក្នុងការជំនួសវត្តមាននៃមនុស្ស។ ការងារដែលបែងចែក និងរៀបចំបានច្បាស់លាស់ធ្វើឱ្យការពិនិត្យវាយតម្លៃ ទៅលើទិន្នន័យកាន់តែមានគុណភាពខ្ពស់។ ដូច្នេះវានឹងបង្កើតគោលដៅច្បាស់លាស់ដែលម៉ាស៊ីនអាចរៀបចំដើម្បីបំពេញការងារបានកាន់តែល្អ ប្រសើរ។

បើគិតអំពីការងារដែលបំពេញដោយម៉ាស៊ីនស្វ័យប្រវត្តិ និងបាតុភូតនៃការជំនួសកម្លាំងពលកម្មយើងគួរតែឈប់គិតអំពីផលប៉ះពាល់ដែលបង្កឡើងដោយបច្ចេកវិទ្យាទៅលើការងារ និងអនាគតនៃការងារ។ ដូចទៅនឹងអ្វីដែលបានបង្ហាញឱ្យឃើញថាវាគឺជារឿង ដែលជៀសមិនរួចទៅហើយដែលបដិវត្តិន៍ឧស្សាហកម្មដំណាក់កាលទីបួនមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទីផ្សារការងារ និងប៉ះពាល់ដល់ទីកន្លែងជុំវិញការងារជុំវិញពិភពលោក។ ប៉ុន្តែក្នុងន័យនេះវាមិនមានន័យថាយើង និងមានការប្រឈមដ៏ខ្លាំងក្លាផ្នែកការងាររវាងមនុស្សទល់ និងម៉ាស៊ីនឡើយ។

ជាការពិតបើពិនិត្យមើលទៅលើករណីជាច្រើនលំហូរចូលនៃប្រព័ន្ធបច្ចេកវិទ្យាទំនើបទាំងបច្ចេកវិទ្យាដែលមានរូបរាង និងបច្ចេកវិទ្យាជីវសាស្ត្រ (ដែលជាចលនាកំពុងនាំទៅរកការផ្លាស់ប្តូរពលកម្មបច្ចុប្បន្ន) គឺវានឹងជួយ

បង្កើនប្រសិទ្ធភាព និងការយល់ដឹងរបស់ការងារដែលខ្លួនកំពុងបំពេញដែលមានន័យថា ថ្នាក់ដឹកនាំរៀបចំ និងចាត់ចែងការងារ និងចេះអភិវឌ្ឍន៍ប្រព័ន្ធអប់រំដើម្បីឆ្លើយតបបច្ចេកវិទ្យា និងម៉ាស៊ីនដែលមានភាពវៃឆ្លាត។

**គ. ផលប៉ះពាល់ទៅលើជំនាញ**

នៅពេលអនាគត ដែលយើងអាចមើលឃើញការងារដែលមានគ្រោះថ្នាក់ទាបដោយសារវត្តមានគ្រឿងម៉ាស៊ីន គឺជាការងារដែលត្រូវការជំនាញទាក់ទងនឹងសង្គម និងភាពច្នៃប្រឌិត ជាពិសេសពាក់ព័ន្ធ និងការសម្រេចចិត្តដែលមិនប្រាកដប្រជា និងការអភិវឌ្ឍគំនិតដើម្បីដោះស្រាយបញ្ហានានា។ ការងារប្រភេទខាងលើនេះក៏ប្រហែលអាចប្រឈមនាពេលអនាគតដែរ។ បើយើងគិតទៅការងារដែលត្រូវការភាពវៃឆ្លាត និងច្នៃប្រឌិតខ្ពស់បំផុតដូចជាការងារផ្នែកសរសេរអាចមានហានិភ័យដោយសារម៉ាស៊ីនផងដែរ។ ម៉ាស៊ីនដ៏វៃឆ្លាតបំផុតទាំងនោះអាចសរសេរអត្ថបទដែលទាក់ទាញអ្នកអានបានល្អបំផុត។ ការសរសេររបស់មនុស្សផងដែរ ដែលលទ្ធផលនេះបានបង្ហាញតាមរយៈការធ្វើតេស្តមួយរបស់កាសែត The New York Times ក្នុងសំណេរអត្ថបទអានពីរផ្សេងគ្នាដើម្បីរកភាពខុសគ្នាតែចុងក្រោយវាពិតជាមានការលំបាក ដើម្បីបញ្ជាក់ថាអត្ថបទមួយណាត្រូវបានសរសេរដោយមនុស្ស និងអត្ថបទមួយណាដែលត្រូវបានសរសេរឡើងដោយអ្នកនិពន្ធមនុស្សយន្ត។ បច្ចេកវិទ្យាគឺកំពុងតែរីកចម្រើនយ៉ាងលឿន ហើយលោកសហស្ថាបនិកនៃវិទ្យាសាស្ត្រដែលជាក្រុមហ៊ុនមានជំនាញក្នុងការផលិតអត្ថបទនិពន្ធដោយស្វ័យប្រវត្តិបានព្យាករណ៍ថានៅពាក់កណ្តាលឆ្នាំ២០២០ (៩០%) នៃការរាយការណ៍ពត៌មានអាចត្រូវបានសរសេរឡើងដោយម៉ាស៊ីន ដែលសឹងតែមិនត្រូវការការត្រួតពិនិត្យពីលើរបស់មនុស្សទេលើកលែងតែទៅលើការរចនា។

ស្ថិតនៅក្នុងបរិបទនៃបរិស្ថានការងារ ដែលកំពុងតែរីកចម្រើនឥតឈប់ឈរសមត្ថភាព ដើម្បីព្យាករណ៍ទុកមុនអំពីអនាគតនៃទីផ្សារការងារ តម្រូវការចំណេះដឹង និងជំនាញដើម្បីឆ្លើយតបទៅលើការផ្លាស់ប្តូរ គឺកាន់តែសំខាន់ឡើងៗសម្រាប់គ្រប់ផ្នែកដែលពាក់ព័ន្ធទាំងអស់។ ចរន្តថ្មីៗទាំងនេះខុសគ្នាតាមប្រភេទនៃឧស្សាហកម្ម និងភូមិសាស្ត្រ ហើយដូច្នេះវាមានសារៈសំខាន់ណាស់ ដែលមនុស្សត្រូវយល់ដឹងអំពីឧស្សាហកម្ម និងលទ្ធផលចុងក្រោយ នៃបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទីបួន។ នៅក្នុងរបាយកាណ៍របស់វេទិកាអនាគត (Forum's Future Jobs) ស្តីពីរបាយការណ៍ការងារយើងបានសាកសួរទៅកាន់មន្ត្រីផ្នែកមនុស្សអំពីការងារដែលធំជាងគេទាំងដប់នៅក្នុងបណ្តាឧស្សាហកម្ម និងទីផ្សារសេដ្ឋកិច្ចចំនួន១៥ ដើម្បីព្យាករណ៍អំពីផលប៉ះពាល់របស់ការងារទូទៅ និងជំនាញនានារហូតដល់ឆ្នាំ២០២០។ បើសិនប្រៀបធៀបជាមួយការងារ ដែលត្រូវការប្រើប្រាស់កម្លាំង៤ការងារដែលត្រូវប្រើជំនាញបច្ចេកទេសរបាយការណ៍នោះបានរកឃើញថា នៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ គឺជាឆ្នាំដែលសំខាន់ត្រូវប្រឈមទៅនឹងការផ្លាស់ប្តូរ។ ទីផ្សារការងារជារួម គឺនិងមិនសូវផ្លាស់ប្តូរទេប៉ុន្តែនឹងមានការប្រេបាច់បញ្ចូលគ្នារវាងការងារនៅក្នុងឧស្សាហកម្ម និងជំនាញទៅក្នុងមុខរបរជាច្រើន។ ខណៈដែលតម្លៃពលកម្ម និងសមភាពនៃជីវិត និងការងារ គឺត្រូវគេរំពឹងថានឹងរីកចម្រើនបន្តិចបន្តួចសម្រាប់មុខរបរភាគច្រើនសុវត្ថិភាពការងារ គឺត្រូវបានរំពឹងថានិងកាន់តែធ្លាក់ចុះពាក់កណ្តាលបើតាមការស្រាវជ្រាវ។ បញ្ហាដែលចំបងនៅទីនេះ គឺពាក់ព័ន្ធនឹងការផ្សារភ្ជាប់គ្នារវាងពេលវេលា និងកិច្ចប្រឹងប្រែងដែលតម្រូវឱ្យមានសមត្ថភាពជំនាញបច្ចេកទេសខុសៗពីគ្នាខណៈដែលវានឹងមានគ្រោះថ្នាក់ទៅដល់ការងារដែលពាក់ព័ន្ធលើការផ្តល់សេវាកម្មផ្ទាល់ខ្លួន និងប្រភេទការងារដែលត្រូវបានបំពេញភាគច្រើនដោយបុរសដែលពិបាកនឹងថ្លឹងថ្លែង។ បើដូចច្នេះបដិវត្តន៍ឧស្សាហកម្ម

ដំណាក់កាលទីបួនប្រហែលជានាំទៅរកភាពខុសគ្នារវាងតួនាទីរបស់បុរស និងស្ត្រីនៅក្នុងសង្គមការងារ។ នេះគឺជាលទ្ធផលអវិជ្ជមានមួយពីបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទីបួនខណៈដែលវានឹងបង្កើនវិសមភាពយេនឌ័រ និងគម្លាតយេនឌ័រទាំងមូល ដែលធ្វើឱ្យវាកាន់តែពិបាកដើម្បីលើកកម្ពស់ភាពប៉ិនប្រសប់របស់ពួកគេនៅក្នុងទីផ្សារការងារនាពេលអនាគត។ វាក៏បន្ថែមគ្រោះថ្នាក់កាន់តែខ្លាំងក្លាឡើងដោយការកើនឡើងនៃភាពផ្សេងគ្នា និងការរីកចម្រើនដែលកាន់តែអាក្រក់ជាងមុខទៅទៀត។

## ឃ. ប្រភពនៃការផ្ទុះឡើងនៃបច្ចេកវិទ្យា

ប្រភពច្រើនចម្រុះគ្នានៃការផ្ទុះឡើងនៃប្រព័ន្ធបច្ចេកវិទ្យាបង្កឱ្យមានទម្រង់នៃផលប៉ះពាល់ផ្សេងៗពីគ្នាទៅលើអាជីវកម្ម។ នៅផ្នែកខាងផ្គត់ផ្គង់ឧស្សាហកម្មជាច្រើនកំពុងតែមើលឃើញនូវសេចក្តីណែនាំនៃបច្ចេកវិទ្យាថ្មីដែលបានបង្កើតវិធីថ្មីទាំងស្រុងដើម្បីបំពេញតម្រូវការអតិថិជនចាស់ និងបំពេញតម្រូវការសង្វាក់តម្លៃចាស់ដែលកំពុងតែផ្ទុះឡើងគួរឱ្យកត់សំគាល់។ មានឧទាហរណ៍ជាច្រើនដែលបច្ចេកវិទ្យាមានថាមពលសម្រាប់ផ្ទុក និងជាក្រឡាចត្រង្គថ្មី និងបង្កើនល្បឿនឆ្ពោះទៅរកប្រភពវិមជ្ឈការបន្ថែមទៀត។ ការអនុញ្ញាតឱ្យមានការរីករាលដាលនៃការបោះពុម្ព 3Dធ្វើឱ្យមានការចែកចាយផលិត និងផ្នែកថែទាំគ្រឿងបន្លាស់កាន់តែមានភាពងាយស្រួល និងមានតម្លៃថោក។ ពេលវេលា និងភាពឈ្លាសវៃពិតប្រាកដនឹងផ្តល់ការយល់ដឹងតែមួយគត់នៅលើអតិថិជន និងប្រតិបត្តិផ្នែកទ្រព្យសម្បត្តិដែលនឹងពង្រីកទៅតាមនិន្នាការបច្ចេកវិទ្យាដទៃទៀត។ តម្លៃដែលពួកគេបានផ្តល់នេះ គឺជាមូលហេតុដែលត្រូវពិចារណាអំពីការគំរាមកំហែងដ៏ធំបំផុតរបស់ពួកគេដែលមិនធ្លាប់បានចាត់ទុកថាបច្ចេកវិទ្យា គឺជាគូប្រកួតប្រជែង។ ទោះជាយ៉ាងណាវាជាកំហុសមួយដែលគិតថាការផ្ទុះឡើងនៃដៃគូប្រកួតប្រជែងផ្នែកបច្ចេកវិទ្យានេះនឹងមកតែតាមរយៈការបង្កើតប៉ុណ្ណោះទេ។ ប៉ុន្តែឌីជីថលអាចឱ្យធ្វើមានយ៉ាងធំទូលាយហើយឆ្លងទៅដល់ព្រំដែនឧស្សាហកម្មតាមរយៈការបង្កើនអនុភាពអតិថិជនរបស់ខ្លួនជាគោលហើយហេដ្ឋារចនាសម្ព័ន្ធ ឬបច្ចេកវិទ្យា។ ការផ្លាស់ប្តូរនៃក្រុមហ៊ុនទូរគមនាគមន៍ទៅក្នុងការថែទាំសុខភាព និងផ្នែករថយន្តស្វ័យប្រវត្តិផ្សេងៗជាឧទាហរណ៍។ ទំហំនៅតែអាចជាគុណប្រយោជន៍ក្នុងការប្រកួតប្រជែង ប្រសិនបើមានការបង្កើនអនុភាពប្រកបដោយភាពឆ្លាតវៃ។ ទោះជាយ៉ាងណាក៏ដោយក៏បន្ទាត់ក្រោមគេនៅតែមានថ្នាក់ដឹកនាំ ក្រុមហ៊ុន និងនាយកប្រតិបត្តិជាន់ខ្ពស់ត្រូវយល់នៃបច្ចេកវិទ្យាវាបានប៉ះពាល់ទាំងសងខាងទាំងផ្នែកតម្រូវការ និងផ្គត់ផ្គង់នៃអាជីវកម្មរបស់ខ្លួន។ ផ្ទុយទៅវិញទាំងនេះត្រូវតែប្រឈមនឹងការសន្មតរបស់ក្រុមប្រតិបត្តិការរបស់ខ្លួន និងសៃពួកគេក្នុងការធ្វើអ្វីមួយ។ នៅក្នុងរយៈពេលដ៏ខ្លីពួកគេបានផ្លាស់ប្តូរជាបន្តបន្ទាប់។ ផលប៉ះពាល់ដ៏សំខាន់ទាំងបួន បដិវត្តន៍ឧស្សាហកម្មលើកទី៤មានផលប៉ះពាល់សំខាន់ចំនួនបួននៅលើ អាជីវកម្មនៅទូទាំងឧស្សាហកម្មៈ៖

- រំពឹងទុករបស់អតិថិជនត្រូវបានផ្លាស់ប្តូរ
- ផលិតផលត្រូវបានគេធ្វើឱ្យប្រសើរដោយទិន្នន័យដែលធ្វើឱ្យប្រសើរឡើងនូវផលិតភាពទ្រព្យសកម្ម
- ភាពជាដៃគូថ្មីមួយត្រូវបានគេបង្កើតឡើងជាក្រុមហ៊ុនដែលបានរៀនពីសារៈសំខាន់នៃទម្រង់ថ្មីនៃកិច្ចសហប្រតិបត្តិការនេះ
- ម៉ូដែលកំពុងតែប្រតិបត្តិការត្រូវបានថ្លែងទៅជាម៉ូដែលឌីជីថលថ្មី។

- **ផលិតផលបង្កើនដោយទិន្នន័យ**

បច្ចេកវិទ្យាថ្មីកំពុងផ្លាស់ប្តូររបៀបដែលអង្គការយល់ដឹង និងចាត់ចែងទ្រព្យសម្បត្តិរបស់ពួកគេដូចជាផលិតផលនិងសេវាកម្មត្រូវបានលើកកំពស់ជាមួយសមត្ថភាពឌីជីថលដែលបង្កើនគុណតម្លៃរបស់ពួកគេ។ ឧទាហរណ៍៖ ក្រុមហ៊ុន Tesla បង្ហាញពីរបៀបដែលធ្វើឱ្យទាន់សម័យកម្មវិធីលើរលកធាតុអាកាស (Over the air software) និងការតភ្ជាប់អាចត្រូវបានប្រើដើម្បីពង្រឹងផលិតផលមួយរថយន្តមួយបន្ទាប់ពីការទិញជាជាងអនុញ្ញាតឱ្យវាធ្លាក់តម្លៃតាមពេលវេលា។ មិនមែនសម្ភារៈថ្មីដែលធ្វើឱ្យឧបករណ៍ប្រើប្រាស់បានយូរ និងធន់ប៉ុណ្ណោះទេប៉ុន្តែទិន្នន័យ និងការវិភាគក៏កំពុងផ្លាស់ប្តូរតួនាទីនៃការថែរទាំផងដែរ។ ការវិភាគបានផ្តល់ដោយឧបករណ៍ចាប់សញ្ញាំ (sensors) ដែលបានដាក់នៅលើឧបករណ៍ (assets) ដើម្បីអនុញ្ញាតឱ្យការត្រួតពិនិត្យខ្ជាប់ខ្ជួន និងការថែទាំរបស់គេរិតតែសកម្មផងដែរ ហើយការធ្វើដូច្នេះ គឺដើម្បីបង្កើនការប្រើប្រាស់របស់គេឱ្យដល់កម្រិតអតិបរិមា។

- **នវានុវត្តន៍សហការ**

បទពិសោធន៍របស់អតិថិជនលើពិភពលោក សេវាកម្មផ្អែកលើទិន្នន័យ និងការបំពេញមុខងាររបស់ឧបករណ៍តាមរយៈការវិភាគតម្រូវឱ្យមានទម្រង់ថ្មីនៃសហប្រតិបត្តិការជាពិសេសត្រូវបានផ្តល់ឱ្យនូវល្បឿន នៃការបង្កើតថ្មី និងការបង្អាក់កំពុងកើតឡើង។ នេះគឺជាការពិតសម្រាប់អ្នកកំពុងកាន់អំណាច និងជំនួញដែលបានបង្កើតរួចហើយ និងក្មេងខ្ចីផងដែរ។ សម្រាប់សហគ្រាសដែលបង្កើតជារឿយៗខ្វះខាតជំនាញជាក់លាក់ និងមានសមត្ថភាពឆ្លើយ។ វេទិកាឈានមុខខាងបច្ចេកវិទ្យា (Forum Technology neer) បានបង្កើតឡើងនៅសាកលវិទ្យាល័យស្តេនហ្វដក្នុងឆ្នាំ២០០៨។ ភាពជាដៃគូប្រភេទនេះផ្តល់ឱ្យក្រុមហ៊ុនស៊ីមិនអាចរកដៃគូ ដែលអាចជួយបញ្ហាប្រឈមស្មុគ្រស្មាញនៃការទាញយកការយល់ដឹងចេញពីទិន្នន័យដ៏ទូលំទូលាយ ចំណែកឯក្រុមហ៊ុនអាយ៉ាសឌីអាចធ្វើឱ្យមានសុពលភាពដល់វិធីសាស្ត្រវិភាគទិន្នន័យភូមិសាស្ត្ររបស់ខ្លួន ជាមួយទិន្នន័យពីភពលោកពិតនៅខណៈពេលដែលពង្រីកវត្តមានទីផ្សារ។ ទោះបីយ៉ាងណាក៏ដោយសហប្រតិបត្តិការរបៀបនេះជារឿយៗចេញឆ្ងាយពីគោលដៅត្រង់ពួកគេតម្រូវឱ្យមានការវិនិយោគពិសេសពីភាគីទាំងពីរ។

ដើម្បីអភិវឌ្ឍន៍យុទ្ធសាស្ត្រហ្មត់ចត់ស្វែងរកដៃគូសមស្របបង្កើតខ្សែទំនាក់ទំនងដើម្បីដំណើរការ និងឆ្លើយតបយ៉ាងបត់បែនចំពោះលក្ខខណ្ឌដែលកំពុងផ្លាស់ប្តូរទាំងក្នុង និងក្រៅភាពជាដៃគូ។ ជួនកាលសហប្រតិបត្តិការប្រភេទនេះ ភ្ញាស់(spawn) ម៉ូដែលមុខជំនួញថ្មី ដូចជាគម្រោងចែករំលែក រថយន្តក្រុងដែលនាំមកនូវជំនួញរួមគ្នាពីពហុឧស្សាហកម្មដើម្បីផ្តល់នូវបទពិសោធន៍អតិថិជនរួមបញ្ចូលគ្នា។ បែបនេះមានគុណប្រយោជន៍ល្អនៅពេលដែលអ្នកទន់ខ្សោយជាងគេភ្ជាប់ទៅក្នុងចង្វាក់ភាពជាដៃគូ។ ក្រុមហ៊ុនត្រូវតែទៅមុខឱ្យបានល្អពីក្រោយទីផ្សារ និងកិច្ចព្រមព្រៀងលក់ដើម្បីយល់នូវរបៀបនៃការអនុម័តយកវិធីសាស្ត្រសហការគ្នាពេញលេញ (Comprehensive collaborative approaches)។

### ង. សង្គម

នៅក្នុងវិស័យសង្គម ការកសាងសង្គមឌីជីថលបង្កឱ្យមានផលប៉ះពាល់មួយចំនួនដែលកើតមានឡើងតាមរបៀបថ្មីដូចខាងក្រោម៖ ផលប៉ះពាល់ដល់វប្បធម៌ និងប្រពៃណី និងការប្រាស្រ័យទាក់ទង ការជ្រាបចូលនៃវប្បធម៌ និងប្រពៃណីដទៃ តាមរយៈបច្ចេកវិទ្យាឌីជីថលអាចជះឥទ្ធិពលមកលើវប្បធម៌ និងប្រពៃណីពីបុរាណរបស់កម្ពុជាដែលអាចបង្កឱ្យមានប្រតិកម្មសង្គម (Social Backlash) បើមិនមានការគិតគូរលើវិធានការជាក់លាក់។

ជាមួយគ្នានេះឧបករណ៍ឌីជីថលកំពុងផ្លាស់ប្តូររបៀប ឬបែបបទនៃការប្រាស្រ័យទាក់ទង រួមមានជាអាទិ៍ ការផ្សព្វផ្សាយ ការកម្សាន្ត ការទទួលបាននូវចំណេះដឹង ការប្រកបអាជីវកម្ម។ ទន្ទឹមនេះការចំណាយពេលច្រើនជាមួយនឹងបច្ចេកវិទ្យាខណៈចំណាយពេលតិចក្នុងការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយគ្នានៅផ្ទះ និងទីកន្លែងធ្វើការ។ នៅក្នុងការរីកចម្រើនផ្នែកវិទ្យាស្ត្រការធ្វើពាណិជ្ជកម្ម និងការបង្កើតថ្មី គឺជាដំណើរការនៃភាពរីកចម្រើននៅក្នុងសង្គម ការអភិវឌ្ឍធនធានមនុស្ស និងការផ្លាស់ប្តូរការគិតអំពីសីលធម៌សង្គម។ វាមានផលវិបាកដែរដែលការយល់ដឹងសង្គមពីប្រព័ន្ធបច្ចេកវិទ្យាថ្មីៗមានវិស័យជាច្រើនដែលជួបការបង្កើតអ្វីដែលថ្មីនៅក្នុងសង្គម។ ឧបសគ្គធំបំផុតនៅក្នុងសង្គមគឺការស្រូបយក និងការបបនូវភាពជឿនលឿនទៅក្នុងសង្គម ដែលប្រកាន់ទំនៀមទំលាប់ប្រពៃណីនៅក្នុងបដិវត្តន៍ឧស្សាហកម្មលើកទីបួនមានការសាកល្បងបានមានភាពតានតឹង និងបានកើតឡើងដោយសារមានក្រុមខ្លះបានការពារនៃជំនឿសាសនា និងទស្សនៈរបស់ពួកគេពីឥទ្ធិពលនៃទំនើបកម្មរបស់ពិភពលោក។

នៅពេលដែលបច្ចេកវិទ្យាធំៗត្រូវបានផ្លាស់ប្តូរប្រជាជនសង្គម និងស្ថាប័នផ្សេងៗ ក៏នឹងផ្លាស់ប្តូរដែរ។ ឥទ្ធិពលដែលមានគឺជារឿងដែលពួកយើងត្រូវជៀសវាង និងយកចិត្តទុកដាក់ដើម្បីឱ្យសង្គមមានការផ្លាស់ប្តូរបច្ចេកវិទ្យាដោយសមស្របតាមស្ថានភាពនៅក្នុងសង្គមជាក់នៅក្នុងការពិភាក្សាមុនគឺបានព្យបង្ហាញអំពីភាពខុសគ្នានៃឥទ្ធិពលរបស់បដិវត្តន៍ឧស្សាហកម្មលើកទីបួនទៅលើសេដ្ឋកិច្ចជំនួញ ភូមិសាស្រ្តនយោបាយសន្តិសុខអន្តរជាតិ តំបន់ និងទីក្រុងបង្ហាញយ៉ាងច្បាស់ថា បដិវត្តន៍ឧស្សាហកម្មថ្មីៗ និងមានឥទ្ធិពលជាច្រើនទៅលើសង្គម។

**ច. និយោជន៍ ឬរបរ**

ការប្រកបដោយសក្តានុពលនៃបច្ចេកវិទ្យាលើកំណើនសេដ្ឋកិច្ចនោះក៏ដោយសារៈសំខាន់ចំពោះការបង្ហាញឱ្យឃើញពីផលប៉ះពាល់ ជាអវិជ្ជមានរបស់វានៅលើទីផ្សារការងារយ៉ាងតិចណាស់ក៏ក្នុងរយៈពេលខ្លីដែរ។ ការភ័យខ្លាចអំពីផលប៉ះពាល់នៃបច្ចេកវិទ្យានៅលើនិយោជន៍នោះ ក្រោយមកបានឱ្យមានការកាត់បន្ថយក្នុងការប្រើប្រាស់កម្លាំងពលកម្មខ្លះ និងបែរមករកលើការប្រើប្រាស់ប្រព័ន្ធបច្ចេកបវិទ្យាជំនួយវិញ។ មូលហេតុដែលនាំឱ្យបដិវត្តន៍បច្ចេកវិទ្យាថ្មីនេះ និងការបង្កឱ្យមានចលាចលច្រើនជាងបដិវត្តន៍ឧស្សាហកម្មពីពេលមុនៗល្បឿន(អ្វីគ្រប់យ៉ាងដែលកំពុងកើតឡើងក្នុងល្បឿនលឿនជាងពេលពីមុន) វិសាលភាព និងជម្រៅ (ផ្លាស់ប្តូររ៉ាឌីកាលជាច្រើនត្រូវបានកើតមានឡើងក្នុងពេលដំណាលគ្នា) និងការផ្លាស់ប្តូរប្រព័ន្ធទាំងស្រុង។ ផលប៉ះពាល់នៃការប្រកួតប្រជែងពីរដែលបច្ចេកវិទ្យាអនុវត្តន៍លើវិស័យការងារ ឬនិយោជន៍៖

- ទី១. ផលវិនាសកម្មនៃការផ្ទុះឡើងនៃបច្ចេកវិទ្យា និងស្វ័យប្រវត្តិកម្មមកជំនួសមូលធនសម្រាប់កម្លាំងពលកម្មដែលធ្វើឱ្យកម្មករបាត់បង់ការងារ ឬដើម្បីរៀបចំជំនាញរបស់ពួកគេឡើងវិញនៅគ្រប់ទីកន្លែង
- ទី២. ផលវិនាសកម្មដោយការផ្ទុះឡើងនៃបច្ចេកវិទ្យាកើតឡើងជាមួយ និងផលមូលធនកម្មដែលតម្រូវការទំនិញថ្មីៗ និងសេវាកម្មនានាមានការកើនឡើង ហើយឈានទៅរកការបង្កើតនូវអាជីពថ្មី ឬមុខរបរថ្មីៗជំនួញ ឬពាណិជ្ជកម្មថ្មី និងឧស្សាហកម្មថ្មីៗ។[105]

### ២.៣.២. ទិសដៅការងារបន្ទាប់

ការប្រែប្រួលគោលនយោបាយ និងសេដ្ឋកិច្ចសង្គមជាសាកលដូចជា ការអនុវត្តគោលនយោបាយគាំពារនិយម ភាពមិនច្បាស់លាស់នៃគោលនយោបាយពាណិជ្ជកម្មរបស់ប្រទេសមហាអំណាចសេដ្ឋកិច្ចបម្រែបម្រួលនៃ

[105] សៀវភៅ «បដិវត្តន៍ឧស្សាហកម្មលើកទី៤» ទំព័រទី៣២-៤២

សេដ្ឋកិច្ចជាសាកលជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យបច្ចេកវិទ្យាដូចជា ការចាប់ផ្ដើមអនុវត្តនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា និងការអូសបន្លាយភាពមិនប្រាកដប្រជានៃស្ថានភាពនយោបាយហិរញ្ញវត្ថុ សន្តិសុខទាំងក្នុងតំបន់ និងពិភពលោកបានបង្កើតឱកាសឱ្យមានសកម្មភាព។ ការកែសម្រួលបទប្បញ្ញត្តិ និងវិធានការការងារជាក់លាក់មួយចំនួន ដែលមានស៊ីចង្វាក់គ្នាទៅនឹងឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកាន់តែមានទំហំធំ និងស្មុគស្មាញ។ ពង្រឹងបន្ថែមលើការអភិវឌ្ឍសមត្ថភាព និងធនធានមនុស្ស យកចិត្តទុកដាក់ពង្រឹងការអនុវត្តរចនាសម្ព័ន្ធគ្រប់គ្រងថ្មី និងផ្ដល់ឱកាសក្នុងការពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងដឹកនាំ ការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងកិច្ចប្រតិបត្តិការផ្សេងៗ និងការត្រួតពិនិត្យតាមដានវាយតម្លៃលើការបំពេញការងាររបស់មន្ត្រីគយ និងរដ្ឋាករ គឺជាឱកាសដ៏មានតម្លៃក្នុងការជំរុញប្រសិទ្ធភាពឱ្យមានអនុលោមភាព និងការអនុវត្តច្បាប់។

ដំណោះស្រាយបញ្ហាប្រឈមមានន័យបំផុតបើគេអាចប្រមូលផ្ដុំប្រាជ្ញាជារួមនៃគំនិតដើម្បីសម្របតាមកំណត់ និងទាញសក្តានុពលនៃការរីកសាយភាយដោយអនុវត្តន៍តាមបរិបទ (គំនិត) ច្នៃប្រឌិតអំពីការគ្រប់គ្រងនៅប្រព័ន្ធឌីជីថល។ ការបម្រើការងារត្រូវមានទិសដៅ និងគោលបំណងច្បាស់លាស់លើការបែងចែកនៃការងារក្នុងការគ្រប់គ្រងគួបផ្សំជាមួយគុណសម្បត្តិផ្សេងៗទៀតដើម្បីធ្វើការផ្លាស់ប្តូរជាមួយសកម្មភាពឆ្ពោះទៅមុខនៃការចង់បានផលរួមក្នុងការអនុវត្តការងារ។ ចំពោះការគ្រប់គ្រងមេដឹកនាំត្រូវយល់ និងមានភាពវៃឆ្លាតតាមបរិបទ។[106] ការសម្គាល់ទៅលើបរិបទនេះគេចង់បានការកំណត់ ជាសមត្ថភាព និងឆន្ទៈក្នុងការប្រមើលមើលនិន្នាការដែលកំពុងតែលេចឡើង និងការតភ្ជាប់ចំណុចតូចៗ។ ទាំងនេះជាលក្ខណៈរួមនៃការដឹកនាំដែលមានប្រសិទ្ធភាពទូទាំងជំនាន់នៅក្នុងបដិវត្តន៍ឧស្សាហកម្មលើកទី៤ពួកគេ គឺជាតម្រូវការជាមុនសម្រាប់ការសម្របសម្រួល និងការរស់រានមានជីវិត។

- ដើម្បីអភិវឌ្ឍតាមបរិបទត្រូវសម្រេចចិត្តត្រូវតែយល់អំពីតម្លៃនៃបណ្ដាញចម្រុះសិន។ ការប្រឈមមានតាមកម្រិតថា តើអាចប្រឈមបានដល់កម្រិតណាមួយ? ប្រសិនបើការគ្រប់គ្រងបានតភ្ជាប់ទំនាក់ទំនងគ្នាបានល្អនឹងធ្វើឱ្យអាចត្រៀមខ្លួនដើម្បីចូលរួមជាមួយបញ្ហាដែលកំពុងប្រឈម
- តាមរយៈការធ្វើការងាររួមគ្នា និងសហការគ្នាជាមួយមេដឹកនាំអាជីវកម្ម រដ្ឋាភិបាល សង្គមស៊ីវិល ជំនឿផ្នែកសិក្សាស្រាវជ្រាវនៅមហាវិទ្យាល័យ និងយុវជនជំនាន់ក្រោយដែលអាចធ្វើឱ្យបានដើម្បីបានជាទស្សនៈរួមជាមួយនៃអ្វីដែលកំពុងអនុវត្តន៍បន្តកើតឡើង
- សារៈសំខាន់ក្នុងការអភិវឌ្ឍ អនុវត្តន៍គំនិតរួមបញ្ចូលគ្នា ព្រមទាំងដំណោះស្រាយដែលនឹងមានលទ្ធផលក្នុងការផ្លាស់ប្តូរប្រកបដោយនិរន្តរភាព
- ព្រំដែនរវាងវិស័យ និងអាជីព គឺសិប្បនិម្មិតហើយកំពុងក្លាយជាផលអវិជ្ជមានកាន់តែខ្លាំងឡើង។ វាជាការចាំបាច់មួយដើម្បីរំលាយឧបសគ្គទាំងនេះ ដោយការចូលរួមអំណាចនៃបណ្ដាញដើម្បីបង្កើតភាពជាដៃគូរដែលមានប្រសិទ្ធភាព

[106] The term ‟contextual intelligence˝ was coined by Nihtin Nohria several years before he became the dean of Harvard Business School˝.

- ក្រុមហ៊ុន និងអង្គការដែលបរាជ័យក្នុងការធ្វើនេះហើយមិនបានអនុវត្តន៍អ្វីដែលខ្លួនបានសន្យាក្នុងការកសាងក្រុមចម្រុះ និងជួបពេលលំបាកក្នុងការសម្របខ្លួនទៅនឹងការរំខាននៃយុគសម័យឌីជីថល
- ថ្នាក់ដឹកនាំផងដែរត្រូវបង្ហាញសមត្ថភាពក្នុងការផ្លាស់ប្តូរផ្លូវចិត្ត គំនិតក្របខណ្ឌ និងគោលការណ៍រៀបចំ។ ក្នុងពិភពលោកមានការផ្លាស់ប្តូរយ៉ាងលឿននេះការគិតតែមួយជ្រុង និងមានទស្សនៈតែមួយជ្រុងអំពីអនាគត គឺត្រូវជាប់គាំងដែលនេះជាមូលហេតុល្អប្រសើរជាងមុន
- វិធីសាស្ត្ររបស់មេដឹកនាំនានាចំពោះបញ្ហារឿងក្តី បញ្ហាប្រឈមត្រូវតែមានលក្ខណៈសន្តនិយម (Holistic) អាចបត់បែនបាន និងអាចប្រែប្រួលបានពេល គឺការរួមបញ្ចូលគ្នាជាបន្តបន្ទាប់នូវផលប្រយោជន៍ និងទស្សនៈចម្រុះជាច្រើន។

ទន្ទឹមនឹងប៉ុន្មានឆ្នាំចុងក្រោយនេះប្រព័ន្ធICT នៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដែលបង្ហាញអំពីសក្តានុពលនៃវិស័យឌីជីថលក្នុងការប្រែក្លាយជាប្រភពកំណើនថ្មី។ ការប្រើប្រាស់សេវាក៏ដូចជាអ៊ីនធឺណេតតាមទូរស័ព្ទចល័តបាន និងកំពុងបន្តកើនឡើងជាលំដាប់។ ទោះជាយ៉ាងនេះក្តីវិសាលភាពគ្របដណ្តប់ និងការប្រើប្រាស់ភាគច្រើនប្រមូលផ្តុំនៅតាមទីក្រុង និងទីប្រជុំជនធំៗហើយគុណភាពសេវាកំពុងក្លាយជាបញ្ហាប្រឈមដោយសារកំណើននៃការប្រើប្រាស់ ជាគំហុកក្នុងបរិការណ៍នៃការរាតត្បាតជម្ងឺកូវីដ-១៩ និងការប្រកួតប្រជែងយ៉ាងខ្លាំងក្លា។ ការអភិវឌ្ឍការចាប់យកឌីជីថលក៏ដូចជាការធ្វើឌីជីថលូបនីយកម្ម និងការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និងសង្គមនៅកម្ពុជាស្ថិតនៅដំណាក់កាលចាប់ផ្តើមនៅឡើយ។ ក្នុងបរិបទនេះឧបសគ្គមួយចំនួនទាំងកត្តាជំរុញ និងកត្តាចាប់យកបច្ចេកវិទ្យាក្នុងចំណោមតួអង្គសំខាន់ៗបាន និងកំពុងរាំងស្ទះដល់ដំណើរឆ្ពោះទៅមុខនៃការត្រៀមខ្លួនឌីជីថលរបស់កម្ពុជា។

តាមការវាយតម្លៃ ជាអន្តរជាតិការត្រៀមខ្លួនរបស់កម្ពុជាជារួមក្នុងការចាប់យកវិស័យឌីជីថលស្ថិតនៅក្នុងកម្រិតមួយទាប។ ជាក់ស្តែងសម្រាប់កត្តាជំរុញការត្រៀមខ្លួនកម្ពុជាឈរនៅលេខរៀងទី ១០២ ក្នុងចំណោមប្រទេស១៤១ ឬលេខរៀងទី៧ ក្នុងចំណោមប្រទេសសមាជិកអាស៊ានទាំង៩ (លើកលែងប្រទេសព្រុយណេ) ដែលត្រូវបានចាត់ទុកថា ជាប្រទេសក្នុងចំណោមប្រទេសមានល្បឿនទាបក្នុងការត្រៀមខ្លួនឌីជីថល ឬមានការត្រៀមខ្លួនឌីជីថលបណ្តើរៗ ជាពិសេសលើផ្នែកការអភិវឌ្ឍធនធានមនុស្ស ការចាប់យកបច្ចេកវិទ្យា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និងការកែសម្រួលបរិយាកាសធុរកិច្ច។ សម្រាប់ការចាប់យកបច្ចេកវិទ្យាក្នុងចំណោមតួអង្គសំខាន់ៗកម្ពុជាក៏ឈរក្នុងលំដាប់ទាបធៀបនឹងប្រទេសក្នុងតំបន់ដែលបង្ហាញឱ្យឃើញថាការចាប់យកបច្ចេកវិទ្យាក្នុងចំណោមរដ្ឋាភិបាលពលរដ្ឋ និងធុរជននៅមានកម្រិតទាបនៅឡើយ។ នៅក្នុងដំណើរឆ្ពោះទៅបរិវត្តកម្មឌីជីថលការត្រៀមខ្លួន គឺជាបុរេលក្ខខណ្ឌចាំបាច់ដែលប្រទេសនានាបាន និងកំពុងរៀបចំ និងដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាយុទ្ធសាស្ត្រក្នុងការចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីសេដ្ឋកិច្ចឌីជីថល។ តាមរយៈឧត្តមានុវត្តន៍នៃការអនុវត្តនៅតាមបណ្តាប្រទេសនានាការចាប់យកសេដ្ឋកិច្ច និងសង្គមឌីជីថលផ្តោតលើសមាសធាតុសំខាន់ៗដែលរួមមាន៖

១. មូលដ្ឋានឌីជីថល សំដៅដល់ការកសាងនូវហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល

២. ក្របខណ្ឌច្បាប់សំដៅដល់ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដើម្បីលើកកម្ពស់ភាពជឿទុកចិត្តលើការប្រើប្រាស់ទំនិញ និងសេវាឌីជីថល និងការធ្វើធុរកិច្ចឌីជីថល ព្រមទាំងធានាការការពារសន្តិសុខសាយប័រ (Cybersecurity)

៣. មូលធនមនុស្សសំដៅដល់ការអភិវឌ្ឍធនធានមនុស្សដោយការអប់រំ និងការបណ្តុះបណ្តាលពហុជំនាញ ព្រមទាំងការបណ្តុះនូវអ្នកមានទេពកោសល្យក្នុងការអភិវឌ្ឍនវានុវត្តន៍ និងបច្ចេកវិទ្យាថ្មីៗឆ្លើយតបទៅនឹងតម្រូវការនាពេលបច្ចុប្បន្ន និងពេលអនាគត

៤. ការធ្វើបរិវត្តកម្មឌីជីថលនៃវិស័យសាធារណៈសំដៅធ្វើសមាហរណកម្មប្រព័ន្ធរដ្ឋាភិបាលគ្រប់ក្រសួង-ស្ថាប័ន និងធានាបាននូវការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋគ្រប់រូប គ្រប់ពេលវេលា និងគ្រប់ទីកន្លែង

៥. ធុរកិច្ចឌីជីថលសំដៅដល់ការបង្កើតនូវបរិយាកាសអំណោយផលសម្រាប់ប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ចឌីជីថលតាមរយៈការធ្វើទំនើបកម្មវិស័យឯកជន, ការជំរុញធុរកិច្ចថ្មីៗ និងការធានាបាននូវការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលប្រកបដោយចីរភាព និងបរិយាបន្នកម្ម។

### ២.៣.៣. ដំណោះស្រាយ និងការប្រកួតប្រជែង

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅកម្ពុជាមានភាពរីកចម្រើនខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះដើម្បីឆ្លើយតបនឹងកំណើនដ៏ខ្លាំងក្លានៃតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការប្រើប្រាស់លើសេវាអ៊ីនធឺណេតជាពិសេសអ៊ីនធឺណេតតាមទូរស័ព្ទចល័តដាក់ស្តែងកម្ពុជាមានវឌ្ឍនភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធ ទូរគមនាគមន៍នៅលំដាប់មធ្យមនៅក្នុងកម្រិតតំបន់ និងសកល។ ទោះបីជាហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណេតនៅកម្ពុជាមានវិសាលភាពគ្របដណ្តប់កាន់តែល្អប្រសើរមានថ្លៃសមរម្យជាពិសេសនៅតាមទីក្រុង និងទីប្រជុំជនធំៗគុណភាពជារួមនៅមានកម្រិតនៅឡើយ ដែលទាមទារឱ្យមានការពង្រឹងបន្ថែម។ ទន្ទឹមនេះហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅពុំទាន់គ្រប់គ្រាន់ក្នុងការជំរុញបរិវត្តកម្មឌីជីថល និងការចាប់យកកាលានុវត្តភាពថ្មីៗបាននោះឡើយ។ ដូច្នេះសម្រាប់ជាមូលដ្ឋានក្នុងការធ្វើបរិវត្តកម្មឌីជីថលដែលនឹងជ្រាបចូលស្ទើរគ្រប់កោសិកានៃសង្គម និងគ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលនឹងផ្តោតការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលលើទិដ្ឋភាពពធំៗដែលរួមមានការតភ្ជាប់ឌីជីថល ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល និងឡូហ្ស៊ីស្ទិកក្នុងការដឹកជញ្ជូនគោលដៅចុងក្រោយ ។

យុទ្ធសាស្ត្រនយោបាយបានជួយឆ្លុះបញ្ចាំងពីឧស្សាហកម្មទីផ្សារតាមពិតវិធីសាស្ត្រស្ទើរតែទាំងអស់ដែលបានលើកឡើងមកពន្យល់នៅក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានគេប្រើប្រាស់រួចទៅហើយដោយក្រុមហ៊ុនរកប្រាក់ចំណេញមុនពេលដែលវិធីសាស្ត្រទាំងនេះត្រូវបានយកមកប្រើក្នុងនយោបាយ។ ទោះបីជាវាមិនអាចទៅរួចក្នុងការប៉ាន់ស្មានថាតើយុទ្ធនាការនយោបាយនឹងវិវឌ្ឍន៍យ៉ាងដូចម្តេចនាពេលអនាគតក៏ដោយវិស័យពាណិជ្ជកម្ម និងផ្នែកដែលកំពុងតែកកើតឡើងមួយចំនួនផ្សេងទៀតនៃការស្រាវជ្រាវ និងការពិសោធន៍ផ្តល់នូវតម្រុយខ្លះៗអំពីអ្វីដែលយុទ្ធនាការនឹងត្រូវធ្វើនៅពេលអនាគត។[107]នៅក្នុងជំពូកនេះយើងនឹងស្វែងយល់ពីបច្ចេកវិទ្យាដែលកំពុងរីកចម្រើន

[107] គេហទំព័រ https://capx.co/the-hyper-personalised-future-of-oliticalcampaigning/ ដកស្រង់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១

ជាច្រើនក្នុងការប្រើទិន្នន័យផ្ទាល់ខ្លួន និងបច្ចេកវិទ្យាផ្សេងទៀតដែលកំពុងមានឥទ្ធិពលនៅក្នុងយុទ្ធនាការឃោសនានយោបាយពេលថ្មីៗនេះ។

ការប្រើប្រាស់រូបយន្តនយោបាយ និងការឃោសនាតាមកុំព្យូទ័រនៅក្នុងការជះឥទ្ធិពលតាមអនឡាញដូចជាការប្រើប្រាស់ Hashtag ដែលពេញនិយមនៅលើ Twitter ជាដើមត្រូវបានគេចងក្រងទៅជាឯកសារយ៉ាងត្រឹមត្រូវ ហើយការប្រើវិធីសាស្ត្រនេះក៏ជាប្រធានបទដែលសកម្មក្នុងការងារស្រាវជ្រាវផងដែរ។[108] ដូចដែលអ្នកស្រាវជ្រាវម្នាក់បានព្រមានថា ក្នុងរយៈពេលពីរបីឆ្នាំបន្ទាប់ ការសន្ទនារូបយន្តអាចស្វែងរកអ្នកប្រើប្រាស់ដែលងាយរងគ្រោះ ហើយចូលទៅជិតពួកគេនៅលើឆានែលជជែកកំសាន្តឯកជន។ ការរុករកការសន្ទនាហើយធ្វើការវិភាគទិន្នន័យរបស់អ្នកប្រើ ដើម្បីកែសម្រួលដល់សារនៃការឃោសនាប្រជាភិថុតឱ្យកាន់តែល្អ និងចង្អុលបង្ហាញមនុស្សឱ្យឆ្ពោះទៅរកទស្សនៈជ្រុលនិយម និងជំទាស់ត្រូវបានគេប្រើក្នុងយុទ្ធនាការឃោសនានយោបាយក្នុងហេតុផលជាច្រើនដូចជាការអនុញ្ញាតឱ្យយុទ្ធនាការឃោសនា ឆ្លើយតបទៅនឹងការសាកសួររបស់អ្នកបោះឆ្នោតប្រកបដោយប្រសិទ្ធភាពជួយអ្នកប្រើប្រាស់រុករកព័ត៌មាននយោបាយស៊ីជម្រៅប្រចាំថ្ងៃលុបបំបាត់ពីកំហុស ដោយចៃដន្យរបស់មនុស្សអាចធ្វើការនៅលើបណ្តាញច្រើន និងអាចផ្តល់ការឆ្លើយតបមានលក្ខណៈបុគ្គលទៅកាន់អ្នកប្រើប្រាស់ដែលកំពុងចូលជាមួយពួកគេ។[109] បើយោងតាមការពន្យល់ពីអ្នកជំនាញផ្នែកទំនាក់ទំនងម្នាក់ដែល "ក្នុងន័យនេះរូបយន្តអាចបង្កើតមូលទិន្នន័យបានភ្លាមៗ អាចផ្តល់ស្ថិតិអំពីចំណូលចិត្តការស្នើសុំ និងចម្ងល់របស់ប្រជាជន"។[110] ក្នុងករណីផ្សេងទៀតបានកំណត់នូវគោលដៅអ្នកប្រើប្រាស់ជាមួយការស្ទង់មតិ ដើម្បីវាស់ស្ទង់ពីការឆ្លើយតបទៅនឹងបញ្ហាដែលអនុញ្ញាតឱ្យយុទ្ធនាការឃោសនាអាចធ្វើការប្រមូលទិន្នន័យបន្ថែមបាន។ យុទ្ធនាការឃោសនាទាំងនោះទំនងជាទាញផលចំណេញក្នុងការប្រើបច្ចេកវិទ្យាដូចគ្នានេះ និងធ្វើឱ្យវាកាន់តែមានភាពជឿនលឿនក្នុងការកែច្នៃភាសាធម្មជាតិដែល Google, Amazon និងក្រុមហ៊ុន Microsoft ធ្លាប់ប្រើរូបយន្តរបស់ពួកគេឱ្យកាន់តែដូចមនុស្ស។ ហេតុផលនៅពីក្រោយការស្រាវជ្រាវនេះ គឺដើម្បីអង្កេតឱ្យលម្អិតថាតើបច្ចេកវិទ្យាឌីជីថលទាំងនេះបានបង្ហាញពីគំនិត។ ប្រសិនបើវាអាចធ្វើទៅបានយុទ្ធនាការឃោសនាប្រហែលជានឹងប្រើបច្ចេកវិទ្យា "អត្តសញ្ញាណដែលអាចផ្លាស់ប្តូរបាន" ដើម្បីជះឥទ្ធិពលលើមតិយោបល់ និងបង្កើតភាពរំជើបរំជួលក្នុងចំណោមមនុស្សដែលវាគិតថាជាអ្នកគាំទ្របេក្ខជននយោបាយរបស់ពួកគេ។[111]

ក្នុងព្រឹត្តិការណ៍ Digital Cambodia 2020 នឹងត្រូវបានរៀបចំនៅសាលពិព័រណ៍កោះពេជ្រដែលមានវិទ្យាស្ថានជាតិ NIPTICT ជាម្ចាស់ព្រឹត្តិការណ៍, គាំទ្រដោយក្រសួងចំនួន ០៦ រួមមានក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងពាណិជ្ជកម្ម, និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ព្រឹត្តិការណ៍ Digital Cambodia 2020 ជាព្រឹត្តិការណ៍ឈានមុខប្រចាំឆ្នាំលើកទី២ របស់ព្រះរាជាណាចក្រកម្ពុជាលើវិស័យបច្ចេកវិទ្យាឌីជីថលដែលមានគោលបំណងបង្កើត Platform ថ្នាក់ជាតិដើម្បីៈ

---

[108]គេហទំព័រ https://www.wired.com/story/new-tool-shows-howbots- ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

[109] គេហទំព័រ http://theconversation.com/howartificial-intelligence-conquered-democracy-7767 ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

[110] គេហទំព័រ https://chatbotsmagazine.com/bots-arenot-ដកស្រង់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១

[111] អត្ថបទដកស្រង់ Hughes, 'អ្នកស្រាវជ្រាវស្វែងរកអត្តសញ្ញាណឌីជីថលតាមរយៈការវិភាគអន្តរកម្មតអ៊ីមែលនៅលើអនឡាញ' គេហទំព័រ https://ourdataourselves.tacticaltech.org/posts/upcoming-tech-km/ ដកស្រង់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១

១. បង្ហាញអំពីបរិយាកាស និងEcosystem ប្រកបដោយអំណោយផល និងភាពទាក់ទាញសម្រាប់ការវិនិយោគវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៅកម្ពុជា

២. បង្ហាញអំពីវឌ្ឍនភាពនៃការអភិវឌ្ឍក្របខណ្ឌគោលនយោបាយ និងគតិយុត្ត និងផលិតផលសេវាពាក់ព័ន្ធនឹងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

៣. បញ្ជ្រាបអំពីសារៈសំខាន់ និងភាពមិនអាចខ្វះបាននៃវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដល់គ្រប់មជ្ឍដ្ឋាន ជាពិសេសយុវជននិងស្ត្រីក្នុងន័យធ្វើឱ្យប្រសើរឡើងនៃការអប់រំសម្រាប់សិស្ស-និស្សិត និងជំនាញបច្ចេកទេស បង្កើនប្រសិទ្ធភាពការងារ ផលិតភាព និងពង្រឹងភាពប្រកួតប្រជែងសហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យមរបស់កម្ពុជាលើឆាកតំបន់ និងអន្តរជាតិ

៤. កៀរគរគ្រប់តួអង្គពាក់ព័ន្ធក្នុងវិស័យឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន រួមមាន ស្ថាប័នរាជរដ្ឋាភិបាល អ្នកវិនិយោគជាតិនិងអន្តរជាតិ អាជីវកម្មបង្កើតថ្មី (Tech Startup) អ្នកវិជ្ជាជីវៈ និងគ្រឹះស្ថានសិក្សាស្រាវជ្រាវ ព្រមទាំងសង្គមស៊ីវិលដើម្បីផ្លាស់ប្តូរបទពិសោធន៍និងឧត្តមានុវត្តន៍ និងពិភាក្សាយោបល់អំពីនិន្នាការថ្មីៗក៏ដូចជា អំពីបញ្ហាប្រឈមនានាលើវិស័យឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ

៥. ជំរុញលើសហគ្រិនភាព និងនវានុវត្តន៍ថ្មីៗ

៦. អភិវឌ្ឍបណ្តាញអាជីវកម្មរវាងអាជីវកម្មបង្កើតថ្មី (Startup) ជាមួយសហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យម។

ការបញ្ជាក់ពី Digital Cambodia 2020 នឹងមានការចូលរួមពីរដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ាន និងវាគ្មិនដែលបានចូលរួមជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលប្រមាណ១២០ រូប។ ព្រឹត្តិការណ៍នេះក៏មានការតាំងពិព័ណ៌ប្រមាណ១៧០ស្តង់ និងសង្ឃឹមថានឹងមានអ្នកចូលរួមលើសពី ៣០, ០០០នាក់មកពីស្ថាប័នជាតិនិងអន្តរជាតិ រួមមាន៖ ស្ថាប័នរាជរដ្ឋាភិបាល ទូត ប្រតិបត្តិករទូរគមនាគមន៍ ក្រុមហ៊ុនផ្តល់សេវាកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រុមហ៊ុនអភិវឌ្ឍបច្ចេកវិទ្យា ធនាគារ មីក្រូហិរញ្ញវត្ថុ អាជីវកម្មបង្កើតថ្មី (Tech Startup) អង្គការក្រៅរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងដៃគូអភិវឌ្ឍន៍។ ការរៀបចំកិច្ចប្រជុំនេះត្រូវបានរៀបចំឡើងដោយស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងចតុកោណទី២ អំពីការធ្វើពិពិធកម្មសេដ្ឋកិច្ច មុំទី៣ អំពីការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ ចំណុចទី៦ អំពីការអភិវឌ្ឍសហគ្រិនភាព និងប្រព័ន្ធអេកូឡូស៊ីឌីជីថលដែលជាបរិស្ថានអំណោយផលដល់ការបង្កើតធុរកិច្ចថ្មីៗ ការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងធុរកិច្ច និងការបង្កើតយន្តសហប្រតិបត្តិការសហគ្រិន ភាពក្នុងក្របខណ្ឌរាជរដ្ឋាភិបាលឬភាពជាដៃគូជាមួយវិស័យឯកជន។ ឯកឧត្តមរដ្ឋមន្ត្រីក៏បានមានប្រសាសន៍បន្តថារាជរដ្ឋាភិបាលកម្ពុជាក្នុងអណត្តិទី៦ នេះបានកំណត់គោលដៅអាទិភាពរបស់ខ្លួនក្នុងការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងចាប់យកបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដោយក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តរៀបចំបទបញ្ញត្តិគោលនយោបាយ និងដាក់ចេញនូវសកម្មភាពបន្តបន្ទាប់ដើម្បីចាប់យកកាលានុវត្តន៍ភាពជំរុញដល់ការអភិវឌ្ឍបច្ចេកវិទ្យាពាក់ព័ន្ធនឹងទីផ្សារជំនួញ គ្រប់គ្រងបរិយាកាសធុរកិច្ច និងកាត់បន្ថយហានិភ័យបង្កពីការអភិវឌ្ឍបច្ចេកវិទ្យា។ ជាក់ស្តែងបន្ថែមលើការគាំទ្រតាមរយៈគោលនយោបាយនិងបទបញ្ញត្តិរាជរដ្ឋាភិបាលបាន និងកំពុងពង្រឹងមូលដ្ឋាន

គ្រឹះនៃហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថលទាំងផ្នែករឹង និងទន់ និងអភិវឌ្ឍធនធានមនុស្សនិងជំនាញឱ្យស្របទៅនឹងតម្រូវការនិងបរិបទថ្មីនៃសេដ្ឋកិច្ច។[112]

របាយការណ៍ថ្មីរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានឱ្យដឹងថាកម្ពុជានឹងអាចសម្រេចបានចក្ខុវិស័យសេដ្ឋកិច្ចឆ្នាំ ២០៣០ និង២០៥០ លុះត្រាតែបច្ចេកវិទ្យាថ្មីៗត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីធ្វើឱ្យប្រសើរឡើង និងធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួន។

UNDP បានឱ្យដឹងនៅក្នុងរបាយការណ៍របស់ខ្លួនស្តីពី "ការទទួលយកឧស្សាហកម្ម ៤.0 នៅកម្ពុជា" ថាសេដ្ឋកិច្ចកម្ពុជាបានកើនឡើងក្នុងអត្រាខ្ពស់ជាង ៧ភាគរយក្នុងមួយឆ្នាំចាប់តាំងពី ឆ្នាំ២០១១ ហើយកម្ពុជាបានដាក់ចេញនូវចក្ខុវិស័យរបស់ខ្លួន ដើម្បីក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។

របាយការណ៍នេះ បានឱ្យដឹងថា "ចក្ខុវិស័យនេះអាចទទួល បានលុះត្រាតែបច្ចេកវិទ្យាថ្មីៗត្រូវបានគេប្រើដើម្បីបង្កើនតម្លៃឧស្សាហកម្ម ធ្វើពិពិធកម្មការនាំចេញ និងពង្រឹងសហគ្រាសធុនតូច និងមធ្យម"។ វិស័យផលិតកម្មនៅប្រទេសកម្ពុជាបានចូលរួមចំណែកជាង១៦ភាគរយ ដល់ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសក្នុងឆ្នាំ ២០១៨ ហើយបច្ចុប្បន្ននេះបានផ្តល់ការងារចំនួន ១,៤ លានកន្លែង។

ទោះយ៉ាងណាផលិតកម្មរបស់កម្ពុជាត្រូវបានផ្តោតលើវិស័យធំៗចំនួនពីរ វាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង អាហារ និងភេសជ្ជៈ។ របាយការណ៍បន្ថែមថាផលិតផលទាំងនេះបានរួមចំណែក ៨0ភាគរយនៃតម្លៃផលិតកម្មបន្ថែម និង៧៦ភាគរយ នៃការនាំចេញរបស់ប្រទេស។

ឧស្សាហកម្ម ៤.0 មានសក្តានុពលក្នុងការបង្កើតប្រភពថ្មីនៃតម្លៃសម្រាប់កម្មករ ក្រុមហ៊ុន សហគ្រាស និងប្រទេសនានា ហើយកម្មវិធី និងដំណោះស្រាយឧស្សាហកម្ម ៤.0 កាន់តែមានតម្លៃទាប កាន់តែទូលំទូលាយ និងងាយស្រួលប្រើប្រាស់។ក្រុមហ៊ុនផលិតកម្មអាចជំរុញឧស្សាហកម្ម ៤.0 ដើម្បីផ្តល់ជូននូវផលិតផលសេវាកម្ម ខ្សែសង្វាក់ផ្គត់ផ្គង់ឆ្លាតវៃ និងចែកចាយ។

ប៉ុន្តែកម្រិតនៃការទទួលយកឧស្សាហកម្ម៤.0 នៅកម្ពុជានៅតែទាបនៅឡើយដោយកត់សម្គាល់ថាបច្ចេកវិទ្យាឌីជីថលនៅក្នុងក្រុមហ៊ុនភាគច្រើន (ជាង ៩0 ភាគរយ) នៅតែស្ថិតក្នុងកម្រិតមូលដ្ឋាននៅឡើយ។

នៅកម្រិតក្រុមហ៊ុន ឧបសគ្គក្នុងការប្រើប្រាស់ឧស្សាហកម្ម ៤.0 នៅក្នុងប្រទេសកម្ពុជារួមមានកង្វះការយល់ដឹងអំពីបច្ចេកវិទ្យាឌីជីថល និងអត្ថប្រយោជន៍របស់ពួកគេការយល់ដឹងខ្ពស់នៃបច្ចេកវិទ្យា ការបង្វែរការប្រើបច្ចេកវិទ្យាថ្មី ចន្លោះប្រហោងជំនាញ ការទទួលបានការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសនៅមានកម្រិត និងការរាំងស្ទះការទទួលបានហិរញ្ញវត្ថុ។[113]

[112]គេហទំព័រ https://www.digitalcambodia.com.kh/author/sophea/ ដកស្រង់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១

[113] គេហទំព័រ https://cambodiafinancialtimes.com/sme/3824/ ដកស្រង់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវខាងលើយើងសង្កេតឃើញថារាជរដ្ឋាភិបាលបាន និងខិតខំប្រឹងប្រែងក្នុងការធ្វើកំណែទម្រង់សេវាសាធារណៈ ដែលមានការវិវឌ្ឍពីការផ្តល់សេវាសាធារណៈតាមបែបប្រពៃណីទៅជាការផ្តល់សេវាសាធារណៈតាមបែបបច្ចេកវិទ្យាទំនើបដែលទទួលបានការរីកចម្រើន និងទទួលបាននូវលទ្ធផលខ្ពស់ឆាប់រហ័សក្នុងរយៈពេលចុងក្រោយនេះ។ ក្នុងអំឡុងពេលនោះដែរ យើងក៏សង្កេតឃើញថាកំណើននៃការប្រើប្រាស់អ៊ីនធឺណេតក៏មានការកើនឡើងជាលំដាប់រហូតដល់យើងអាចនិយាយថា មនុស្សនាពេលបច្ចុប្បន្នរស់នៅមិនអាចខ្វះអ៊ីនធឺណេតបាន។ លើសពីនេះទៅទៀតការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យា គឺជាការបង្កើតនូវយុទ្ធសាស្ត្រដ៏ល្អប្រសើរមួយរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់នូវភាពងាយស្រួល ព្រមទាំងមានភាពទំនើបបន្តិចម្តងៗទៅកាន់ប្រជាពលរដ្ឋ។ ចំពោះគោលនយោបាយវិញរាជរដ្ឋាភិបាលកម្ពុជាក៏បានធ្វើកំណែទម្រង់ដែលមានមូលដ្ឋានទូលំទូលាយជាច្រើនក្នុងគោលបំណងពង្រឹងភាពប្រកួតប្រជែងនឹងប្រទេសដទៃសម្រេចបាននូវការអភិវឌ្ឍ និងនាវានុវត្តសេដ្ឋកិច្ច និងសង្គមឌីជីថល។ ការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធឌីជីថលមានសក្តានុពលដ៏ធំធេងសម្រាប់រួមចំណែកដល់សេដ្ឋកិច្ច និងសង្គមកិច្ចរបស់កម្ពុជា ហើយជាមធ្យោបាយសម្រាប់ការធ្វើអាជីវកម្ម ការទូទាត់ប្រាក់ ការបណ្តុះបណ្តាល ការផ្តល់ព័ត៌មាន ការប្រមូល និងផ្តល់ទិន្នន័យដែលស្របទៅតាមច្បាប់ និងលិខិតបទដ្ឋាននានាតាមរយៈការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកជាក់ស្តែងដូចជាការចុះបញ្ជីអាជីវកម្មតាមថ្នាលតែមួយអេឡិចត្រូនិក CamDigikey។ ជាការពិតណាស់រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តន៍នូវគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងដោះស្រាយកង្វះខាតឬសគល់នៃប្រព័ន្ធអេកូឡូហ្ស៊ី ហើយម្យ៉ាងទៀតគឺដើម្បីយល់ដឹងពីវិសាលភាពពេញលេញនៃកាលានុវត្តភាពនៃវិស័យពាណិជ្ជកម្ម និងវិស័យដទៃទៀតនៅកម្ពុជា។ សកម្មភាពទាំងនោះតម្រូវឱ្យមានការចូលរួមចំណែកក្នុងការអនុវត្តពីក្រសួង ស្ថាប័នដែលពាក់ព័ន្ធ។ ជាក់ស្តែងនាពេលបច្ចុប្បន្នពិភពលោកកំពុងស្ថិតក្នុងបរិបទកូវីដ-១៩ ហើយប្រទេសកម្ពុជាយើងក៏ជាប្រទេសមួយក្នុងចំណោមប្រទេសទាំងអស់ដែលរងនូវផលប៉ះពាល់ និងការរាំងស្ទះនូវដំណើរការប្រព្រឹត្តទៅលើវិស័យទាំងឡាយដែលធ្វើឱ្យប្រទេសជាតិជួបផលលំបាកក្នុងការគ្រប់គ្រង។ ក៏ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានខិតខំអស់ពីកម្លាំងកាយ ចិត្តក្នុងការចាត់នូវវិធានការទប់ស្កាត់ជម្ងឺនេះដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ផ្តល់នូវសេវាសាធារណៈក៏ដូចជាការកាត់បន្ថយនូវការរីករាលដាលនូវជម្ងឺនេះដ៏កាចសាហាវ។ ដោយមើលឃើញពីបញ្ហា និងទុក្ខលំបាកនេះហើយទើបរាជរដ្ឋាភិបាល បានចេញនូវសម្រេចប្រកាសឱ្យមានការចូលរួមចំណែកនូវការទប់ស្កាត់ជម្ងឺពីបណ្តាក្រសួង-ស្ថាប័នទាំងឡាយបានចាប់យកបច្ចេកវិទ្យាឌីជីថលដោយប្រជាពលរដ្ឋក្នុងសង្គមបាន និងកំពុងស្វែងរកដំណោះស្រាយលើផលប៉ះពាល់នៃវិធានការរឹតត្បឹតការធ្វើដំណើរការផ្អាកដំណើរការអាជីវកម្មចលនា នៃការបំពេញការងារតាមផ្ទះក៏ដូចជា ការរក្សាគម្លាតសុវត្ថិភាពសង្គមដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការអនុវត្តកិច្ចការងាររៀងៗខ្លួនក្នុងគោលបំណងកាត់បន្ថយការជួបជុំផ្ទាល់ដែលជាបញ្ហាប្រឈមនឹងការឆ្លងជម្ងឺ។ លើសពីនេះទៅទៀតការអនុវត្តការងារ និងការផ្តល់សេវាសាធារណៈនៅតាមក្រសួង-ស្ថាប័នតាមរយៈការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងបរិបទកូវីដ-១៩ នេះក៏ធ្វើឱ្យមានការយល់ដឹងកាន់តែច្បាស់ពីវិស័យបច្ចេកវិទ្យា និងចលករក្នុងការពន្លឿនជាមួយនឹងការផ្តល់ភាពងាយស្រួលក្នុងការបំពេញតួនាទី និងភារកិច្ចរបស់រាជរដ្ឋាភិបាលដើម្បីឆ្លើយតបទៅនឹងក្របខណ្ឌគោលនយោបាយស្តីពីសេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម៤.០។ សរុបមក អ្វីដែលក្រសួង-ស្ថាប័នបានសម្រេចនា

ពេលកន្លងមកនេះ គឺបានបង្ហាញពីគោលជំហររបស់រាជរដ្ឋាភិបាលក្នុងការទទួលយកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាឧបករណ៍ដ៏សំខាន់មួយក្នុងការងារកែទម្រង់ និងបង្កើតប្រសិទ្ធភាពការងាររដ្ឋបាលប្រចាំថ្ងៃ។ កម្ពុជាកំពុងស្ថិតក្នុងដំណើរឆ្ពោះទៅរកបដិវត្តន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាហេតុនាំឱ្យរាជរដ្ឋាភិបាលបន្តពង្រីកវិសាលភាពនៃប្រព័ន្ធនេះឈានទៅគ្របដណ្តប់ដល់គ្រប់ក្រសួង-ស្ថាប័នផ្សេងទៀត ដើម្បីរៀបចំការផ្តល់អាជ្ញាប័ណ្ណនានាតាមថ្នាលបច្ចេកវិទ្យាព័ត៌មានថែមទៀតដើម្បីជួយឱ្យប្រទេសមានការរីកចម្រើន និងសម្រេចបាននូវចក្ខុវិស័យវែងឆ្ងាយរបស់ខ្លួននិងទទួលបានការរីកចម្រើន ជាពិសេសមានភាពជឿនលឿនមិនខុសពីប្រទេសដែលបានអភិវឌ្ឍន៍។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវទាំងទ្រឹស្តី និងទិដ្ឋភាពជាក់ស្តែងអំពីការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យារួចមកយើងខ្ញុំទាំងពីរនាក់សង្កេតឃើញថាទោះបីការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈនៅកម្ពុជាទទួលបានការប្រព្រឹត្តទៅយ៉ាងរលូនក៏ដោយ យ៉ាងណាមិញក៏នៅតែមានការខ្វះចន្លោះ និងបញ្ហាប្រឈមមួយចំនួនបានបង្កឱ្យមានភាពរាំងស្ទះដែលបង្អាក់ក្នុងដំណើរការអនុវត្តការងាររបស់រដ្ឋាភិបាល និងបង្អាក់ធុរជនក្នុងការចុះបញ្ជីអាជីវកម្មថ្មីដោយការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនេះ។ ដើម្បីចូលរួមជំរុញ លើកកម្ពស់ និងពង្រឹងការអនុវត្តការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យាឱ្យកាន់តែប្រសើរឡើងមួយកម្រិតទៀតដោយរក្សាស្ថិរភាព ការអភិវឌ្ឍ និងនវានុវត្តន៍ថែមទាំងទាក់ទាញការវិនិយោគដែលប្រកបដោយភាពជឿទុកចិត្តពីសំណាក់វិនិយោគិនបរទេស។

អាស្រ័យហេតុនេះហើយក្រុមយើងខ្ញុំសូមមានអនុសាសន៍មួយចំនួនដូចជា៖

- ស្នើសុំឱ្យគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធឱ្យជួយពង្រឹង និងបង្កើនល្បឿននៃសេវាអ៊ីនធឺណេតឱ្យមានលក្ខណៈលឿនជាងមុនពីព្រោះដំណើរការ និងការប្រព្រឹត្តទៅនៃការផ្តល់សេវសាធារណៈរបស់រាជរដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ គឺពឹងផ្អែកទាំងស្រុងតាមរយៈការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេតដែលមានសេវាលឿនទាន់ចិត្ត ទើបការងារទាំងឡាយមានដំណើរការយ៉ាងរលូន និងឆាប់រហ័ស
- ស្នើសុំឱ្យមានការតភ្ជាប់បណ្តាញអ៊ីនធឺណេតទៅតាមទីជនបទដើម្បីជួយសម្រួលដល់ការទទួលបាននូវសេវាសាធារណៈដល់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ដាច់ស្រយាល ឬទីជនបទដែលឆ្ងាយពីទីក្រុង
- ទាមទារឱ្យមានការពង្រឹងប្រព័ន្ធសន្តិសុខឱ្យមានភាពរឹងមាំដោយមានការគ្រប់គ្រងសុវត្ថិភាពលើព័ត៌មានវិទ្យា (Cybersecurity) ដើម្បីអនុវត្តន៍នៃការទប់ស្កាត់ ការឆ្លើយតប និងការការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំងហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ប្រព័ន្ធប្រតិបត្តិការ និងកម្មវិធី ពីការជ្រួតជ្រាបចូលនិងការវាយប្រហារគ្រប់រូបភាព ជាពិសេសតាមប្រព័ន្ធអ៊ីនធឺណេតនេះ ព្រោះថាមួយរយៈកន្លងមកនេះគេហទំព័រស្ថាប័នរដ្ឋ និងស្ថាប័នធនាគារមួយចំនួនទទួលរងនូវការវាយប្រហាជាច្រើនដែលបង្ហាញពីអសន្តិសុខ និងអស្ថេរភាពនៅក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានេះ
- ពង្រឹង និងបណ្តុះបណ្តាលធនធានមនុស្សទៅលើអក្ខរកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍវិស័យឌីជីថលនេះ។ ពោលគឺមានការយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យា (IT) ឱ្យមានការយល់ដឹងបានច្រើន ព្រោះការយល់ដឹង និងការមានចំណេះដឹងច្បាស់លាស់ពីការប្រើប្រាស់បច្ចេកវិទ្យាជាកត្តាជំរុញឱ្យមានកំណើននៃការប្រើប្រាស់ការផ្តល់សេវាសាធារណៈ ឧទាហរណ៍ដូចជាការចុះបញ្ជីយានយន្ត និងការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលពង្រឹងពីការឆ្លើយតបរបស់ប្រជាពលរដ្ឋទៅនឹងទីផ្សារការងារនានា ការទទួលបាននូវភាពងាយស្រួលក្នុងការផ្តល់ និងការទទួលបាននូវសេវាសាធារណៈនៅតាមក្រសួង-ស្ថាប័នក្នុងពេលបច្ចុប្បន្ន និងអនាគត
- ក្រសួងសាមី ដែលអនុវត្តន៍កិច្ចការងារត្រូវមានអ្នកចេះច្បាស់លាស់សម្រាប់ធ្វើការងារមានលក្ខណៈជំនាញដើម្បីគ្រប់គ្រងទិន្នន័យតាមរយៈប្រព័ន្ធអេឡិចត្រូនិក ដោយសារការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធអនឡាញគឺពិតជាមានសារៈសំខាន់ក្នុងការអនុវត្តការងារតាមប្រព័ន្ធអេឡិចត្រូនិក ទើបទាមទារឱ្យមានជនបង្គោលដែលមានជំនាញក្នុងការផ្តល់សេវាសាធារណៈទៅកាន់ប្រជាពលរដ្ឋ ដូច្នេះហើយយើងស្នើសុំឱ្យក្រសួង

សាមីព្រមទាំងស្ថាប័នពាក់ព័ន្ធមេត្តារៀបចំអ្នកគ្រប់គ្រងទិន្នន័យបែបឌីជីថលដែលប្រកបដោយគុណភាព និងជំនាញ។

ក្នុងនាមយើងជាបញ្ញាវន្ត ជាអ្នកស្រាវជ្រាវ និងជាពលរដ្ឋក្នុងសង្គមសូមផ្តល់ជាអនុសាសន៍មួយចំនួនខាងលើក្នុងគោលបំណងនូវការផ្តល់ជាគំនិត យោបល់ក្នុងន័យស្ថាបនា និងជាស្មារតីមួយក្នុងការចូលរួមជំរុញការអភិវឌ្ឍប្រទេសនៃការធ្វើទំនើបកម្មក្នុងការផ្តល់សេវាសាធារណៈតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា។ ក្រុមយើងខ្ញុំសង្ឃឹមថាគំនិតមួយចំនួននៃអនុសាសន៍ខាងលើត្រូវបានក្រសួង ស្ថាប័នមេត្តាទទួលយកគំនិតទាំងនេះទៅកែប្រែ និងបំពេញបន្ថែមនៅចន្លោះខ្វះខាតរបស់ខ្លួន ដើម្បីត្រៀមខ្លួនរួចជាស្រេចក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ក្នុងការអនុវត្តសេដ្ឋកិច្ចឌីជីថលបន្តទៅមុខទៀត និងដើម្បីសម្រេចបាននូវការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមមួយទាំងមូលឱ្យឈានឆ្ពោះទៅកាន់សង្គមដែលមានការតភ្ជាប់ក្នុងការប្រកួតប្រជែងលក្ខណៈសកលផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- ច្បាប់ស្តីពីទូរគមនាគមន៍
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- អនុក្រឹត្យ លេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ប្រកាសលេខ៤៣០/២០ ក.ប/ប្រ.ក.ខ/ល ស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០
- ប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០
- ប្រកាសអន្តរក្រសួង លេខ៣៣៥ សហវ ប្រ.ក ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សេចក្តីជូនដំណឹងរបស់ធនាគារជាតិ លេខធ៧.០២០.៥៦៩ ស.ជ.ណ ចុះនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ស្តីពីយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- សេចក្តីណែនាំ នៃក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ លេខ០១១ សណន ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់ផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ (E-Crime 2020)
- សេចក្តីណែនាំ លេខ៣១៤០ អពដ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tax on Income-Tol E-Filing) ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១
- សេចក្តីប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់ទីផ្សារអនឡាញក្រសួងពាណិជ្ជកម្មសម្រាប់លក់គ្រឿងឧបភោគបរិភោគចាំបាច់ ក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល

## ២. គោលនយោបាយ

- គោលនយោបាយជាតិស្តី បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន ឆ្នាំ ២០០៩ "សំណើរគោលនយោបាយសំរាប់រាជរដ្ឋាភិបាលកម្ពុជា"
- គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០ "ឆ្ពោះទៅសន្តិភាព និងកម្មញភាពនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន"
- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥
- យោងតាមរបាយការណ៍ស្តីពី វិស័យឌីជីថល សង្គម និងទូរស័ព្ទចល័ត របស់អេភីអេស៊ី ឆ្នាំ ២០១៥

- បញ្ញត្តិករទូរគមនាគមន៍កម្ពុជា "ការជារអ៊ីនធឺណេត"
- អង្គការសុខភាពពិភពលោក (២០២០) របាយការណ៍ទី៥ ស្តីពីស្ថានភាពជម្ងឺរាតត្បាតកូវីដ-១៩នៅកម្ពុជា

## ៣. សៀវភៅតែខនិពន្ធ


- វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត
- សៀវភៅ នីតិរដ្ឋបាលទូទៅ អនុបណ្ឌិត ហៀង សាង
- សៀវភៅ សិក្ខាប័ននីតិរដ្ឋបាល លោក អ ចំរើន
- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥
- Toolkit សម្រាប់រៀបចំផែនការបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT) សម្រាប់ភ្នាក់ងាររដ្ឋាភិបាលរដ្ឋាភិបាល របស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (NiDA) ឆ្នាំ២០០៨
- OECD, **the E-government Imperative**, Paris: OECD Publications, 2003
- Project for Capacity Building on ICT Management for NiDA


## ៤. គេហទំព័រ


- គេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម http://www.moc.gov.kh/km-kh/
- គេហទំព័រ https://shop.moc.gov.kh/
- គេហទំព័ររបស់ក្រសួងមហាផ្ទៃ https://www.interior.gov.kh/news/detail/2347
- គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh
- គេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh
- គេហទំព័ររបស់ទីស្តីការគណរដ្ឋមន្ត្រី https://www.ocm.gov.kh/wp-
- គេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា https://www.cambodiainvestment.gov.kh/KM/
- គេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ https://mef.gov.kh/documents/
- គេហទំព័រ World Bank https://www.worldbank.org/km/country/cambodia/overview
- គេហទំព័រអំពី The follow-up Study Report on e-Government Service Development Plan https://www.jica.go.jp/project/cambodia/0609376/04/pdf/05_egov_2009_e.pdf
- គេហទំព័រ https://www.kas.de/en/web/kambodscha/single-title/-/content/e-government-what-can-cambodia-learn-from-e-estonia
- គេហទំព័រ https://secudemy.com/egov-digital/
- គេហទំព័រសេវាកម្មចុះបញ្ជីតាមរយៈតំណ https://www.registrationservices.gov.kh/
- Digital "Government-to-Business" service in Cambodia: Overview and Challenges by **Maria Yang and Darapich Sovann** publishes in January 28 2020 https://www.kas.de/en/web/kambodscha/single-title/-/content/digital-government-to-business-services-in-cambodia-overview-and-challenges

- គេហទំព័រ https://opendevelopmentcambodia.net/km/topics/science-and-technology/
- គេហទំព័រ https://www.trc.gov.kh/summary-on-cambodian-ict-masterplan-2020/
- គេហទំព័រ https://www.who.int/docs/default-source/wprodocuments/countries/cambodia/covid-19/covid-19-joint-who-moh-sitrep-05.pdf?sfvrsn=845
- គេហទំព័រ Castillo, G. G. (២០២០) ស្ថានភាពជម្ងឺកូវីដ-១៩នៅកម្ពុជា https://focusweb.org/cambodia-covid-19-situationer/.
- គេហទំព័រ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសនាគ្រាអាសន្នរបស់ប្រទេសកម្ពុជានិងការប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីដ-១៩ ៖ https://www.asiapacific.ca/publication/cambodias-state-emergency-law-and-fight-against-covid-19
- គេហទំព័រ https://youtu.be/Cv5YSq989tc
- គេហទំព័រ https://cd-center.org/wp-content/uploads/2020/04/RGC-Measure-COVID-19-Update17042020
- គេហទំព័រ https://policypulse.org/kh/
- គេហទំព័រ https://www.interior.gov.kh/document/detail/1033
- គេហទំព័រ Turton, S. (២០២០). ប្រទេសកម្ពុជាចេញបទបញ្ជាហាមឃាត់ការធ្វើដំណើរចេញចូលក្រុងភ្នំពេញ៖ https://asia.nikkei.com/Politics/Cambodia-issues-order-banning-travel-to-and-from-Phnom-Penh
- គេហទំព័រព័ត៌មាន https://www.khmertimeskh.com/50714122/mandatory-quarantine-to-help-prevent-coronavirus-spread/
- គេហទំព័រ https://focusweb.org/cambodia-covid-19-situationer/
- គេហទំព័រ https://fmis.mef.gov.kh/contents/uploads/2020/11/20200803_675_announcement_about_to_add_ITD_office_of_MEF_From_cabinet
- កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) «វិបត្តិកូវីដ-១៩ ដែលបានគំរាមកំហែងដល់សេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍»អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) "ការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ នៅក្នុងរដ្ឋសមាជិកអាស៊ាន"
- គេហទំព័រ https://cambodia-vaccine.gov.kh/login

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១ ៖ កិច្ចប្រជុំរបស់រដ្ឋាភិបាល

ឧបសម្ព័ន្ធទី២ ៖ នីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ឧបសម្ព័ន្ធទី៣ ៖ ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ឧបសម្ព័ន្ធទី៤ ៖ រចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលរបស់ប្រទេសកម្ពុជា

## ២. ឧបសម្ព័ន្ធគតិយុត្តិ

ឧបសម្ព័ន្ធទី១ ៖ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ឧបសម្ព័ន្ធទី២ ៖ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

ឧបសម្ព័ន្ធទី៣ ៖ ច្បាប់ស្តីពីទូរគមនាគមន៍

ឧបសម្ព័ន្ធទី៤ ៖ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ឧបសម្ព័ន្ធទី៥ ៖ អនុក្រឹត្យ លេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ឧបសម្ព័ន្ធទី៦ ៖ ប្រកាសលេខ៤៣០/២០ ក.ប/ប្រ.ក.ខ/ល ស្តីពីការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

ឧបសម្ព័ន្ធទី៧ ៖ ប្រកាសអន្តរក្រសួង លេខ៣៣៥ សហវ ប្រ.ក ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ឧបសម្ព័ន្ធទី៨ ៖ សេចក្តីជូនដំណឹងរបស់ធនាគារជាតិ លេខធ៧.០២០.៥៦៩ ស.ជ.ណ ចុះនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ ស្តីពីយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ឧបសម្ព័ន្ធទី៩ ៖ សេចក្តីណែនាំ នៃក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ លេខ០១១ សណន ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់ផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ (E-Crime 2020)

ឧបសម្ព័ន្ធទី១០ ៖ សេចក្តីណែនាំ លេខ៣១៤០ អពជ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tax on Income-Tol E-Filing)

ឧបសម្ព័ន្ធទី១១ ៖ សេចក្តីប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់ទីផ្សារអនឡាញក្រសួងពាណិជ្ជកម្មសម្រាប់លក់គ្រឿងឧបភោគ បរិភោគចាំបាច់ ក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ កិច្ចប្រជុំរបស់រដ្ឋាភិបាល



សកម្មភាព៖ កិច្ចប្រជុំរបស់រដ្ឋាភិបាលទាក់ទងហ្នឹងការរៀបចំ និងការប្រព្រឹត្តទៅនៃការផ្តល់សេវាសាធារណៈតាមប្រព័ន្ធឌីជីថល ដោយកិច្ចប្រជុំនេះធ្វើឡើងតាមរយៈប្រព័ន្ធ Zoom ដែលបានអនុវត្តទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល ដោយអនុវត្តនូវវិធីសាស្រ្ត ៣កុំ ៣ការពារ។

## ឧបសម្ព័ន្ធទី២ ៖ នីតិវិធីនៃការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន



# ឧបសម្ព័ន្ធទី៣ ៖ ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន




## ១. ការបង្កើតគណនីលើ CamDigiKey App

- ដោនឡូត CamDigiKey App ពី App Store ឬ Play Store លើទូរស័ព្ទរបស់អ្នក។




- ចូលទៅកាន់ CamDigiKey App រួចចុចប៊ូតុង"ចុះឈ្មោះ"។
- បញ្ចូលលេខទូរស័ព្ទដៃរបស់អ្នកទៅក្នុង App នោះលេខកូដស្វ័យប្រវត្តិនឹងត្រូវបានផ្ញើទៅកាន់លេខទូរស័ព្ទដៃរបស់អ្នក។
- វាយលេខកូដនោះចូលក្នុង App ដើម្បីបញ្ជាក់លេខទូរស័ព្ទដៃរបស់អ្នក។
- បង្កើតលេខកូដផ្ទាល់ខ្លួនចំនួន ៦ ខ្ទង់។












- បំពេញព័ត៌មានអត្តសញ្ញាណរបស់អ្នក។
- បំពេញថ្ងៃ ខែ ឆ្នាំកំណើត ភេទ និងទីកន្លែងកំណើត។
- បំពេញអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។
- បំពេញព័ត៌មានអត្តសញ្ញាណប័ណ្ណ (សម្រាប់សញ្ជាតិខ្មែរ) ឬលិខិតឆ្លងដែន (សម្រាប់សញ្ជាតិបរទេស)។






- វាយលេខកូដមួយផ្សេងទៀតដែលបានផ្ញើទៅកាន់សារអេឡិចត្រូនិករបស់អ្នកទៅក្នុង App ដើម្បីបញ្ជាក់សារអេឡិចត្រូនិករបស់អ្នក។
- បញ្ចូលរូបថតអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នក។
- ចុច "ថតរូប" រួចថតរូបរបស់អ្នក។
- រង់ចាំយ៉ាងយូរ ២៤ ម៉ោងសម្រាប់ការត្រួតពិនិត្យ។
- អ្នកបានបង្កើតគណនី CamDigiKey ដោយជោគជ័យ។









# ឧបសម្ព័ន្ធទី៤ ៖ រចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលកម្ពុជា




រចនាសម្ព័ន្ធនេះ ជាផែនទីបង្ហាញផ្លូវដែលអាចកំណត់ទិសដៅបានត្រឹមត្រូវបំផុតសម្រាប់កម្មវិធីរបស់រដ្ឋាភិបាលឌីជីថលទូទៅនៅក្នុងប្រទេសកម្ពុជានេះ ហើយវាក៏ ជាមគ្គុទ្ទេសដែលមានភាពបត់បែនតាមកាលៈទេសៈផងដែរ។

# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

## ស្តីពី

## ពាណិជ្ជកម្មតាមប្រព័ន្ធ
## អេឡិចត្រូនិក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១. ភស្តុតាងនោះជាទំនាក់ទំនងអេឡិចត្រូនិក។ ឬ

២. ភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើម។

**មាត្រា១២ .- ការបង្កើតកិច្ចសន្យានិងសុពលភាពកិច្ចសន្យា**

១. សំណើ ស្វីការ និងកិច្ចសន្យា អាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិកបាន។

២. កិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិកដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ មានសុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាន នៅពេលដែលសំណើនិងស្វីការត្រូវគ្នា។

**មាត្រា១៣ .- អានុភាពរវាងគូភាគី**

អ្នកផ្ញើនិងអ្នកទទួលនៃទំនាក់ទំនងអេឡិចត្រូនិក មិនត្រូវបដិសេធអានុភាពគតិយុត្ត សុពលភាព និងភាពអាចអនុវត្តបាននៃការបង្ហាញឆន្ទៈ ឬសេចក្តីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។

**មាត្រា១៤ .- ការអនុវត្តដោយឡែកតាមការព្រមព្រៀងរបស់គូភាគី**

១. តាមការព្រមព្រៀង គូភាគីដែលចូលរួមក្នុងការបង្កើត ការផ្ញើ ការទទួល ការរក្សាទុក ឬ ដំណើរការទំនាក់ទំនងអេឡិចត្រូនិក អាចអនុវត្តផ្សេងពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី២ នៃច្បាប់នេះ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

២. ទោះជាមានបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី២ គូភាគីនៃកិច្ចសន្យា ឬប្រតិបត្តិការណាមួយអាចៈ

ក. មិនប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិក ទំនាក់ទំនងអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកក្នុងកិច្ចសន្យា ឬប្រតិបត្តិការណាមួយតាមការព្រមព្រៀងគ្នា។ ឬ

ខ. ដាក់លក្ខខណ្ឌតម្រូវបន្ថែមផ្សេងៗដែលពាក់ព័ន្ធនឹងទម្រង់ ឬយថាភូតភាពនៃកិច្ចសន្យា ឬប្រតិបត្តិការតាមការព្រមព្រៀងគ្នា។

## ជំពូកទី៣
## ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា១៥ .- ពេលវេលានិងទីកន្លែងនៃការបញ្ជូនចេញនិងការទទួលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

១. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលៈ

ក. ព័ត៌មាននោះ បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសក្នុងនាមអ្នកផ្ញើ។ ឬ

ខ. ក្នុងករណីដែលព័ត៌មាននោះ ត្រូវបានបញ្ជូនតែមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសព័ត៌មាន ត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលព័ត៌មាននោះត្រូវបានទទួលក្នុងពេលណាមួយ។

២. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើ ទោះបីព័ត៌មាននោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ។

៣. ពេលវេលានៃការទទួលព័ត៌មានគឺពេលដែលព័ត៌មាននោះ អាចទាញយកបានដោយអ្នកទទួលនៅក្នុងអាសយដ្ឋានអេឡិចត្រូនិកដែលអ្នកទទួលបានបញ្ជាក់ជាមុន។ ព័ត៌មានត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៤. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកមិនត្រូវបានផ្តល់ដោយអ្នកទទួល នោះពេលវេលាទទួលបានព័ត៌មាន គឺជាពេលវេលាដែលអ្នកទទួលបានដឹងអំពីការផ្ញើចេញនិងអាចទាញយកព័ត៌មាននោះ តាមរយៈអាសយដ្ឋានអេឡិចត្រូនិកណាមួយ ហើយសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៥. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្តល់ដោយអ្នកទទួល ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មតថាបានទទួលនៅពេលព័ត៌មាននោះបានទៅដល់អាសយដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល ហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

**មាត្រា១៦ .- សំណើបង្កើតកិច្ចសន្យា**

រាល់ការស្នើសុំចុះកិច្ចសន្យា តាមរយៈទំនាក់ទំនងអេឡិចត្រូនិកដែលមិនសំដៅតែដល់បុគ្គលណាមួយជាក់លាក់ផ្សេងទៀត ត្រូវបានចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។ ការស្នើសុំចុះកិច្ចសន្យានោះ នឹងត្រូវចាត់ទុកថាជាសំណើបង្កើតកិច្ចសន្យា ប្រសិនបើការស្នើសុំនោះបានបង្ហាញឱ្យឃើញច្បាស់អំពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ចនៅពេលមានស្នើការពីភាគីម្ខាងទៀត។

**មាត្រា១៧ .- ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តសម្រាប់បង្កើតកិច្ចសន្យា**

កិច្ចសន្យាដែលបង្កើតឡើងដោយអន្តរកម្មរវាងប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយឬជាមួយប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបានបដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យានោះឡើយ ដោយសម្អាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យឬក្នុងការចូលធ្វើសកម្មភាពដោយផ្ទាល់ក្នុងប្រព័ន្ធស្វ័យប្រវត្តឬក្នុងការបង្កើតកិច្ចសន្យា។

**មាត្រា១៨ .- កំហុសឆ្គងនៃការបញ្ចូលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក**

នៅពេលដែលបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យប្រវត្តរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តនេះមិនផ្តល់ឱកាសឱ្យបុគ្គលនោះធ្វើការកែប្រែនូវព័ត៌មានដែលខុស បុគ្គលឬភាគីដែលជំនួសមុខឱ្យបុគ្គលដែលបញ្ចូលព័ត៌មាននោះមានសិទ្ធិកែតម្រូវ ឬដកចេញនូវព័ត៌មានដែលខុសនោះបាន ក្នុងករណី៖

១. បុគ្គលនោះបានជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើងឱ្យបានឆាប់បំផុត ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក។ និង

**មាត្រា៣២ .- ការការពារទិន្នន័យ**

១. បុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវប្រើគ្រប់មធ្យោបាយដើម្បីធានាថា ព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុផល ដើម្បីជៀសវាង ការបាត់បង់ ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការលាតត្រដាងព័ត៌មានទាំងនោះ លើកលែងតែមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះឬពីភាគីផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់។

២. បុគ្គលទាំងឡាយមិនត្រូវជ្រៀតជ្រែកក្នុងប្រព័ន្ធអេឡិចត្រូនិក ចូលប្រើប្រាស់ ទាញយកថតចម្លង ស្រង់យក ធ្វើឱ្យបែកធ្លាយ លុបបំបាត់ ឬកែប្រែទិន្នន័យ ដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ដោយទុច្ចរិត ឬគ្មានការអនុញ្ញាតឡើយ។

**មាត្រា៣៣ .- ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់**

បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ក៏ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានាទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។

## ជំពូកទី៧
## សកម្មភាពនិងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៣៤ .- ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ**

១. ក្រសួងឬស្ថាប័នរដ្ឋនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាពនិងប្រតិបត្តិការ ដូចខាងក្រោម៖

ក. ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើតឬរក្សាទុកឯកសារ។

ខ. ការចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាត។

គ. ការកំណត់មធ្យោបាយនិងរបៀបក្នុងការទូទាត់ប្រាក់។ ឬ

ឃ. សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

២. នៅពេលដែល ក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាព ឬប្រតិបត្តិការណាមួយ ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ក្រសួងឬស្ថាប័ននោះអាចបញ្ជាក់៖

ក. របៀបនិងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវទទួលចុះបញ្ជី បង្កើតរក្សាទុក ឬបោះផ្សាយ។

ខ. ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

គ. របៀបនិងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក។

ឃ. ដំណើរការគ្រប់គ្រងនិងនីតិវិធីដែលសមស្របដើម្បីធានាសុក្រឹតភាព សុវត្ថិភាពនិងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់ និង

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤២ .- នីតិវិធីផ្សេងទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក**

បន្ថែមលើមធ្យោបាយបង្ហាញភស្តុតាងដូចមានចែងក្នុងច្បាប់នេះ ភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបង្កើតឡើង តាមបច្ចេកទេសនិងនីតិវិធីផ្សេងទៀតដូចជា ការបញ្ជាក់ដោយសារការីឬស្ថាប័នមានសមត្ថកិច្ច កំណត់ត្រាក្នុងមធ្យោបាយអេឡិចត្រូនិកដែលមិនអនុញ្ញាតឱ្យមានការកែប្រែបាន និងលទ្ធផលកោសល្យវិច័យលើប្រព័ន្ធអេឡិចត្រូនិកតាមការរកឃើញរបស់យុត្តាធិការតុលាការ។

**មាត្រា៤៣ .- ការបំពានលើកូដនីយកម្ម**

បុគ្គលទាំងឡាយមិនត្រូវដាក់កូដក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលជាភស្តុតាងអាចនាំទៅដល់ការចោទប្រកាន់ ឬការដាក់កូដលើទិន្នន័យ ឬភស្តុតាងក្នុងប្រព័ន្ធអេឡិចត្រូនិកដែលទាក់ទិននឹងបទល្មើសឡើយ។

**មាត្រា៤៤ .- ការទទួលយកកំណត់ត្រាអេឡិចត្រូនិកពីបរទេស**

ភស្តុតាងអេឡិចត្រូនិកដែលបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ចនៃបណ្តារដ្ឋបរទេសត្រូវបានទទួលយកជាភស្តុតាង ប្រសិនបើប្រព័ន្ធអេឡិចត្រូនិកដែលកត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិកនោះមានសុក្រឹតភាពស្របតាមបទដ្ឋាន ដូចមានចែងក្នុងជំពូកទី៨នៃច្បាប់នេះ។

**មាត្រា៤៥ .- ការទទួលយកព័ត៌មានអេឡិចត្រូនិកមកពីបរទេស**

ដើម្បីកំណត់ថាព័ត៌មានក្នុងទម្រង់អេឡិចត្រូនិកមួយអាចទទួលយកឬមិនអាចទទួលយកបាន ឬអាចទទួលយកបានត្រឹមកម្រិតណាមួយនោះ មិនត្រូវគិតពីទីតាំងដែលព័ត៌មាននោះត្រូវបានបង្កើតឡើងឬត្រូវបានប្រើប្រាស់ ឬទីតាំងអាជីវកម្មដែលបានបង្កើតឡើងនៅបរទេសនោះឡើយ ឱ្យតែកំណត់ត្រាអេឡិចត្រូនិកនោះអាចចូលនិងទាញយកមកប្រើបាននៅក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩
## ការទូទាត់និង/ឬការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៤៦ .- ប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

១. បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដល់សាធារណជនត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។

២. ធនាគារជាតិនៃកម្ពុជាជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិទាក់ទងនឹងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៤៧ .- ការទទួលខុសត្រូវរបស់បុគ្គលផ្តល់សេវាទូទាត់**

១. បុគ្គលផ្តល់សេវាទូទាត់មិនត្រូវផ្តល់ជូនអតិថិជននូវឧបករណ៍ទូទាត់ ដែលអតិថិជនមិនបានស្នើសុំនោះទេ លើកលែងតែករណីដែលបណ្ណទូទាត់នោះជាបណ្ណទូទាត់ហួសរយៈពេលប្រើប្រាស់ ឬដល់ពេលត្រូវផ្លាស់ប្តូរ។

២. មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលផ្តល់សេវាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជននិងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវលើករណីដូចខាងក្រោម៖

ក. ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន។

ខ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំ បាត់បង់ ឬចោរកម្មនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

គ. ប្រតិបត្តិការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨ខាងក្រោម។

ឃ. ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជនឬការប្រតិបត្តិខុសពីបញ្ជារបស់អតិថិជន។ ឬ

ង. ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

៣. បុគ្គលផ្តល់សេវាទូទាត់អាចរួចផុតពីការទទួលខុសត្រូវបានតែក្នុងករណីប្រធានស័ក្តិ ឬជាកំហុសរបស់អតិថិជនផ្ទាល់ប៉ុណ្ណោះ។

៤. ក្នុងករណីដែលបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវ បុគ្គលផ្តល់សេវាទូទាត់ត្រូវសងថ្លៃខូចខាតជូនអតិថិជនក្នុងរយៈពេលមិនឱ្យលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៨នៃច្បាប់នេះ នូវតម្លៃប្រតិបត្តិការដែលបានខាតបង់សោហ៊ុយ និងការពិន័យក្នុងការបង់ការប្រាក់យឺតយ៉ាវដែលកើតចេញពីប្រតិបត្តិការនេះ ដោយ មិនទាន់គិតបញ្ចូលការសងថ្លៃខូចខាតដទៃទៀតដែលអាចកើតឡើងចំពោះអតិថិជន។

៥. បុគ្គលទាំងឡាយមិនត្រូវចេញផ្សាយបណ្ណទូទាត់ ឬកែប្រែបណ្ណទូទាត់ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើម ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងទុច្ចរិត ឆបោក ឬក្លែងបន្លំដែលនាំឱ្យមានព្យសនកម្មដល់បុគ្គលមួយផ្សេងទៀតឡើយ។

**មាត្រា៤៨ .- ការទទួលខុសត្រូវរបស់អតិថិជន**

១. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ អំពីប្រតិបត្តិការដែលកើតឡើងដោយគ្មានការអនុញ្ញាត កំហុសឆ្គង ឬភាពមិនត្រឹមត្រូវផ្សេងទៀតនៅក្នុងគណនីរបស់ខ្លួន។

ROYAUME DU CAMBODGE LE MINISTRE du PALAIS ROYAL

២. អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ឬគ្រឹះស្ថានដែលទទួលបានការអនុញ្ញាតពីបុគ្គលផ្តល់សេវាទូទាត់អំពីករណីបាត់បង់ឬអំពើចោរកម្មលើឧបករណ៍/មធ្យោបាយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬការលួចយកទិន្នន័យសម្រាប់ប្រើប្រាស់ជាមួយឧបករណ៍ទូទាត់។ ការជូនដំណឹងនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរឬតាមមធ្យោបាយអេឡិចត្រូនិកណាមួយដែលទទួលយកដោយបុគ្គលផ្តល់សេវាទូទាត់ ហើយត្រូវជូនដំណឹងជាបន្ទាន់តាមលទ្ធភាពដែលអាចធ្វើទៅបានឬមិនឱ្យលើសរយៈពេល២(ពីរ)ថ្ងៃ បន្ទាប់ពីបានដឹងថាមានករណីចោរកម្មឬបាត់បង់ឧបករណ៍ទូទាត់កើតឡើង។

៣. ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាការបាត់បង់ឬការខូចខាតក្នុងករណីខាងលើជាកំហុសរបស់អតិថិជន បុគ្គលផ្តល់សេវាទូទាត់មានសិទ្ធិទាមទារឱ្យអតិថិជនទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ។

៤. ក្នុងករណីមិនមានភស្តុតាងបញ្ជាក់អំពីកំហុសរបស់អតិថិជនទេ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ ដោយឥតលក្ខខណ្ឌ។

## ជំពូកទី១០
## សមត្ថកិច្ច ការប្តឹងតវ៉ា និងនីតិវិធីនៃការដាក់ពិន័យ

**មាត្រា៤៩ .- សមត្ថកិច្ច**

ការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការដាក់ពិន័យ ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ក្នុងករណីដែលបុគ្គលមិនអនុវត្តតាមវិធានការខាងលើ ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អាចធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ច។

**មាត្រា៥០ .- នីតិវិធីនៃការប្តឹងតវ៉ា**

១. បុគ្គលដែលមិនសុខចិត្តនឹងការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ និងការដាក់ពិន័យរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

២. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវសម្រេចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ។

៣. បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានសិទ្ធិប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាបានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងនៃសេចក្តីសម្រេចនោះ។

**មាត្រា៦២ .- អំពើល្មើសលើការបំពានលើកូដនីយកម្ម**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០ (ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៤៣។

**មាត្រា៦៣ .- អំពើល្មើសលើការធ្វើប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០ (មួយលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៤៦។

**មាត្រា៦៤ .- អំពើល្មើសលើការក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០ (ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា៤៧។

**មាត្រា៦៥ .- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

១. នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៥៣ដល់មាត្រា៥៥ កថាខណ្ឌទី២នៃមាត្រា៥៦និងមាត្រា៥៩ដល់មាត្រា៦៤នៃច្បាប់នេះ។

២. នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចតទៅនេះ៖

- ក. ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។
- ខ. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។
- គ. ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។
- ឃ. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។
- ង. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ សារព័ត៌មានអេឡិចត្រូនិក ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៦៦ .- ការទុកជានិរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦៧ .- ការអនុវត្តច្បាប់នេះ**

ក្រោយពីចូលជាធរមាន ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល៦(ប្រាំមួយ)ខែ ទើបអនុវត្ត។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១៩

នស/រកម.១១១៩.០១៧

នសីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

# ព្រះរាជក្រម

នស/រកម/១១១៩/០១៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

# ស្តីពី

# កិច្ចការពារអ្នកប្រើប្រាស់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី១

# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-** គោលបំណង

ច្បាប់នេះមានគោលបំណងធានាឱ្យមានកិច្ចការពារអ្នកប្រើប្រាស់និងចូលរួមលើកកម្ពស់ការប្រកួតប្រជែងដោយសុចរិត។

**មាត្រា២ .-** គោលដៅ

ច្បាប់នេះមានគោលដៅកំណត់វិធាននិងយន្តការដើម្បីចូលរួមចំណែកបង្កើតបរិយាកាសនៃការធ្វើពាណិជ្ជកម្មដែលក្នុងនោះ៖

- សិទ្ធិនិងផលប្រយោជន៍របស់អ្នកប្រើប្រាស់ត្រូវបានការពារ
- ការធ្វើពាណិជ្ជកម្មនោះមានការប្រកួតប្រជែងដោយសុចរិត និង
- អ្នកប្រើប្រាស់និងពាណិជ្ជករធ្វើសកម្មភាពជាមួយគ្នាដោយមានទំនុកចិត្ត។

**មាត្រា៣ .-** វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយដែលធ្វើធុរកិច្ច ទោះបីរកប្រាក់ចំណេញ ឬមិនរកប្រាក់ចំណេញក្តី រួមទាំងការលក់ទំនិញឬសេវាផ្សេងៗឬសិទ្ធិប្រត្យក្សលើអចលនទ្រព្យ ឱ្យអ្នកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងផ្សេងពីនេះ។

**មាត្រា៤ .-** និយមន័យ

១- **ការទទួលបាន** សំដៅដល់ការទទួលបានទំនិញនិងសិទ្ធិប្រត្យក្សលើអចលនទ្រព្យតាមរយៈអំណោយ ការទិញលក់ ការដោះដូរ ឬតាមការព្រមព្រៀងផ្សេងៗទៀត ព្រមទាំងការទទួលបានសេវាតាមរយៈការព្រមព្រៀងនានា។

២- **ការផ្សាយពាណិជ្ជកម្ម** សំដៅដល់ការផ្សព្វផ្សាយជាសាធារណៈឬការផ្សព្វផ្សាយទៅកាន់ក្រុមណាមួយក្នុងចំណោមសាធារណជនទោះតាមទម្រង់ណាក៏ដោយ ក្នុងគោលបំណងជំរុញការផ្គត់ផ្គង់ទំនិញ ឬសេវា ឬការលក់ឬការផ្តល់សិទ្ធិប្រត្យក្សលើអចលនទ្រព្យ។

៣- **បញ្ញត្តិករមានសមត្ថកិច្ច** សំដៅដល់ក្រសួង ស្ថាប័នណាមួយដែលមានមុខងារនិងតួនាទីការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់អ្នកប្រើប្រាស់ក្រោមការទទួលខុសត្រូវរបស់ខ្លួន។

៤- **ធុរកិច្ច** សំដៅដល់សកម្មភាពដែល៖

- ទំនិញឬសេវាត្រូវបានទទួលឬផ្គត់ផ្គង់ ឬដែលសិទ្ធិប្រត្យក្សលើអចលនទ្រព្យ ត្រូវបានទទួល ឬបោះបង់ ឬ
- បានធ្វើឡើងតាមវិធីដែលមានការរៀបចំនិងមានភាពច្បាស់លាស់ ឬ
- បុគ្គលធ្វើសកម្មភាពនោះមានគោលបំណងរកប្រាក់ចំណេញទោះបីជាសកម្មភាពដែលបានធ្វើដោយបុគ្គលនោះជាសកម្មភាពចម្បង ឬបន្ទាប់បន្សំ ឬមិនធ្វើជាប្រចាំក៏ដោយ។

៥- **អ្នកប្រើប្រាស់** សំដៅដល់ បុគ្គលដែលទទួលបានទំនិញឬសេវា៖

ក- ដែលជាធម្មតាយកទៅប្រើប្រាស់ជាលក្ខណៈផ្ទាល់ខ្លួន ក្នុងផ្ទះ ឬក្នុងគ្រួសារ និង

ខ- ក្នុងគោលបំណង៖

- មិនផ្គត់ផ្គង់បន្តក្នុងការធ្វើពាណិជ្ជកិច្ច ឬ

- មិនប្រើប្រាស់ក្នុងដំណើរការចង្វាក់ផលិតកម្មឬការផលិត ឬ
- មិនប្រើប្រាស់ទំនិញក្នុងសកម្មភាពពាណិជ្ជកម្ម ដូចជា ដើម្បីជួសជុលអគារឬយកទៅធ្វើជាវត្ថុតាំងភ្ជាប់លើអចលនទ្រព្យ។

៦- **សិទ្ធិអ្នកប្រើប្រាស់** សំដៅដល់៖

- សិទ្ធិទទួលបានព័ត៌មាននិងការអប់រំដើម្បីថ្លឹងថ្លែងនូវភាពខុសគ្នារវាងទំនិញឬសេវា និងដើម្បីការពារពីការក្លែងបន្លំនិងពីការបោកប្រាស់តាមការផ្សាយពាណិជ្ជកម្ម
- សិទ្ធិជ្រើសរើសទំនិញឬសេវាដែលមានការប្រកួតប្រជែងគ្នាអំពីថ្លៃនិងគុណភាព
- សិទ្ធិត្រូវបានដឹងឮអំពីកង្វល់និងទទួលការពិនិត្យដោះស្រាយពីបញ្ញត្តិករមានសមត្ថកិច្ចនិងរាជរដ្ឋាភិបាល
- សិទ្ធិទាមទារសំណងតាមច្បាប់នេះឬតាមច្បាប់ផ្សេង។

៧- **អំពើ** សំដៅដល់ការធ្វើ ការបដិសេធ ឬការមិនអើពើក្នុងការធ្វើសកម្មភាពណាមួយ រួមទាំងការគ្រប់គ្រងឬការដឹកនាំសកម្មភាពធុរកិច្ច។

៨- **ការលាតត្រដាងព័ត៌មាន** សំដៅដល់ការបង្ហាញព័ត៌មានគ្រប់គ្រាន់និងត្រឹមត្រូវដល់សាធារណជន។

៩- **ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់សកម្មភាពទិញលក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្មនិងរដ្ឋប្បវេណី ព្រមទាំងសកម្មភាពនិងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

១០- **ការប្រកួតប្រជែងដោយសុចរិត** សំដៅដល់ការប្រកួតប្រជែងឈរលើមូលដ្ឋានថ្លៃទាប គុណភាពល្អ និងសេវាល្អ ដោយផ្អែកលើគោលការណ៍និរន្តរភាពផ្នែកសេដ្ឋកិច្ចយូរអង្វែងនិងមិនបំពានអំណាចឬជំហរឧត្តមភាពលើទីផ្សារ។

១១- **ការអះអាងដោយបំភាន់** សំដៅដល់ការអះអាងមួយដែលបុគ្គលកំពុងធ្វើសកម្មភាពធុរកិច្ចណាមួយធ្វើឱ្យអ្នកប្រើប្រាស់ជឿថាអ្វីមួយពិត ប៉ុន្តែជាក់ស្តែងមិនមែនជាការពិត។

១២- **បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតឬរៀបចំឡើងយ៉ាងត្រឹមត្រូវតាមច្បាប់ជាធរមាន ទោះបីដើម្បីរកប្រាក់ចំណេញឬមិនរកប្រាក់ចំណេញក្តី បានចុះបញ្ជីឬមិនបានចុះបញ្ជីក្តី។

១៣- **ការផ្សព្វផ្សាយព័ត៌មាន** សំដៅដល់ការធ្វើឱ្យដឹងដល់សាធារណជនទូទៅ រួមបញ្ចូលទាំង ការផ្សព្វផ្សាយតាមរយៈគេហទំព័ររបស់បញ្ញត្តិករពាក់ព័ន្ធឬតាមមធ្យោបាយផ្សេងៗទៀតដែលសាធារណជនមានលទ្ធភាពអាចរកព័ត៌មានបានដោយសេរីនិងដោយគ្មានការរារាំង។

១៤- **សេវា** សំដៅដល់រាល់សិទ្ធិ អត្ថប្រយោជន៍ អាទិភាព ឬរាល់ការសម្រួលទាំងឡាយដែលត្រូវបានផ្តល់ឬបានឱ្យតាមប្រភេទនៃកិច្ចសន្យា មានជាអាទិ៍ដូចខាងក្រោម លើកលែងសេវាហិរញ្ញវត្ថុមិនមែនធនាគារ៖

ក- កិច្ចសន្យាទាក់ទងដល់៖

- ការបំពេញការងារទោះបីមានឬគ្មានការផ្គត់ផ្គង់ទំនិញក៏ដោយ ឬ
- ការផ្តល់ភាពងាយស្រួលឬការពេញចិត្តលើភាពងាយស្រួលរួមមាន ការស្នាក់នៅ ការលំហែ ការថែទាំមនុស្ស សត្វ ឬវត្ថុផ្សេងៗ ការកម្សាន្ត(លើកលែងល្បែងពាណិជ្ជកម្ម) ចំណត ឬ
- ការផ្តល់សិទ្ធិ អត្ថប្រយោជន៍ ឬផ្តល់អាទិភាព ដើម្បីទទួលបានប្រាក់កម្រៃ។

ខ- កិច្ចសន្យារវាងអ្នកផ្តល់សេវាហិរញ្ញវត្ថុជាមួយនឹងអតិថិជនរបស់ខ្លួន។

១៥- **ការផ្គត់ផ្គង់** សំដៅដល់៖

- ការផ្គត់ផ្គង់ទំនិញតាមរយៈការផ្ដល់ជាអំណោយ ការលក់ ការដោះដូរ ការជួល ឬការទិញដោយបង់ម្លស់ជាដើម និង
- ការផ្ដល់សេវា។

១៦- **ការផ្គត់ផ្គង់ច្រើនលើក** សំដៅដល់៖

- ការផ្គត់ផ្គង់ច្រើនលើកដែលមានលក្ខណៈជាអចិន្ត្រៃយ៍នូវទំនិញតាមរយៈការផ្ដល់ជាអំណោយ ការលក់ ការដោះដូរ ការជួល ឬការទិញដោយបង់រម្លស់ និង
- ការផ្ដល់សេវាច្រើនលើក។

១៧- **សេចក្ដីបរិយាយពាណិជ្ជកម្ម** សំដៅដល់ការបង្ហាញឬការបរិយាយអំពីទំនិញ រួមមានបរិមាណឬទំហំ របៀបបង្កើតឬផលិត សារធាតុដែលប្រើប្រាស់សម្រាប់ផលិត ពេលវេលាផលិត ភាពសមតាមបំណង ភាពមាំ មុខងារ លក្ខណៈឬភាពត្រឹមត្រូវ និងចរិតលក្ខណៈនៃរូបរាងដែលជាប់នឹងទំនិញ។ សេចក្ដីបរិយាយពាណិជ្ជកម្មមិនរាប់បញ្ចូលម៉ាកឬពាណិជ្ជនាមឡើយ។

១៨- **អំពើមិនសុចរិត** សំដៅដល់អំពើណាមួយរបស់បុគ្គលនៅក្នុងធុរកិច្ចដែលអាចបំភាន់ឬបោកបញ្ឆោតអ្នកប្រើប្រាស់ ទោះបីជាអំពើនោះធ្វើដោយចេតនាឬអចេតនា ក៏ដោយ៖

- ទង្វើឬអំណះអំណាងទាំងឡាយ ដូចជា ការផ្សាយពាណិជ្ជកម្ម ការជំរុញការលក់ និងអំណះអំណាងផ្សេងទៀត
- ការធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំអំពីថ្លៃ តម្លៃ ឬគុណភាពនៃទំនិញឬសេវា។ បុគ្គលក្នុងធុរកិច្ចមិនអាចពឹងផ្អែកទៅលើការបោះពុម្ពអក្សរនិងស្លាកសញ្ញាតូចៗពិបាកមើល និងការអះអាងការពារខ្លួនដែលមានលក្ខណៈធ្វើឱ្យមានភាពភាន់ច្រឡំ ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវ
- ការមិនបង្ហាញដល់អ្នកប្រើប្រាស់នូវការសន្យា ការរំពឹងទុក និងព័ត៌មានដែលពាក់ព័ន្ធ
- ទាញអត្ថប្រយោជន៍ពីអ្នកប្រើប្រាស់ ប្រសិនបើអ្នកផ្គត់ផ្គង់ដឹងថាអ្នកប្រើប្រាស់មិនស្ថិតក្នុងជំហរអាចការពារផលប្រយោជន៍របស់ខ្លួនបានឬមិនមានសមត្ថភាពយល់ដឹងពីទំនិញឬសេវា ដូចជា ចរិតលក្ខណៈ ប្រភេទ ភាសា អានុភាពនៃប្រតិបត្តិការឬបញ្ហានានាដែលទាក់ទងនឹងប្រតិបត្តិការនោះ ឬ
- អំពើផ្សេងៗទៀតដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៥ .-** គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់

ត្រូវបានបង្កើតគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ដោយមានអគ្គនាយកដ្ឋានទទួលបន្ទុកកិច្ចការពារអ្នកប្រើប្រាស់របស់ក្រសួងពាណិជ្ជកម្ម ជាសេនាធិការ ដើម្បីបំពេញភារកិច្ចនានាពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ ស្របតាមបញ្ញត្តិនៃច្បាប់នេះ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## សមាគមអ្នកប្រើប្រាស់

**មាត្រា៦ ._** ការបង្កើតសមាគមអ្នកប្រើប្រាស់

អ្នកប្រើប្រាស់តាមវិស័យនីមួយៗមានសិទ្ធិបង្កើតសមាគមរបស់ខ្លួនដោយត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។

**មាត្រា៧ ._** សមាគមអ្នកប្រើប្រាស់

សមាគមអ្នកប្រើប្រាស់តាមវិស័យណាមួយ ត្រូវមានការអនុញ្ញាតពីក្រសួងឬស្ថាប័នដែលមានតួនាទីនិងភារកិច្ចគ្របដណ្តប់លើវិស័យរបស់ខ្លួនជាមុនសិន។

បន្ទាប់ពីបានបង្កើតនិងចុះបញ្ជីសមាគមនៅក្រសួងមហាផ្ទៃនិងទទួលបានការអនុញ្ញាតពីបញ្ញត្តិករមានសមត្ថកិច្ចពាក់ព័ន្ធរួចហើយ សមាគមនោះត្រូវតម្កល់ឯកសារចុះបញ្ជីនិងលិខិតអនុញ្ញាតខាងលើ នៅគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

**មាត្រា៨ ._** តួនាទីនិងភារកិច្ចរបស់សមាគមអ្នកប្រើប្រាស់

សមាគមអ្នកប្រើប្រាស់មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ផ្តល់ប្រឹក្សាឯករាជ្យជូនអ្នកប្រើប្រាស់និងសម្របសម្រួលបញ្ហាទាក់ទងនឹងអ្នកប្រើប្រាស់
- ធ្វើជាអ្នកតំណាងចំពោះមុខគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ឬចំពោះមុខតុលាការជំនួសអ្នកប្រើប្រាស់ណាមួយឬក្រុមអ្នកប្រើប្រាស់ ដែលសិទ្ធិនិងផលប្រយោជន៍របស់ពួកគាត់ត្រូវបានបំពាន
- តំណាងទស្សនៈនិងផលប្រយោជន៍របស់អ្នកប្រើប្រាស់នៅក្នុងវេទិកាសាធារណៈ ឬសារព័ត៌មាន
- ទទួលការប្រឹក្សាពីបញ្ញត្តិករមានសមត្ថកិច្ចណាមួយ អំពីបទប្បញ្ញត្តិស្តីពីបទដ្ឋានព័ត៌មានដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់ ដែលចេញដោយបញ្ញត្តិករមានសមត្ថកិច្ចនោះ
- បង្កើតក្រុមការងារការពារអ្នកប្រើប្រាស់តាមវិស័យនីមួយៗ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ប្រគល់ជូន។

## ជំពូកទី៤
## អំពើមិនសុចរិតក្នុងធុរកិច្ច

**មាត្រា៩ ._** អំពើមិនសុចរិត

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវពាក់ព័ន្ធនឹងអំពើមិនសុចរិតឡើយ។

អំពើមិនសុចរិត សំដៅដល់អំពើណាមួយរបស់បុគ្គលនៅក្នុងធុរកិច្ចដែលអាចបំភាន់ឬបោកបញ្ឆោតអ្នកប្រើប្រាស់ ទោះបីជាអំពើនោះធ្វើដោយចេតនាឬអចេតនា ក៏ដោយ៖

- ការថ្លែងឬអំណះអំណាងទាំងឡាយ ដូចជា ការផ្សាយពាណិជ្ជកម្ម ការជំរុញការលក់ និងអំណះអំណាងផ្សេងទៀត

- ការធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំអំពីថ្លៃ តម្លៃ ឬគុណភាពនៃទំនិញឬសេវា។ បុគ្គលក្នុងធុរកិច្ចមិនអាចពឹងផ្អែកទៅលើការបោះពុម្ពអក្សរនិងស្លាកសញ្ញាតូចៗពិបាកមើល និងការអះអាងការពារខ្លួនដែលមានលក្ខណៈធ្វើឱ្យមានភាពភាន់ច្រឡំ ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវ
- ការមិនបង្ហាញដល់អ្នកប្រើប្រាស់នូវការសន្យា ការរំពឹងទុក និងព័ត៌មានដែលពាក់ព័ន្ធ
- ការទាញអត្ថប្រយោជន៍ពីអ្នកប្រើប្រាស់ ប្រសិនបើអ្នកផ្គត់ផ្គង់ដឹងថាអ្នកប្រើប្រាស់មិនស្ថិតក្នុងជំហរអាចការពារផលប្រយោជន៍របស់ខ្លួនបានឬមិនមានសមត្ថភាពយល់ដឹងពីទំនិញ ឬសេវា ដូចជាចរិតលក្ខណៈ ប្រភេទ ភាសា អានុភាពនៃប្រតិបត្តិការ ឬបញ្ហានានាដែលទាក់ទងនឹងប្រតិបត្តិការនោះ ឬ
- អំពើផ្សេងៗទៀតដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។

**មាត្រា១០.- អំពើមិនសុចរិតទាក់ទងនឹងទំនិញ**

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវពាក់ព័ន្ធនឹងអំពើមិនសុចរិតដែលមានលក្ខណៈជាការបំភាន់ឬបោកបញ្ឆោតដល់សាធារណជន ទាក់ទងនឹងប្រភេទ ដំណើរការផលិត ចរិតលក្ខណៈ ភាពសមតាមបំណង បរិមាណ រង្វាស់រង្វាល់ ក្រិតខ្នាត ស្តង់ដា ឬគុណភាពនៃទំនិញឡើយ។

**មាត្រា១១.- អំពើមិនសុចរិត *ទាក់ទងនឹងសេវា***

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវពាក់ព័ន្ធនឹងអំពើមិនសុចរិតដែលមានលក្ខណៈបំភាន់ឬបោកបញ្ឆោតដល់សាធារណជន ទាក់ទងនឹងប្រភេទ ស្តង់ដា ចរិតលក្ខណៈ ភាពសមតាមបំណង ទំហំឬគុណភាពនៃសេវាឡើយ។

**មាត្រា១២.- ការអះអាងដោយបំភាន់**

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវផ្គត់ផ្គង់ ជំរុញការផ្គត់ផ្គង់ ឬជំរុញការប្រើប្រាស់ទំនិញ ឬសេវា ដោយអះអាងដោយបំភាន់ណាមួយដូចខាងក្រោម៖

- ទំនិញនោះមានលក្ខណៈពិសេសដោយឡែកចំពោះប្រភេទ បទដ្ឋាន គុណភាព ចំណាត់ថ្នាក់ បរិមាណ សមាសធាតុ រចនាបថ ម៉ូដែល ឬទំនិញនោះមានប្រវត្តិពិសេស ឬទំនិញនោះមានការប្រើប្រាស់ពិសេសកន្លងមកហើយ
- សេវានោះមានលក្ខណៈពិសេសដោយឡែកចំពោះ ប្រភេទ បទដ្ឋាន គុណភាព ទំហំ ឬសេវានោះត្រូវបានផ្គត់ផ្គង់ដោយបុគ្គលពិសេសណាមួយ ឬដោយបុគ្គលណាមួយដែលមានមុខជំនាញ ឬមានលក្ខណសម្បត្តិពិសេសក្នុងការធ្វើពាណិជ្ជកម្ម
- បុគ្គលមានកេរ្តិ៍ឈ្មោះណាមួយបានឯកភាពទទួលទំនិញឬសេវានោះរួចហើយ
- ទំនិញនោះជាទំនិញថ្មី ឬជាទំនិញដែលត្រូវបានធ្វើឱ្យដូចថ្មី ឬជាទំនិញដែលបានផលិត បានបង្កើតឡើង បានកែច្នៃ នៅពេលវេលាពិសេសជាក់លាក់ណាមួយ
- ទំនិញឬសេវានោះមានការឧបត្ថម្ភគាំទ្រ មានការទទួលស្គាល់ មានការបញ្ជាក់ មានប្រសិទ្ធភាពសម្រាប់ការប្រើប្រាស់ មានវត្ថុរណប មានការប្រើប្រាស់ច្រើន ឬមានអត្ថប្រយោជន៍ច្រើន
- បុគ្គលណាមួយបានឧបត្ថម្ភគាំទ្រ បានទទួលស្គាល់ បានបញ្ជាក់ ឬមានសម្ព័ន្ធភាពជាមួយ
- ទំនិញឬសេវានោះមានការទទួលស្គាល់អំពីថ្លៃ
- ទំនិញឬសេវានោះមានតម្រូវការច្រើន

- ទំនិញឬសេវានោះមានរួមបញ្ចូលឬមិនរួមបញ្ចូលនូវការធានារ៉ាប់រង សំណងទូទាត់ ឬដំណោះស្រាយសិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត
- ទំនិញមានប្រភពដើមមកពីទីកន្លែងណាមួយ។

ការអះអាងដោយបំភាន់ផ្សេងទៀតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដែលជាប្រធានគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់តាមសំណើរបស់បញ្ញត្តិករមានសមត្ថកិច្ច។

## ជំពូកទី៥
## ការអនុវត្តមិនសុចរិត

**មាត្រា១៣ .-** ការហាមឃាត់ការលក់មិនសុចរិត

ការលក់ដែលធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំក្នុងការទិញទំនិញឬសេវាត្រូវហាមឃាត់។

**មាត្រា១៤ .-** ការសន្យាផ្ដល់ជាអំណោយនិងរង្វាន់

រាល់បុគ្គលមិនត្រូវសន្យាផ្ដល់ជាអំណោយ រង្វាន់ ឬវត្ថុឥតគិតថ្លៃដទៃទៀត ក្នុងចេតនាបោកប្រាស់ ឬភូតកុហកដល់អ្នកប្រើប្រាស់ពាក់ព័ន្ធនឹង៖

- ការផ្គត់ផ្គង់ទំនិញឬសេវា ឬ
- ការលក់ឬការផ្ដល់សិទ្ធិប្រត្យក្សលើអចលនទ្រព្យ។

**មាត្រា១៥ .-** ការផ្សាយពាណិជ្ជកម្មជានុយ

១- រាល់បុគ្គលមិនត្រូវផ្សាយពាណិជ្ជកម្មដើម្បីផ្គត់ផ្គង់ទំនិញឬសេវាក្នុងថ្លៃជាក់លាក់ណាមួយដែលបុគ្គលនោះគ្មានបំណងផ្គត់ផ្គង់ឬគ្មានមូលដ្ឋានសមស្របដែលអាចជឿជាក់បានថាបុគ្គលនោះអាចផ្គត់ផ្គង់បានតាមថ្លៃដែលបានផ្សាយ។

២- រាល់បុគ្គលដែលបានផ្សាយពាណិជ្ជកម្មទំនិញឬសេវាដើម្បីផ្គត់ផ្គង់ក្នុងថ្លៃជាក់លាក់ណាមួយត្រូវតែផ្គត់ផ្គង់ទំនិញឬសេវានោះតាមថ្លៃដែលបានផ្សាយនោះក្នុងរយៈពេលកំណត់ណាមួយនិងបរិមាណសមរម្យ។

៣- ក្នុងករណីមានបណ្ដឹងឬការតវ៉ាចំពោះបុគ្គលណាមួយ ពាក់ព័ន្ធនឹងការមិនបានផ្ដល់ទំនិញឬសេវាទៅឱ្យអ្នកប្រើប្រាស់ តាមបញ្ញត្តិដែលមានចែងក្នុងមាត្រានេះ បុគ្គលនោះអាចការពារខ្លួនបានប្រសិនបើបុគ្គលនោះបង្ហាញថា៖

ក- បានផ្ដល់ការផ្គត់ផ្គង់ឬឱ្យបុគ្គលផ្សេងទៀតដែលទទួលសិទ្ធិផ្គត់ផ្គង់ទំនិញឬសេវាដែលបានផ្សាយពាណិជ្ជកម្មដល់អ្នកប្រើប្រាស់ជំនួសគាត់ ក្នុងរយៈពេលកំណត់ណាមួយ ក្នុងបរិមាណកំណត់ណាមួយ និងក្នុងថ្លៃ ដូចដែលបានផ្សាយពាណិជ្ជកម្ម ហើយដែលការផ្គត់ផ្គង់នោះត្រូវបានយល់ព្រមពីអ្នកប្រើប្រាស់ផងដែរ។

ខ- បានផ្ដល់ការផ្គត់ផ្គង់ភ្លាមៗឬឱ្យបុគ្គលផ្សេងទៀតដែលទទួលសិទ្ធិផ្គត់ផ្គង់ជំនួសគាត់ក្នុងអំឡុងពេលកំណត់មួយជូនដល់អ្នកប្រើប្រាស់នូវទំនិញឬសេវាដែលសមមូលទាំងបរិមាណទាំងថ្លៃ ដូចដែលបានផ្សាយពាណិជ្ជកម្ម ហើយដែលការផ្គត់ផ្គង់នោះត្រូវបានយល់ព្រមពីអ្នកប្រើប្រាស់ផងដែរ។

**មាត្រា១៦ .-** ការលក់អូសទាញដោយមិនសុចរិត

ការលក់អូសទាញដោយមិនសុចរិត សំដៅដល់ការលក់ទាក់ទាញឬជំរុញ អ្នកទិញណាម្នាក់ឱ្យទិញទំនិញ ឬសេវាដោយផ្អែកលើលក្ខខណ្ឌថា អ្នកទិញនោះនឹងទទួលបានប្រាក់រង្វាន់ ប្រាក់កម្រៃជើងសារ ឬ

អត្ថប្រយោជន៍ដទៃទៀតជាថ្នូរនឹងការផ្តល់ឈ្មោះអតិថិជនសក្តានុពល ឬម្យ៉ាងទៀត ជួយដល់បុគ្គលនោះក្នុងការបញ្ចុះបញ្ចូលឬអូសទាញអ្នកទិញឬអ្នកប្រើប្រាស់ផ្សេងទៀតដើម្បីទទួលបានកម្រៃជើងសារឬការបញ្ចុះថ្លៃទំនិញឬបង្កើតនូវព្រឹត្តិការណ៍ផ្សេងទៀតអូសទាញអ្នកទិញផ្សេងទៀតឱ្យមកទិញទំនិញតាមការបញ្ចុះបញ្ចូលរបស់អ្នកប្រើប្រាស់ដំបូងមែន ហើយអតិថិជនសក្តានុពលនោះពិតជាបានមកទិញទំនិញឬសេវាតាមការបញ្ចុះបញ្ចូលរបស់អ្នកទិញឬអ្នកប្រើប្រាស់ដំបូងមែន ប៉ុន្តែលក្ខខណ្ឌទាំងនោះមិនត្រូវបានបំពេញដោយអ្នកលក់។

**មាត្រា១៧ .- ការទាមទារឬការទទួលយកការទូទាត់ដោយគ្មានចេតនាផ្គត់ផ្គង់ទំនិញឬសេវាតាមការបញ្ជាទិញ**

មុនពេលផ្គត់ផ្គង់ទំនិញឬសេវា អ្នកផ្គត់ផ្គង់មិនត្រូវទាមទារឬទទួលយកនូវការទូទាត់ឬតម្លៃតបស្នងដទៃទៀត ក្នុងករណីដែលអ្នកផ្គត់ផ្គង់នោះ៖

- មិនមានបំណងផ្គត់ផ្គង់ទំនិញឬសេវាតាមការបញ្ជាទិញ ឬ
- មានបំណងផ្គត់ផ្គង់ទំនិញឬសេវាដែលខុសពីទំនិញឬសេវាតាមការបញ្ជាទិញ ឬ
- មិនមានមូលហេតុសមហេតុផលដើម្បីបញ្ជាក់ថាអ្នកផ្គត់ផ្គង់នោះអាចនឹងផ្គត់ផ្គង់ទំនិញឬសេវាបានក្នុងរយៈពេលកំណត់ឬក្នុងរយៈពេលសមស្របតាមការបញ្ជាទិញ។

**មាត្រា១៨ .- ការអះអាងដែលមិនពិតឬដែលបំភាន់អំពីសកម្មភាពធុរកិច្ចមួយចំនួន**

១- បុគ្គលណាមួយមិនត្រូវធ្វើការអះអាងដែលមិនពិតឬដែលបំភាន់ ទាក់ទងទៅនឹងការទទួលបានចំណេញ ហានិភ័យ ឬសារៈសំខាន់ផ្សេងៗទៀតក្នុងសកម្មភាពធុរកិច្ចណាមួយដែលបុគ្គលនោះបានអះអាងថាបុគ្គលផ្សេងទៀតអាចធ្វើសកម្មភាពធុរកិច្ចនោះបានពីទីលំនៅរបស់ខ្លួន។

២- បុគ្គលណាមួយមិនត្រូវធ្វើការអះអាងដែលមិនពិតឬដែលបំភាន់លើចំណុចសំខាន់ៗទាក់ទងនឹងការទទួលបានចំណេញ ហានិភ័យ ឬសារៈសំខាន់ដទៃទៀតនៃសកម្មភាពធុរកិច្ចណាមួយដែលបុគ្គលនោះអញ្ជើញបុគ្គលដទៃទៀតតាមរយៈការផ្សាយពាណិជ្ជកម្មឬតាមមធ្យោបាយផ្សេងទៀតឱ្យចូលរួម ហើយដែលសកម្មភាពធុរកិច្ចនោះតម្រូវឱ្យមាន៖

ក- ការចូលរួមបំពេញការងារដោយបុគ្គលដទៃទៀត ឬ

ខ- ការវិនិយោគប្រាក់និងការចូលរួមបំពេញការងារដោយបុគ្គលដែលទាក់ទងនឹងការវិនិយោគនោះ។

**មាត្រា១៩ .- ការបង្ខិតបង្ខំដោយកម្លាំងនិងការគំរាមតាមផ្លូវចិត្ត**

បុគ្គលណាមួយមិនត្រូវបង្ខិតបង្ខំដោយកម្លាំងដោយការរំខានឬដោយការគំរាមតាមផ្លូវចិត្តទាក់ទងនឹងការផ្គត់ផ្គង់ទំនិញឬសេវាឬការទូទាត់ប្រាក់សម្រាប់ទំនិញឬសេវាឡើយ។

**មាត្រា២០ .- គម្រោងលក់បែបពីរ៉ាមីដ**

បុគ្គលណាមួយមិនត្រូវជំរុញឬប្រតិបត្តិគម្រោងលក់បែបពីរ៉ាមីដឡើយ។

គម្រោងលក់បែបពីរ៉ាមីដ គឺជាគម្រោងដែល៖

១- ផ្តល់ការផ្គត់ផ្គង់ទំនិញនិង/ឬសេវាដើម្បីទទួលបានប្រាក់រង្វាន់ឬតម្លៃតបស្នងមកវិញនិង

២- បង្កើតឱកាសលក់ទិញ ឱកាសវិនិយោគមួយដល់អ្នកចូលរួមជាច្រើនជាលក្ខណៈបុគ្គលឬតាមរយៈភ្នាក់ងារដែលមិនមែនជាការបង្កើតឱកាសលក់ទិញទំនិញឬសេវាពិតប្រាកដ និង

៣- គម្រោងនេះមានលក្ខណៈមិនសុចរិតចំពោះអ្នកចូលរួមជាច្រើន ពីព្រោះ៖

- ប្រាក់រង្វាន់ឬតម្លៃតបស្នងរបស់អ្នកចូលរួមទាំងនោះគឺពឹងផ្អែកលើការជ្រើសរើសអ្នកចូលរួមបន្ថែម

- អ្នកចូលរួមថ្មីមិនអាចរកអ្នកចូលរួមបន្ថែមទៀតបាន។

**មាត្រា២១ .- ការលក់ទំនិញដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត**

បុគ្គលណាមួយមិនត្រូវលក់ទំនិញដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិតឡើយ។

សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត គឺជាសេចក្តីបរិយាយដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទំនិញ ឬការជំរុញការផ្គត់ផ្គង់ទំនិញតាមគ្រប់មធ្យោបាយឬការប្រើប្រាស់ទំនិញដែលត្រូវបានចាត់ទុកថាមិនពិត។

មាត្រានេះអនុវត្តលើទំនិញទាំងឡាយដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិតដោយៈ

- ដេរ សង្កត់ពុម្ពពីលើ បញ្ចូល ភ្ជាប់ ឬបិទពីលើទំនិញ ឬ
- បង្ហាញលើគម្រប លើស្លាក លើបំពង់ លើស្រោមសំបកវេចខ្ចប់ឬលើទំនិញ។

**មាត្រា២២ .- ការអនុវត្តមិនសុចរិតផ្សេងទៀត**

ការអនុវត្តមិនសុចរិតផ្សេងទៀតត្រូវកំណត់ដោយប្រកាសរបស់បញ្ញត្តិករមានសមត្ថកិច្ច ស្របតាមវិសាលភាពនៃតួនាទីនិងភារកិច្ចរបស់បញ្ញត្តិករនោះ ដោយមានការឯកភាពពីគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ដើម្បីការពារសិទ្ធិស្របច្បាប់និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។

## ជំពូកទី៦

## ព័ត៌មានសម្រាប់អ្នកប្រើប្រាស់

**មាត្រា២៣ .-បទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវលាតត្រដាងព័ត៌មានអប្បបរមាដល់អ្នកប្រើប្រាស់ ស្របតាមបទដ្ឋានព័ត៌មានដែលត្រូវកំណត់ដោយប្រកាសរបស់បញ្ញត្តិករមានសមត្ថកិច្ចនិងអាចមានការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ក្នុងករណីចាំបាច់។

**មាត្រា២៤ .- កាតព្វកិច្ចក្នុងការប្រតិបត្តិតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

បុគ្គលដែលធ្វើធុរកិច្ច ផ្គត់ផ្គង់ សន្យាផ្គត់ផ្គង់ ឬផ្សាយពាណិជ្ជកម្មថានឹងផ្គត់ផ្គង់ទំនិញឬសេវាត្រូវប្រតិបត្តិតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់។

**មាត្រា២៥ .- ការជូនដំណឹងអំពីបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

បទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ ត្រូវផ្សព្វផ្សាយដោយបញ្ញត្តិករពាក់ព័ន្ធនិង/ឬគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ហើយនៅពេលដែលត្រូវបានផ្សព្វផ្សាយរួច បទដ្ឋានព័ត៌មាននោះនឹងត្រូវក្លាយជាផ្នែកមួយនៃបទដ្ឋានព័ត៌មានដែលស្ថិតក្រោមច្បាប់នេះ ហើយនឹងត្រូវអនុវត្តដោយគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

**មាត្រា២៦ .- ការរៀបចំនិងការដាក់ឱ្យអនុវត្តបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

បញ្ញត្តិករមានសមត្ថកិច្ចត្រូវរៀបចំបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់ដែលទាក់ទងនឹងទំនិញឬសេវាសម្រាប់សកម្មភាពធុរកិច្ចដែលស្ថិតក្នុងវិសាលភាពនៃតួនាទីនិងភារកិច្ចរបស់បញ្ញត្តិករទាំងនោះ ដើម្បីការពារសិទ្ធិស្របច្បាប់និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។

ក្នុងករណីដែលបទប្បញ្ញត្តិរៀបចំដោយបញ្ញត្តិករមានសមត្ថកិច្ចណាមួយ មានទំនាស់នឹងបទប្បញ្ញត្តិដែលរៀបចំដោយបញ្ញត្តិករផ្សេងទៀត គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ត្រូវពិនិត្យនិងរកវិធីដោះស្រាយ។ ក្នុងករណីមិនអាចដោះស្រាយបាន គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ត្រូវដាក់សំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

**មាត្រា២៧ .-** គំរូខ្លឹមសារនៃបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់

១- បទដ្ឋានព័ត៌មានដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់អាចៈ

ក- លាតត្រដាងព័ត៌មានដែលទាក់ទងនឹងប្រភេទ ចំណាត់ថ្នាក់ សុវត្ថិភាព បរិមាណ ប្រភពដើម មុខងារប្រើប្រាស់ ការថែទាំ សមាសធាតុផ្សំ ការរចនា ការដំឡើង វិធីប្រើ ថ្លៃ ការវេចខ្ចប់ ការផ្សព្វផ្សាយ ឬការផ្គត់ផ្គង់ កាលបរិច្ឆេទផលិត និងកាលបរិច្ឆេទផុតកំណត់ការប្រើប្រាស់ ព័ត៌មានអំពីការផលិត ឬព័ត៌មានដែលទាក់ទងនឹងការផ្គត់ផ្គង់ទំនិញឬសេវា និង/ឬ

ខ- បញ្ជាក់អំពីវិធីដែលព័ត៌មាននេះត្រូវបានទទួល និង/ឬ

គ- បញ្ជាក់អំពីទម្រង់និងរបៀបដែលព័ត៌មាននោះត្រូវបានធ្វើការផ្សព្វផ្សាយទាក់ទងនឹងៈ

- ការផ្គត់ផ្គង់ទំនិញឬសេវា ឬ
- ការផ្គត់ផ្គង់ឡើងវិញឬលទ្ធភាពនៃការផ្គត់ផ្គង់ឡើងវិញនៃទំនិញឬសេវា ឬ
- ការជំរុញផ្សព្វផ្សាយតាមវិធីណាក៏ដោយអំពីចំណុចមួយឬច្រើនពាក់ព័ន្ធនឹងការផ្គត់ផ្គង់ ការផ្គត់ផ្គង់ឡើងវិញ ឬលទ្ធភាពនៃការផ្គត់ផ្គង់ឡើងវិញ ចំពោះទំនិញឬសេវា ឬ

ឃ- កំណត់បទដ្ឋានព័ត៌មានអប្បបរមាសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅព្រះរាជាណាចក្រកម្ពុជា។

២- រាល់ព័ត៌មានដែលសរសេរត្រូវមានភាសាខ្មែរ តាមប្រកាសរបស់បញ្ញត្តិករមានសមត្ថកិច្ច។

៣- គំរូសម្រាប់រៀបចំបទដ្ឋានព័ត៌មានផ្សេងទៀតសម្រាប់ផ្តល់ជូនអ្នកប្រើប្រាស់ អាចត្រូវបានកំណត់ដោយគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

## ជំពូកទី៧
## នីតិវិធីនៃការប្តឹងនិងការស៊ើបអង្កេត

**មាត្រា២៨ .-** ស្ថាប័នទទួលពាក្យបណ្តឹងនិងស៊ើបអង្កេត

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់មានសមត្ថកិច្ចទទួលពាក្យបណ្តឹងនិងស៊ើបអង្កេតតាមរយៈ៖

១- ការផ្តួចផ្តើមរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ខ្លួនឯង ឬ

២- បណ្តឹងពីបុគ្គលណាមួយឬសមាគមអ្នកប្រើប្រាស់ណាមួយ

៣- បណ្តឹងពីបញ្ញត្តិករមានសមត្ថកិច្ចណាមួយ។

ក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចស្នើសុំកិច្ចសហការពីស្ថាប័នឬបញ្ញត្តិករមានសមត្ថកិច្ចដើម្បីបំពេញភារកិច្ចខាងលើ ហើយស្ថាប័នឬបញ្ញត្តិករមានសមត្ថកិច្ចនោះត្រូវផ្តល់កិច្ចសហការតាមការស្នើសុំរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

**មាត្រា២៩ .- ការតែងតាំងមន្ត្រីស៊ើបអង្កេត**

មន្ត្រីស៊ើបអង្កេតត្រូវទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីស៊ើបអង្កេត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៣០ .- សិទ្ធិអំណាចត្រួតពិនិត្យ**

មន្ត្រីស៊ើបអង្កេតមានសិទ្ធិដូចតទៅៈ

១- អង្កេត ស្រាវជ្រាវ និងប្រមូលភស្តុតាងពាក់ព័ន្ធនឹងការបំពានច្បាប់នេះ។

២- ត្រួតពិនិត្យផលិតផល ទំនិញនិងសេវា ការផ្សព្វផ្សាយពាណិជ្ជកម្មលក់ ការលក់ផលិតផលណាមួយ ឬការស្តុកទុកចែកចាយដែលតម្រូវឱ្យមានភាពអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

៣- យកសំណាកផលិតផលឬឧបករណ៍ពាក់ព័ន្ធផ្សេងៗទៀត ក្នុងករណីមានការសង្ស័យថាមានការបំពានច្បាប់នេះ។

៤- សាកសួរបុគ្គលពាក់ព័ន្ធដើម្បីទទួលចម្លើយឬឱ្យបញ្ជូនឯកសារឬវត្ថុផ្សេងៗដើម្បីធ្វើការពិចារណា។

៥- ចាត់វិធានការហាមឃាត់ជាបណ្តោះអាសន្នចំពោះការផ្គត់ផ្គង់ ការចែកចាយ ឬចរាចរណ៍លើទីផ្សារនូវប្រភេទផលិតផល ទំនិញ ឬសេវាទាំងឡាយណាដែលបានស្រាវជ្រាវឃើញភស្តុតាងថាមិនមានភាពអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ហើយត្រូវរាយការណ៍ជូនគណៈកម្មការជាតិការពារអ្នកប្រើប្រាស់ដើម្បីសម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ សហការចាត់វិធានការបន្តតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៣១ .- សិទ្ធិអំណាចចុះឆែកឆេរ**

មន្ត្រីស៊ើបអង្កេតត្រូវបានអនុញ្ញាតឱ្យចុះដល់ទីកន្លែងនិងឆែកឆេរទីកន្លែងណាមួយដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីស៊ើបអង្កេតដែលត្រូវចុះបំពេញភារកិច្ចក្នុងបរិវេណ ទីតាំង មានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ និងត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

## ជំពូកទី៨
## នីតិវិធីនៃការចេញសេចក្តីសម្រេច

**មាត្រា៣២ .- នីតិវិធីនៃការចេញសេចក្តីសម្រេច**

បន្ទាប់ពីការស៊ើបអង្កេត គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់មានអំណាចតាមច្បាប់នេះលើការៈ

១- ចេញសេចក្តីសម្រេច និង/ឬ

២- ចេញការកំណត់ទណ្ឌកម្មរដ្ឋបាល

ក្នុងការចេញសេចក្ដីសម្រេចនិង/ឬការកំណត់ទណ្ឌកម្មរដ្ឋបាល គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចធ្វើការពិចារណាលើចំណាត់ការនានាឬលើសំណូមពរដែលបានស្នើឡើងដោយបញ្ញត្តិករមានសមត្ថកិច្ចពាក់ព័ន្ធ ទាក់ទងនឹងការអនុម័តយល់ព្រម ការកែតម្រូវ ឬការបដិសេធចំណាត់ការចំពោះសំណូមពរដែលស្នើឡើងនោះ។

**មាត្រា៣៣ .- នីតិវិធីនៃការដោះស្រាយ**

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចធ្វើការដោះស្រាយតាមការចរចាជាមួយបុគ្គលដែលបានបំពានបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ។

រាល់ការដោះស្រាយមិនត្រូវអនុវត្តលើ៖

១- ករណីព្រហ្មទណ្ឌ។

២- ការបំពានបទប្បញ្ញត្តិនានានៃច្បាប់នេះជាថ្មីទៀតរបស់បុគ្គលនោះឡើយ។

នីតិវិធីនៃការដោះស្រាយត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៣៤ .- សេចក្ដីសម្រេចឱ្យបង្ហាញព័ត៌មានឬផ្សព្វផ្សាយឡើងវិញ**

នៅពេលដែលគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់រកឃើញថាបុគ្គលណាមួយដែលពាក់ព័ន្ធបានបំពាននឹងបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចចេញបទបញ្ជាដូចខាងក្រោម៖

១- តម្រូវឱ្យបុគ្គលដែលមិនបានផ្សព្វផ្សាយព័ត៌មានឬផ្សព្វផ្សាយព័ត៌មានមិនគ្រប់គ្រាន់ធ្វើការផ្សព្វផ្សាយព័ត៌មាននោះឬចំណុចណាមួយនៃព័ត៌មាននោះឱ្យបានគ្រប់គ្រាន់ តាមវិធីដូចដែលបានបញ្ជាក់ក្នុងបទបញ្ជា ដោយចំណាយថវិកាផ្ទាល់ខ្លួនជូនសាធារណជនឬបុគ្គលពាក់ព័ន្ធណាមួយ។

២- តម្រូវឱ្យបុគ្គលដែលបានផ្សព្វផ្សាយព័ត៌មានខុសឬបំភាន់នោះ ធ្វើសេចក្ដីកែតម្រូវឡើងវិញតាមវិធីដូចដែលបានបញ្ជាក់ក្នុងបទបញ្ជា ដោយចំណាយថវិកាផ្ទាល់ខ្លួន។

**មាត្រា៣៥ .- សេចក្ដីសម្រេចហាមឃាត់ពីមុខងារគ្រប់គ្រង**

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចចេញសេចក្ដីសម្រេចហាមឃាត់បុគ្គលណាមួយពីមុខងារគ្រប់គ្រងបាន ប្រសិនបើ៖

១- បុគ្គលនោះបានប្រព្រឹត្តល្មើសដូចខាងក្រោមចាប់ពី២(ពីរ)ដងឡើងទៅ៖

- អំពើមិនសុចរិតពាក់ព័ន្ធនឹងទំនិញនិង/ឬសេវា
- ការអះអាងដោយបំភាន់
- ការសន្យាផ្ដល់ជាអំណោយនិងរង្វាន់
- ការផ្សាយពាណិជ្ជកម្មជានុយ
- ការលក់អូសទាញដោយមិនសុចរិត
- ការទាមទារឬការទទួលយកការទូទាត់ដោយគ្មានចេតនាផ្គត់ផ្គង់ទំនិញឬសេវាតាមការបញ្ជាទិញ
- ការអះអាងដែលមិនពិតឬដែលបំភាន់អំពីសកម្មភាពធុរកិច្ចមួយចំនួន
- ការបង្ខិតបង្ខំដោយកម្លាំងនិងការគំរាមតាមផ្លូវចិត្ត
- គម្រោងលក់បែបពីរ៉ាមីដ និង
- ការលក់ទំនិញដែលមានភ្ជាប់សេចក្ដីបរិយាយពាណិជ្ជកម្មមិនពិត។

២- បុគ្គលនោះបានប្រព្រឹត្តល្មើសដូចខាងក្រោម យ៉ាងតិច២(ពីរ)ដង ក្នុងរយៈពេល៥(ប្រាំ) ឆ្នាំ នៅពេលដែលបុគ្គលនោះមានឋានៈជានាយក ឬអ្នកគ្រប់គ្រងរបស់នីតិបុគ្គលៈ

- មិនបានលាតត្រដាងបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់
- មិនបានបំពេញកាតព្វកិច្ចក្នុងការប្រតិបត្តិតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់
- មិនបានធ្វើការជូនដំណឹងអំពីបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់។

៣- បុគ្គលដែលត្រូវបានហាមឃាត់ដោយរដ្ឋបរទេសទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ ដូចមានចែងក្នុងចំណុច១និង២។

**មាត្រា៣៦ .- ការផ្សព្វផ្សាយសេចក្ដីសម្រេចហាមឃាត់ពីមុខងារគ្រប់គ្រង**

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ត្រូវផ្ដល់ច្បាប់ចម្លងសេចក្ដីសម្រេចហាមឃាត់នីមួយៗ ដែលមានចែងក្នុងមាត្រា៣៥នៃច្បាប់នេះ ឱ្យទៅៈ

ក- បុគ្គលពាក់ព័ន្ធឬសមាគមអ្នកប្រើប្រាស់ណាមួយ។

ខ- បញ្ញត្តិករមានសមត្ថកិច្ច និង

គ- អង្គភាពចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម។

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវផ្សព្វផ្សាយសេចក្ដីសម្រេចហាមឃាត់នានា ដែលមានចែងនៅក្នុងមាត្រា៣៥នៃច្បាប់នេះ នៅលើគេហទំព័រឬព្រឹត្តិបត្ររបស់ខ្លួនឬតាមមធ្យោបាយផ្សេងទៀត ។

**មាត្រា៣៧ .- រយៈពេលនៃការហាមឃាត់ពីមុខងារគ្រប់គ្រង**

ការហាមឃាត់មិនឱ្យកាន់តួនាទីជានាយកឬជាអ្នកគ្រប់គ្រងរបស់នីតិបុគ្គលក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវតិចជាង២(ពីរ)ឆ្នាំនិងមិនត្រូវលើសពី៥(ប្រាំ)ឆ្នាំឡើយ។

## ជំពូកទី៩
## ការប្ដឹងតវ៉ា

**មាត្រា៣៨ .- ការកែតម្រូវលើសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់**

បុគ្គលណាមួយដែលពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ អាចប្ដឹងទាមទារឱ្យគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ពិនិត្យឡើងវិញ កែតម្រូវ ឬដកសេចក្ដីសម្រេច ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលសេចក្ដីជូនដំណឹងអំពីសេចក្ដីសម្រេច។

បណ្ដឹងឱ្យពិនិត្យឡើងវិញ ត្រូវបញ្ជាក់ចំណុចដូចខាងក្រោមៈ

- បញ្ជាក់ឱ្យបានច្បាស់ថាការរកឃើញណាមួយឬច្រើនរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់អាចតវ៉ាបាន និង
- បង្ហាញថាសេចក្ដីសម្រេច ឬទណ្ឌកម្មរដ្ឋបាលរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ មិនមានភស្ដុតាងរឹងមាំដូចបានបញ្ជាក់នៅក្នុងកំណត់ហេតុរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

ក្នុងករណីនេះ គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវពិនិត្យនិងសម្រេចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា៣៩ .- សិទ្ធិក្នុងការប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច**

បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ អាចប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាបាន ក្នុងរយៈពេល៣០(សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងអំពីសេចក្ដីសម្រេចចុងក្រោយ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី១០

## ទោសប្បញ្ញត្តិ

**មាត្រា៤០ .- ទណ្ឌកម្មនិងការពិន័យអន្តរការណ៍**

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ការដកហូត ឬការលុបចោលវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មឬអាជ្ញាបណ្ណ ការពិន័យអន្តរការណ៍ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ការដកហូត ឬការលុបចោលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មឬអាជ្ញាបណ្ណ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីស៊ើបអង្កេត។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរលត់បណ្ដឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីស៊ើបអង្កេតអាចកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស ដូចមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤១ .- អំពើមិនសុចរិតទាក់ទងនឹងទំនិញ សេវា ឬការអះអាងដោយបំភាន់**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើមិនសុចរិតពាក់ព័ន្ធនឹងទំនិញ សេវា ឬការអះអាងដោយបំភាន់ ដូចមានចែងក្នុងមាត្រា៩ មាត្រា១០ មាត្រា១១ និងមាត្រា១២។

ក្នុងករណីទទួលរងនូវការព្រមានជាលាយលក្ខណ៍អក្សរម្ដងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសតាមកថាខណ្ឌទី១ខាងលើនេះ ត្រូវព្យួរ ដកហូត ឬលុបចោលវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មឬអាជ្ញាបណ្ណ។

ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះអំពើល្មើសនឹងកថាខណ្ឌទី១ខាងលើនេះ ពាក់ព័ន្ធនឹងគុណភាពនិងប្រភពដើមនៃទំនិញ។

**មាត្រា៤២ .- ស្ថានទម្ងន់ទោសនៃអំពើមិនសុចរិតទាក់ទងនឹងទំនិញ សេវា ឬការអះអាងដោយបំភាន់ ដោយសារប៉ះពាល់ដល់សុខភាពនិងសុវត្ថិភាព**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះអំពើល្មើសនឹងកថាខណ្ឌទី១នៃមាត្រា៤១ ក្នុងករណីដែលបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពនិងសុវត្ថិភាពអ្នកប្រើប្រាស់។

**មាត្រា៤៣ .- ស្ថានទម្ងន់ទោសនៃអំពើមិនសុចរិតទាក់ទងនឹងទំនិញ សេវា ឬការអះអាងដោយបំភាន់ ដោយសារពិការភាពឬមរណភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី៤ ០០០ ០០០ (បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះអំពើល្មើសនឹងកថាខណ្ឌទី១នៃមាត្រា៤១ ដែលបណ្តាលឱ្យមានពិការភាពអចិន្ត្រៃយ៍ឬបណ្តាលឱ្យបាត់បង់អាយុជីវិត។

**មាត្រា៤៤ .- អំពើទាក់ទងនឹងការអនុវត្តមិនសុចរិត**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៥០ ០០០ ០០០(ហាសិបលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តការផ្សាយពាណិជ្ជកម្មជានុយ ការទាមទារឬការទទួលយកការទូទាត់ដោយគ្មានចេតនាផ្គត់ផ្គង់ទំនិញឬសេវាតាមការបញ្ជាទិញ ការអះអាងដែលមិនពិតឬដែលបំភាន់អំពីសកម្មភាពធុរកិច្ចមួយចំនួន ការបង្ខិតបង្ខំដោយកម្លាំង និងការគំរាមតាមផ្លូវចិត្ត។

**មាត្រា៤៥ .- អំពើលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល ចំពោះអំពើលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត។

**មាត្រា៤៦ .- ស្ថានទម្ងន់ទោសនៃការលក់បែបពីរ៉ាមីដឬលក់ទំនិញដែលភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត ដោយសារប៉ះពាល់ដល់សុខភាពនិងសុវត្ថិភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០ (មួយលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះអំពើលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត ហើយដែលបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពនិងសុវត្ថិភាពអ្នកប្រើប្រាស់។

**មាត្រា៤៧ .- ស្ថានទម្ងន់ទោសនៃការលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត ដោយសារពិការភាពឬមរណភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី៤ ០០០ ០០០ (បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះអំពើលក់បែបពីរ៉ាមីដឬការលក់ទំនិញដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិត ដែលបណ្តាលឱ្យមានពិការភាពអចិន្ត្រៃយ៍ឬបណ្តាលឱ្យបាត់បង់អាយុជីវិត។

**មាត្រា៤៨ .- អំពើល្មើសលើការមិនអនុលោមតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើមិនអនុលោមតាមបទដ្ឋានព័ត៌មានសម្រាប់អ្នកប្រើប្រាស់។

**មាត្រា៤៩ .- អំពើបំពានសេចក្តីសម្រេចដែលហាមឃាត់ពីការគ្រប់គ្រង**

ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលណាដែលបំពានសេចក្តីសម្រេចដែលហាមឃាត់ពីការគ្រប់គ្រង។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា៥០ ..** ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា៥១ ..** ប្រកាសជាការប្រញាប់

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៦កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១៩

ចារស.១៩១១.១៦៥៣

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

នស/រកម/១២១៥/០១៧

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋសភា ចូល
លេខ ២៣៤
ថ្ងៃទី ២១/១២ ឆ្នាំ២០១៥ ម៉ោង ៩:១០
បញ្ជូនទៅ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីទូរគមនាគមន៍ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

# ស្តីពី

# ទូរគមនាគមន៍

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណង ៖

- ធានាការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញនិងការផ្តល់សេវាទូរគមនាគមន៍ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព គុណភាព ភាពអាចទុកចិត្តបាន និងថ្លៃសមរម្យ ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ច
- ធានាការចូលរួមនិងលើកទឹកចិត្តដល់វិស័យឯកជន ក្នុងការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងការប្រកួត ប្រជែងស្របច្បាប់និងប្រកបដោយប្រសិទ្ធភាព និង
- ធានាការការពារអ្នកប្រើប្រាស់ និងជំរុញការកៀរគរចំណូលថវិកាជាតិ ។

**មាត្រា ២.–**

ច្បាប់នេះមានគោលដៅកំណត់អំពី ៖

- សមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ការបង្កើត មុខងារ និងភារកិច្ចរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- ចំណាត់ថ្នាក់និងប្រភេទនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ
- សមត្ថកិច្ចគ្រប់គ្រង និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ
- ស្តង់ដាគុណភាពនៃសេវា និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍
- កាតព្វកិច្ចសេវាសកល
- ការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ
- ប្លង់លេខទូរគមនាគមន៍ជាតិ និងអាសយដ្ឋានអេឡិចត្រូនិក
- វិធានស្តីពីថ្លៃសេវាទូរគមនាគមន៍ និងការប្រកួតប្រជែងដោយស្របច្បាប់ និងស្មោះត្រង់
- សិទ្ធិរបស់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និង
- សិទ្ធិរបស់អ្នកប្រើប្រាស់ ។

**មាត្រា ៣.–**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ប្រតិបត្តិការទូរគមនាគមន៍ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែវិស័យសន្តិសុខ និងការពារជាតិ ។

**មាត្រា ៤.–**

និយមន័យនៃពាក្យបច្ចេកទេសក្នុងច្បាប់នេះ ត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

# ជំពូកទី ២
## សមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**មាត្រា ៥.-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរកាត់ថា **ក.ប.ទ.** ។

**ក.ប.ទ.** មានសមត្ថកិច្ចដូចតទៅ ៖

ក- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងក្របខណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងប្រតិបត្តិការ ទូរគមនាគមន៍និងហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ- ធ្វើជាហត្ថលេខី និងជាតំណាងនៃរាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យទូរគមនាគមន៍

គ- ជំរុញការបង្កើត និងការប្រើប្រាស់កម្មវិធីកាតព្វកិច្ចសេវាសកល និងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

ឃ- ផ្តល់សេចក្តីណែនាំ ជួយសម្រួលកិច្ចការពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ដល់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

ង- លើកកម្ពស់ និងជំរុញការអនុវត្តច្បាប់នេះឲ្យមានប្រសិទ្ធភាព

ច- ចេញប្រកាសពាក់ព័ន្ធនឹងចំណុចដូចខាងក្រោម ៖

១) លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

២) ការតភ្ជាប់បណ្តាញរវាងប្រតិបត្តិករទូរគមនាគមន៍

៣) ការកំណត់ស្តង់ដាសម្រាប់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ និងការផ្តល់សេវាទូរគមនាគមន៍ ព្រមទាំងស្តង់ដាគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

៤) ប្លង់លេខទូរគមនាគមន៍ជាតិ និងអាសយដ្ឋានអេឡិកត្រូនិក

៥) លក្ខខណ្ឌនៃការបែងចែក និងការប្រើប្រាស់បន្ទាត់ប្រេកង់ស៍ និងការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតអាជ្ញាបណ្ណប្រេកង់វិទ្យុ

៦) សកម្មភាពប្រកួតប្រជែងស្របច្បាប់ និងស្មោះត្រង់របស់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

៧) ការគ្រប់គ្រងប្រព័ន្ធ និងសេវាអ៊ិនធឺណិត និង

ឆ- បំពេញកិច្ចការផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់នេះ ឬបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធ ។

SECRÉTARIAT ROYAL DU CAMBODGE · MINISTÈRE DU PALAIS ROYAL

**មាត្រា ៦.-**

**គ.ប.ឆ.** មានសមត្ថកិច្ចគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាគ្រប់ប្រភេទ និងសេវាថ្មីៗស្របតាមការវិវត្តនៃបច្ចេកវិទ្យាលើវិស័យនេះ ។ គ្រប់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ត្រូវផ្តល់ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាមក **គ.ប.ឆ.**។

ការប្រព្រឹត្តទៅនៃការគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍និងព័ត៌មានវិទ្យា ត្រូវកំណត់ដោយប្រកាសរបស់ **គ.ប.ឆ.**។

**មាត្រា ៧.-**

ក្នុងករណីប្រធានសក្តិ **គ.ប.ឆ.** ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចបញ្ជាទៅប្រតិបត្តិករទូរគមនាគមន៍ដែលពាក់ព័ន្ធឲ្យចាត់វិធានការចាំបាច់ ដោយផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៣
## និយ័តករទូរគមនាគមន៍កម្ពុជា

### ផ្នែកទី ១
### ការបង្កើតនិយ័តករទូរគមនាគមន៍កម្ពុជា

**មាត្រា ៨.-**

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់នេះ ។

និយ័តករទូរគមនាគមន៍កម្ពុជា សរសេរកាត់ថា **ន.ទ.ក.** ។

**មាត្រា ៩.-**

**ន.ទ.ក.** ត្រូវដឹកនាំដោយប្រធាន ១(មួយ)រូប ឋានៈស្មើរដ្ឋលេខាធិការ និងមានសមាជិកមួយចំនួន ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

ប្រធាននិងសមាជិក **ន.ទ.ក.** មានអាណត្តិ ៣(បី) ឆ្នាំ ។

បេក្ខភាពរបស់ប្រធាន និងសមាជិក **ន.ទ.ក.** ត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រី **គ.ប.ឆ.** ជូនប្រមុខរាជរដ្ឋាភិបាល ។ ប្រធាន និងសមាជិក **ន.ទ.ក.** ត្រូវមានសញ្ញាបត្រថ្នាក់ឧត្តមសិក្សាមានសមត្ថភាព និងលក្ខណសម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ព្រមទាំងមានបទពិសោធយ៉ាងតិច ១០(ដប់) ឆ្នាំ សម្រាប់ជំនាញមួយ ឬច្រើន ដូចជាទូរគមនាគមន៍ ព័ត៌មានវិទ្យា នីតិសាស្ត្រ រដ្ឋបាលសាធារណៈ សេដ្ឋកិច្ច និងពាណិជ្ជកម្ម ព្រមទាំងផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្តែង ។

# ផ្នែកទី ២
# មុខងារ និងភារកិច្ចរបស់និយ័តករទូរគមនាគមន៍កម្ពុជា

**មាត្រា ១០.-**

**ន.ទ.ក**. បំពេញមុខងារនិងភារកិច្ច ដោយមានស្វ័យភាពខាងផ្នែករដ្ឋបាល និងនិយ័តកម្ម ព្រមទាំងដោយឯករាជ្យពីប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ។

**ន.ទ.ក**. មានថវិកាស្វយ័តដោយត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ **ក.ប.ទ**. ។

**មាត្រា ១១.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃថវិការបស់ **ន.ទ.ក**. ត្រូវកំណត់ដោយអនុក្រឹត្យយោងតាមសំណើរបស់ **ក.ប.ទ**. និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

**មាត្រា ១២.-**

**ន.ទ.ក**. មានមុខងារ និងភារកិច្ចដូចខាងក្រោម ៖

ក- ធ្វើនិយ័តកម្មស្របតាមគោលនយោបាយនិងក្របខណ្ឌគតិយុត្តនៃវិស័យទូរគមនាគមន៍ និងបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា

ខ- ត្រួតពិនិត្យ និងតាមដានការផ្ដល់សេវាទូរគមនាគមន៍ស្របតាមបទប្បញ្ញត្តិជាធរមាន

គ- លើកសំណើផ្ដល់យោបល់លើវិសោធនកម្មប្រកាស ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

ឃ- ចេញសេចក្ដីសម្រេចបន្ថែមលើករណីមួយចំនួនស្របតាមមាត្រា ៥ ចំណុច(ច)នៃច្បាប់នេះ

ង- រាយការណ៍ និងផ្ដល់អនុសាសន៍ជូនរដ្ឋមន្ត្រី **ក.ប.ទ**. នូវបញ្ហាទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងការអភិវឌ្ឍ និងការត្រួតពិនិត្យវិស័យទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ច- ផ្ដល់ កែប្រែ ព្យួរ ផ្ទេរ ឬដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ឆ- ពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងអនុញ្ញាតលើពាក្យស្នើសុំដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ជ- ពិនិត្យឯកសារផ្ដល់ព័ត៌មានទាក់ទងនឹងសំណុំឯកសារស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដែលដាក់ពាក្យសុំមក **ន.ទ.ក**. ដើម្បីធានានូវការគោរពតាមលក្ខខណ្ឌ នៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត និងចុះបញ្ជីឯកសារដែលបានបំពេញតាមលក្ខខណ្ឌកំណត់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ឈ-ត្រួតពិនិត្យឯកសារផ្តល់ព័ត៌មានអំពីការគ្រប់គ្រងថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយសវនករឯករាជ្យដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងព័ត៌មានពុំមែន ហិរញ្ញវត្ថុដែលត្រូវផ្តល់ជូនដោយប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍រៀងរាល់ឆ្នាំសារពើពន្ធ ដើម្បីជានានូវការគោរពលក្ខខណ្ឌប្រកួតប្រជែងនៅក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ញ- ដើរតួនាទីជាស្ថាប័នត្រួតពិនិត្យ និងដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការទូរគមនាគមន៍ស្របតាមការកំណត់នៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ដ- ចាត់វិធានការសមស្របតាមច្បាប់នេះ ដើម្បីសហការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ លក្ខខណ្ឌនៃបច្ចេកវិទ្យា លក្ខខណ្ឌនៃស្តង់ដាគុណភាពនៃសេវា និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ដែលត្រូវកំណត់ក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ឋ- ដឹកនាំរៀបចំក្រមសីលធម៌វិជ្ជាជីវៈនៃវិស័យទូរគមនាគមន៍ ។

**មាត្រា ១៣.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ **ន.ទ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ

**មាត្រា ១៤.-**

គ្មានបុគ្គលណាអាចបំពេញប្រតិបត្តិការទូរគមនាគមន៍ ឬតាំងខ្លួនជាប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទេ លើកលែងតែបុគ្គលនោះបានទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណពី **ន.ទ.ក.** ស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

### ផ្នែកទី ១
### លក្ខខណ្ឌតម្រូវនៃការស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

**មាត្រា ១៥.-**

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតដើម្បីបំពេញប្រតិបត្តិការពី **ន.ទ.ក.**

ក- ការនាំចូល ការនាំចេញ ការផ្គត់ផ្គង់ និងការចែកចាយគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

ខ- ការបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិត

គ- ការបើកលក់ និង/ឬជួសជុលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

ឃ- ការបោះពុម្ពផ្សាយសៀវភៅលេខទូរគមនាគមន៍ និង

ង- ការធ្វើប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ។

## មាត្រា ១៦.-

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ ដើម្បីបំពេញប្រតិបត្តិការពី **ន.ទ.ក.** ដូចតទៅ ៖

ក- ការទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និងចែកចាយ គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

ខ- ការទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និង

គ- ប្រតិបត្តិការផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ។

## មាត្រា ១៧.-

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ដើម្បីបំពេញប្រតិបត្តិការពី **ន.ទ.ក.** ដូចតទៅ ៖

ក- ការស្ថាបនា ឬ/និងការផ្តល់សេវាប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍

ខ- ការផ្តល់សេវាទូរគមនាគមន៍ និង

គ- ប្រតិបត្តិការផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ។

## មាត្រា ១៨.-

ប្រតិបត្តិករទូរគមនាគមន៍ណាដែលបានទទួលការណែនាំពី **ន.ទ.ក.** តាមមាត្រា ៧៨ កថាខណ្ឌទី១ នៃច្បាប់នេះ ដែលតម្រូវឲ្យអនុវត្តតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែមនៃអាជ្ញាបណ្ណ ត្រូវគោរពតាមការណែនាំក្នុងរយៈពេលជាក់លាក់មួយដែលកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ឬសេចក្តីសម្រេចបន្ថែមរបស់ **ន.ទ.ក.** ។

# ផ្នែកទី ២
# នីតិវិធីនៃការស្នើសុំ និងការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

## មាត្រា ១៩.-

ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវគោរពតាមនីតិវិធីដូចតទៅ៖

ក- បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ដើម្បីបំពេញប្រតិបត្តិការ ដូចមានចែងក្នុងមាត្រា ១៥ មាត្រា ១៦ និងមាត្រា ១៧ នៃច្បាប់នេះ ដោយត្រូវគោរពតាមទម្រង់បែបបទ និងលក្ខខណ្ឌកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត និង

ខ- **ន.ទ.ក.** អាចតម្រូវឲ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែមតាមការចាំបាច់ និងអាចបដិសេធពិនិត្យពាក្យស្នើសុំនោះ រហូតដល់អ្នកដាក់ពាក្យស្នើសុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់ស្របតាមបទប្បញ្ញត្តិ នៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

## មាត្រា ២០.-

ការសម្រេចផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវអនុវត្តដូចតទៅ ៖

ក- **ន.ទ.ក.** អាចផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ដល់អ្នកដាក់ពាក្យស្នើសុំដើម្បីបំពេញប្រតិបត្តិការ ដូចមានចែងក្នុងមាត្រា ១៥ មាត្រា ១៦ និងមាត្រា ១៧ នៃច្បាប់នេះ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

ខ- ក្នុងរយៈពេលដែលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណនៅមានសុពលភាព ប្រសិនបើលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត មានការប្រែប្រួល លិខិតអនុញ្ញាតវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ដែលបានផ្តល់រួចហើយ ត្រូវបំពេញបន្ថែមតាមលក្ខខណ្ឌនៃការប្រែប្រួលនោះ ។ **ន.ទ.ក.** ត្រូវផ្តល់ដំណឹងទៅប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ រយៈពេល ១(មួយ) ឆ្នាំ មុនពេលកែប្រែលក្ខខណ្ឌនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ។

គ- **ន.ទ.ក.** មិនត្រូវបដិសេធការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដល់អ្នកដាក់ពាក្យស្នើសុំដោយមិនបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងដោយមិនបានផ្តល់ឱកាសដល់អ្នកដាក់ពាក្យស្នើសុំឲ្យធ្វើការពន្យល់ឡើយ ។

## មាត្រា ២១.-

**ន.ទ.ក.** ត្រូវបង្កើតនិងរក្សាបញ្ជីលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណទាំងអស់ដែលខ្លួនបានផ្តល់តាមទម្រង់បែបបទត្រឹមត្រូវ ដោយចុះបញ្ជាក់នូវព័ត៌មានជាក់លាក់មួយចំនួន ។ ទម្រង់បែបបទនៃការបង្កើតបញ្ជីនឹងត្រូវកំណត់នៅក្នុងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ **ន.ទ.ក.** ។

**ន.ទ.ក.** ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈពាក់ព័ន្ធនឹងប្រតិបត្តិការទូរគមនាគមន៍ ។

LE ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

## ផ្នែកទី ៣
## ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬ
## ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការដាក់ប្រាតិភោគ និងការក្ស័យធន

### មាត្រា ២២.-

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការដាក់ប្រាតិភោគនូវសិទ្ធិ ដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ដូចមានចែងក្នុងជំពូកទី ៤ នៃច្បាប់នេះត្រូវគោរពតាមច្បាប់នេះ និងបទប្បញ្ញត្តិជាធរមាន ។

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការដាក់ប្រាតិភោគនូវសិទ្ធិ ដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវគោរពតាមនីតិវិធីដូចគ្នាទៅនឹងការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងនីតិវិធីដែលមានចែងក្នុងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។

ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ មានបំណងចង់បញ្ឈប់ប្រតិបត្តិការរបស់ខ្លួន ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍នោះត្រូវជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅ **ន.ទ.ក.** យ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនថ្ងៃបញ្ចប់ប្រតិបត្តិការដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់ប្រតិបត្តិការ និងចុះហត្ថលេខាដោយប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ឬមេធាវីតំណាងផ្ទាល់របស់ខ្លួន ។

### មាត្រា ២៣.-

ក្នុងករណីពិនិត្យឃើញថា ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ អាចជាអសាធនីយ ឬមានបញ្ហាផ្នែកហិរញ្ញវត្ថុ ស្របតាមការវាយតម្លៃរបស់សវនករឯករាជ្យ **ន.ទ.ក.** មានសិទ្ធិស្នើសុំទៅតុលាការ បន្ទាប់ពីបានទទួលការយល់ព្រមពី **ក.ប.ទ.** ដើម្បីប្រកាសបើកសំណុំរឿងក្ស័យធន និងតែងតាំងអភិបាលបណ្តោះអាសន្ន ស្របតាមបទប្បញ្ញត្តិស្តីពីក្ស័យធន ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។ អភិបាលបណ្តោះអាសន្នដែលអាចត្រូវបានតែងតាំង ត្រូវបំពេញលក្ខណសម្បត្តិបន្ថែមស្របតាមប្រកាសរួមរបស់ **ក.ប.ទ.** និងក្រសួងយុត្តិធម៌ ។

## ជំពូកទី ៥
## ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ

### មាត្រា ២៤.-

ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញនិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ **ក.ប.ទ.** ផ្អែកតាមបទប្បញ្ញត្តិជាធរមាន ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL •

### មាត្រា ២៥.-

ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ អាចត្រូវបានប្រើប្រាស់ជាអាទិភាពនៅក្នុងលម្ហអាកាស លម្ហសាធារណៈ លើដី ក្រោមដី បាតទន្លេ និងបាតសមុទ្រ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

ការរៀបចំប្លង់ស្ថាបនាប្រព័ន្ធគមនាគមន៍ មជ្ឈមណ្ឌលប្រជុំជន មជ្ឈមណ្ឌលលំនៅឋាន តំបន់ឧស្សាហកម្ម តំបន់សេដ្ឋកិច្ចពិសេស និងតំបន់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវមានរួមបញ្ចូលនូវប្លង់ស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទូរគមនាគមន៍ផងដែរ ។

### មាត្រា ២៦.-

ទីតាំងសម្រាប់ប្រើប្រាស់សេវាទូរគមនាគមន៍សាធារណៈ អាចកំណត់ជាអាទិភាពនៅតាមស្ថានីយរថភ្លើង ស្ថានីយរថយន្តសាធារណៈ កំពង់ផែ អាកាសយានដ្ឋាន ច្រកទ្វារព្រំដែន មន្ទីរពេទ្យ និងទីកន្លែងសាធារណៈផ្សេងទៀត ស្របតាមការកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

## ផ្នែកទី ១
## ការប្រើប្រាស់ដីធ្លីសម្រាប់ផ្តល់សេវាទូរគមនាគមន៍

### មាត្រា ២៧.-

ការកំណត់ទីតាំងនៃដីធ្លី សំណង់ ឬអគារណាមួយសម្រាប់ដំឡើង សាងសង់ ឬប្រើប្រាស់ជាហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញនិងការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិផ្សេងទៀត ។

### មាត្រា ២៨.-

ប្រតិបត្តិករទូរគមនាគមន៍ ត្រូវពិភាក្សា និងស្នើសុំការអនុញ្ញាតពីក្រសួង ស្ថាប័ន និង/ឬអាជ្ញាធរមានសមត្ថកិច្ច មុននឹងដំឡើងខ្សែកាប្លិ៍និងឧបករណ៍ពាក់ព័ន្ធនៅលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

ប្រតិបត្តិករទូរគមនាគមន៍ ត្រូវចរចា និងចុះកិច្ចព្រមព្រៀងជាមួយកម្មសិទ្ធិករ ស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត មុននឹងដំឡើងខ្សែកាប្លិ៍និងឧបករណ៍ពាក់ព័ន្ធនៅលើទ្រព្យសម្បត្តិឯកជន ។

### មាត្រា ២៩.-

ប្រតិបត្តិករទូរគមនាគមន៍អាចកំណត់និងចូលក្នុងទីតាំងសម្រាប់សាងសង់ ដំឡើងនិង/ឬថែរក្សាហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ ឬគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ដើម្បីសិក្សាលក្ខណៈបច្ចេកទេស បន្ទាប់ពីបានទទួលការអនុញ្ញាតពីកម្មសិទ្ធិករ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

### មាត្រា ៣០.-

កម្មសិទ្ធិករដីឬអ្នកម្ចាស់ការត្រូវជូនដំណឹងនិងសុំកិច្ចសហការទៅក្រសួង ស្ថាប័ន និង/ឬអាជ្ញាធរមានសមត្ថកិច្ច និងប្រតិបត្តិករទូរគមនាគមន៍យ៉ាងតិចបំផុត ១៥(ដប់ប្រាំ)ថ្ងៃ មុននឹងបើកការដ្ឋានជីកលុងដីឯកជន ឬដីសាធារណៈ ដើម្បីជៀសវាងការបង្កព្យសនកម្មដល់ហេដ្ឋារចនាសម្ព័ន្ធ ឬបណ្តាញទូរគមនាគមន៍ ។

## ផ្នែកទី ២
## ការតភ្ជាប់ និងការប្រើប្រាស់បណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធរួម

### មាត្រា ៣១.-

ដើម្បីធានាប្រសិទ្ធភាពនៃការតភ្ជាប់ ការគ្រប់គ្រងបណ្តាញ និងការប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់នៅក្នុងវិស័យទូរគមនាគមន៍ ប្រតិបត្តិករទូរគមនាគមន៍ដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះត្រូវ ៖

ក- តភ្ជាប់បណ្តាញទូរគមនាគមន៍របស់ខ្លួនជាមួយបណ្តាញទូរគមនាគមន៍ដទៃ

ខ- អនុញ្ញាតឲ្យប្រតិបត្តិករទូរគមនាគមន៍ដទៃ មានលទ្ធភាពប្រើប្រាស់សេវាទូរគមនាគមន៍របស់ខ្លួនដូចដែល មានចែងក្នុងចំណុច (ក) នៃមាត្រានេះ ផ្អែកតាមសំណើដែលមានខ្លឹមសារ និងលក្ខខណ្ឌសមរម្យ ដោយគ្មានការរើសអើង និងស្របតាមលក្ខខណ្ឌនៃស្តង់ដាបច្ចេកទេស គុណភាពនៃសេវា គោលការណ៍ តម្លាភាព និងថ្លៃសមរម្យ

គ- ធានាការប្រើប្រាស់សេវាទូរគមនាគមន៍ដល់ប្រតិបត្តិករទូរគមនាគមន៍ដទៃ ដោយស្របតាមបញ្ញត្តិ ដែលមានចែងក្នុងចំណុច (ខ) នៃមាត្រានេះ

ឃ- ធ្វើកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ យោងតាមបទប្បញ្ញត្តិស្តីពីការតភ្ជាប់បណ្តាញរវាងប្រតិបត្តិករទូរគមនាគមន៍

ង- ដាក់សំណើស្តីពីការប្រើប្រាស់សេវាទូរគមនាគមន៍ ដូចដែលបានកំណត់ក្នុងចំណុច (ក) នៃមាត្រានេះ ទៅ **ន.ទ.ក.** ។ ក្នុងករណីដែលប្រតិបត្តិករទូរគមនាគមន៍ទាំងសងខាងពុំឯកភាពគ្នា **ន.ទ.ក.** មានសិទ្ធិសម្រេចចុងក្រោយអំពីខ្លឹមសារ និងលក្ខខណ្ឌទាំងឡាយណាដែលប្រតិបត្តិករទូរគមនាគមន៍ទាំងសងខាង ពុំឯកភាពគ្នា ផ្អែកតាមបទប្បញ្ញត្តិស្តីពីការកំណត់ខ្លឹមសារ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងដែលបានកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ច- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ **ន.ទ.ក.** អំពីការព្រមព្រៀងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីមានការឯកភាពរវាងប្រតិបត្តិករទូរគមនាគមន៍ដែលមានការពាក់ព័ន្ធ និង

ឆ- ផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរតាមការស្នើសុំរបស់ **ន.ទ.ក.** ទាក់ទងនឹងចំណុច (ក) នៃមាត្រានេះ និងព័ត៌មានផ្សេងទៀតដែល **ន.ទ.ក.** យល់ឃើញថាចាំបាច់ ។

## មាត្រា ៣២.-

ដើម្បីធានាប្រសិទ្ធភាពនៃការតភ្ជាប់ ការគ្រប់គ្រងបណ្តាញ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការប្រកួតប្រជែងស្របច្បាប់ និងស្មោះត្រង់នៅក្នុងវិស័យទូរគមនាគមន៍ ប្រតិបត្តិករទូរគមនាគមន៍ដូចដែលបានកំណត់ក្នុងចំណុច (ក) នៃមាត្រា ១៧ នៃច្បាប់នេះត្រូវ ៖

ក- ផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញនិងសេវាហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍ទៅប្រតិបត្តិករទូរគមនាគមន៍ដទៃទៀតដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះ

ខ- ផ្តល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ ឬគ្រឿងសម្ភារៈបរិក្ខាររួមគ្នាជាមួយប្រតិបត្តិករទូរគមនាគមន៍ដទៃទៀត ដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះ និង

គ- គោរពតាមបទប្បញ្ញត្តិ ដូចដែលមានចែងក្នុងមាត្រា ៣១ នៃច្បាប់នេះ ។

## មាត្រា ៣៣.-

**ន.ទ.ក.** ត្រូវបង្កើតនិងរក្សាបញ្ជីកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ និងកិច្ចព្រមព្រៀងគោលដែលប្រតិបត្តិករ ទូរគមនាគមន៍បានធ្វើស្របតាមទម្រង់បែបបទត្រឹមត្រូវ កំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

## មាត្រា ៣៤.-

**ក.ប.ទ.** ត្រូវដឹកនាំ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និង/ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធលើការរៀបចំប្លង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបណ្តាញរួមលើវិស័យទូរគមនាគមន៍ ដោយត្រូវបន្សុំជាមួយនឹងប្លង់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ការផ្គត់ផ្គង់ថាមពល ការបំភ្លឺសាធារណៈ ការផ្គត់ផ្គង់ទឹកស្អាត ការបង្ហូរកាកសំណល់រឹងនិងរាវ និងប្លង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ។

**ក.ប.ទ.** ត្រូវផ្សព្វផ្សាយបទប្បញ្ញត្តិស្តីពីការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបណ្តាញរួមពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទៅប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ។

## មាត្រា ៣៥.-

ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញរួមពាក់ព័ន្ធវិស័យគមនាគមន៍និងទូរគមនាគមន៍ ការផ្គត់ផ្គង់ថាមពល ការបំភ្លឺសាធារណៈ ការផ្គត់ផ្គង់ទឹកស្អាត ការបង្ហូរកាកសំណល់រឹងនិងរាវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ត្រូវធ្វើឡើងប្រកបដោយប្រសិទ្ធភាព សំដៅការពារសោភណភាព បរិស្ថាន និងសុខុមាលភាពសាធារណៈ និងត្រូវស្របតាមប្លង់នគរូបនីយកម្ម ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញរួមពាក់ព័ន្ធវិស័យគមនាគមន៍ និងទូរគមនាគមន៍ ការផ្គត់ផ្គង់ថាមពល ការបំភ្លឺសាធារណៈ ការផ្គត់ផ្គង់ទឹកស្អាត ការបង្ហូរកាកសំណល់រឹង និងរាវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៦.-**

**ន.ទ.ក**. ត្រូវរៀបចំលក្ខខណ្ឌបន្ថែមស្តីពីការតភ្ជាប់ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញជាតិ និងអន្តរជាតិ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរួម ស្របតាមការកំណត់របស់ច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

## ផ្នែកទី ៣
## ស្តង់ដា គុណភាពនៃសេវា និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍

**មាត្រា ៣៧.-**

**ក.ប.ទ**. ត្រូវរៀបចំលក្ខខណ្ឌកំណត់អំពីស្តង់ដាទូរគមនាគមន៍ជាតិ និងបទដ្ឋានស្តីពីឯកការូបនីយកម្មរវាងស្តង់ដាជាតិនិងអន្តរជាតិដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធបញ្ជូនស៊ីញ៉ាល់ បណ្តាញដែលអាចបំពេញ ប្រតិបត្តិការរវាងគ្នាទៅវិញទៅមក និងគុណភាពនៃសេវា ព្រមទាំងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ។ ប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ដែលស្ថិតនៅក្រោមស្តង់ដាទូរគមនាគមន៍ជាតិជាអាទិ៍ គ្រឿងសម្ភារៈបរិក្ខារហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍សម្រាប់អ្នកប្រើប្រាស់នឹងត្រូវកំណត់ក្នុងបទប្បញ្ញត្តិដោយឡែក ។

**ន.ទ.ក**.ត្រូវផ្សព្វផ្សាយជាសាធារណៈនូវស្តង់ដាទាំងអស់នៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ។

**មាត្រា ៣៨.-**

**ក.ប.ទ**. ត្រូវរៀបចំលក្ខខណ្ឌកំណត់អំពីស្តង់ដានៃការផ្តល់សេវាទូរគមនាគមន៍ប្រកបដោយគុណភាព ។

## ជំពូកទី ៦
## កាតព្វកិច្ចសេវាសកល

**មាត្រា ៣៩.-**

កម្មវិធីកាតព្វកិច្ចសេវាសកលមានគោលបំណងដូចតទៅ ៖

ក- លើកទឹកចិត្តការសាងសង់ និងការអភិវឌ្ឍបណ្តាញទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ខ- ជំរុញការផ្ដល់សេវាទូរគមនាគមន៍មូលដ្ឋាន សេវាទូរគមនាគមន៍តម្លៃបន្ថែម និងសេវាគ្រាអាសន្នឲ្យបានទូលំទូលាយដល់តំបន់ជនបទនិងដាច់ស្រយាល និង

គ- ជំរុញការកាត់បន្ថយគម្លាតឌីជីថល ដើម្បីចូលរួមអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ។

**មាត្រា ៤០.-**

យន្តការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល ត្រូវបានបង្កើតឡើងដោយផ្អែកលើគោលការណ៍តម្លាភាព អព្យាក្រឹត និងមិនរើសអើង ។ យន្តការនេះត្រូវកំណត់អំពីកាតព្វកិច្ចសេវាសកលដែលរួមមាន ៖

ក- ការបង្កើត និងការគ្រប់គ្រងមូលនិធិកាតព្វកិច្ចសេវាសកល

ខ- កាតព្វកិច្ច ឬលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាបណ្ណសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ

គ- លក្ខខណ្ឌសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដទៃទៀតដែលអាចប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកល

ឃ- នីតិវិធីនៃការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកល និង

ង- ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកាតព្វកិច្ចសេវាសកល ។

យន្តការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤១.-**

**ន.ទ.ក.** ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកលស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៤២.-**

មូលនិធិកាតព្វកិច្ចសេវាសកលអាចមានប្រភពមកពីថវិកាក្នុង ឬក្រៅប្រទេស ។

ប្រតិបត្តិករទូរគមនាគមន៍ត្រូវចូលរួមលើកកម្ពស់កម្មវិធីកាតព្វកិច្ចសេវាសកល ដោយត្រូវចូលរួមវិភាគទានរៀងរាល់ឆ្នាំចំនួន ២ (ពីរ) ភាគរយ នៃចំណូលដុល ទៅក្នុងមូលនិធិកាតព្វកិច្ចសេវាសកល ។

## ជំពូកទី ៧

## ការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

**មាត្រា ៤៣.-**

យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ ត្រូវកំណត់អំពី ៖

ក- ការបង្កើតនិងការគ្រប់គ្រងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

ខ- កាតព្វកិច្ច ឬលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាបណ្ណសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ដូចដែលមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

គ- លក្ខខណ្ឌសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលដទៃទៀតដែលអាចប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ

ឃ- នីតិវិធីនៃការប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាពនិងការស្រាវជ្រាវ និងការអភិវឌ្ឍ និង

ង- ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ ។

យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤៤.-**

**ក.ប.ទ.** ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការបង្កើត គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់ មូលនិធិនៃការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ ស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៤៥.-**

ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ត្រូវមានផែនការផ្ទាល់ខ្លួនដើម្បីកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ ស្របតាមការវិវត្តនៃបច្ចេកវិទ្យាថ្នាក់តំបន់ និងសកលលោក ។

**មាត្រា ៤៦.-**

មូលនិធិនៃការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ អាចមានប្រភពមកពីថវិកាក្នុង ឬក្រៅប្រទេស ។

ប្រតិបត្តិករទូរគមនាគមន៍ ត្រូវចូលរួមលើកកម្ពស់ការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ ដោយត្រូវបង់វិភាគទានរៀងរាល់ឆ្នាំ ចំនួន ១(មួយ) ភាគរយ នៃចំណូលដុល ទៅក្នុងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍ ។

## ជំពូកទី ៨
## ការគ្រប់គ្រងធនធានវិសាលគមន៍ប្រេកង់វិទ្យុ

**មាត្រា ៤៧.-**

វិសាលគមន៍ប្រេកង់វិទ្យុ គឺជាធនធានរបស់រដ្ឋដែលពុំត្រូវធ្វើជាកម្មវត្ថុនៃការលក់ទិញ ប៉ុន្តែអាចធ្វើជាកម្មវត្ថុនៃការជួល ឬការផ្តល់សិទ្ធិប្រើប្រាស់តាមរយៈការផ្តល់អាជ្ញាបណ្ណ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

វិសាលគមន៍ប្រេកង់វិទ្យុត្រូវស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ **ក.ប.ទ.**។ ការរៀបចំការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៤៨.-**

**គ.ប.ទ.** ត្រូវរៀបចំផែនការជាតិវិសាលគមន៍ប្រេកង់សវិទ្យុ ។ ផែនការជាតិវិសាលគមន៍ប្រេកង់សវិទ្យុត្រូវកំណត់នូវចំណុចមួយចំនួន ជាអាទិ៍ ៖

ក- ការរៀបចំតារាងបែងចែកប្រេកង់សវិទ្យុ

ខ- ការប្រើប្រាស់បន្ទារប្រេកង់សវិទ្យុ និងវិធានការទប់ស្កាត់ការឆ្លងរំខានការទទួលស៊ីញ៉ាល់ជាដើម

គ- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់បន្ទារប្រេកង់សវិទ្យុ ។

**ទ.ទ.គ.** ត្រូវចេញបទប្បញ្ញត្តិបន្ថែមពាក់ព័ន្ធនឹងការទូទាត់ប្រាក់កម្រៃពីអ្នកទទួលអាជ្ញាបណ្ណចំពោះការប្រើប្រាស់ ប្រេកង់សវិទ្យុ ស្របតាមប្រកាសរបស់ **គ.ប.ទ.** ។

បុគ្គលទាំងអស់ ត្រូវគោរពតាមផែនការជាតិវិសាលគមន៍ប្រេកង់សវិទ្យុ ។

# ជំពូកទី ៩
# ការកំណត់ប្លង់លេខទូរគមនាគមន៍ជាតិ និងអាសយដ្ឋានអេឡិកត្រូនិក

**មាត្រា ៤៩.-**

**គ.ប.ទ.** មានសមត្ថកិច្ចគ្រប់គ្រងប្លង់លេខទូរគមនាគមន៍ជាតិនិងអាសយដ្ឋានអេឡិកត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការគ្រប់គ្រង និងការកំណត់ប្លង់លេខទូរគមនាគមន៍ជាតិ ការបែងចែកក្បាលលេខទូរគមនាគមន៍ និងការផ្តល់លេខទូរគមនាគមន៍ រួមទាំងលេខទូរគមនាគមន៍សម្រាប់អង្គភាពសង្គ្រោះបន្ទាន់ ព្រមទាំងការគ្រប់គ្រងអាសយដ្ឋានអេឡិកត្រូនិក ត្រូវធ្វើឡើងស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៥០.-**

**ទ.ទ.គ.** ត្រូវណែនាំនិងផ្សព្វផ្សាយប្លង់លេខទូរគមនាគមន៍ជាតិ និងអាសយដ្ឋានអេឡិកត្រូនិកទាក់ទងនឹងចំណុចមួយចំនួនដូចខាងក្រោមនេះ ចំពោះប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ៖

ក- ការបែងចែកក្បាលលេខទូរគមនាគមន៍ លេខទូរគមនាគមន៍ និងអាសយដ្ឋានអេឡិកត្រូនិក

ខ- ការផ្ទេរ ការប្រគល់មកវិញ ឬការដកហូតក្បាលលេខទូរគមនាគមន៍ និងលេខទូរគមនាគមន៍ព្រមទាំងអាសយដ្ឋានអេឡិកត្រូនិក

គ- កម្រៃនៃការប្រើប្រាស់ក្បាលលេខទូរគមនាគមន៍ និងលេខទូរគមនាគមន៍ ព្រមទាំងអាសយដ្ឋានអេឡិកត្រូនិក និង

ឃ- ចំណុចផ្សេងទៀតដែលត្រូវកំណត់បន្ថែមដោយ **គ.ប.ទ.** ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

## មាត្រា ៥១.-

**ន.ទ.ក**. ត្រូវណែនាំនិងផ្សព្វផ្សាយលេខទូរគមនាគមន៍ និងអាសយដ្ឋានអេឡិកត្រូនិកទាក់ទងនឹងចំណុចមួយចំនួនដូចខាងក្រោមនេះដល់អ្នកប្រើប្រាស់ ៖

ក- ការប្រើប្រាស់ រក្សាទុក ផ្លាស់ប្តូរ ឬផ្ទេរលេខទូរគមនាគមន៍

ខ- ការប្រើប្រាស់ រក្សាទុក ផ្លាស់ប្តូរ ឬផ្ទេរអាសយដ្ឋានអេឡិកត្រូនិក និង

គ- ចំណុចផ្សេងទៀតដែលត្រូវកំណត់បន្ថែមដោយ **ក.ប.ទ**. ។

## មាត្រា ៥២.-

**ក.ប.ទ**. ត្រូវកំណត់អំពីការបែងចែក និងអនុញ្ញាតឲ្យផ្ទេរក្បាលលេខទូរគមនាគមន៍ លេខទូរគមនាគមន៍ និងអាសយដ្ឋានអេឡិកត្រូនិករវាងប្រតិបត្តិករទូរគមនាគមន៍ ដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះ ។ ការបែងចែកនិងការអនុញ្ញាតនេះ ត្រូវគោរពគោលការណ៍តម្លាភាពនិងពុំរើសអើង។

## មាត្រា ៥៣.-

**ក.ប.ទ**. ត្រូវបង្កើតនិងរក្សាប្លង់លេខទូរគមនាគមន៍ជាតិ ក្បាលលេខទូរគមនាគមន៍ និងអាសយដ្ឋានអេឡិកត្រូនិក និងបញ្ជីប្រតិបត្តិករទូរគមនាគមន៍ដូចដែលបានកំណត់ក្នុងមាត្រា ១៧ នៃច្បាប់នេះ។ ទម្រង់បែបបទនេះត្រូវកំណត់ ដោយប្រកាសរបស់ **ក.ប.ទ**. ។

**ន.ទ.ក**. ត្រូវផ្សព្វផ្សាយប្លង់លេខទូរគមនាគមន៍ជាតិ និងបញ្ជីដូចបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ជាសាធារណៈ ។

# ជំពូកទី ១០
# ថ្លៃសេវាទូរគមនាគមន៍ និងការប្រកួតប្រជែង

## មាត្រា ៥៤.-

**ក.ប.ទ**. មានសមត្ថកិច្ចកំណត់វិធានស្តីពីថ្លៃសេវាទូរគមនាគមន៍ ដើម្បីធានាការប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់ ។

## មាត្រា ៥៥.-

**ក.ប.ទ**. ត្រូវរៀបចំប្រកាសដើម្បីកំណត់វិធានស្តីពីថ្លៃសេវាទូរគមនាគមន៍ ដោយអនុលោមតាមចំណុចមួយ ចំនួនដូចតទៅ ៖

ក- គោលនយោបាយនិងបទប្បញ្ញត្តិនៃការប្រកួតប្រជែង ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀត

ខ- ថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុរបស់សវនកររឯករាជ្យដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងព័ត៌មានមិនមែនហិរញ្ញវត្ថុដែលត្រូវប្រគល់ដោយប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និង

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL

គ- ចំណុចផ្សេងទៀតដែលត្រូវកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៥៦.-**

**ន.ទ.ក**. មានសមត្ថកិច្ចត្រួតពិនិត្យនិងតាមដានថ្លៃសេវាទូរគមនាគមន៍ ។ **ន.ទ.ក**. ត្រូវផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តស្ដីពីថ្លៃសេវាទូរគមនាគមន៍ដែលមានខ្លឹមសារមួយចំនួនដូចខាងក្រោម ៖

ក- ថ្លៃសេវាទូរគមនាគមន៍រវាងអ្នកទទួលអាជ្ញាបណ្ណ

ខ- ថ្លៃសេវាទូរគមនាគមន៍រវាងអ្នកទទួលអាជ្ញាបណ្ណនិងអ្នកប្រើប្រាស់

គ- រូបមន្តគណនាថ្លៃដើមនៃសេវាទូរគមនាគមន៍ និងទម្រង់បែបបទនៃការប្រគល់ថ្លៃដើមរបស់សេវានេះ និង

ឃ- ទម្រង់បែបបទនៃការបញ្ចុះថ្លៃសេវាទូរគមនាគមន៍ដែលត្រូវគោរពគោលការណ៍តម្លាភាព ស្មើភាព និងសមរម្យ ។

**មាត្រា ៥៧.-**

**ក.ប.ទ**. មានសិទ្ធិសើរើលិខិតបទដ្ឋានគតិយុត្តស្ដីពីថ្លៃសេវាទូរគមនាគមន៍ ។

**មាត្រា ៥៨.-**

ប្រតិបត្តិករទូរគមនាគមន៍មិនត្រូវកំណត់ថ្លៃសេវាទូរគមនាគមន៍ទាបជាងថ្លៃដើម ដូចមានចែងក្នុងចំណុច (គ) មាត្រា ៥៦ នៃច្បាប់នេះទេ ។

ប្រតិបត្តិករទូរគមនាគមន៍ ត្រូវផ្ដល់សេវាគ្រាអាសន្នដោយពុំយកថ្លៃ ។

**ន.ទ.ក**. ត្រូវចាត់វិធានការបន្ថែមសមស្របដូចមានចែងក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ដើម្បីធានានូវការប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់ ។

**មាត្រា ៥៩.-**

ប្រតិបត្តិករទូរគមនាគមន៍ត្រូវ ៖

ក- ផ្សព្វផ្សាយជាសាធារណៈនូវតារាងថ្លៃសេវាទូរគមនាគមន៍ ស្របតាមការកំណត់នៅក្នុងចំណុច (ក) នៃ មាត្រា៥៦នៃច្បាប់នេះ និង

ខ- ផ្សព្វផ្សាយជាសាធារណៈនូវថ្លៃសេវាទូរគមនាគមន៍ រួមទាំងការផ្លាស់ប្ដូរ ឬការកែប្រែថ្លៃសេវានេះ ស្រប តាមការកំណត់នៅក្នុងចំណុច (ខ) នៃមាត្រា ៥៦ នៃច្បាប់នេះ ។

**មាត្រា ៦០.-**

**ន.ទ.ក**. មានសមត្ថកិច្ចត្រួតពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់ក្នុងទីផ្សារទូរគមនាគមន៍ ហើយត្រូវរាយការណ៍ជូន **ក.ប.ទ**. ដើម្បីរៀបចំបទប្បញ្ញត្តិ

បន្ថែម ។ ដើម្បីធានាការប្រកួត ប្រជែងស្របច្បាប់ និងស្មោះត្រង់ **ន.ទ.ក.** ត្រូវអនុវត្តលក្ខខណ្ឌមួយចំនួនជាអាទិ៍ ៖

ក- ជួយអ្នកប្រើប្រាស់ឲ្យទទួលសេវាក្នុងថ្លៃសមរម្យ មានគុណភាពល្អ និងមានជម្រើសច្រើន

ខ- គាំទ្រឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងអ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដោយស្មើភាព និងតម្លាភាព

គ- ការពារអ្នកទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ មិនឲ្យខូចផលប្រយោជន៍ដោយសារការប្រកួតប្រជែងមិនស្របច្បាប់និងមិនស្មោះត្រង់ និង

ឃ- លក្ខខណ្ឌនៃការប្រកួតប្រជែងផ្សេងទៀតដែលត្រូវកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## មាត្រា ៦១.-

គ្រប់ប្រតិបត្តិការទូរគមនាគមន៍ ត្រូវធ្វើឡើងដោយគោរពគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកបដោយប្រសិទ្ធភាព ។

ត្រូវបានហាមឃាត់សកម្មភាពដែលត្រូវបានប្រព្រឹត្តផ្ទុយនឹងគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកបដោយប្រសិទ្ធភាព ៖

ក- រាល់ការប្រមូលផ្តុំ ការព្រមព្រៀង ការមូលមតិ ដោយតុណ្ហីភាព ឬជាលាយលក្ខណ៍អក្សរលើការបំពេញ ប្រតិបត្តិការដែលមានចរិតរាំង រឹតបន្តឹង បង្ខូចដល់ការប្រកួតប្រជែងលើទីផ្សារ ប្រសិនបើកិច្ចទាំងនោះ ត្រូវបានធ្វើឡើងដើម្បី ៖

១) រាំង ឬកម្រិតសិទ្ធិលើការជ្រៀតចូលទីផ្សារទូរគមនាគមន៍ដោយប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើន

២) បង្កជាឧបសគ្គដល់ការកំណត់ថ្លៃដោយសេរីដែលជាកត្តានាំឲ្យមានការឡើង ឬចុះថ្លៃដែលបង្កប់ចរិត លក្ខណៈនិម្មិត

៣) កម្រិតសិទ្ធិមួយផ្នែក ឬទាំងស្រុងលើការគ្រប់គ្រងប្រតិបត្តិការទូរគមនាគមន៍ ការវិនិយោគ ឬការអភិវឌ្ឍ បច្ចេកវិទ្យា ឬ

៤) បែងចែកទីផ្សារទូរគមនាគមន៍ ឬប្រភពផ្គត់ផ្គង់ ។

ខ- រាល់ការរំលោភឧត្តមភាពទីផ្សារដែលមានចរិតលក្ខណៈដូចបានកំណត់ក្នុងចំណុច (ក) ដែលនាំឲ្យ ប៉ះពាល់ដល់ទីផ្សារ ឬផ្នែកមួយនៃទីផ្សារ ដោយប្រតិបត្តិករ ក្រុមប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ដែលអាចនាំឲ្យប៉ះពាល់ដល់ដំណើរការ ឬដល់ប្រព័ន្ធនៃការប្រកួតប្រជែង។ ការរំលោភនេះ អាចជាការបដិសេធលក់ ការលក់ដោយមានលក្ខខណ្ឌ ការលក់ដោយមានភាពរើសអើង ឬការលុបចោល កិច្ចសន្យាដោយហេតុថាភាគីម្ខាងទៀតមិនព្រមទទួលយកលក្ខខណ្ឌពាណិជ្ជកម្មដោយគ្មានហេតុផល ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

គ- រាល់ការរំលោភលើអនិស្សរភាពរបស់ប្រតិបត្តិករ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ណាមួយ ដែលមានចរិតលក្ខណៈ ដូចបានកំណត់ក្នុងចំណុច (ក) ដែលអាចនាំឲ្យប៉ះពាល់ដល់ដំណើរការ ឬដល់ប្រព័ន្ធនៃការប្រកួតប្រជែង ។ ការរំលោភនេះអាចជាការបដិសេធលក់ ការលក់ដោយមានលក្ខខណ្ឌ ឬការលក់ដោយមានភាពរើសអើង ។

ឃ- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នារវាងប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ដែលបង្កប់នូវចរិតលក្ខណៈ ដូចមានចែងក្នុងចំណុច (ក) ។

## មាត្រា ៦២.-

សកម្មភាពខាងក្រោមដែលបង្កប់នូវចរិតលក្ខណៈណាមួយ ដូចមានចែងក្នុងមាត្រា ៦១ កថាខណ្ឌទី ២ (ក) នៃច្បាប់នេះ ក៏ត្រូវបានចាត់ទុកជាអំពើរំលោភលើគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកប ដោយប្រសិទ្ធភាព ជាអាទិ៍ ៖

ក- ការព្រមព្រៀងគ្នាផ្ដល់សិទ្ធិផ្ដាច់មុខចំពោះប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើន ឬការបំពេញប្រតិបត្តិការទាំងឡាយណាដែលឈានទៅរកការទទួលសិទ្ធិផ្ដាច់មុខ

ខ- ការផ្ដល់ឧបត្ថម្ភធនតាមគ្រប់រូបភាពនិងទម្រង់ទាំងអស់ លើកលែងតែមានការអនុញ្ញាតដោយបទប្បញ្ញត្តិផ្សេងទៀត

គ- ការប្រើប្រាស់ព័ត៌មានសម្ងាត់ផ្នែកពាណិជ្ជកម្ម បច្ចេកទេស ហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់ប្រតិបត្តិករ ទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើនដោយប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើនផ្សេងទៀត ឬដោយបុគ្គលទាំងឡាយណាដែលមានប្រយោជន៍

ឃ- ការមិនផ្ដល់នូវព័ត៌មានបច្ចេកទេសពាក់ព័ន្ធគ្រឿងសម្ភារៈបរិក្ខារសំខាន់ៗ និងព័ត៌មានផ្នែកពាណិជ្ជកម្ម ដោយប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ជូនទៅប្រតិបត្តិករទូរគមនាគមន៍ដទៃ ឬបុគ្គលទាំងឡាយណាដែលមានប្រយោជន៍

ង- ការរើសអើង ឬបដិសេធពុំផ្ដល់សេវាដោយប្រតិបត្តិករទូរគមនាគមន៍ ដល់ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍មួយ ឬច្រើន ឬដៃគូពាណិជ្ជកម្មផ្សេងៗ ឬអ្នកប្រើប្រាស់ដោយ ពុំរាប់បញ្ចូលនូវគម្លាត ដែលបណ្ដាលមកពីបរិមាណនៃការផ្ដល់សេវា ទំហំនៃបណ្ដាញ ទីកន្លែងផ្ដល់សេវារយៈពេលនៃការផ្ដល់សេវា និងធាតុផ្សំផ្សេងទៀតកំណត់ដោយ **ន.ទ.ក.**

ច- ការផ្ដល់ជាកញ្ចប់នូវសេវា និង/ឬផលិតផល ឬការលក់ដោយមានលក្ខខណ្ឌដែលមានចរិតលក្ខណៈប្រកួតប្រជែងមិនស្របច្បាប់ ផ្អែកតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន និង

ច- សិទ្ធិបង្កើតសមាគម និងសហការរៀបចំក្រមសីលធម៌វិជ្ជាជីវៈ ផ្អែកតាមរដ្ឋធម្មនុញ្ញ និងបទប្បញ្ញត្តិផ្សេងទៀត និង

ឆ- សិទ្ធិទាំងឡាយដែលត្រូវកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៦៥.-**

អ្នកប្រើប្រាស់ មានសិទ្ធិមូលដ្ឋានដូចខាងក្រោម ៖

ក- សិទ្ធិទទួលសេវាទូរគមនាគមន៍ប្រកបដោយគុណភាព និងព័ត៌មានពាក់ព័ន្ធនឹងសេវានេះ

ខ- សិទ្ធិទទួលការការពារព័ត៌មានឯកជន សន្តិសុខ និងសុវត្ថិភាពនៃការប្រើប្រាស់សេវាទូរគមនាគមន៍ លើកលែងមានច្បាប់ពិសេសចែងផ្សេងពីនេះ

គ- សិទ្ធិចូលរួមពិគ្រោះយោបល់ពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ និងបទប្បញ្ញត្តិទាក់ទងនឹងការអភិវឌ្ឍ វិស័យទូរគមនាគមន៍

ឃ- សិទ្ធិសាកសួរព័ត៌មានចំពោះ **ន.ទ.ក.** អំពីបញ្ហាពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

ង- សិទ្ធិទទួលនូវយន្តការដោះស្រាយវិវាទរវាងអ្នកប្រើប្រាស់ និងប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ដែលត្រូវបានកំណត់ដោយច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

ច- សិទ្ធិពាក់ព័ន្ធនឹងការទទួលសំណងចំពោះព្យសនកម្ម ដែលបង្កដោយការបំពានកាតព្វកិច្ចនៃកិច្ចសន្យារបស់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍

ឆ- សិទ្ធិបង្កើតសមាគមអ្នកប្រើប្រាស់សេវាទូរគមនាគមន៍ផ្អែកតាមរដ្ឋធម្មនុញ្ញ និងបទប្បញ្ញត្តិផ្សេងទៀត និង

ជ- សិទ្ធិទាំងឡាយដែលត្រូវកំណត់ដោយបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ៦៦.-**

ការបង្កើត ការដំឡើង ការប្រើប្រាស់ ឬការកែប្រែហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញទូរគមនាគមន៍ ឬការបង្កើត ការដំឡើង ការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិស័យទូរគមនាគមន៍ ដែលបង្កការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងនាំឲ្យអន្តរាយដល់សន្តិសុខជាតិ ត្រូវហាមឃាត់ ។

ROYAUME DU CAMBODGE • SECRETARIAT ROYAL • MINISTERE DU PALAIS

# ជំពូកទី ១២
# ការដោះស្រាយវិវាទ

## មាត្រា ៦៧.-

ក្រៅពីករណីបទល្មើសព្រហ្មទណ្ឌ គ្រប់វិវាទដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ជាអាទិ៍ វិវាទរវាងប្រតិបត្តិករទូរគមនាគមន៍ និងប្រតិបត្តិករទូរគមនាគមន៍ និងរវាងប្រតិបត្តិករទូរគមនាគមន៍ និងអ្នកប្រើប្រាស់ភាគីវិវាទត្រូវដាក់សំណុំរឿងទៅ **ន.ទ.ក.** ដើម្បីធ្វើការផ្សះផ្សា ។

នីតិវិធីនៃការផ្សះផ្សាត្រូវកំណត់ដោយ **ក.ប.ទ.**។ កម្រៃសេវាសម្រាប់ការដោះស្រាយវិវាទត្រូវកំណត់ដោយប្រកាសរួមរវាង **ក.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## មាត្រា ៦៨.-

លទ្ធផលនៃការផ្សះផ្សា ត្រូវចុះក្នុងកំណត់ហេតុដែលធ្វើឡើងដោយ **ន.ទ.ក.** ។ កំណត់ហេតុនេះត្រូវចុះពីការយល់ព្រមសះជា ឬការមិនយល់ព្រមសះជារវាងភាគីវិវាទ និងត្រូវចុះហត្ថលេខាដោយ **ន.ទ.ក.** និងភាគីវិវាទទាំងអស់ រួចត្រូវចម្លងជូនគ្រប់ភាគីវិវាទ ។

ការព្រមព្រៀងដែលបានធ្វើឡើងនៅចំពោះមុខ **ន.ទ.ក.** មានអានុភាពអនុវត្តក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ចាប់ពីថ្ងៃទទួលបានកំណត់ហេតុសះជា ។

ក្នុងករណីពុំព្រមអនុវត្តតាមការព្រមព្រៀងដូចមានក្នុងកំណត់ហេតុសះជា ឬក្នុងករណីពុំមានការយល់ព្រមសះជា ភាគីវិវាទអាចបន្តនីតិវិធីទៅមជ្ឈត្តការ ឬប្ដឹងទៅតុលាការមានសមត្ថកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន ។

ដើម្បីទទួលបានគុណវុឌ្ឍិជាមជ្ឈត្តករក្នុងវិស័យទូរគមនាគមន៍ មជ្ឈត្តករក្នុងន័យនៃបទប្បញ្ញត្តិស្ដីពីមជ្ឈត្តការពាណិជ្ជកម្ម ត្រូវទទួលការបណ្ដុះបណ្ដាលបន្ថែមពី **ក.ប.ទ.** ។ លក្ខខណ្ឌនៃការបណ្ដុះបណ្ដាលនេះត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ។

បទប្បញ្ញត្តិនៃមាត្រានេះពុំអនុវត្តចំពោះចំណុច (ង) នៃមាត្រា ៣១ នៃច្បាប់នេះទេ ។

## មាត្រា ៦៩.-

បន្ថែមទៅលើវិធានការដែល **ក.ប.ទ.** ដាក់ឲ្យអនុវត្តនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ **ន.ទ.ក.** អាចចាត់វិធានការ ដូចខាងក្រោមក្នុងករណីប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬបទប្បញ្ញត្តិផ្សេងទៀត ៖

ក- ចេញលិខិតព្រមាន

ខ- ចេញបទបញ្ជាឲ្យជួសជុល ឬផ្ដល់សំណងព្យសនកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត

គ- ស្នើសុំឲ្យតុលាការមានសមត្ថកិច្ចចេញសេចក្ដីសម្រេចតម្រូវឲ្យអនុវត្តតាមបទប្បញ្ញត្តិជាធរមាន និងឲ្យជួសជុល ឬផ្ដល់សំណងព្យសនកម្ម

ROYAUME DU CAMBODGE · CABINET DU MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ឃ- ចាត់វិធានការដាក់ទណ្ឌកម្មរដ្ឋបាល ។ ទណ្ឌកម្មរដ្ឋបាលនិងនីតិវិធីត្រូវកំណត់បន្ថែមដោយប្រកាសរបស់ **ក.ប.ឆ.** ។

## ជំពូកទី ១៣
## អធិការកិច្ចទូរគមនាគមន៍

### មាត្រា ៧០.-

រដ្ឋមន្ត្រី **ក.ប.ឆ.** ត្រូវចាត់តាំងមន្ត្រីអធិការកិច្ចទូរគមនាគមន៍ ដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ ។

មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានភារកិច្ច និងសិទ្ធិដូចខាងក្រោម ៖

ក- ធ្វើអធិការកិច្ចបច្ចេកទេសលើគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទូរគមនាគមន៍ និងការផ្តល់សេវាទូរគមនាគមន៍

ខ- ស្រាវជ្រាវ អង្កេត តាមដាន ទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងវិស័យទូរគមនាគមន៍

គ- ដកយកសំណាកទិន្នន័យ និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យស្តង់ដា និងមុខងារគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និងការធ្វើវិភាគផ្ទៀងផ្ទាត់បរិមាណសេវាទូរគមនាគមន៍

ឃ- ចាប់យកវត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង និង

ង- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី **ក.ប.ឆ.** ។

### មាត្រា ៧១.-

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ដោយអនុវត្តឲ្យស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រី **ក.ប.ឆ.** ។

### មាត្រា ៧២.-

ក្នុងក្របខណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការពិនិត្យ និងការស៊ើបអង្កេតបទល្មើសដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសិទ្ធិអំណាចធ្វើការឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀត ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ក្នុងករណីចាំបាច់ដែល ត្រូវឃាត់ខ្លួនជនសង្ស័យ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវទទួលការអនុញ្ញាត និងត្រូវស្ថិតនៅក្រោមការដឹកនាំ សម្របសម្រួលដោយផ្ទាល់ពីព្រះរាជអាជ្ញា ។

មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសមត្ថកិច្ច អាចស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៧៣.-**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវមានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ។ នៅពេលប្រតិបត្តិការ អនុវត្តច្បាប់ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ត្រូវមានលិខិតបញ្ជាបេសកកម្ម ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៤.-**

នៅក្នុងដំណើរការអធិការកិច្ចវិស័យទូរគមនាគមន៍ ក្នុងករណីមានភស្តុតាងជាក់ស្តែង ឬលទ្ធផលវិភាគ ផ្ទៀងផ្ទាត់បញ្ជាក់ថាសេវានិងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ណាមួយ មានលក្ខណៈបច្ចេកទេសផ្ទុយពីស្តង់ដា ដែលត្រូវបានកំណត់នៅក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត នៅពេលស្នើសុំការចុះបញ្ជី ឬមានប្រតិបត្តិការណាមួយ បង្កប់នូវចរិតលក្ខណៈផ្ទុយពីគោលការណ៍នៃការប្រកួតប្រជែងស្របច្បាប់ ដែលបានកំណត់ក្នុងច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសមត្ថកិច្ចចាត់វិធានការផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សេវា ការផ្គត់ផ្គង់ ការចែកចាយគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និងប្រតិបត្តិការផ្សេងទៀតពាក់ព័ន្ធនឹងបទល្មើស ដើម្បីដោះស្រាយ តាមនីតិវិធី ។

**មាត្រា ៧៥.-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ អាចប្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៅ **ក.ប.ទ.** គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ។

រដ្ឋមន្ត្រី **ក.ប.ទ.** ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី **ក.ប.ទ.** ជននោះមានសិទ្ធិធ្វើបណ្តឹង ទៅយន្តការផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬទៅតុលាការតាមនីតិវិធី ។

**មាត្រា ៧៦.-**

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ ក្នុងករណីដែលវត្ថុតាងនៃបទល្មើសជាផលិតផលហាមឃាត់ ឬមានគ្រោះថ្នាក់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ មានសិទ្ធិស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើការបំផ្លាញចោល ដោយអនុលោមតាមនីតិវិធីជាធរមាន ។

ការចំណាយលើការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងនៅក្នុងដំណើរការ អនុវត្តច្បាប់នេះ គឺជាបន្ទុករបស់ម្ចាស់វត្ថុតាងនៃបទល្មើស ។ ករណីអត្តសញ្ញាណម្ចាស់វត្ថុតាងនៃបទល្មើសមិនត្រូវបាន ស្គាល់រាល់ការចំណាយជាបន្ទុករបស់រដ្ឋ ។

**មាត្រា ៧៧.-**

បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចទូរគមនាគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.** ។

## ជំពូកទី ១៤
## ទោសប្បញ្ញត្តិ

**មាត្រា ៧៨.-**

ក្រោយពេលផ្តល់អាជ្ញាបណ្ណក្រោមច្បាប់នេះ ប្រសិនបើពិនិត្យឃើញថាប្រតិបត្តិករទូរគមនាគមន៍ មិនអនុវត្តតាម លក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ ឬលក្ខខណ្ឌណាមួយដែលកំណត់ដោយច្បាប់នេះ ឬបទប្បញ្ញត្តិផ្សេងទៀត **និ.ទ.ក.** អាចចាត់វិធានការជាអាទិ៍ដូចខាងក្រោម ៖

ក- ដឹកនាំកែតម្រង់ប្រតិបត្តិករទូរគមនាគមន៍ឲ្យអនុវត្តតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម

ខ- ដាក់កំហិតលើអាជ្ញាបណ្ណ

គ- ព្យួរអាជ្ញាបណ្ណរហូតដល់ប្រតិបត្តិករទូរគមនាគមន៍គោរពពេញលេញតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែម ។

ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬបទប្បញ្ញត្តិផ្សេងទៀត **និ.ទ.ក.** អាចចាត់វិធានការជាអាទិ៍ដូចខាងក្រោម ៖

ក- ព្យួរបណ្តោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយកប្រតិបត្តិ សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់របស់ប្រតិបត្តិករទូរគមនាគមន៍

ខ- ជ្រើសរើសនិងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករទូរគមនាគមន៍ ។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ឲ្យទៅ **និ.ទ.ក.** តាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាជាមួយ **និ.ទ.ក.** ឬ

គ- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅរបស់ប្រតិបត្តិករទូរគមនាគមន៍ ទោះបីជាសកម្មភាពទាំងនោះបានធ្វើឡើងស្រប ឬមិនស្របតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណក៏ដោយ ។

**និ.ទ.ក.** អាចចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ លុះត្រាតែបានជូនដំណឹងជា លាយលក្ខណ៍អក្សរជាមុនដល់ប្រតិបត្តិករទូរគមនាគមន៍ អំពីមូលហេតុនៃការចាត់វិធានការនេះនិងបានផ្តល់ឱកាសឲ្យ ប្រតិបត្តិករទូរគមនាគមន៍ធ្វើការពន្យល់ ។

**មាត្រា ៧៩.-**

បទល្មើសក្នុងវិស័យទូរគមនាគមន៍ដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការដាក់ពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ **ក.ប.ទ.** ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការដាក់ពិន័យអន្តរកាណ៍ត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ទ.** ។

**មាត្រា ៨០.-**

ការបង្កើត ការដំឡើង ការប្រើប្រាស់ ឬការកែប្រែហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញទូរគមនាគមន៍ ឬការបង្កើត ការដំឡើង ការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិស័យទូរគមនាគមន៍ កាលបើអំពើនេះអាចនាំឲ្យអន្តរាយដល់សន្តិសុខជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៨១.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨០ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១៤០ ០០០ ០០០ (មួយរយសែសិបលាន) រៀល ទៅ ៣០០ ០០០ ០០០ (បីរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៨២.-**

ការបំផ្លាញ ឬការធ្វើឲ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញទូរគមនាគមន៍ ដោយចេតនា ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

អំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៖

- ពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ កាលបើអំពើនេះបង្កឲ្យមានរបួសដល់អ្នកដទៃ ។
- ពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះនាំឲ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ។
- ពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តឡើងជាក្រុមមានការចាត់តាំង ។
- ពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះបណ្តាលឲ្យអ្នកដទៃស្លាប់ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ៨៣.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨២ ខាងលើនេះ ត្រូវពិន័យជាប្រាក់

ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៤០០ ០០០ ០០០ (បួនរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៨៤.-**

ការបង្កើត ការដំឡើង ការប្រើប្រាស់ ឬការកែប្រែហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញទូរគមនាគមន៍ ឬគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ដើម្បីបង្កការកាត់ផ្តាច់ ការរំខាន ឬការជ្រៀតជ្រែកលើហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធទូរគមនាគមន៍ ឬបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៨៥.-**

ការបង្កើតប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលដំណើរការជាមួយបណ្តាញទូរគមនាគមន៍សម្រាប់ប្រើប្រាស់ក្នុងគោលបំណងគេចវេះពីការទូទាត់ប្រាក់ ឬកេងចំណេញលើបរិមាណនៃការផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៨៦.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨៤ និងមាត្រា ៨៥ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៨៧.-**

ការប្រើប្រាស់ ឬការអនុញ្ញាតឲ្យប្រើប្រាស់ដោយបន្លំនូវសេវាទូរគមនាគមន៍ ក្នុងគោលបំណងគេចវេះពីការទូទាត់ប្រាក់ ឬកេងចំណេញលើបរិមាណនៃការផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៨៨.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨៧ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៨៩.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ចំពោះ ៖

ក- ការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់នេះ ដោយគ្មានលិខិតអនុញ្ញាតពី **ន.ធ.ក.** ។

ខ- ការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ ដោយគ្មានវិញ្ញាបនបត្រពី **ន.ធ.ក.** ។

**មាត្រា ៩០.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៨៩ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩១.-**

ការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា១៧នៃច្បាប់នេះ ដោយគ្មានអាជ្ញាបណ្ណពី **ន.ធ.ក.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន)រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៩២.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩១ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៣.-**

អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល កាលបើការគំរាមកំហែងនេះធ្វើឡើង ម្តងហើយម្តងទៀត តាមគ្រប់មធ្យោបាយទូរគមនាគមន៍ ទោះបីជាបង្ហាញ ឬពុំបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនក្តី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

អំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៖

- ពី ៦ (ប្រាំមួយ) ខែ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល កាលបើអំពើនេះត្រូវបានធ្វើឡើងដោយមានបញ្ហាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ ។
- ពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល កាលបើអំពើនេះ ជាអំពើគំរាមកំហែងថានឹងសម្លាប់ ។
- ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល កាលបើអំពើនេះ ជាអំពើគំរាមកំហែងថានឹងសម្លាប់ ដោយមានបញ្ហាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ ។

**មាត្រា ៩៤.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៣ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៥.-**

អំពើគំរាមកំហែងថានឹងប្រព្រឹត្តការបំផ្លិចបំផ្លាញ ការធ្វើឲ្យទ្រុឌទ្រោម ឬការធ្វើឲ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់ជនដទៃ កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត តាមគ្រប់មធ្យោបាយទូរគមនាគមន៍ ទោះបីជាបង្ហាញ ឬពុំបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនក្តី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន)រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

អំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល កាលបើអំពើគំរាម កំហែងនេះមានភ្ជាប់នូវបញ្ហាឲ្យបំពេញ ឬមិនបំពេញកិច្ចអ្វីមួយ ។

**មាត្រា ៩៦.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៥ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា ៩៧.-**

ការលបស្តាប់ឬការលបថតការសន្ទនា ដោយការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ដោយបុគ្គលដែលពុំមែនជាភាគីនៃការសន្ទនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងទទួលពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។

បទប្បញ្ញត្តិកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តទេ ក្នុងករណីដែលការស្តាប់ ឬការថតការសន្ទនានោះ ធ្វើឡើងដោយមានការយល់ព្រមពីបុគ្គលដែលមានការពាក់ព័ន្ធ ឬដោយមានការអនុញ្ញាតពីអាជ្ញាធរ ជម្នាញរូប ។

ត្រូវផ្តន្ទាទោសដូចគ្នាចំពោះការផ្សព្វផ្សាយខ្លឹមសារនៃការសន្ទនា ដោយពុំបានទទួលសិទ្ធិស្របច្បាប់ពីភាគីនៃការសន្ទនា ឬពីអាជ្ញាធរជម្នាញរូប ឬពីបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ៩៨.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៧ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៩៩.-**

ការផលិត ការដំឡើង ឬការចែកចាយដោយគ្មានការអនុញ្ញាតពីអាជ្ញាធរជម្នាញរូបនូវកម្មវិធីសូហ្វវែរ ឬឧបករណ៍ស្តាប់ ឬថតការសន្ទនាដោយការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ១០០.-**

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៩៩ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមាន ចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ១០១.-**

ការយកអត្តសញ្ញាណតតិយជន ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ ក្នុងកាលៈទេសៈដែលនាំឲ្យមាន ឬដែលអាចនាំឲ្យមានការចោទប្រកាន់ខាងបទព្រហ្មទណ្ឌចំពោះតតិយជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

## មាត្រា ១០២.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយភ្ជាប់នូវលក្ខខណ្ឌកែតម្រូវសម្រាប់រយៈពេលកំណត់ណាមួយ ដោយ **គ.ធ.ភ.** ចំពោះប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ដែលធ្វើការប្រកួតប្រជែងមិនស្របច្បាប់ល្មើសនឹងកថាខណ្ឌទី ១ នៃមាត្រា ៥៨ មាត្រា ៦១ ឬមាត្រា ៦២ នៃច្បាប់នេះ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ។

## មាត្រា ១០៣.-

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១០២ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០(មួយពាន់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

## មាត្រា ១០៤.-

ជនណាដែលបានក្លែងបន្លំព័ត៌មានអំពីថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុ ឬព័ត៌មានពុំមែនហិរញ្ញវត្ថុ ហើយបានផ្ញើទៅ **គ.ធ.ភ.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ។

## មាត្រា ១០៥.-

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១០៤ ខាងលើនេះ ត្រូវពិន័យជាប្រាក់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ទៅ ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចដែលមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

## មាត្រា ១០៦.-

ចំពោះបទល្មើសប្រព្រឹត្តដោយរូបវន្តបុគ្គលដូចមានចែងក្នុងច្បាប់នេះ ទោសបន្ថែមមួយឬច្រើន ដែលមានចែង ក្នុងក្រមព្រហ្មទណ្ឌដូចខាងក្រោមនេះ អាចត្រូវបានប្រកាស ៖

១- ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណាដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេល ដែលប្រកបវិជ្ជាជីវៈនេះ ។

៣- ការហាមឃាត់ចំពោះការស្នាក់នៅ ។

៤- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស ។

៥- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៦- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៧- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៩- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១០- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

១១- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១២- ការបិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៣- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

## មាត្រា ១០៧.-

អំពើល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គល គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។

អង្គការ ឬអ្នកតំណាងរបស់នីតិបុគ្គល សំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមនីតិបុគ្គល ស្របតាមលក្ខន្តិកៈរបស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលនោះទេ ។

## មាត្រា ១០៨.-

មន្ត្រី **ក.ប.ទ.** និង **ន.ទ.ក.** ណាដែលរំលោភលើសមត្ថកិច្ចរបស់ខ្លួន ឬប្រើសិទ្ធិអំណាចរារាំងការអនុវត្តច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលតាមច្បាប់ជាធរមានដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ១០៩.-**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៨២ មាត្រា ៨៤ មាត្រា ៨៥ មាត្រា៨៧ មាត្រា ៩៩ មាត្រា ១០១ មាត្រា ១០២ និងមាត្រា ១០៤ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមបានសម្រេចដែរ ។

## ជំពូកទី ១៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១១០.-**

ក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ត្រូវបំពេញទម្រង់បែបបទថ្មីនៅ **ន.ទ.ក.** ដើម្បីសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណដែលនៅមានសុពលភាពក្រោយច្បាប់នេះចូលជាធរមាន ត្រូវអនុវត្តតាមលក្ខខណ្ឌស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងទៀត ។

**មាត្រា ១១១.-**

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា គឺជានិយ័តករទូរគមនាគមន៍កម្ពុជាបន្ទាប់ពីច្បាប់នេះចូលជាធរមាន ។ បញ្ញត្តិករ ទូរគមនាគមន៍កម្ពុជា ត្រូវបំពេញមុខងារ និងភារកិច្ចបន្តរហូតដល់អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនិយ័តករ ទូរគមនាគមន៍កម្ពុជា ចូលជាធរមាន ។

**មាត្រា ១១២.-**

លក្ខខណ្ឌដូចដែលមានចែងក្នុងបទប្បញ្ញត្តិនៃជំពូក ៦ និងជំពូក ៧ នៃច្បាប់នេះ នឹងត្រូវអនុវត្តក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

# ជំពូកទី ១៦
## អវសានប្បញ្ញត្តិ

**មាត្រា ១១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១៤.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៥

ចារស. ១៥១២.០០៤៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
**ហត្ថលេខា**
**ត្រាក់ សុខុន**

លេខ:១១៥៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីទូរគមនាគមន៍
# សទ្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ

- **កាតព្វកិច្ចសេវាសកល** សំដៅដល់កាតព្វកិច្ចរបស់ប្រតិបត្តិករទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការផ្តល់សេវាទូរគមនាគមន៍មូលដ្ឋាន និងសេវាតម្លៃបន្ថែមជូនដល់ប្រជាពលរដ្ឋទូទៅគ្រប់រូប ក្នុងតម្លៃសមរម្យ គុណភាពសេវាល្អ និងអាចប្រើប្រាស់បាននៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- **កម្មវិធីកាតព្វកិច្ចសេវាសកល** សំដៅដល់គោលនយោបាយឬផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង រៀបចំ និងអនុវត្តកាតព្វកិច្ចសេវាសកល ។
- **កម្មវិធីសូហ្វវែរ** សំដៅដល់កម្មវិធីកុំព្យូទ័រទាំងឡាយណាដែលរចនាឡើងក្នុងគោលបំណងសម្រួលដល់អ្នកប្រើប្រាស់ដើម្បីធ្វើអ្វីមួយនៅលើឬតាមរយៈកុំព្យូទ័រ កុំព្យូទ័របន្ទះ ទូរស័ព្ទវៃឆ្លាត ឬឧបករណ៍ បច្ចេកវិទ្យា ទាំងឡាយណាដែលត្រូវ ការការបញ្ចូលកម្មវិធី បែបខាងលើនេះ ។
- **ការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ** សំដៅដល់យន្តការកសាង បណ្តុះបណ្តាល និងពង្រឹង សមត្ថភាពវិជ្ជាជីវៈ ការស្រាវជ្រាវ និងការអភិវឌ្ឍក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។
- **ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ** សំដៅដល់ការតភ្ជាប់រវាងហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញរបស់ប្រតិបត្តិករទូរគមនាគមន៍មួយ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញរបស់ប្រតិបត្តិករទូរគមនាគមន៍មួយទៀត ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ឬអតិថិជននៃបណ្តាញផ្សេងគ្នាអាចភ្ជាប់ ការប្រាស្រ័យទាក់ទង ឬការសន្ទនាជាមួយគ្នាបានដោយរលូន ។
- **ការបោះពុម្ពផ្សាយសៀវភៅលេខទូរគមនាគមន៍** សំដៅដល់សកម្មភាពនៃការបោះពុម្ពផ្សាយសៀវភៅ អត្ថបទឬឯកសារលេខទូរគមនាគមន៍ ក្រោមទម្រង់ជាក្រដាស ឬអេឡិកត្រូនិក ក្នុងគោលបំណងធ្វើអាជីវកម្ម ឬពាណិជ្ជកិច្ច ។
- **កិច្ចព្រមព្រៀងគោល** សំដៅដល់លិខិតបទដ្ឋានគតិយុត្ត ឬបទប្បញ្ញត្តិដែលកំណត់អំពីខ្លឹមសារ និងលក្ខខណ្ឌ ស្តីពីការតភ្ជាប់និងលទ្ធភាពនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទូរគមនាគមន៍ ។
- **កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់** សំដៅដល់កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញ ។
- **ក្បាលលេខទូរគមនាគមន៍** សំដៅដល់លេខ លេខកូដ និងសញ្ញាពិសេសទូរគមនាគមន៍ ដែលត្រូវបាន បែងចែកឲ្យទៅប្រតិបត្តិករទូរគមនាគមន៍យកទៅប្រើប្រាស់ ក្នុងការផ្តល់សេវា ទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

LE MINISTRE DU PALAIS ROYAL · ROYAUME DU CAMBODGE

- **គម្លាតឌីជីថល** សំដៅដល់គម្លាតនៃការទទួលបានសេវានិងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅតាមទីក្រុង ទីប្រជុំជន និងជនបទ។
- **គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍** សំដៅដល់សម្ភារៈបរិក្ខារ ឧបករណ៍ គ្រឿងបង្គុំ ឬឋបនីយកណ្ដ ដែលត្រូវបានផលិត និង/ឬនាំចេញឬនាំចូលយកមកប្រើប្រាស់ក្នុងប្រព័ន្ធទូរគមនាគមន៍ និង បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។
- **ថ្លៃដើមនៃសេវាទូរគមនាគមន៍** សំដៅដល់ថ្លៃដើមនៃសេវាទូរគមនាគមន៍ដែលប្រតិបត្តិករ ទូរគមនាគមន៍ត្រូវ ផ្ដល់ជូន **និ.ទ.ក.** ក្នុងពេលកំណត់មួយជាក់លាក់សម្រាប់ធ្វើជាមូលដ្ឋាន ដើម្បី ត្រួតពិនិត្យនិងតាមដានអំពីនីត្យានុកូលភាពនិងភាពស្មោះត្រង់នៃការប្រកួតប្រជែង ។ រូបមន្ត កំណត់ថ្លៃដើមនេះ ត្រូវកំណត់ដោយ **ក.ប.ទ.** តាមសំណើរបស់ **និ.ទ.ក.** ។
- **ថ្លៃសេវាទូរគមនាគមន៍** សំដៅដល់ថ្លៃសេវាទូរគមនាគមន៍ទាំងឡាយណាដែលត្រូវបានកំណត់ ដោយប្រតិបត្តិករទូរគមនាគមន៍ ជូនដល់អ្នកប្រើប្រាស់ ។
- **ទិន្នន័យសេវាទូរគមនាគមន៍និងព័ត៌មានវិទ្យា** សំដៅដល់ទិន្នន័យទាំងឡាយពាក់ព័ន្ធនឹងប្រតិបត្តិការ ទូរគមនាគមន៍ ដែលត្រូវបានផ្ដល់តាមរយៈការតភ្ជាប់បណ្ដាញផ្ទាល់ ឬតាមមធ្យោបាយ បច្ចេកទេស សមស្របផ្សេងទៀតជាមួយ ប្រតិបត្តិករឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ។
- **ទីផ្សារទូរគមនាគមន៍** សំដៅដល់ទីកន្លែងសម្រាប់ធ្វើពាណិជ្ជកិច្ចវិស័យទូរគមនាគមន៍ ។
- **ទម្រង់ទាំងអស់** សំដៅដល់ទម្រង់ទាំងឡាយដែលត្រូវបានកំណត់ក្នុងបទប្បញ្ញត្តិស្ដីពីការប្រកួត ប្រជែង ។
- **ទូរគមនាគមន៍** សំដៅដល់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងការបញ្ជូននិងទទួលស៊ីញ៉ាល់ ទិន្នន័យ សំឡេង រូបភាព ឬប្រភេទព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលក្រោម ទម្រង់អេឡិក ត្រូម៉ាញ៉េទិក អគ្គិសនី វិទ្យុ ពន្លឺ ឬទម្រង់ដទៃទៀត ។
- **ធនធានវិសាលគមន៍ហ្វ្រេកង់សវិទ្យុ** សំដៅដល់ធនធាននៃថាមពលអេឡិកត្រូម៉ាញ៉េទិកទាំងមូល ដែលត្រូវបានផ្សាយនិងត្រូវបានកំណត់ជាហ្វ្រេកង់ស៍ ឬជំហានរលកអាកាស ។
- **ហ្វ្រេកង់សវិទ្យុ** សំដៅដល់អត្រាលំយោលនៃរលកអាកាសវិទ្យុ ក្នុងចិរវេលាកំណត់មួយ ។
- **និយ័តករទូរគមនាគមន៍កម្ពុជា** សំដៅដល់និយ័តករទូរគមនាគមន៍ដែលត្រូវបានបង្កើតដោយ ច្បាប់នេះ ។
- **បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល ។
- **បុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលកំពុងធ្វើ ពាណិជ្ជកិច្ច ក្នុងវិស័យទូរគមនាគមន៍ ដោយមិនរាប់បញ្ចូលនូវប្រតិបត្តិករទូរគមនាគមន៍ ។
- **បណ្ដាញរួម** សំដៅដល់បណ្ដាញទាំងឡាយណាដែលត្រូវបានប្រើប្រាស់ដោយប្រតិបត្តិករ ទូរគមនាគមន៍ពីរ ឬច្រើន ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- **ប្រតិបត្តិករទូរគមនាគមន៍** សំដៅដល់នីតិបុគ្គលដែលទទួលអាជ្ញាបណ្ណធ្វើប្រតិបត្តិការទូរគមនាគមន៍ទាំងអស់ នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។
- **ប្រតិបត្តិការទូរគមនាគមន៍** សំដៅដល់រាល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងការបញ្ជូននិងទទួលស៊ីញ៉ាល់ ទិន្នន័យ សំឡេង រូបភាព ឬប្រភេទព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលក្រោមទម្រង់អេឡិកត្រូម៉ាញ៉េទិក អគ្គិសនី វិទ្យុ ពន្លឺ ឬទម្រង់ដទៃទៀត ។
- **ប្លង់លេខទូរគមនាគមន៍ជាតិ** សំដៅដល់ប្លង់ដែលត្រូវបានរៀបចំ ដើម្បីគ្រប់គ្រង និងកំណត់អំពីលេខ លេខកូដ និងសញ្ញាសម្គាល់ពិសេសទូរគមនាគមន៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- **ប្លង់វិសាលគមន៍ហ្វ្រេកង់សវិទ្យុជាតិ** សំដៅដល់ប្លង់ដែលកំណត់ បែងចែក និងប្រើប្រាស់ធនធានវិសាលគមន៍ វិទ្យុជាតិប្រកបដោយប្រសិទ្ធភាព ស្របតាមបទដ្ឋាន ឬស្តង់ដា ក្នុងតំបន់ និងអន្តរជាតិ ។
- **មជ្ឈត្តការមានសមត្ថកិច្ច** សំដៅដល់ការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ដែលក្នុងនោះ មជ្ឈត្តករ ទទួលបានការបណ្តុះបណ្តាលក្នុងវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងទទួលបានគុណវុឌ្ឍិពី **ន.ប.ទ.** ។
- **មូលនិធិនៃកាតព្វកិច្ចសេវាសកល** សំដៅដល់សំណុំនៃថវិកាទាំងឡាយដែលប្រើប្រាស់ដើម្បីទ្រទ្រង់និងអនុវត្ត កម្មវិធីកាតព្វកិច្ចសេវាសកល ។
- **មូលនិធិនៃការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ** សំដៅដល់សំណុំនៃថវិកាទាំងឡាយដែល ប្រើប្រាស់ដើម្បីទ្រទ្រង់ និងលើកកម្ពស់ដល់ការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍ ក្នុងវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។
- **លេខទូរគមនាគមន៍** សំដៅដល់លេខ លេខកូដ និងសញ្ញាសម្គាល់ពិសេសទូរគមនាគមន៍ ។
- **វិស័យសន្តិសុខនិងការពារជាតិ** ក្នុងន័យនៃមាត្រា ៣ នៃច្បាប់នេះ សំដៅដល់ប្រតិបត្តិការទូរគមនាគមន៍ដែលត្រូវបានប្រើប្រាស់សម្រាប់វិស័យសន្តិសុខនិងការពារជាតិ ។
- **សេវាគ្រាអាសន្ន** សំដៅដល់សេវាទូរគមនាគមន៍ដែលត្រូវបានប្រើប្រាស់ក្នុងគ្រាអាសន្ន ដោយសាធារណជន និងត្រូវបានផ្តល់ទៅដល់អង្គភាពនគរបាលជាតិ អង្គភាពពន្លត់អគ្គិភ័យ និងអង្គភាពសេវារថយន្តសង្គ្រោះបន្ទាន់ ។
- **សេវាទូរគមនាគមន៍** សំដៅដល់សេវាទាំងឡាយណាដែលត្រូវបានផ្តល់សម្រាប់ការបញ្ជូន និងការទទួលសំឡេង ទិន្នន័យ ស៊ីញ៉ាល់ រូបភាព ឬប្រភេទព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលក្រោមទម្រង់អេឡិកត្រូម៉ាញ៉េទិក អគ្គិសនី វិទ្យុ ពន្លឺ ឬទម្រង់ដទៃទៀត ។ សេវាទូរគមនាគមន៍ក្នុងន័យនៃច្បាប់នេះ រួមបញ្ចូលទាំងសេវាទូរគមនាគមន៍មូលដ្ឋាន និងសេវាទូរគមនាគមន៍បន្ថែម ។

- **សេវាទូរគមនាគមន៍មូលដ្ឋាន** សំដៅដល់សេវាទូរគមនាគមន៍ទាំងឡាយណា ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ធ្វើការប្រាស្រ័យទាក់ទង ឬសន្ទនាជាមួយគ្នាដោយផ្ទាល់ក្នុងពេលវេលាពិតប្រាកដស្របតាមការកំណត់របស់អង្គការ ពាណិជ្ជកម្មពិភពលោក ។
- **សេវាទូរគមនាគមន៍តម្លៃបន្ថែម** សំដៅដល់សេវាទាំងឡាយណាដែលប្រតិបត្តិករ ទូរគមនាគមន៍ផ្តល់នូវតម្លៃបន្ថែម លើសេវាទូរគមនាគមន៍មូលដ្ឋានតាមរយៈការធ្វើឲ្យប្រសើរឡើងនូវទម្រង់ ឬមាតិកាព័ត៌មាន ឬផ្តល់ការរក្សាទុក និងទាញយកព័ត៌មាន ។
- **សេវាទូរគមនាគមន៍សាធារណៈ** សំដៅដល់សេវាទូរគមនាគមន៍សម្រាប់បម្រើដល់សាធារណជន ។
- **ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ** សំដៅដល់បង្គុំនៃបរិក្ខារទូរគមនាគមន៍ដូចជា ឋបមាណីទូរគមនាគមន៍បណ្តាញបញ្ជូនស៊ីញ៉ាល់ និងសំណង់ទូរគមនាគមន៍ពាក់ព័ន្ធ ។
- **ហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទូរគមនាគមន៍** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធទាំងឡាយណាដែលត្រូវបានប្រើប្រាស់សម្រាប់ទ្រទ្រង់ និងគាំពារហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ។
- **ហេដ្ឋារចនាសម្ព័ន្ធរួបរួម** សំដៅទៅលើសំណុំហេដ្ឋារចនាសម្ព័ន្ធ ដែលរាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធ ប្រើប្រាស់សម្រាប់បម្រើវិស័យគមនាគមន៍ ថាមពល ទឹកស្អាត កាកសំណល់រឹងនិងរាវ វិស័យទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ។
- **អនិស្សរភាព** ភាពដែលចំណុះគេ ។
- **អាសយដ្ឋានអេឡិកត្រូនិក** សំដៅដល់លេខឬអក្សរអេឡិកត្រូនិក សម្រាប់កំណត់អំពី អាសយដ្ឋាន ឬអត្តសញ្ញាណនៃបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ។
- **ឧបសម្ព័ន្ធនៃថវិកា** សំដៅដល់ថវិកាដែលត្រូវបានរៀបចំក្នុងតារាងដោយឡែកពីថវិការបស់ក្រសួង ស្ថាប័ន អាណាព្យាបាលបច្ចេកទេស ដោយត្រូវគោរពតាមទម្រង់គំរូ ដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។ ថវិកានេះត្រូវភ្ជាប់ជាមួយថវិការបស់ក្រសួង ស្ថាប័ន អាណាព្យាបាលបច្ចេកទេស និងត្រូវបម្រើឲ្យគោលបំណងនៃគោលនយោបាយរបស់ក្រសួង ស្ថាប័នអាណាព្យាបាល បច្ចេកទេស ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......សហវ.......

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលតម្លៃសេវាសាធារណៈលើប្រភេទសេវាចំនួនបី នៃកម្រងសេវាសាធារណៈដែលជាឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម÷

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវាចាស់ | តម្លៃសេវាកែសម្រួលថ្មី |
|---|---|---|---|
| | I. **អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម** | | |
| | **នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម** | | |
| | ក. ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | | |
| ១ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ១ ៦៨០ ០០០៛ | ១ ០១០ ០០០៛ |
| ២ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលត្រូវចុះបញ្ជី | ៣០០ ០០០៛ | ១៨០ ០០០៛ |
| ១៤ | ឆ. ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស | ៤០ ០០០៛ | ២៥ ០០០៛ |

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ តទៅ។

ថ្ងៃសុក្រ ៤កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៤/១១៣៦

## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃ
## ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤/

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលសរសេរជាអក្សរកាត់ថា **ក.ជ.វ.ប.** ដើម្បីជំរុញកិច្ចអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅកម្ពុជាឲ្យមានការរីកចម្រើនដូចបណ្ដាប្រទេសជឿនលឿនក្នុងតំបន់និងក្នុងសកលលោក។

## ជំពូកទី២
## សមាសភាពរបស់ ក.ជ.វ.ប.

**មាត្រា២ .-**

**ក.ជ.វ.ប.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងផែនការ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |

- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប សមាជិក
- អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល១រូប សមាជិក
- អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា១រូប សមាជិក
- អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ១រូប សមាជិក
- តំណាងស្ថាប័នសិក្សាស្រាវជ្រាវ១ចំនួន សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា១រូប សមាជិក
- អគ្គលេខាធិការ **ក.ជ.វ.ប.** លេខាធិការ។

សមាសភាពជាក់ស្តែងរបស់ **ក.ជ.វ.ប.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ ក.ជ.វ.ប.

**មាត្រា៣ .-**

**ក.ជ.វ.ប** មានតួនាទីភារកិច្ចដូចខាងក្រោម៖

- រៀបចំតាក់តែងសេចក្តីព្រាងនិងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- កំណត់តម្រូវការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលស្នើឡើងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជនដែលពាក់ព័ន្ធ
- ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មាធិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជា ឬរបស់អគ្គលេខាធិការដ្ឋាន **ក.ជ.វ.ប**
- កៀរគរជំនួយនិងការគាំទ្រធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដែលជាតម្រូវការនៃស្ថាប័នឬអង្គភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- កំណត់អាទិភាពការងារវិទ្យាសាស្ត្រនិងបច្ចេកវិទ្យារយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- បញ្ជ្រាបការយល់ដឹង ការឲ្យតម្លៃ និងការចែករំលែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ជំរុញនិងលើកទឹកចិត្ត ការចូលរួម ការលើកស្ទួយក្នុងកិច្ចអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាពីគ្រប់មជ្ឈដ្ឋាន/.

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប សមាជិក
- អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល១រូប សមាជិក
- អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា១រូប សមាជិក
- អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ១រូប សមាជិក
- តំណាងស្ថាប័នសិក្សាស្រាវជ្រាវ១ចំនួន សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា១រូប សមាជិក
- អគ្គលេខាធិការ **គ.ជ.វ.ប.** លេខាធិការ។

សមាសភាពជាក់ស្តែងរបស់ **គ.ជ.វ.ប.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ គ.ជ.វ.ប.

**មាត្រា៣ ._**

**គ.ជ.វ.ប** មានតួនាទីភារកិច្ចដូចខាងក្រោម៖

- រៀបចំតាក់តែងសេចក្តីព្រាងនិងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- កំណត់តម្រូវការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលស្នើឡើងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជនដែលពាក់ព័ន្ធ
- ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មាធិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជា ឬរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប**
- កៀរគរជំនួយនិងការគាំទ្រធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដែលជាតម្រូវការនៃស្ថាប័នឬអង្គភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- កំណត់អាទិភាពការងារវិទ្យាសាស្ត្រនិងបច្ចេកវិទ្យារយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- បញ្ជ្រាបការយល់ដឹង ការឲ្យតម្លៃ និងការចែករំលែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ជំរុញនិងលើកទឹកចិត្ត ការចូលរួម ការលើកស្ទួយក្នុងកិច្ចអភិវឌ្ឍ វិទ្យាសាស្ត្រ និងបច្ចេក-វិទ្យាពីគ្រប់មជ្ឈដ្ឋាន/.



- កំណត់គោលការណ៍អភិវឌ្ឍធនធានមនុស្សដើម្បីបម្រើតម្រូវការនិងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងគម្រោងកម្មវិធីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ហើយធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ជ.វ.ប.

**មាត្រា៤.-**

**ក.ជ.វ.ប.** ត្រូវធ្វើការប្រជុំយ៉ាងតិច២(ពីរ)ដងក្នុង១(មួយ)ឆ្នាំ។ ក្នុងករណីចាំបាច់ **ក.ជ.វ.ប.** អាចប្រជុំជាវិសាមញ្ញបាន។

សមាជិក **ក.ជ.វ.ប.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានអចិន្ត្រៃយ៍ឬអនុប្រធានដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

ប្រធាន **ក.ជ.វ.ប.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកឯកទេសដែលពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជន ចូលរួមផ្តល់យោបល់ក្នុងករណីចាំបាច់។

**ក.ជ.វ.ប.** អាចមានទីប្រឹក្សាបច្ចេកទេសនិងអ្នកជំនាញការជាតិ អន្តរជាតិមួយចំនួនតាមការចាំបាច់។

**ក.ជ.វ.ប.** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែកដែលមានគំរូភ្ជាប់ជាឧបសម្ព័ន្ធ។

បែបបទនៃការប្រជុំរបស់ **ក.ជ.វ.ប.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា៥.-**

**ក.ជ.វ.ប.** ត្រូវមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ដែលមានទីតាំងនៅក្រសួងផែនការ។

អគ្គលេខាធិការដ្ឋាននៃ **ក.ជ.វ.ប.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **ក.ជ.វ.ប.** ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**មាត្រា៦ ..**

ត្រូវបានបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជាចំណុះឲ្យ **គ.ជ.ទ.ប.** ដើម្បីជួយការងារបច្ចេកទេស។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា៧ ..**

ការចំណាយសម្រាប់ដំណើរការរបស់ **គ.ជ.ទ.ប.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងផែនការ។

**គ.ជ.ទ.ប.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៨ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ ..**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ២០១៤

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

នស.រកត.០៩១៤.១១៥៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ១១៦៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ឧបសម្ព័ន្ធ

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៤

## ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៨៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងសម្រួល និងបង្កបរិយាកាសល្អដល់ការបង្កើតអាជីវកម្មតាមរយៈការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីចូលរួមចំណែកលើកកម្ពស់បរិយាកាសធុរកិច្ចឱ្យប្រសើរឡើង និងទាក់ទាញការវិនិយោគ នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់នីតិវិធី លក្ខខណ្ឌតម្រូវ និងការអនុញ្ញាតដល់ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដែលក្នុងនោះមាន÷

- ការចុះបញ្ជីពាណិជ្ជកម្ម ដោយក្រសួងពាណិជ្ជកម្ម
- ការចុះបញ្ជីពន្ធដារ ដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ការពិនិត្យនិងទទួលសេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## នីតិវិធីនៃការចុះបញ្ជីអាជីវកម្ម និង ការពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាន និងឯកសារភ្ជាប់

**មាត្រា ៥.-**

បុគ្គលស្នើសុំ ត្រូវបំពេញព័ត៌មាននិងបញ្ចូលឯកសារភ្ជាប់តាមលក្ខខណ្ឌតម្រូវទាំងអស់ ក្នុងទម្រង់អេឡិចត្រូនិក ដែលកំណត់ក្នុងគេហទំព័រចុះបញ្ជី https://www.registrationservices.gov.kh។

បុគ្គលស្នើសុំ អាចផ្ទេរសិទ្ធិឱ្យអ្នកតំណាងចុះបញ្ជី ដើម្បីធ្វើការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះក្នុងនាមបុគ្គលស្នើសុំ ដោយមានភ្ជាប់មកជាមួយនូវឯកសារផ្ទេរសិទ្ធិ ឬ/និង ឯកសារពាក់ព័ន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៦.-**

ព័ត៌មាននិងឯកសារភ្ជាប់ស្នើសុំចុះបញ្ជីអាជីវកម្ម ដែលបានបំពេញដោយបុគ្គលស្នើសុំ សម្រាប់តម្កល់តាមក្រសួង-ស្ថាប័នមានសមត្ថកិច្ចជាទម្រង់អេឡិចត្រូនិក ត្រូវបញ្ជូនដល់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ តាមរយៈថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (Cambodia Data Exchange - CamDX) សម្រាប់ជាកម្មវត្ថុនៃការពិនិត្យ និងសម្រេចផ្ដល់ការអនុញ្ញាតការចុះបញ្ជីអាជីវកម្ម។

ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃព័ត៌មាននិងឯកសារភ្ជាប់ តាមសមត្ថកិច្ចពាក់ព័ន្ធរបស់ក្រសួង-ស្ថាប័ននីមួយៗ ក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ដោយអនុលោមតាមអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីព័ត៌មាន និងឯកសារភ្ជាប់មិនត្រឹមត្រូវ ឬ/និងមិនគ្រប់គ្រាន់ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវជូនដំណឹងដល់បុគ្គលស្នើសុំ ដើម្បីធ្វើការកែតម្រូវ ឬបំពេញបន្ថែម។ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្តល់វិញ្ញាបនបត្រឬលិខិតបញ្ជាក់ ក្នុងរយៈពេលដូចមានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ដោយគិតចាប់ពីថ្ងៃដែលបុគ្គលស្នើសុំបានកែតម្រូវ ឬបំពេញបន្ថែម។

**មាត្រា ៧.-**

កម្រៃសេវាពាក់ព័ន្ធនឹងការចុះបញ្ជីអាជីវកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ កម្រៃសេវានេះ មិនត្រូវបានប្រគល់ជូនបុគ្គលស្នើសុំឡើយ ទោះបីជាមានការបដិសេធលើការស្នើសុំក៏ដោយ។

## ជំពូកទី៣
## ការផ្តល់ ព្យួរ និងដកហូតវិញ្ញាបនបត្រ និងលិខិតបញ្ជាក់ របស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច តាមរយៈគេហទំព័រចុះបញ្ជី

### ផ្នែកទី១
### ការផ្តល់វិញ្ញាបនបត្រ និងលិខិតបញ្ជាក់

**មាត្រា ៨.-**

ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យស្នើសុំ ក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលត្រូវបានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ និងត្រូវផ្តល់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ត្រូវចេញជាទម្រង់ឌីជីថល ដែលអាចបោះពុម្ពបាន សម្រាប់ប្រើប្រាស់ជាផ្លូវការ តាមរយៈគេហទំព័រចុះបញ្ជី។

**មាត្រា ៩.-**

ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមានការឯកភាពលើការចុះបញ្ជីពាណិជ្ជកម្មដោយក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវលើព័ត៌មាននិងឯកសារភ្ជាប់ និងត្រូវផ្តល់ការចុះបញ្ជីពន្ធដារតាមទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជី សម្រាប់ប្រើប្រាស់ជាផ្លូវការ រួមមាន ប័ណ្ណពន្ធប៉ាតង់ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ និងលិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :......៤.៣០/២០......ក.ប/ប្រ.ក.ន.ល

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ៣៣៥សហវ-ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងដាក់ឱ្យដំណើរការការផ្តល់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និង



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

គណនេយ្យភាព ព្រមទាំងស្របតាមសំណើរបស់វិស័យឯកជននៅក្នុងក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យដំណើរការសេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ចំពោះសេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ថ្នាក់កណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នូវសេវាសាធារណៈ ដូចខាងក្រោម៖

- សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ https://lacms.mlvt.gov.kh
- សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ https://tvcms.mlvt.gov.kh
- សម្រាប់សេវាសាធារណៈពាក់ព័ន្ធជនបរទេស https://fwcms.mlvt.gov.kh

ដោយឡែក ចំពោះសេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពច្រកចេញ-ចូលតែមួយរាជធានី ខេត្ត នឹងត្រូវឱ្យដាក់ដំណើរការ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ តទៅ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ប្រធានអង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ២ កើត ខែ មុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- អង្គការវិជ្ជាជីវៈគ្រប់ជាន់ថ្នាក់
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៣.ជី..សហវ.....ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ. បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញលិខិតជូនដំណឹងលេខ១៣៣ សជណ.អវ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសរួមលេខ០៩ សកអ/៩៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៤ របស់អតីតក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងក្រសួងសុខាភិបាល ស្តីពីការពិនិត្យកាយសម្បទាសម្រាប់ជនកម្ពុជា និងជនបរទេស ដែលមកប្រកបមុខរបរនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសរួមលេខ៣៣០ ស.ក.ប.យ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០០ របស់អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និង ក្រសួងសុខាភិបាល ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស
- បានឃើញប្រកាសរួមលេខ១៣៩ សកបយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ របស់អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល ស្តីពីលក្ខខណ្ឌ និងបេសកកម្ម សេវាពេទ្យសហគ្រាស
- យោងលទ្ធផលកិច្ចប្រជុំរបស់ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈនៃក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .–**

អនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .–**

សេវាសាធារណៈដែលផ្តល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសអន្តរក្រសួងនេះ។



14 [illegible]

**ប្រការ៣ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសអន្តរក្រសួង និងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ព្រមទាំងនីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដាសេវា ឬមានការយកកម្រៃលើសការកំណត់ ឬការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទសារអេឡិចត្រូនិក ដែលផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬអង្គភាពប្រឆាំងអំពើពុករលួយផងដែរ។ ក្នុងករណីមានបណ្តឹងតវ៉ា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវពិនិត្យលទ្ធភាពដោះស្រាយឱ្យបានឆាប់ ឬដោះស្រាយក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបណ្តឹងតវ៉ាពីសាមីជន។

**ប្រការ៤ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនឹងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពង្រឹង និងពង្រីកប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online System) សម្រាប់ការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

**ប្រការ៥ .-**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

ការកែសម្រួលភារកិច្ចលើការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជ្រាបជាព័ត៌មាន និងតាមដានការអនុវត្ត។

**ប្រការ៧ .-**

រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំដាច់ដោយឡែកពីគ្នា ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ យោងតាមភារកិច្ចប្រមូលចំណូលរៀងៗខ្លួន ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

នៅពេលអនុវត្តចំណូល រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៨ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៩ .-**

កម្រងសេវាសាធារណៈ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ អាចកែប្រែបានតាមការចាំបាច់តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ១០ .-**

ប្រកាសអន្តរក្រសួងលេខ៧១៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសអន្តរក្រសួងនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២០ តទៅ។

ថ្ងៃ............ ខែ............ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២០-៥២៩-ឥស.ស.ណ

ថ្ងៃ សុក្រ ៤ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០២០

**ជម្រាបមក**
**លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ** ៖ សេចក្ដីជូនដំណឹងអំពីយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**យោង** ៖
- អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃពុធ ០៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្ដីពី ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង
- លិខិតលេខ ៦០៣៨ សហវ.គសហ ចុះថ្ងៃពុធ ៣រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា ឲ្យបានជ្រាបថា បច្ចុប្បន្ន ធុរជនត្រូវប្រើប្រាស់វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ដើម្បីអាចបង្កើតគណនីនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ យោងតាមអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃពុធ ០៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្ដីពី ការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការចុះបញ្ជីអាជីវកម្មយន្តការថ្មីត្រូវធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរួមមួយ ដែលត្រូវបានប្រកាសដាក់ឲ្យដំណើរការជាផ្លូវការនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ហើយវិញ្ញាបនបត្រ ឬ/និងលិខិតបញ្ជាក់ផ្សេងៗ ត្រូវចេញជាទម្រង់ឌីជីថល ដែលធុរជនអាចបោះពុម្ព (Print) ដោយខ្លួនឯង និងយកទៅប្រើប្រាស់ជាផ្លូវការបាន ដោយមិនបាច់តម្រូវឲ្យយកឯកសារដែលមានត្រាច្បាប់ដើមដូចមុនទៀតទេ។ វិញ្ញាបនបត្រ ឬ/និងលិខិតបញ្ជាក់ផ្សេងៗក្នុងទម្រង់ឌីជីថល អាចបញ្ជាក់ពីភាពត្រឹមត្រូវបានតាមរយៈលេខសម្គាល់សហគ្រាស ដែលអាចផ្ទៀងផ្ទាត់បានលើគេហទំព័រចុះបញ្ជីពាណិជ្ជកម្ម។

អាស្រ័យហេតុនេះ គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវចាប់ផ្ដើមទទួលយកឯកសារដែលបោះពុម្ព (Print) ចេញពីឯកសារទម្រង់ឌីជីថល ស្របតាមយន្តការថ្មីនៃការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ចូលរួមសហការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ។

**ក.ឧ. ទេសាភិបាល**
**អគ្គនាយកត្រួតពិនិត្យ**

**រ័ត្ន សុវណ្ណនរៈ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គស្នងការដ្ឋាននគរបាលជាតិ**
លេខ: ០១១ ឥលន

# សេចក្តីណែនាំ
## ស្តីពី
## ការអនុញ្ញាតឲ្យប្រើប្រាស់ផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ
( E-Crime2020 )

ក្នុងគោលបំណងធានាបាននិរន្តរភាព និងសន្តិសុខទិន្នន័យបទល្មើសព្រហ្មទណ្ឌស្ថិតនៅក្នុងនិយាមបណ្ណសារដ្ឋានស្របតាមបច្ចេកវិទ្យាព័ត៌មានវិទ្យា អគ្គស្នងការដ្ឋាននគរបាលជាតិបានឯកភាពជាគោលការណ៍អនុញ្ញាតឲ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ (E-Crime2020) **ចាប់ពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០២១ នេះតទៅ។**

ដើម្បីទាញយកទិន្នន័យបទល្មើសព្រហ្មទណ្ឌចេញពី Database យកទៅប្រើប្រាស់ផ្លូវការក្នុងការវិភាគវាយតម្លៃអំពីស្ថានភាពបទល្មើសតាមភូមិសាស្ត្រ តាមកាលកំណត់ ព្រមជាមួយនឹងការគ្រប់គ្រងសាវតារជាតិជនសង្ស័យ ជនរងគ្រោះ ប្រវត្តិនៃការអនុវត្តទោសរបស់ជនល្មើស ក៏ដូចជាការអនុវត្តដីកាបង្គាប់ប្រកបដោយប្រសិទ្ធភាព ជាពិសេសការទាញយកទិន្នន័យទាំងនោះបានគ្រប់កាលៈទេសៈ អគ្គស្នងការដ្ឋាននគរបាលជាតិសូមធ្វើការណែនាំដល់នាយកដ្ឋាន-អង្គភាពជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដូចខាងក្រោម៖

១-ត្រូវបានកំណត់ជាគោលការណ៍សម្រាប់រយៈពេល នៃការបញ្ចូលទិន្នន័យបទល្មើសទៅក្នុងប្រព័ន្ធ អំឡុងពេល **៤៨ម៉ោង** បន្ទាប់ពីបទល្មើសបានកើតឡើង និងកំណត់ឲ្យកត់ត្រាទិន្នន័យដីកាបង្គាប់ **ចាប់ពីឆ្នាំ ២០០០** រហូតមកដល់បច្ចុប្បន្ន ព្រមទាំងត្រូវធ្វើបច្ចុប្បន្នភាពទិន្នន័យជាប្រចាំ។

២-ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវធានានិរន្តរភាពធនធានមន្ត្រី និងការបំពាក់ឧបករណ៍សម្ភារៈបច្ចេកទេស រួមទាំងការផ្គត់ផ្គង់អ៊ីនធឺណែតសម្រាប់ផែនសេនាធិការ ឬក្រុមមន្ត្រីមានសមត្ថកិច្ចបញ្ចូលទិន្នន័យបទល្មើសរក្សាទុកក្នុងទិន្នដ្ឋាន។

៣-នាយកដ្ឋានសរុប-ផែនការ និងនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ត្រូវពង្រឹងកិច្ចសហការក្នុងការតាមដានត្រួតពិនិត្យទិន្នន័យបទល្មើសព្រហ្មទណ្ឌ ដែលមន្ត្រីជំនាញ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្តបានកត់ត្រាបញ្ចូលរក្សាទុកក្នុងទិន្នដ្ឋាន និងណែនាំឲ្យបញ្ចូលទិន្នន័យបានត្រឹមត្រូវតាមគោលការណ៍កំណត់។

៤-ផែនព្រហ្មទណ្ឌ និងផែនសេនាធិការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវសហការក្នុងការផ្តល់ឯកសារ ព័ត៌មាន រូបថត ពាក់ព័ន្ធករណីបទល្មើសតាមទម្រង់ឯកភាពគ្នា ដើម្បីធ្វើជាមូលដ្ឋានក្នុងការបញ្ចូលទិន្នន័យរក្សាទុកក្នុងទិន្នដ្ឋានឲ្យបានទាន់ពេលវេលា។ ក្នុងករណីដែលស្នងការដ្ឋាននគរបាលរាជធានី-ខេត្តពុំមានរូបថតជនសង្ស័យ ឬជនរងគ្រោះ សូមស្នើកិច្ចសហការពីនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ដើម្បីដោះស្រាយផ្តល់ជូន។

៥-បន្ទាប់ពីទិន្នន័យបទល្មើសដែលត្រូវបានកត់ត្រារក្សាទុកក្នុងទិន្នផ្ទានរួចហើយ ក្នុងអំឡុងពេល **៤៨ម៉ោង** មន្ត្រីជំនាញកត់ត្រាអាចកែតម្រូវទិន្នន័យបានគ្រប់ចំណុចនៅក្នុងប្រព័ន្ធ ប៉ុន្តែបន្ទាប់ពី**៤៨ម៉ោង** ប្រព័ន្ធពុំអនុញ្ញាតឲ្យមន្ត្រីជំនាញកត់ត្រានៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត កែតម្រូវកំណត់ត្រាបទល្មើសបានឡើយ។ លើកលែងតែស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើសំណើជាផ្លូវការមក **ប្រធាននាយកដ្ឋានសរុប-ផែនការ** ពិនិត្យសម្រេច និងអនុញ្ញាតឲ្យក្រុមការងារបច្ចេកទេសកែតម្រូវជូន។

៦-ក្នុងករណីដំណើរការប្រតិបត្តិការប្រព័ន្ធមានភាពរអាក់រអួល សូមមន្ត្រីជំនាញកត់ត្រាទំនាក់ទំនងមកមន្ត្រីជំនាញបច្ចេកទេសព័ត៌មានវិទ្យានៃអគ្គស្នងការដ្ឋាននគរបាលជាតិ រៀងរាល់ម៉ោងធ្វើការតាមរយៈលេខទូរស័ព្ទដែលបានផ្តល់ជូនក្នុងប្រព័ន្ធ ឬ ក្នុងគ្រុប Telegram ។

៧-ដើម្បីពង្រឹងការសម្ងាត់ផ្ទៃក្នុង និងចៀសវាងទិន្នន័យបទល្មើសបែកធ្លាយចេញទៅក្រៅអង្គភាព ផែនសេនាធិការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវធ្វើបច្ចុប្បន្នភាពមន្ត្រីមានសមត្ថកិច្ចប្រើប្រាស់ប្រព័ន្ធ ក្នុងករណីមានការផ្លាស់ប្តូរ ផ្ទេរចេញ ឬមានបទបញ្ជាពីថ្នាក់ដឹកនាំអង្គភាព សូមជូនដំណឹងបន្ទាន់មកប្រធាននាយកដ្ឋានសរុប-ផែនការ ដើម្បីពិនិត្យលុបគណនីនោះចេញពីប្រព័ន្ធ។

៨-ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវប្រកាសផ្សព្វផ្សាយអំពីការប្រើប្រាស់ផ្លូវការនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យបទល្មើសព្រហ្មទណ្ឌ (E-Crime2020) និងណែនាំលើកកម្ពស់ស្មារតីទទួលខុសត្រូវក្នុងការអនុវត្តភារកិច្ចរបស់ក្រុមការងារបញ្ចូលទិន្នន័យ ឲ្យខិតខំប្រមូលទិន្នន័យបទល្មើសដែលបានកើតឡើងក្នុងដែនសមត្ថកិច្ចរាជធានី-ខេត្តនីមួយៗ យកមកបញ្ចូលរក្សាទុកក្នុងទិន្នផ្ទានតាមគោលការណ៍កំណត់។

ទទួលបានសេចក្តីណែនាំនេះ ស្នើ**ប្រធាននាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** ចាត់តាំងអនុវត្តប្រកបដោយប្រសិទ្ធភាព ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ......... ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០២១
**អគ្គស្នងការនគរបាលជាតិ**

នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន

ចម្លងជូន
-ឯកឧត្តម លោកជំទាវ អគ្គស្នងការរង
"ដើម្បីជូនជ្រាប"
-ប្រធាននាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ
-ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
"ដើម្បីចាត់តាំងអនុវត្ត"
-ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៣១៤០......អពដ

ថ្ងៃព្រហស្បតិ៍ ០៧កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

# សេចក្ដីណែនាំ
## ស្ដីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tax on Income -ToI E-Filing)

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងលោក-លោកស្រីជាប្រធានសមាគមនិងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងបរទេសទាំងអស់ ឱ្យបានជ្រាបថា កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវសេចក្ដីណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មីសម្រាប់អ្នកជាប់ពន្ធ សម្រាប់ដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែ។ បន្ថែមលើការអនុវត្តតាមសេចក្ដីណែនាំខាងលើ និងស្របតាមយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ និងគោលការណ៍កំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានអភិវឌ្ឍរួចរាល់នូវប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ដើម្បីសម្រួលដល់ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដើម្បីពង្រឹងសេវាផ្នែកចាត់ចែងលិខិតប្រកាសពន្ធជូនអ្នកជាប់ពន្ធឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ស័ក្ដិសិទ្ធិភាព ធានាបាននូវតម្លាភាព ភាពងាយស្រួល ឆាប់រហ័ស ចំណេញពេលវេលា និងភាពជឿទុកចិត្តក្នុងការផ្ដល់សេវាជូនដល់អ្នកជាប់ពន្ធ។

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ចាប់ពីខែមីនា ឆ្នាំ២០២១ នេះតទៅ ដោយត្រូវអនុវត្តតាមបែបបទនិងនីតិវិធី ដូចខាងក្រោម÷

### ១. សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ÷

អ្នកជាប់ពន្ធមធ្យមនិងធំទាំងអស់ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ក្នុងរយៈពេល ៣ ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ។

#### ១.១ ការចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ ToI E-Filing

អ្នកប្រើប្រាស់ដែលមានគណនី និងធ្លាប់ប្រើប្រាស់ប្រព័ន្ធ E-Filing ដើម្បីបង់ពន្ធប្រចាំខែរួចហើយ មិនតម្រូវឱ្យចុះឈ្មោះប្រើប្រាស់ឡើងវិញទេ ដោយគ្រាន់តែចូលប្រើប្រាស់គណនីដែលមានស្រាប់ ដូចធ្លាប់ចូលប្រើប្រាស់ប្រព័ន្ធ E-Filing ប្រចាំខែនេះ។ ដោយឡែក ចំពោះអ្នកប្រើប្រាស់ទាំងឡាយណាដែលពុំទាន់មានគណនី ត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ដោយត្រូវចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន https://www.tax.gov.kh ដើម្បីចុះឈ្មោះបង្កើតគណនី (User Account) សម្រាប់ប្រើប្រាស់ប្រព័ន្ធ ដោយត្រូវវាយបញ្ចូលព័ត៌មានដូចខាងក្រោម÷


អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

- ព័ត៌មានបុគ្គលរបស់អ្នកប្រើប្រាស់
- លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកប្រើប្រាស់
- លេខសម្គាល់ការចុះបញ្ជីព័ត៌មានបុគ្គល (TID) ប្រសិនបើមាន
- ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ រួមមាន អ្នកជាប់ពន្ធ, អ្នកតំណាងក្រុមហ៊ុន, ឬភ្នាក់ងារសេវាកម្មពន្ធដារ (និងត្រូវបំពេញលេខអាជ្ញាប័ណ្ណ សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ) និង
- លេខទូរស័ព្ទ និងអ៊ីម៉ែលដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទឬអ៊ីម៉ែលត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

## ១.២ នីតិវិធីលម្អិតក្នុងការប្រើប្រាស់ប្រព័ន្ធ ToI E-Filing

បន្ទាប់ពីបានចុះឈ្មោះបង្កើតគណនី (User Account) សម្រាប់ប្រើប្រាស់ហើយ ឬមានគណនីដែលបានបង្កើតរួចស្រាប់ អ្នកប្រើប្រាស់អាចចូលក្នុងប្រព័ន្ធ គ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) បានដោយត្រូវអនុវត្តតាមនីតិវិធីលម្អិត ដូចខាងក្រោម÷

- ចូលទៅគេហទំព័រដែលមានអាសយដ្ឋាន https://www.tax.gov.kh ដោយប្រើប្រាស់គណនីដែលបានបង្កើតរួច ដោយត្រូវជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing)
- បន្ទាប់មក បង្កើតពាក្យស្នើសុំប្រកាសពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដើម្បីបញ្ចូលព័ត៌មានសហគ្រាសដែលត្រូវប្រកាសដូចខាងក្រោម÷
  - លេខអត្តសញ្ញាណកម្មសារពើពន្ធ (VATIN)
  - លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration Identification Card) នៅលើប័ណ្ណប្លាស្ទិកដែលអគ្គនាយកដ្ឋានពន្ធដារផ្តល់ជូនលោក-លោកស្រី
  - លេខទូរស័ព្ទដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទត្រូវបានផ្លាស់ប្តូរ លោក-លោកស្រីត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។ អគ្គនាយកដ្ឋានពន្ធដារនឹងមិនទទួលខុសត្រូវចំពោះការបញ្ចូលព័ត៌មានលេខទូរស័ព្ទខុសរបស់អ្នកប្រើប្រាស់ឡើយ ហើយករណីបញ្ចូលខុស អ្នកប្រើប្រាស់នឹងមិនអាចចូលប្រើប្រាស់ប្រព័ន្ធបានឡើយ
- បញ្ចូលព័ត៌មាននៃប្រតិបត្តិការរបស់សហគ្រាសជាបន្តបន្ទាប់តាមវិញ្ញាសដែលមានក្នុងប្រព័ន្ធ តាមចំណុចលម្អិតនីមួយៗពីទំព័រទី១ ដល់ទំព័រទី១៦ (ដូចមានក្នុងឧបសម្ព័ន្ធ TOI 01)
- ផ្ទៀងផ្ទាត់ទិន្នន័យ និងចុចប៊ូតុងបង្កើតពាក្យស្នើសុំប្រកាសពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ រួចចុចបញ្ជូន (Submit)
- ក្នុងការបង់ប្រាក់ពន្ធ អ្នកជាប់ពន្ធអាចមានជម្រើសដូចខាងក្រោម÷
  - ក្នុងករណីអ្នកជាប់ពន្ធបង់ប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅធនាគារ អ្នកជាប់ពន្ធត្រូវបោះពុម្ពពាក្យស្នើសុំប្រកាសពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (ដូចមានក្នុងឧបសម្ព័ន្ធ TOI 01-A) ដើម្បីទៅបង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារជាដៃគូដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ
  - ក្នុងករណីអ្នកជាប់ពន្ធបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) អ្នកជាប់ពន្ធអាចជ្រើសរើសគណនីធនាគារជាដៃគូដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ របស់លោក-លោកស្រី (ដូចមានក្នុងឧបសម្ព័ន្ធ TOI 01-C) និងបង់ពន្ធ ហើយបោះពុម្ពបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ (ដូចមានក្នុងឧបសម្ព័ន្ធ TOI 01-B)

- អ្នកជាប់ពន្ធពុំចាំបាច់យកលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ និងពាក្យស្នើសុំបង់ប្រាក់ពន្ធមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ ដោយគ្រាន់តែបោះពុម្ពលិខិតបញ្ជាក់ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំចំនួន ១៦ ទំព័រ និងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ ដើម្បីទុកជាឯកសារ និងត្រូវរក្សាទុកឯកសារនានាដែលពាក់ព័ន្ធនឹងការដាក់លិខិតប្រកាសនេះ ដើម្បីបង្ហាញជូនរដ្ឋបាលសារពើពន្ធនៅពេលដែលត្រូវបានស្នើសុំត្រួតពិនិត្យ ឬធ្វើសវនកម្មពន្ធដារ។

## ២. សម្រាប់អ្នកជាប់ពន្ធតូច÷

អ្នកជាប់ពន្ធតូចអាចដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) ក្នុងរយៈពេល ៣ ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ។ ក្នុងករណី អ្នកជាប់ពន្ធតូចមិនទាន់អាចបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលតាមកម្មវិធីនេះបាន អាចបំពេញលិខិតប្រកាសពន្ធដោយដៃនិងដាក់លិខិតប្រកាសពន្ធនៅរដ្ឋបាលសារពើពន្ធបាន។

### ២.១ ការទាញយក និងចូលប្រើប្រាស់កម្មវិធី

អ្នកប្រើប្រាស់ដែលមានគណនី និងធ្លាប់ប្រើប្រាស់កម្មវិធីខាងលើ ដើម្បីបង់ពន្ធប្រចាំខែរួចហើយ មិនតម្រូវឱ្យចុះឈ្មោះប្រើប្រាស់ឡើងវិញទេ ដោយគ្រាន់តែចូលប្រើប្រាស់គណនីដែលមានស្រាប់ ដូចធ្លាប់ចូលប្រើប្រាស់កម្មវិធីនេះ។ ដោយឡែក ចំពោះអ្នកប្រើប្រាស់ទាំងឡាយណាដែលពុំទាន់មានគណនី ត្រូវចុះឈ្មោះប្រើប្រាស់ដោយចូលទៅទាញយកកម្មវិធីបានតាម App Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ iOS) ឬទាញយកពី Play Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ Android) ដោយស្វែងរកពាក្យ **GDT Tax Prefiling App** និងត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម÷

- ព័ត៌មានបុគ្គលរបស់អ្នកប្រើប្រាស់
- លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកប្រើប្រាស់
- លេខសម្គាល់ការចុះបញ្ជីព័ត៌មានបុគ្គល (TID) ប្រសិនបើមាន
- ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ រួមមាន អ្នកជាប់ពន្ធ, អ្នកតំណាងក្រុមហ៊ុន, ឬភ្នាក់ងារសេវាកម្មពន្ធដារ (និងត្រូវបំពេញលេខអាជ្ញាប័ណ្ណ សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ) និង
- លេខទូរស័ព្ទ និងអ៊ីម៉ែលដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទនិងអ៊ីម៉ែលត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

### ២.២ នីតិវិធីលម្អិតក្នុងការប្រើប្រាស់កម្មវិធី

ក្នុងការប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefilling App) អ្នកប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីលម្អិតដូចតទៅ÷

- ចូលទៅកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច ដោយប្រើប្រាស់គណនីដែលបានបង្កើតរួច
- បន្ទាប់មក ចុចប៊ូតុង បន្ថែមសហគ្រាសថ្មី ដើម្បីបញ្ចូលព័ត៌មានសហគ្រាសដែលត្រូវប្រកាសដូចខាងក្រោម÷
    - លេខអត្តសញ្ញាណកម្មសារពើពន្ធ (BIN)
    - លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration Identification Card) នៅលើប័ណ្ណប្លាស្ទិកដែលអគ្គនាយកដ្ឋានពន្ធដារផ្តល់ជូនលោក-លោកស្រី
    - លេខទូរស័ព្ទរបស់ម្ចាស់ភាគហ៊ុនដែលឈរឈ្មោះនៅលើប័ណ្ណពន្ធប៉ាតង់និងបានផ្តល់នៅពេលចុះបញ្ជីពន្ធដារនិងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទត្រូវបានផ្លាស់ប្តូរ លោក-លោកស្រីត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។ អគ្គនាយកដ្ឋានពន្ធដារនឹងមិនទទួលខុសត្រូវចំពោះការបញ្ចូលព័ត៌មានលេខទូរស័ព្ទខុសរបស់អ្នកប្រើប្រាស់ឡើយ ហើយករណីបញ្ចូលខុស អ្នកប្រើប្រាស់នឹងមិនអាចចូលប្រើប្រាស់កម្មវិធីបានឡើយ

- ជ្រើសរើសជម្រើសគ្រប់គ្រងការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ
- បញ្ចូលព័ត៌មាននៃប្រតិបត្តិការរបស់សហគ្រាសជាបន្តបន្ទាប់តាមរំហូរដែលមានក្នុងកម្មវិធី
- ផ្ទៀងផ្ទាត់ទិន្នន័យ និងចុចប៊ូតុងបង្កើតលេខកូដសម្រាប់បង់ពន្ធប្រចាំឆ្នាំ
- ក្នុងការបង់ប្រាក់ពន្ធ លោក-លោកស្រីអាចបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) ដោយចុចប៊ូតុងបង់ប្រាក់ រួចជ្រើសរើសធនាគារដើម្បីធ្វើប្រតិបត្តិការបង់ពន្ធ។ ពេលលោក-លោកស្រីបង់ពន្ធជោគជ័យ កម្មវិធីនឹងផ្ញើបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធទៅសារអេឡិចត្រូនិកដែលលោក-លោកស្រីប្រើនៅពេលចុះឈ្មោះបង្កើតគណនី
- លោក-លោកស្រីក៏អាចបង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារជាដៃគូដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អ្នកជាប់ពន្ធដែលប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefilling App) ពុំចាំបាច់យកលិខិតប្រកាសមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ។

**៣. ការបំពេញលិខិតប្រកាសពន្ធដោយដៃ៖**

អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច ដែលមិនទាន់អាចប្រើប្រាស់ប្រព័ន្ធនេះបាន អាចស្នើសុំមករដ្ឋបាលសារពើពន្ធ ដើម្បីបំពេញលិខិតប្រកាសពន្ធដោយដៃនិងដាក់លិខិតប្រកាសពន្ធនៅរដ្ឋបាលសារពើពន្ធជាបណ្ដោះអាសន្នបាន។ អ្នកជាប់ពន្ធដែលស្នើសុំបំពេញលិខិតប្រកាសពន្ធដោយដៃ អាចបញ្ជូនលិខិតប្រកាសពន្ធនិងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធមករដ្ឋបាលសារពើពន្ធ តាមរយៈប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ (E-Uploader) ដោយអនុវត្តតាមនីតិវិធីដូចមានចែងក្នុងសេចក្ដីណែនាំលេខ ៧៧០៥ អពដ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ (ដូចមានក្នុងឧបសម្ព័ន្ធ-សេចក្ដីណែនាំលេខ ៧៧០៥ អពដ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០)។

*ដើម្បីស្វែងយល់បន្ថែមអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) និងកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) អ្នកប្រើប្រាស់អាចពិនិត្យមើលលម្អិតក្នុងសៀវភៅណែនាំស្ដីពីការប្រើប្រាស់ របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមាននៅលើគេហទំព័រ* https://www.tax.gov.kh *ឬចូលទស្សនាវីដេអូណែនាំ (Video Tutorial) ឬអាចទូរស័ព្ទមក Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android។*

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងលោក-លោកស្រីជាប្រធានសមាគមនិងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងបរទេសទាំងអស់ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំស្ដីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI E-Filing) ដើម្បីធ្វើការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំឱ្យបានត្រឹមត្រូវនិងទទួលបាននូវប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# សេចក្តីប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ទីផ្សារអនឡាញក្រសួងពាណិជ្ជកម្មសម្រាប់លក់គ្រឿងឧបភោគបរិភោគចាំបាច់ ក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្រ្តរាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា យោងតាមសេចក្តីណែនាំលេខ ០១ សណន ស្តីពីវិធានការលម្អិតដើម្បីរឹតបន្តឹងការអនុវត្តសេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្រ្តរាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល ក្រសួងបានដាក់ឱ្យប្រើប្រាស់ទីផ្សារអនឡាញក្រសួងពាណិជ្ជកម្មសម្រាប់លក់គ្រឿងឧបភោគបរិភោគចាំបាច់ជូនប្រជាពលរដ្ឋរស់នៅក្នុងតំបន់ក្រហម ចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ នេះតទៅ។

ដើម្បីធ្វើការបញ្ជាទិញ សូមចូលទៅកាន់គេហទំព័រ shop.moc.gov.kh ឬតាម QR Code ខាងក្រោម៖

ក្នុងករណីត្រូវការជំនួយក្នុងការប្រើប្រាស់ផ្សារអនឡាញ ឬការបញ្ជាទិញ សូមទាក់ទងមកកាន់លេខទូរស័ព្ទ៖ 012 767 043 / 089 355 696 / 069 524 499 / 015 805 313 / 017 855 011 ។

ក្រោយពីទទួលបានការបញ្ជាទិញ ក្រុមការងារនឹងរៀបចំចាត់ចែងការដឹកជញ្ជូនទៅដល់មុខផ្ទះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១០កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469